រាជរដ្ឋាភិបាលកម្ពុជា

# សៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាល
# ស្តីពី
# ការដាក់បញ្ចូលពិការភាព
# នៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ



*បោះពុម្ពលើកទី២ ខែមិថុនា ឆ្នាំ២០១៧*

unicef

Australian Aid

# មាតិកា


**១. សេចក្តីផ្តើម ..... ១**

១.១. មូលហេតុនៃការរៀបចំសៀវភៅណែនាំ ..... ១

១.២. ការរំពឹងទុកនឹងមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងរយៈពេលវែង ..... ២

១.៣. ជំនាញចាំបាច់សម្រាប់គ្រូបណ្តុះបណ្តាល ..... ២

១.៤. អ្នកប្រើប្រាស់សៀវភៅណែនាំ ..... ៣

១.៥. របៀបប្រើប្រាស់សៀវភៅណែនាំ ..... ៤

១.៦. សេចក្តីថ្លែងអំណរគុណ ..... ៦

**២. ការត្រៀមរៀបចំសម្រាប់ការបណ្តុះបណ្តាល ..... ៧**

២.១. មុនការបណ្តុះបណ្តាល ..... ៧

២.២. ក្នុងអំឡុងពេលបណ្តុះបណ្តាល ..... ៩

២.៣. ក្រោយការបណ្តុះបណ្តាល ..... ១០

២.៤. ការត្រៀមគំនិតជាគ្រូបណ្តុះបណ្តាល ..... ១០

២.៥. បញ្ជី ឯកសារ សម្ភារៈសម្រាប់ការបណ្តុះបណ្តាល ..... ១១

**៣. គោលបំណង គោលដៅ និងកាលវិភាគនៃការបណ្តុះបណ្តាល ..... ១២**

៣.១. គោលបំណងនៃការបណ្តុះបណ្តាល ..... ១២

៣.២. គោលដៅនៃការបណ្តុះបណ្តាល ..... ១២

៣.៣. កាលវិភាគបណ្តុះបណ្តាល ..... ១៥

ជំពូកទី១ ៖ ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល ..... ១៦

ជំពូកទី២ ៖ ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាព ..... ២២

ជំពូកទី៣ ៖ ការបង្ហាញពីការគោរព និងសេចក្តីថ្លៃថ្នូរ ..... ៤៤

ជំពូកទី៤ ៖ ការប្រាស្រ័យទាក់ទងជាមួយជនពិការ ..... ៥៦

ជំពូកទី៥ ៖ ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ជនពិការ ..... ៦៧

ជំពូកទី៦ ៖ ការជានាឱ្យមានការចូលរួមយ៉ាងសកម្ម ..... ៧៧

ជំពូកទី៧ ៖ ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ ..... ៩២

ជំពូកទី៨ ៖ ការវាយតម្លៃ និងបិទវគ្គបណ្តុះបណ្តាល ..... ១១៩

**៤. សេចក្តីសន្និដ្ឋាន ..... ១២៣**

៤.១. សូចនាករនៃភាពជោគជ័យ ..... ១២៣

៤.២. ផែនការបន្ទាប់ ..... ១២៤

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១ ៖  កាលវិភាគនៃការបណ្តុះបណ្តាល ........ ១២៦
ឧបសម្ព័ន្ធទី២ ៖  រូបភាពបទបញ្ហាផ្ទៃក្នុងសម្រាប់ការបណ្តុះបណ្តាល ........ ១២៧
ឧបសម្ព័ន្ធទី៣ ៖  ករណីសិក្សា ........ ១២៨
ឧបសម្ព័ន្ធទី៤ ៖  ពិការភាព ........ ១៣៣
ឧបសម្ព័ន្ធទី៥ ៖  គំនូរស្រ្តីពិការ ........ ១៣៤
ឧបសម្ព័ន្ធទី៦ ៖  សំណួរវាយតម្លៃសម្រាប់កំណត់ជនពិការ ........ ១៣៥
ឧបសម្ព័ន្ធទី៧ ៖  បញ្ជីផ្ទៀងផ្ទាត់ការបង្កភាពងាយស្រួលសម្រាប់ជនពិការ ........ ១៣៦
ឧបសម្ព័ន្ធទី៨ ៖  បញ្ជីផ្ទៀងផ្ទាត់កិច្ចប្រជុំ និងព្រឹត្តិការណ៍ដែលជនពិការអាចចូលរួមបាន ........ ១៤០
ឧបសម្ព័ន្ធទី៩ ៖  ក្រដាសកាតពណ៌សម្រាប់ការបំផុស ........ ១៤៣
ឧបសម្ព័ន្ធទី១០ ៖  បញ្ជីសំណួរវាយតម្លៃចំណេះដឹងមុនការបណ្តុះបណ្តាល ........ ១៤៤
ឧបសម្ព័ន្ធទី១១ ៖  បញ្ជីសំណួរវាយតម្លៃចំណេះដឹងក្រោយការបណ្តុះបណ្តាល ........ ១៤៦
ឧបសម្ព័ន្ធទី១២ ៖  ចម្លើយនៃបញ្ជីសំណួរវាយតម្លៃចំណេះដឹងមុន និងក្រោយការបណ្តុះបណ្តាល. ១៤៨

# ១. សេចក្តីផ្តើម

## ១.១. មូលហេតុនៃការរៀបចំសៀវភៅណែនាំ

ក្នុងចំណោមប្រជាជនទាំងអស់នៅលើពិភពលោកមានពិការភាព១៥% (ក្នុងចំណោមមនុស្ស៧នាក់មានម្នាក់មានពិការភាព)។ ជារឿយៗពួកគាត់ត្រូវបានរាំង ឬផាត់ចេញមិនអាចចូលរួមក្នុងសង្គមបាន ទោះបីជា ពួកគេមានសិទ្ធិដូចគ្នានឹងមនុស្សផ្សេងទៀត ដូចជា សិទ្ធិទទួលបានការអប់រំ មានការងារធ្វើ រៀបអាពាហ៍ពិពាហ៍ និងចូលរួមនៅក្នុងសហគមន៍ជាដើម។ រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកដឹកនាំសហគមន៍ត្រូវធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានសេវា និងព័ត៌មាន។

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចធ្វើការងារ ដើម្បីឱ្យមានសមភាពសម្រាប់ប្រជាពលរដ្ឋ នៅក្នុងប្រទេសរបស់ខ្លួន រួមទាំងជនពិការ ដូចដែលបានបញ្ជាក់នៅក្នុងយុទ្ធសាស្រ្តចតុកោណ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព។ ទន្ទឹមគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាកំពុងស្ថិតនៅក្នុងដំណើរការផ្ទេរមុខងារ និងធនធានមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការផ្ទេរមុខងារ និងធនធានទាំងនេះមានន័យថា បន្ថែមការទទួលខុសត្រូវ និងសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល។

រដ្ឋបាលឃុំ សង្កាត់ គឺជានីតិបុគ្គលសាធារណៈ ដែលសមាជិកក្រុមប្រឹក្សារបស់ខ្លួនកើតចេញពីការបោះឆ្នោតពីប្រជាពលរដ្ឋ។ ដូច្នេះ រដ្ឋបាលឃុំ សង្កាត់ត្រូវមានគណនេយ្យភាព និងការឆ្លើយតបចំពោះបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋគ្រប់រូបក្នុងសហគមន៍របស់ខ្លួន ជាពិសេសជនងាយរងគ្រោះ។ ផែនការអនុវត្តរយៈពេល៣ឆ្នាំ ដំណាក់កាលទី២(ផអ៣ទី២)នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផ្តោតជាសំខាន់លើបរិយាប័ន្ន[1] និងសមធម៌សង្គម ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អ ដែលកំពុងបានផ្តល់ឱកាសឱ្យជនពិការបានចូលរួមក្នុងដំណើរការអភិវឌ្ឍ។ អ្នកចូលរួមក្នុងការបណ្តុះបណ្តាល រួមទាំង ជនពិការនឹងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការប្តេជ្ញាចិត្តធ្វើឱ្យប្រសើរឡើងនូវវប្បធម៌ប្រជាធិបតេយ្យដោយមានការចូលរួមនៅមូលដ្ឋាន គណនេយ្យភាពចំពោះប្រជាពលរដ្ឋ សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធនាំមកនូវការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដើម្បីឈានទៅរកការកាត់បន្ថយភាពក្រីក្រ។

បច្ចុប្បន្ននេះ សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតក្នុងការធ្វើឱ្យជនពិការ អាចចូលរួមនៅក្នុងកម្មវិធីនានារបស់រាជរដ្ឋាភិបាល។ ដូច្នេះហើយបានជា ក្រសួងមហាផ្ទៃ អង្គការយូនីសេហ្វ (UNICEF) និងស្ថាប័នដទៃទៀត មានបំណងកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការបង្កលក្ខណៈឱ្យជនពិការបានចូលរួមក្នុងអភិបាលកិច្ច និងការអភិវឌ្ឍ។

[1] ការដាក់បញ្ចូលជនពិការ យេនឌ័រ កុមារ ចាស់ជរា ជនជាតិភាគតិច និងជនងាយរងគ្រោះ។

### ១.២. ការរំពឹងទុកនឹងមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងរយៈពេលវែង

ការផ្លាស់ប្តូរជាវិជ្ជមានក្នុងរយៈពេលវែងដែលរំពឹងទុកថា នឹងកើតចេញពីការបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ(ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត) គឺ ៖

#### ក). គោលបំណងនៃវគ្គបណ្តុះបណ្តាល

អ្នកធ្វើសេចក្តីសម្រេចចិត្ត និងទីប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានសមត្ថភាព(ចំណេះដឹង ជំនាញ និងឥរិយាបថ)ប្រសើរឡើងក្នុងការកំណត់ និងលុបបំបាត់ឧបសគ្គនានាដែលរាំងជនពិការ ដើម្បីឱ្យពួកគាត់អាចទទួលបានសិទ្ធិស្មើភាព និងការអភិវឌ្ឍប្រកបដោយសមធម៌នៅក្នុងមូលដ្ឋានរបស់ខ្លួន។

#### ខ). គោលដៅទូទៅនៃវគ្គបណ្តុះបណ្តាល

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ អ្នកធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់ក្រោមជាតិនឹងអាច ៖

១. ជំនះការសន្មតក្នុងសង្គមដែលមិនផ្តល់ការគោរព និងធ្វើឱ្យអាប់ឱនដល់សេចក្តីថ្លៃថ្នូររបស់ជនពិការ
២. ផ្តល់ការគាំទ្រដល់ការប្រមូលស្ថិតិបែងចែកតាមពិការភាព និងរក្សាបច្ចុប្បន្នភាពស្ថិតិទាំងនេះនៅគ្រប់កម្រិតទាំងអស់
៣. រៀបរាប់អំពីឧបសគ្គនានាដែលរាំងការចូលរួមរបស់ជនពិការប្រកបដោយសមភាព
៤. ពិគ្រោះយោបល់ជាមួយនឹងជនពិការ និងអ្នកថែទាំជនពិការក្នុងលក្ខណៈជាប្រព័ន្ធ និងប្រកបដោយអត្ថន័យនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិនិយោគនៅថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ដើម្បីផ្តល់លទ្ធភាពឱ្យជនពិការអាចចូលរួម នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត
៥. ជានាជនពិការអាចទទួលបានសេវាសាធារណៈកាន់តែប្រសើរជាងមុន ដូចជា លទ្ធភាព ចេញចូលទីកន្លែង និងលទ្ធភាពទទួលបានព័ត៌មានជាដើម
៦. បំពេញភារកិច្ចជាក់លាក់នៅថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការដាក់បញ្ចូលពិការភាព

### ១.៣. ជំនាញចាំបាច់សម្រាប់គ្រូបណ្តុះបណ្តាល

ការបណ្តុះបណ្តាលនេះសន្មតថា មនុស្សពេញវ័យរៀនសូត្រកាន់តែមានប្រសិទ្ធភាព នៅពេលការរៀនសូត្រត្រូវបានធ្វើឡើងជាជំហានៗ ឬមានការចែករំលែកបទពិសោធន៍ជាក់ស្តែងមានការឆ្លុះបញ្ចាំងពីការរៀនសូត្រទាញយកមេរៀនចេញពីការរៀនសូត្រ ដើម្បីយកទៅអនុវត្តក្នុងស្ថានភាពផ្សេងៗ។ ការបណ្តុះបណ្តាលនេះ ផ្តោតជាសំខាន់លើការរៀនសូត្របែបអនុវត្តជាក់ស្តែងទៅតាមលទ្ធភាព និងសមត្ថភាពរបស់អ្នកចូលរួមទាំងអស់។ ជាការសំខាន់ណាស់ដែលអ្នកចូលរួមត្រូវចែករំលែកបទពិសោធន៍ នូវអ្វីៗដែលពួកគាត់បានរៀន។ ដូច្នេះ ក្នុងការបណ្តុះបណ្តាលនេះនឹងមានការងារជាក្រុម ការចែករំលែក និងការពិភាក្សាគ្នាជាច្រើន។

យន្តការនៃការបណ្តុះបណ្តាលកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីការបញ្ជ្រាបពិការភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិមាន៣ដំណាក់កាល រួមមាន ៖

១. ទីប្រឹក្សាអន្តរជាតិផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោល(ToT)ស្តីពីការដាក់បញ្ជ្រាបពិការភាពទៅក្នុងការងារអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិដល់គ្រូបង្គោលថ្នាក់ជាតិ

២. គ្រូបង្គោលថ្នាក់ជាតិផ្តល់វគ្គបណ្តុះបណ្តាលនេះដល់គ្រូបង្គោលថ្នាក់ក្រោមជាតិ ឬគ្រូបង្គោលរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត

៣. គ្រូបង្គោលថ្នាក់ក្រោមជាតិឬគ្រូបង្គោលមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត នឹងបន្តផ្តល់វគ្គនេះដល់ក្រុមគោលដៅផ្ទាល់។

គ្រូបណ្តុះបណ្តាលចាំបាច់ត្រូវចូលរួមនៅក្នុងការបណ្តុះបណ្តាលគ្រូបង្គោល មុនពេលអាចផ្តល់វគ្គបណ្តុះបណ្តាលនេះដល់អ្នកចូលរួម។ ក្រោយពីការបណ្តុះបណ្តាលគ្រូបង្គោលនឹងទទួលបាន ចំណេះដឹងនិងជំនាញដូចខាងក្រោម ៖

- យល់ពីការរៀនសូត្ររបស់មនុស្សពេញវ័យ និងបែបផែននៃការរៀនសូត្រផ្សេងៗគ្នា
- កែសម្រួលការបណ្តុះបណ្តាល(ខ្លឹមសារ ដំណើរការ និងទម្រង់ការងារ)សម្រាប់ក្រុមគោលដៅផ្សេងៗគ្នា និងធ្វើឱ្យមេរៀនដែលទទួលបានអាចយកទៅអនុវត្តបាន
- យល់ដឹងច្បាស់ពីវិធីសាស្ត្រភ្លោះ(twin track approach)ភាពខុសប្លែកគ្នារវាងការដាក់បញ្ជ្រាបពិការភាព និងសកម្មភាពជាក់លាក់ពាក់ព័ន្ធនឹងពិការភាព និងអាចពន្យល់ពីចំណុចនេះឱ្យអ្នកដទៃយល់បាន
- ភ្ជាប់ទំនាក់ទំនងដោយខ្លួនឯង ជាមួយនឹងគុណតម្លៃនៃសេចក្តីថ្លៃថ្នូរ និងការគោរពគ្នា
- សម្របសម្រួល តាមបែបផែនដាក់បញ្ជ្រាបដែលមានការចូលរួម
- ធ្វើការងារជាមួយនឹងគ្រូបណ្តុះបណ្តាលផ្សេងទៀត
- មានទំនុកចិត្តលើខ្លឹមសារនៃការបណ្តុះបណ្តាលនេះ

## ១.៤. អ្នកប្រើប្រាស់សៀវភៅណែនាំ

សៀវភៅណែនាំអំពីការបណ្តុះបណ្តាលនេះ ផ្តល់ព័ត៌មានដល់គ្រូបណ្តុះបណ្តាលអំពីការបញ្ជ្រាបពិការភាពទៅក្នុងការងារអភិបាលកិច្ចមូលដ្ឋាន។ ក្រុមគោលដៅនៃសៀវភៅណែនាំអំពីការបណ្តុះបណ្តាលនេះរួមមាន ៖

- គ្រូបណ្តុះបណ្តាលថ្នាក់ជាតិរបស់ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងស្ថាប័នពាក់ព័ន្ធ
- ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិរបស់ គ.ជ.អ.ប/ក្រសួងមហាផ្ទៃ
- គ្រូបង្គោលមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ឬទីប្រឹក្សានានានៅថ្នាក់ក្រោមជាតិ
- គ្រូបណ្តុះបណ្តាលជាជនពិការដែលមានបទពិសោធន៍នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- គ្រូបណ្តុះបណ្តាលរបស់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ។

សៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាលនេះ ត្រូវប្រើរួមគ្នាជាមួយនឹងសៀវភៅណែនាំសម្រាប់អ្នកចូលរួមចំនួន៣ផ្សេងទៀត(ថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត) ដែលស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ អ្នកចូលរួមក្នុងការបណ្តុះបណ្តាលនឹងទទួលបានសៀវភៅណែនាំ ដែលមានព័ត៌មានសម្រាប់រំលឹកអំពីការបណ្តុះបណ្តាលដែលពួកគាត់បានចូលរួម និងពីរបៀបប្រើប្រាស់ ព្រមទាំងអ្វីដែលពួកគាត់បានរៀន ដើម្បីយកទៅអនុវត្តនៅក្នុងការងាររបស់ពួកគាត់។ សៀវភៅណែនាំសម្រាប់អ្នកចូលរួម ក៏មានទុកកន្លែងសម្រាប់កត់ត្រាចំណុចផ្សេងៗ និងមេរៀនដែលបានរៀនផងដែរ។

## ១.៥. របៀបប្រើប្រាស់សៀវភៅណែនាំ

សៀវភៅណែនាំសម្រាប់អ្នកបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងទម្រង់ដូចៗគ្នាៈ

- សៀវភៅនេះមាន៨ ជំពូក ដែលបែងចែកជាមេរៀន ។
- គ្រប់ជំពូកទាំងអស់ចាប់ផ្តើម ដោយមានការបង្ហាញពីវត្ថុបំណងរបស់ជំពូក និងការបង្ហាញដោយសង្ខេបខ្លីអំពីចំណងជើងមេរៀន រយៈពេលគិតជានាទី និងសម្ភារៈឯកសារ ដែលចាំបាច់ត្រូវមាន។
- គ្រប់មេរៀនទាំងអស់ចាប់ផ្តើមដោយមានការបង្ហាញពីគោលបំណងនៃមេរៀននោះ រយៈពេលសម្រាប់មេរៀននោះ ចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែម និងមាតិកានៃការបណ្តុះបណ្តាល ដែលរៀបរាប់ពីជំហានលម្អិត ដែលនឹងមានក្នុងមេរៀននោះ។
- រយៈពេលដែលបែងចែក គឺគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។ ក្នុងនាមជាគ្រូបណ្តុះបណ្តាលអ្នកអាចធ្វើការកែសម្រួលកម្មវិធីត្រង់ណាក៏បានទៅតាមពេលវេលា និងកាលៈទេសៈជាក់ស្តែង។ កាលវិភាគលម្អិតបង្ហាញតាមជំពូកនីមួយៗ និងគ្រប់មេរៀនទាំងអស់(ឧបសម្ព័ន្ធទី១)។
- មានការកំណត់សម្គាល់ជាក់លាក់សម្រាប់គ្រូបណ្តុះបណ្តាល ។
- សៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាលមានភ្ជាប់ជាមួយនូវស្លាយសម្រាប់ប្រើប្រាស់ ទៅតាមមេរៀននីមួយៗ។
- ក្នុងជំពូកទី២ និងរៀបរាប់ពីសារៈសំខាន់នៃការត្រៀមរៀបចំ ។ សូមអានជំពូកនេះឱ្យបានហ្មត់ចត់ មុនការបណ្តុះបណ្តាល។
- ជំហានផ្សេងៗនៃការបណ្តុះបណ្តាលត្រូវបានបង្ហាញជាមួយនឹងរូបសញ្ញាសំខាន់ៗ ដើម្បីបង្ហាញពីប្រភេទជំហាន ឬរំលេចឱ្យឃើញពីបញ្ហាដែលចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ពិសេស។ រូបទាំងនេះត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។

| **រូបសញ្ញា** | **អត្ថន័យ** |
|---|---|
|  | សារគន្លឹះសំខាន់ៗរបស់មេរៀននេះ |
|  | សកម្មភាពសម្រាប់គ្រូបណ្ដុះបណ្ដាល |
|  | ស្វែងរកឯកសារ ផ្ទាំងរូបភាព ឬរូបភាពក្នុងឧបសម្ព័ន្ធនៅផ្នែកខាងក្រោយនៃសៀវភៅណែនាំនេះ |
|  | សារសំខាន់ៗដែលត្រូវចងចាំ |
|  | លំហាត់ |
|  | សំណួរ ដែលត្រូវសួរក្នុងវគ្គបណ្ដុះបណ្ដាល |
|  | បញ្ហាតាមឃុំ សង្កាត់ |
|  | បញ្ហាតាមក្រុង ស្រុក ខណ្ឌ |
|  | បញ្ហាតាមរាជធានី ខេត្ត |

## ១.៦. សេចក្តីថ្លែងអំណរគុណ

លំហាត់ និងរូបភាពជាច្រើន ត្រូវបានដកស្រង់ចេញពីសៀវភៅណែនាំដែលមានស្រាប់ ដូចជា ៖ មេរៀន១.២, ២.២ និងឧបសម្ព័ន្ធទី២ និង៥ រូបភាព

Heng, C., Tep, D., Tith, H., Ton, D., Vallins, N., Walji F. &Astbury, J. (2013). Challenging Discrimination Against Women with Disabilities: A Community Toolkit.BanteaySrei, CDPO, CBM Australia, IWDA and Monash University.

### មេរៀន២.១ និងឧបសម្ព័ន្ធទី៣ ៖ ករណីសិក្សា

Sreymom – ADD Cambodia

Thavy - LIGHT FOR THE WORLD

Ben Sophal – CBM

Makara – KomarPikar Foundation

### មេរៀន២.៤ ៖ ល្បែងដំណើរជីវិត

Coe, S. &Wapling, L. (2010). Travelling Together: How to Include Disabled People on the Main Road of Development. World Vision UK.

### ឧបសម្ព័ន្ធ ៤ ៖ បញ្ជីផ្ទៀងផ្ទាត់នៃកិច្ចប្រជុំដែលជនពិការអាចចូលរួមបាន

CBM. Tool: Accessible Meetings or Events.

## ២. ការត្រៀមរៀបចំសម្រាប់ការបណ្ដុះបណ្ដាល

ការត្រៀមរៀបចំ គឺជាគន្លឹះសំខាន់សម្រាប់ការបណ្ដុះបណ្ដាល។ នៅពេលដែលអ្នកត្រៀមខ្លួនបានល្អ មានន័យថា អ្នកអាចទទួលបានជោគជ័យនៃការបណ្ដុះបណ្ដាលរបស់អ្នកពាក់កណ្ដាលរួចទៅហើយ។ ដូច្នេះ សូមត្រៀមរៀបចំខ្លួនឱ្យបានល្អ វានឹងធ្វើឱ្យអ្នកមានទំនុកចិត្ត និងមានភាពងាយស្រួល ជាមួយនឹងការងាររបស់អ្នកក្នុងដំណើរការវគ្គបណ្ដុះបណ្ដាល។

### ២.១. មុនការបណ្ដុះបណ្ដាល

ខាងក្រោម អ្នកនឹងឃើញកាលវិភាគរយៈពេល៣សប្ដាហ៍ ដែលបង្ហាញពីអ្វីដែលអ្នកគួរត្រៀមរៀបចំ នៅមុនការបណ្ដុះបណ្ដាល។ នៅក្នុងតារាងខាងក្រោម មានការបង្ហាញពីសកម្មភាព សម្រាប់ការត្រៀមរៀបចំទូទៅផង និងសកម្មភាពត្រៀមរៀបចំ សម្រាប់មេរៀនជាក់លាក់ផង ដែលទាមទារឱ្យមានការផ្ដោតការយកចិត្តទុកដាក់បន្ថែមទៀត។ មានការបង្ហាញពីកន្លែង ដែលអាចរកឃើញព័ត៌មានលម្អិតបន្ថែមទៀតក្នុងសៀវភៅណែនាំ។

| ពេលវេលា | សកម្មភាព |
|---|---|
| ៣សប្ដាហ៍មុនការបណ្ដុះបណ្ដាល | • ក្រុមគ្រូបង្គោលត្រូវប្រជុំពិភាក្សាគ្នា ដើម្បីសម្រេចចិត្តអំពីកាលវិភាគ និងការបែងចែកតួនាទី និងការទទួលខុសត្រូវសម្រាប់មុនពេល ក្នុងអំឡុងពេល និងក្រោយពេលបណ្ដុះបណ្ដាល<br>• រៀបចំកន្លែងបណ្ដុះបណ្ដាល និងធ្វើការបញ្ជាក់ថាតើ កន្លែង បណ្ដុះបណ្ដាលនោះមានការបង្កភាពងាយស្រួលពេញលេញសម្រាប់ជនពិការដែរឬទេ (ប្រសិនបើអាចគួររៀបចំទីកន្លែងនៅអាគាររដ្ឋបាលសាធារណៈ)<br>• អញ្ជើញភ្ញៀវកិត្តិយសជាអធិបតី ដើម្បីថ្លែងមតិស្វាគមន៍ និងបើកវគ្គបណ្ដុះបណ្ដាលសម្រាប់ជំពូកទី១ នៅថ្ងៃដំបូងនៃការបណ្ដុះបណ្ដាល(មេរៀន១.១) និងបិទវគ្គបណ្ដុះបណ្ដាលនៅចុងថ្ងៃទី៣ នៃការបណ្ដុះបណ្ដាល<br>• ទាក់ទងអាជ្ញាធរមូលដ្ឋាន ដើម្បីស្វែងរកអគារសាធារណៈសម្រាប់ពិនិត្យទៅលើការបង្កភាពងាយស្រួលដល់ជនពិការ(ក្នុងជំពូកទី៥ នៅថ្ងៃទី៣នៃការបណ្ដុះបណ្ដាល)<br>• ទាក់ទងទៅអង្គការជនពិការ ដើម្បីស្វែងរកអ្នកដែលមានបទពិសោធន៍(អ្នកដែលមានភាពខ្សោយខាងការស្ដាប់ គំហើញ និងភាពខ្សោយខាងសតិបញ្ញា) សម្រាប់ជំពូកទី៤ នៅថ្ងៃទី២ នៃការបណ្ដុះបណ្ដាល<br>• អញ្ជើញតំណាងអង្គការជនពិការ ឱ្យចូលរួមក្នុងជំពូកទី៧ នៅថ្ងៃទី៣ នៃការបណ្ដុះបណ្ដាល (ការរៀបចំផែនការ ដើម្បីដាក់បញ្ចូលពិការភាព)<br>• រៀបចំរកអ្នកបកប្រែភាសាសញ្ញាសម្រាប់មេរៀនដែលមានការចូលរួមពីជនពិការថ្លង់<br>• សាកសួរពីតម្រូវការជាក់លាក់ ដើម្បីឱ្យអ្នកចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល |

| ពេលវេលា | សកម្មភាព |
| --- | --- |
| | ដែលទទួលបានការអញ្ជើញ អាចមកចូលរួមបាន (ដូចជា មធ្យោបាយធ្វើដំណើរភាពងាយស្រួលក្នុងការចេញចូល ភាសា ឯកសារជាអក្សរស្ទាប)<br>• សម្រេចចិត្តថាតើឯកសារសម្ភារ អ្វីខ្លះ ដែលអាចប្រើប្រាស់ សម្រាប់វគ្គបណ្តុះបណ្តាលនេះ (ឧទាហរណ៍ ៖ ការប្រើប្រាស់ស្លាយ PowerPoint និងវីដេអូជាដើម អាស្រ័យទៅលើការមានអគ្គិសនីឬអត់ ការប្រើប្រាស់ ឯកសារសរសេរលើក្រដាសផ្ទាំងធំ អាស្រ័យលើកម្រិតអក្ខរកម្ម ឬមិនសូវប្រើប្រាស់បច្ចេកវិទ្យា តែប្រើប្រាស់លំហាត់អនុវត្តឱ្យបានច្រើន និងជួយដល់ការសរសេរវិញ)<br>• ចាប់ផ្តើមអានសៀវភៅណែនាំ សម្រាប់គ្រូបណ្តុះបណ្តាល និងសៀវភៅណែនាំសម្រាប់អ្នកចូលរួម |
| **២ សប្តាហ៍មុន ការបណ្តុះបណ្តាល** | • ធ្វើគ្រប់ឯកសារដែលចាំបាច់ទាំងអស់ដើម្បី បោះពុម្ព (ដូចជា ផ្ទាំងរូបភាព ឯកសារចែក សៀវភៅណែនាំ ជាដើម)<br>• បន្តអានសៀវភៅណែនាំ សម្រាប់គ្រូបណ្តុះបណ្តាល និងសៀវភៅណែនាំសម្រាប់អ្នកចូលរួម |
| **១ សប្តាហ៍មុន ការបណ្តុះបណ្តាល** | • ពិនិត្យថា អ្នកពិតជាមានគ្រប់ឯកសារដែលចាំបាច់ទាំងអស់ត្រូវបានបោះពុម្ពរួចរាល់ហើយ<br>• ប្រមូលរាល់ឯកសារដែលចាំបាច់ផ្សេងៗទៀត<br>• ទាក់ទងទៅអង្គការជនពិការម្តងទៀត ដើម្បីបញ្ជាក់ពីចនជានមនុស្សដែលមានបទពិសោធន៍នឹងត្រូវមកចូលរួម<br>• បញ្ជាក់ពីទីតាំង ដើម្បីពិនិត្យលើការបង្កភាពងាយស្រួលសម្រាប់ជនពិការ<br>• ប្រាប់អ្នកចូលរួមឱ្យយកឯកសារផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តរបស់ពួកគាត់ មកកាន់វគ្គបណ្តុះបណ្តាល<br>• ស្វែងយល់ស៊ីជម្រៅអំពីសៀវភៅណែនាំការបណ្តុះបណ្តាល និងស្លាយ និងចាប់ផ្តើមត្រៀមរៀបចំសម្រាប់ការបណ្តុះបណ្តាល តាមថ្ងៃ តាមជំពូក និងតាមមេរៀននីមួយៗ<br>• គ្រូបង្គោលម្នាក់ៗត្រូវរៀបចំសម្ភារជំនួយដែលចាំបាច់បន្ថែមពីលើសស្លាយដែលមានស្រាប់ តាមមេរៀនរបស់ខ្លួនដែលបានបែងចែក<br>• ក្រុមគ្រូបង្គោលត្រូវបង្រៀនសាកល្បងគ្នាឯង (Dry run/rehearsal) |
| **១ថ្ងៃមុន ការបណ្តុះបណ្តាល** | • ពិនិត្យលើការបង្កភាពងាយស្រួល និងកែសម្រួល បន្ទប់បណ្តុះបណ្តាលសម្រាប់ជនពិការ ទៅតាមការចាំបាច់<br>• ពិនិត្យលើគ្រប់ឯកសារបណ្តុះបណ្តាលដែលមានទាំងអស់ និងរៀបចំថត |

| ពេលវេលា | សកម្មភាព |
|---|---|
| | ចម្លងឯកសារបណ្តុះបណ្តាលទាំងនេះក្នុងទម្រង់ទន់<br>• ទូរស័ព្ទទៅភ្ញៀវកិត្តិយស ដើម្បីសាកសួរពេលវេលាដែលពួកគាត់នឹងមកដល់<br>• ពិភាក្សាក្រុមគ្រូបង្គោល ៖ តើអ្វីដែលដំណើរការទៅបានល្អ និងតើអ្វីខ្លះ ដែលចាំបាច់ត្រូវធ្វើការកែលម្អ<br>• ពិនិត្យថាតើភ្ញៀវដែលត្រូវបានអញ្ជើញទាំងអស់នឹងចូលរួមដែរឬទេ<br>• ត្រៀមបញ្ជីវត្តមាន<br>• មើលតាមកម្មវិធី និងសៀវភៅណែនាំបណ្តុះបណ្តាល តើអ្វីៗគ្រប់យ៉ាងមានភាពច្បាស់លាស់ បានត្រៀមរួចរាល់ បានរៀបចំហើយឬទេ? ប្រសិនបើមិនទាន់រួចរាល់ តើនៅចាំបាច់ត្រូវធ្វើអ្វីទៀត?<br>• ព្យាយាមស្រមៃពីរូបភាពនៃការបណ្តុះបណ្តាលនេះក្នុងអារម្មណ៍របស់អ្នក ជាការត្រៀមរៀបចំ និងមើលតាមមាតិកានៃការបណ្តុះបណ្តាល |

**២.២. ក្នុងអំឡុងពេលបណ្តុះបណ្តាល**

នៅក្នុងអំឡុងពេលនៃការបណ្តុះបណ្តាល ក៏មានការងារត្រៀមរៀបចំដែលចាំបាច់ត្រូវធ្វើផងដែរ។ នៅក្នុងតារាងខាងក្រោម អ្នកនឹងឃើញសកម្មភាពសំខាន់ៗជាច្រើនដែលត្រូវធ្វើ។

| ពេលវេលា | សកម្មភាព |
|---|---|
| **ក្នុងថ្ងៃនីមួយៗនៃការបណ្តុះបណ្តាល** | • ប្រើប្រាស់វិធីសាស្រ្តតាមបែបចូលរួមសម្រាប់ដឹកនាំសម្របសម្រួលនៃមេរៀននីមួយៗ<br>• ថែរក្សាលំហូរឱ្យស្ថិតនៅក្នុងគន្លងនៃប្លង់មេរៀន និងអាចបទបែនទៅតាម ការចាំបាច់<br>• រាល់សកម្មភាព និងទង្វើរបស់គ្រូបង្គោលត្រូវបង្ហាញពីការលើកកម្ពស់ និងគោរពជនពិការ និងយេនឌ័រ<br>• លើកទឹកចិត្ត និងបង្កឱ្យមានតុល្យភាពក្នុងការចូលរួម<br>• ផ្លាស់ប្តូរកន្លែងអង្គុយរបស់សិក្ខាកាមតាមថ្ងៃនីមួយៗ<br>• ដឹកនាំលេងល្បែងថាមពល<br>• រៀបចំប្រអប់សំបុត្រសម្រាប់ទទួលសំណួរពីសិក្ខាកាម<br>• សង្កេតសកម្មភាព និងប្រតិកម្មរបស់សិក្ខាកាម<br>• រៀបចំការវាយតម្លៃប្រចាំថ្ងៃរបស់សិក្ខាកាម<br>• ធ្វើការឆ្លុះបញ្ចាំងប្រចាំថ្ងៃរបស់ក្រុមគ្រូបង្គោលក្រោយពីបញ្ចប់មេរៀននៃថ្ងៃនីមួយៗ ដើម្បីកែលម្អនៅថ្ងៃបន្ទាប់<br>• ការងារផ្សេងទៀត.....។ |

### ២.៣. ក្រោយការបណ្ដុះបណ្ដាល

នៅក្រោយពេលបណ្ដុះបណ្ដាល គ្រូបង្គោលគួរបំពេញកិច្ចការចាំបាច់មួយចំនួនដូចខាងក្រោម ៖

| ពេលវេលា | សកម្មភាព |
|---|---|
| ក្នុងចន្លោះរយៈពេល១សប្ដាហ៍បន្ទាប់ពីការបណ្ដុះបណ្ដាល | • ប្រជុំឆ្លុះបញ្ចាំងរបស់ក្រុមគ្រូបណ្ដុះបណ្ដាល បន្ទាប់ពីការបណ្ដុះបណ្ដាល ដើម្បីទាញយកចំណុចរៀនសូត្រ<br>• ចងក្រងឯកសារអំពីលទ្ធផលនៃការបណ្ដុះបណ្ដាល (បូកសរុបលទ្ធផលនៃការវាយតម្លៃចំណេះដឹងមុន និងក្រោយវគ្គ និងការវាយតម្លៃបញ្ចប់វគ្គ)<br>• សរសេររបាយការណ៍បញ្ចប់វគ្គបណ្ដុះបណ្ដាល<br>• ផ្ញើរបាយការណ៍ទៅអ្នកពាក់ព័ន្ធ |

### ២.៤ . ការត្រៀមគំនិតជាគ្រូបណ្ដុះបណ្ដាល

ក្រៅពីការរៀបចំសកម្មភាពដែលត្រូវធ្វើជាក់ស្ដែងសម្រាប់ការបណ្ដុះបណ្ដាល អ្វីដែលសំខាន់ផងដែរ គឺការត្រៀមគំនិតរបស់គ្រូបណ្ដុះបណ្ដាល។ តារាងបន្ទាប់ផ្ដល់នូវដំបូន្មាន និងវិធីសម្រាប់អ្នកដែលផ្ដល់ការបណ្ដុះបណ្ដាល។

**គំនិតក្នុងការត្រៀមរៀបចំវគ្គបណ្ដុះបណ្ដាល**

**ក). របៀបធ្វើឱ្យវគ្គបណ្ដុះបណ្ដាលឆ្លើយតបទៅនឹងការគិតគូរពីពិការភាព ៖**

- ទុកពេលឱ្យអ្នកចូលរួមបានលើកឡើងពីខ្លួនឯង និងផ្ដល់ឱកាសឱ្យពួកគាត់បានធ្វើម្ដងហើយម្ដងទៀតអំពីការប្រើប្រាស់សម្លេង និងរបៀបផ្សេងៗនៃការប្រាស្រ័យទាក់ទង។ល។
- នៅពេលដែលមានអ្នកចូលរួម ឬភ្ញៀវជាជនពិការចូលរួម ត្រូវរៀបចំបន្ទប់ ដែលអាចឱ្យរទេះរុញងាយចេញចូល ត្រូវរៀបចំកន្លែងសម្រាប់អ្នកបកប្រែភាសាសញ្ញា ដែលអាចឱ្យជនពិការថ្លង់មើលឃើញ និងត្រូវមានសម្លេងរៀបរាប់ពីរូបភាពនានា។
- មនុស្សជាច្រើនមានគំនិតអវិជ្ជមានអំពីពិការភាព។ គ្រូបណ្ដុះបណ្ដាលចាំបាច់ត្រូវបង្ហាញពីរបៀបនិយាយអំពីពិការភាព ហើយត្រូវបង្ហាញពីការគោរពចំពោះជនពិការ។ ជាការសំខាន់ណាស់ ដែលត្រូវដឹកនាំ តាមរយៈការបង្ហាញគំរូ និងត្រូវកែតម្រូវការនិយាយមិនគួរសមចំពោះជនពិការ ចាប់ពីដំបូងទី ដោយត្រូវរក្សាភាពអព្យាក្រិត នៅពេលធ្វើការកែតម្រូវបែបនេះ។
- នៅក្នុងករណីដែលអាចធ្វើបាន គួរដំណើរការវគ្គបណ្ដុះបណ្ដាលទាំងនេះ (ជាពិសេស ពេលប្រើប្រាស់បញ្ជីត្រួតពិនិត្យភាពងាយស្រួលចេញចូល) ជាមួយនឹងជនពិការផ្ទាល់តែម្ដង (ដែលមកពីអង្គការជនពិការក្នុងមូលដ្ឋាន) និងជំរុញឱ្យមានការជជែកពិភាក្សាគ្នាទៅវិញទៅមក។
- កុំប្រើក្រដាសកាតពណ៌(ក្រដាសពណ៌ឬកាត)ពណ៌ក្រហម និងបៃតងចាស់ដោយសារតែវាពិបាកមើលសម្រាប់អ្នកខ្សោយគំហើញ។

**ខ). របៀបសម្របទៅតាមតម្រូវការ និងបែបផែនផ្សេងៗនៃការរៀនសូត្រ ៖**

**គំនិតក្នុងការត្រៀមរៀបចំវគ្គបណ្ដុះបណ្ដាល**

- ប្រើប្រាស់វិធីសាស្ត្រក្រៅផ្លូវការផ្សេងៗគ្នា ជាមួយនឹងអ្នកចូលរួម និងទុកពេលឱ្យមានការពិភាក្សាមួយទល់មួយ និងការចែករំលែកក្នុងក្រុមធំជារួម ដើម្បីកសាងការជឿជាក់ និងទំនុកចិត្ត
- ជានិច្ចកាល ត្រូវធានាយ៉ាងណាឱ្យអ្នកចូលរួមមានអារម្មណ៍ងាយស្រួលក្នុងការនិយាយពីខ្លួនឯង។ វាជាការសំខាន់ ដែលអ្នកចូលរួមត្រូវមានឱកាសនិយាយអំពីជំនឿផ្ទាល់ខ្លួនអំពីពិការភាព ហើយពួកគាត់មិនមានអារម្មណ៍ថា ត្រូវបានគេបង្ខំឱ្យទទួលយកអ្វីដែលថ្មី ដែលពួកគាត់មិនទាន់យល់ច្បាស់នៅឡើយ។ ក្នុងពេលជាមួយគ្នា អ្នកចូលរួមចាំបាច់ត្រូវទទួលបានការគាំទ្រ ដើម្បីស្វែងយល់ពីការសន្មតទាំងនេះ ធៀបជាមួយនឹងគំនិតថ្មីៗ ដែលត្រូវបានលើកឡើងក្នុងការបណ្ដុះបណ្ដាល។
- ធានាយ៉ាងណាឱ្យអ្នកចូលរួមអាចភ្ជាប់ទំនាក់ទំនងរវាងគំនិតបែបអរូបី និងគំនិតថ្មីទៅនឹងឧទាហរណ៍ក្នុងជីវិតជាក់ស្ដែងជាពិសេសជីវិតផ្ទាល់ខ្លួនរបស់ពួកគាត់។
- តាមមេរៀននីមួយៗ គ្រូបង្គោលគួរប្រើប្រាស់លំដាប់លំដោយនូវគោលការណ៍មួយចំនួន ៖
  - ណែនាំពីលំហាត់
  - ពិនិត្យតាមដានការធ្វើលំហាត់តាមក្រុម (ដើរមើលជុំវិញ ដើម្បីផ្ទៀងផ្ទាត់ថាតើក្រុមនានាយល់លំហាត់ដែរឬទេ)
  - ផ្ដល់ការបញ្ជាក់ និងផ្ដល់ជំនួយ ក្នុងករណីដែលចាំបាច់
  - សម្របសម្រួលការពិភាក្សាក្នុងក្រុមធំ បន្ទាប់មក ធ្វើការឆ្លុះបញ្ចាំងចុងក្រោយ និងទទួលព័ត៌មានត្រលប់ពីគ្រូបណ្ដុះបណ្ដាល
- ផ្ដល់ការណែនាំដល់សិក្ខាកាមដោយផ្អែកតាមសៀវភៅណែនាំសម្រាប់អ្នកចូលរួម និងលើកទឹកចិត្តឱ្យពួកគាត់ធ្វើការកត់ត្រាជាប្រចាំ
- ល្បែងថាមពល ៖ សៀវភៅណែនាំពុំបានដាក់បញ្ចូលឬបង្ហាញអំពីល្បែងថាមពលឡើយ (លើកលែងតែសម្រាប់ថ្ងៃចុងក្រោយ)។ ដូច្នេះ វាអាស្រ័យទៅ លើគ្រូបណ្ដុះបណ្ដាលជាអ្នកសម្រេចចិត្តថាតើត្រូវលេងល្បែងថាមពល ឬក៏អត់។ ជាធម្មតា ល្បែងថាមពលត្រូវធ្វើឡើង ក្រោយសម្រាកញ៉ាំបាយថ្ងៃត្រង់រួច(មុនចាប់ផ្ដើមមេរៀនពេលរសៀល) ឬនៅពេលដែលគ្រូបណ្ដុះបណ្ដាលមើលឃើញថាមពលរបស់សិក្ខាកាមចុះទាបខ្លាំង ឬចុះខ្សោយ។

## ២.៥. បញ្ជី ឯកសារ និងសម្ភារៈសម្រាប់ការបណ្ដុះបណ្ដាល

**ឯកសារ និងសម្ភារៈសម្រាប់ការបណ្ដុះបណ្ដាល**

| | | |
|---|---|---|
| • ក្រដាសផ្ទាំងធំ | • ប្រដាប់បិទ | • ឯកសារសម្រាប់សិក្ខាកាម(Handout) |
| • ក្ដារខៀន | • ស្កុត | • ក្រដាសពណ៌ទំហំ A4 |
| • ហ្វឺតសរសេរលើក្ដារខៀន | • សៀវភៅសរសេរ | • ឧបករណ៍បំពងសម្លេង |
| • ហ្វឺតសរសេរលើក្រដាសផ្ទាំងធំ | • ប៊ិច | • ម៉ាស៊ីនបញ្ចាំងស្លាយ (LCD) |
| • ក្រដាសកាតពណ៌ | • ខ្មៅដៃ | • កុំព្យូទ័រ |

| ឯកសារ និងសម្ភារៈជាក់លាក់ដែលត្រូវរៀបចំជាមុន |
|---|
| **ឯកសារចែក ៖**<br>– បញ្ជីសំណួរវាយតម្លៃចំណេះដឹងមុន និងក្រោយវគ្គបណ្តុះបណ្តាល(ឧបសម្ព័ន្ធទី១០ និងទី១១)<br>**ផ្ទាំងរូបភាព ៖**<br>– ផ្ទាំងរូបភាព(ទំហំ A2) ដែលបង្ហាញពីករណីទាំង៥ (ឧបសម្ព័ន្ធទី៣)<br>– ភាពខ្សោយ + ឧបសគ្គ = ពិការភាព(ឧបសម្ព័ន្ធទី៤)<br>– ឯកសារ(ទំហំ A3 ដែលបង្ហាញពីទម្រង់ផ្សេងៗនៃភាពខ្សោយ)(ឧបសម្ព័ន្ធទី៥)<br>**ផ្សេងៗទៀត ៖**<br>– ក្រដាសកាតពណ៌សម្រាប់ការបំផុសគំនិត(ឧបសម្ព័ន្ធទី៩)<br>– វិញ្ញាបនបត្របញ្ចប់ការសិក្សា<br>– ស៊ុត ទុយោ ជប ។ល។ សម្រាប់ល្បែងថាមពលស៊ុតនៅថ្ងៃទី៣ |

## ៣. គោលបំណង គោលដៅ និងកាលវិភាគនៃការបណ្តុះបណ្តាល

### ៣.១. គោលបំណងនៃការបណ្តុះបណ្តាល

នៅចំណុច១.២ បានបង្ហាញគោលបំណងរួចមកហើយ គោលបំណងនោះ គឺ "អ្នកធ្វើសេចក្តីសម្រេចចិត្ត និងទីប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានសមត្ថភាព(ចំណេះដឹង ជំនាញ និងឥរិយាបទ)ប្រសើរឡើងក្នុងការកំណត់ និងលុបបំបាត់ឧបសគ្គនានាដែលរារាំងជនពិការ ដើម្បីឱ្យពួកគាត់អាចទទួលបានសិទ្ធិស្មើភាព និងការអភិវឌ្ឍប្រកបដោយសមធម៌នៅក្នុងមូលដ្ឋានរបស់ខ្លួន"។

### ៣.២. គោលដៅនៃការបណ្តុះបណ្តាល

ចំណុចខាងក្រោម គឺជាគោលដៅរួម និងគោលដៅជាក់លាក់នៃវគ្គបណ្តុះបណ្តាល ដែលគោលដៅទាំងនេះត្រូវបានរៀបចំឡើងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ៖

| គោលដៅទូទៅនៃវគ្គបណ្តុះបណ្តាល | គោលដៅជាក់លាក់នៃវគ្គបណ្តុះបណ្តាល | | |
|---|---|---|---|
| | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | រាជធានី ខេត្ត |
| ១. ជំនះការសន្មតក្នុងសង្គមដែលមិនផ្តល់ការគោរព និងធ្វើឱ្យអាប់ឱនដល់សេចក្តីថ្លៃថ្នូររបស់ជនពិការ | • ស្វែងយល់ពីភាពខុសប្លែកគ្នារវាងភាពខ្សោយ និងពិការភាព<br>• ស្វែងយល់ និងអាចជំនះនឹងការយល់ឃើញរបស់សង្គមអំពីពិការភាព។ | • ស្វែងយល់ពីភាពខុសប្លែកគ្នារវាងភាពខ្សោយ និងពិការភាព<br>• ស្វែងយល់ និងអាចជំនះនឹងការយល់ឃើញរបស់សង្គមអំពីពិការភាព។ | • ស្វែងយល់ពីភាពខុសប្លែកគ្នារវាងភាពខ្សោយ និងពិការភាព<br>• ស្វែងយល់ និងអាចជំនះនឹងការយល់ឃើញរបស់សង្គម អំពីពិការភាព។ |

| **គោលដៅទូទៅនៃវគ្គបណ្តុះបណ្តាល** | **គោលដៅជាក់លាក់នៃវគ្គបណ្តុះបណ្តាល** | | |
|---|---|---|---|
| | **ឃុំ សង្កាត់** | **ក្រុង ស្រុក ខណ្ឌ** | **រាជធានី ខេត្ត** |
| ២. ផ្តល់ការគាំទ្រដល់ការប្រមូលស្ថិតិបែងចែកតាមពិការភាព និងរក្សាបច្ចុប្បន្នភាពស្ថិតិទាំងនេះនៅគ្រប់កម្រិតទាំងអស់ | • អាចកំណត់ពីអ្នកដែលមានពិការភាពក្នុងសហគមន៍ | • អាចប្រើប្រាស់ទិន្នន័យរួមអំពីពិការភាពក្នុងស្រុករបស់ខ្លួន និងប្រើប្រាស់ទិន្នន័យនេះសម្រាប់គោលបំណងនៃការរៀបចំផែនការ | • អាចប្រើប្រាស់ទិន្នន័យរួមអំពីពិការភាព ក្នុងខេត្តរបស់ខ្លួន និងប្រើប្រាស់ទិន្នន័យនេះសម្រាប់គោលបំណងនៃការរៀបចំផែនការ |
| ៣. រៀបរាប់អំពីឧបសគ្គនានាដែលរាំងការចូលរួមរបស់ជនពិការប្រកបដោយសមភាព | • កំណត់ឥរិយាបថអវិជ្ជមានចំពោះជនពិការ<br>• កំណត់ឧបសគ្គក្នុងការប្រាស្រ័យទាក់ទង<br>• ឧបសគ្គដែលមិនបង្កភាពងាយស្រួលក្នុងការចេញចូល<br>• ឧបសគ្គដែលបង្កដល់ជនពិការពិបាកចូលរួម | • កំណត់ឥរិយាបថអវិជ្ជមានចំពោះជនពិការ<br>• កំណត់ឧបសគ្គក្នុងការប្រាស្រ័យទាក់ទង<br>• ឧបសគ្គដែលមិនបង្កភាពងាយស្រួលក្នុងការចេញចូល<br>• ឧបសគ្គដែលបង្កដល់ជនពិការពិបាកចូលរួម | • កំណត់ឥរិយាបថអវិជ្ជមានចំពោះជនពិការ<br>• កំណត់ឧបសគ្គក្នុងការប្រាស្រ័យទាក់ទង<br>• ឧបសគ្គដែលមិនបង្កភាពងាយស្រួលក្នុងការចេញចូល<br>• ឧបសគ្គដែលបង្កដល់ជនពិការពិបាកចូលរួម |
| ៤. ពិគ្រោះយោបល់ជាមួយនឹងជនពិការ និងអ្នកថែទាំជនពិការក្នុងលក្ខណៈជាប្រព័ន្ធ និងប្រកបដោយអត្ថន័យនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត | • ដឹងពីកន្លែង និងពីអង្គការជនពិការ និងបណ្តាញជនពិការដែលមានវត្តមានក្នុងតំបន់របស់ខ្លួន<br>• ជម្រុញឱ្យមានការចូលរួមឱ្យបានសកម្មពីជនពិការក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តដែលតម្រូវឱ្យមានការចូលរួមពីប្រជា | • វាយតម្លៃលើដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ លើកម្រិតនៃការបញ្ចូលពិការភាព ការចូលរួមរបស់ជនពិការក្នុងសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ | • មានទឹកចិត្តរៀបចំវេទិកាសាធារណៈដែលមានការចូលរួមពីជនពិការ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ពីចលនាជនពិការ អង្គការជនពិការក៏ដូចជាអាជ្ញាធរ ដើម្បីពិភាក្សាពីតម្រូវការ និងការព្រួយបារម្ភ របស់ជនពិការក្នុងរាជធានីខេត្តរបស់ពួកគាត់ |

| គោលដៅទូទៅនៃវគ្គបណ្តុះបណ្តាល | គោលដៅជាក់លាក់នៃវគ្គបណ្តុះបណ្តាល | | |
|---|---|---|---|
| | **ឃុំ សង្កាត់** | **ក្រុង ស្រុក ខណ្ឌ** | **រាជធានី ខេត្ត** |
| ដើម្បីផ្តល់លទ្ធភាពឱ្យជនពិការអាចចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត | ពលរដ្ឋ(ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ | | |
| ៥. ធានាឱ្យជនពិការអាចទទួលបានសេវាសាធារណៈកាន់តែប្រសើរជាងមុន ដូចជាភាពងាយស្រួលក្នុងការចេញចូលទីកន្លែង និងលទ្ធភាពទទួលបានព័ត៌មាន ជាដើម | • អាចពិនិត្យផ្ទៀងផ្ទាត់ដឹងថារាល់អគារសាធារណៈ កន្លែងផ្តល់សេវា និងកន្លែងប្រជុំដែលមានស្រាប់ និងសង់ថ្មីទាំងអស់មានភាពងាយស្រួលចេញចូលស្របតាមស្តង់ដារនៅថ្នាក់ជាតិ<br>• អាចធានាបានថាជនពិការ ក្នុងឃុំអាចទទួលបានព័ត៌មានសាធារណៈ | • ទីប្រឹក្សាអាចពិនិត្យផ្ទៀងផ្ទាត់ដឹងថារាល់អគារសាធារណៈ កន្លែងផ្តល់សេវា និងកន្លែងប្រជុំដែលមានស្រាប់ និងសង់ថ្មីទាំងអស់មានភាពងាយស្រួលចេញចូលស្របតាមស្តង់ដារថ្នាក់ជាតិ<br>• អាចធានាបានថាជនពិការអាចទទួលបានព័ត៌មានសាធារណៈដែលផ្សព្វផ្សាយដោយថ្នាក់ស្រុក | • ទីប្រឹក្សាអាចពិនិត្យផ្ទៀងផ្ទាត់ដឹងថារាល់អគារសាធារណៈកន្លែងផ្តល់សេវា និងកន្លែងប្រជុំដែលមានស្រាប់ និងសង់ថ្មីទាំងអស់មានភាពងាយស្រួលចេញចូល ស្របទៅតាមស្តង់ដារ នៅថ្នាក់ជាតិ<br>• អាចធានាបានថាជនពិការអាចទទួលបានព័ត៌មានសាធារណៈដែលផ្សព្វផ្សាយដោយថ្នាក់ខេត្ត |
| ៦. បំពេញភារកិច្ចជាក់លាក់នៅថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការដាក់បញ្ចូលពិការភាព | • ដឹងពីកន្លែងផ្តល់សេវាដល់ជនពិការក្នុងតំបន់ ឬតំបន់ដែលនៅជិត និងអាចបញ្ជូនជនពិការទៅរកសេវាទាំងនោះ<br>• បញ្ចូលពិការភាពទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនៅថ្នាក់ឃុំ សង្កាត់ និងភូមិ | • យល់ដឹងពីការទទួលខុសត្រូវនៅថ្នាក់ឃុំ និងយល់ដឹងពីសារសំខាន់ៗពាក់ព័ន្ធជាមួយនឹងការបញ្ចូលពិការភាព<br>• បញ្ចូលពិការភាព ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនៅថ្នាក់ស្រុក | • ដឹងពីសិទ្ធិជនពិការចែងក្នុងច្បាប់ និងគោលនយោបាយ<br>• យល់ពីតួនាទីរបស់ក្រុមប្រឹក្សាសកម្មភាព ជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងការទទួលខុសត្រូវផ្សេងទៀត<br>• បញ្ចូលពិការភាពទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនៅថ្នាក់ខេត្ត |

ភាពខុសប្លែកគ្នារវាងថ្នាក់ក្រោមជាតិទាំង៣ថ្នាក់ នឹងត្រូវលើកមកពិភាក្សានៅតាមមេរៀននៃជំពូកនីមួយៗ។ ចំណុចនេះមិនទាមទារឱ្យមានការកែប្រែជំពូកទាំងស្រុងឱ្យស្របតាមស្ថានភាពនីមួយៗនោះទេ។ ដូច្នេះ សៀវភៅណែនាំសម្រាប់គ្រូបណ្ដុះបណ្ដាល អាចប្រើប្រាស់សម្រាប់រៀបចំ និងផ្ដល់ការបណ្ដុះបណ្ដាលទាំង៣ថ្នាក់តែម្ដង។ ត្រង់ចំណុចដែលព័ត៌មាននៅតាមមេរៀននីមួយៗ អាចប្រើប្រាស់បានតែនៅថ្នាក់ក្រោមជាតិមួយ នឹងមានការបង្ហាញប្រាប់ដោយនិមិត្តសញ្ញាដូចខាងក្រោយ ៖

**ឃុំ សង្កាត់**



**ក្រុង ស្រុក ខណ្ឌ**



**រាជធានី ខេត្ត**



អ្នកនឹងឃើញស្លាយផ្សេងៗគ្នាដែលបង្ហាញពីគោលដៅនៃការបណ្ដុះបណ្ដាលសម្រាប់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត។

## ៣.៣. កាលវិភាគបណ្ដុះបណ្ដាល

| **ពេលវេលា** | **ថ្ងៃទី១** | **ថ្ងៃទី២** | **ថ្ងៃទី៣** |
|---|---|---|---|
| ៨:០០-១១:៣០ | • ពិធីបើកវគ្គបណ្ដុះ-បណ្ដាល<br>• ជំពូកទី១៖ ការចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាល<br>• ជំពូកទី២ ៖ ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាព | • ជំពូកទី៣ ៖ ការបង្ហាញពីការគោរព និងសេចក្ដីថ្លៃថ្នូរ<br>• ជំពូកទី៤ ៖ ការប្រាស្រ័យទាក់ទងជាមួយជនពិការ | • ជំពូកទី៥ ៖ ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងសម្រាប់ជនពិការ(ត)<br>• ជំពូកទី៦ ៖ ការធានាឱ្យមានការចូលរួមយ៉ាងសកម្ម |
| ១១:៣០-១៣:៣០ | **អាហារថ្ងៃត្រង់** | | |
| ១៣.៣០-១៧.០០ | • ជំពូកទី២ ៖ ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាព(ត) | • ជំពូកទី៤ ៖ ការប្រាស្រ័យទាក់ទងជាមួយជនពិការ(ត)<br>• ជំពូកទី៥ ៖ ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងសម្រាប់ជនពិការ | ជំពូកទី៧ ៖ ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ<br>• ជំពូកទី៨ ៖ ការវាយតម្លៃ និងការបិទវគ្គ |

**កំណត់សម្គាល់ ៖**

- ពេលព្រឹកសម្រាកអាហារសម្រន់ ១៥នាទី ពីម៉ោង ៩:៣០-៩:៤៥
- ពេលល្ងាចសម្រាកអាហារសម្រន់ ១៥នាទី ពីម៉ោង ១៥:៣០-១៥:៤៥

# ជំពូកទី១

# ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល

# ជំពូកទី១

# ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល

## ក). សេចក្តីពិពណ៌នា

ជំពូកនេះនឹងផ្តោតជាសំខាន់ឱ្យអ្នកចូលរួមយល់ដឹងអំពីកិច្ចការចម្លងដែលនឹងត្រូវអនុវត្តក្នុងរយៈពេលបណ្តុះបណ្តាល ដើម្បីធានាបានថា អ្នកចូលរួមយល់ដឹងអំពីដំណើរការវគ្គសម្រាប់ត្រៀមខ្លួនចូលរួមយ៉ាងសកម្ម។

នៅចុងបញ្ចប់នៃជំពូកនេះ អ្នកចូលរួមនឹង ៖

- អ្នកចូលរួមបានស្គាល់គ្នា
- ធានាឱ្យមានការយល់ដឹងដូចគ្នាអំពីការរំពឹងទុក និងគោលដៅនៃការបណ្តុះបណ្តាលអំពីការដាក់បញ្ចូលពិការភាពទៅក្នុងការងារអភិបាលកិច្ចមូលដ្ឋាន នៅកម្ពុជា
- បញ្ជាក់ឡើងវិញឱ្យបានច្បាស់ពីការយល់មិនត្រឹមត្រូវ ប្រសិនបើមាន
- បង្កើតវិធីសាស្ត្រប្រាស្រ័យទាក់ទង និងចូលរួម ដែលចង់បាន សម្រាប់អ្នកចូលរួមទាំងអស់
- បង្កើតបរិយាកាសដែលមានការចូលរួម នៅក្នុងការបណ្តុះបណ្តាល
- ធានាឱ្យអ្នកចូលរួមយល់ពីតួនាទីរបស់ខ្លួន និងអ្វីដែលពួកគាត់រំពឹងថានឹងទទួលបាន ដើម្បីរួមចំណែកចំពោះការបណ្តុះបណ្តាលនេះ
- រៀបចំក្រុមឱ្យមានភាពសកម្ម និងស្វាហាប់ល្អ។

## ខ). មាតិកាមេរៀន

| លរ | មេរៀន | រយៈពេល | សម្ភារៈ និងឯកសារ |
|---|---|---|---|
| ១.១. | កិច្ចស្វាគមន៍ | ០៥នាទី | ចែកសៀវភៅណែនាំសម្រាប់អ្នកចូលរួម |
| ១.២. | សកម្មភាពមុនវគ្គបណ្តុះបណ្តាល | ៣០នាទី | ក្រដាសកាតពណ៌ ហ្វឺត ស្កុត ក្រដាសផ្ទាំងធំ សំណួរវាយតម្លៃមុនវគ្គបណ្តុះបណ្តាល |
| ១.៣. | ការចាប់ដៃ | ២៥នាទី | ក្រដាសពណ៌ទំហំ A4 |
| **សរុប** | | **៦០នាទី** | |

!

- អញ្ជើញភ្ញៀវកិត្តិយស ដូចជា អភិបាលស្រុក ដើម្បីថ្លែងមតិស្វាគមន៍ និងបើកវគ្គបណ្តុះបណ្តាល។
- ប្រសិនបើពុំមានអគ្គិសនីនោះទេ គេមិនអាចបង្ហាញស្លាយបានឡើយ។ មានន័យថា អ្នកបណ្តុះបណ្តាលត្រូវរកជម្រើសផ្សេង ដូចជា៖
  - សរសេរសារសំខាន់ៗ ដាក់លើក្រដាសផ្ទាំងធំជាមុន
  - មើលស្លាយផ្សេងទៀត ៖ ថាតើសារទាំងនេះអាចយកមក សរសេរលើក្រដាសកាតពណ៌ ឬក្តារខៀនបានដែរឬទេ ?

## គ). ដំណើរការសម្របសម្រួល

| មេរៀន១.១<br>កិច្ចស្វាគមន៍ | |
|---|---|
| គោលដៅ ៖ បង្ហាញសេចក្តីផ្តើម និងការចាប់ផ្តើមវគ្គបណ្តុះបណ្តាល | |
| រយៈពេល | ០៥នាទី |

!

- គ្រូបណ្តុះបណ្តាលអញ្ជើញគណៈអធិបតី ដើម្បីមានមតិស្វាគមន៍ និងបើកវគ្គបណ្តុះបណ្តាល កិច្ចការនេះនឹងត្រូវធ្វើឡើងដោយអភិបាលស្រុកឬភ្ញៀវកិត្តិយសដទៃទៀត
- អ្នកសម្របសម្រួលការណែនាំខ្លួន
- គ្រូបណ្តុះបណ្តាលបង្ហាញសេចក្តីផ្តើម និងចំណុចសំខាន់ដែលជាប់ពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាលសម្រាប់រាជរដ្ឋាភិបាលកម្ពុជា (ចំណុចនេះត្រូវឆ្លុះបញ្ចាំងទៅនឹងមតិរបស់គណៈអធិបតី)។

| មេរៀន១.២<br>សកម្មភាពមុនវគ្គបណ្តុះបណ្តាល | |
|---|---|
| **គោលដៅ ៖** បង្កើតបទបញ្ញាផ្ទៃក្នុង សម្រាប់ការបណ្តុះបណ្តាល និងធានាឱ្យមានការយល់ដឹងដូចៗគ្នាអំពីគោលដៅនៃការរៀនសូត្រ និងគោលបំណងនៃការបណ្តុះបណ្តាល។ | |
| **រយៈពេល** | ៣០នាទី |

សកម្មភាពមុនវគ្គបណ្តុះបណ្តាលសរុបមានចំនួន៧ចំណុច ហើយអ្នកសម្របសម្រួលនឹងពន្យល់ត្រួសៗពីសកម្មភាពទាំងនេះ តាមរយៈការបង្ហាញស្លាយ ឬក្រដាសផ្ទាំងដែលមានខ្លឹមសារ ៖

១. ល័ក្ខខ័ណ្ឌសម្រាប់អ្នកចូលរួម
២. ការបង្កើតបទបញ្ញាផ្ទៃក្នុង
៣. ការងាររដ្ឋបាល និងការរៀបចំចាត់ចែង
៤. ការរំពឹងទុករបស់សិក្ខាកាម
៥. បង្ហាញគោលបំណង គោលដៅ និងកាលវិភាគនៃវគ្គបណ្តុះបណ្តាល
៦. ការវាយតម្លៃចំណេះដឹងអ្នកចូលរួមមុនវគ្គបណ្តុះបណ្តាល
៧. សេចក្តីពន្យល់ពីសៀវភៅណែនាំបណ្តុះបណ្តាល

### ១. ល័ក្ខខ័ណ្ឌសម្រាប់អ្នកចូលរួម

គ្រូបណ្តុះបណ្តាលគួរបញ្ជាក់ពីគោលដៅ និងភាពពាក់ព័ន្ធនៃវគ្គបណ្តុះបណ្តាលនេះ។ បន្ទាប់មកពន្យល់ពីវិធីសាស្ត្រដែលប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាល ៖ ឱ្យមានការចូលរួម និងមានការជជែកពិភាក្សាគ្នាផុលផុសបែបអន្តរកម្ម។ អ្នកចូលរួមមានបែបផែនរៀនសូត្រផ្សេងៗគ្នា។ ដើម្បីធ្វើឱ្យវគ្គបណ្តុះបណ្តាលនេះ ដំណើរការប្រកបដោយប្រសិទ្ធភាព អ្នកចូលរួមត្រូវបំពេញតាមល័ក្ខខ័ណ្ឌខាងក្រោម ៖

- មានឆន្ទៈក្នុងការរៀនសូត្រ និងចែករំលែក។
- ចាត់ទុកអ្នកចូលរួមជាធនធានមួយយ៉ាងសំខាន់ ៖ អ្នកចូលរួមអាចផ្តល់គំនិត រឿងរ៉ាវនានា ។ល។ ដើម្បីជួយចែករំលែកដល់អ្នកចូលរួមផ្សេងៗទៀតបានរៀនសូត្រ។
- ប្រើប្រាស់វិធីសាស្ត្រតាមបែបចូលរួម ៖ នឹងមានការប្រើប្រាស់វិធីសាស្ត្របែបអន្តរកម្ម (ទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក)។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ អ្នកចូលរួមនឹងត្រូវបានស្នើឱ្យរួមចំណែក និងឆ្លើយតប។
- រំពឹងថា ការបណ្តុះបណ្តាលនេះមិនត្រឹមតែជាការផ្ទេរចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែ ការបណ្តុះបណ្តាលក៏ផ្តល់នូវជំនាញ និងការផ្លាស់ប្តូរឥរិយាបថផងដែរ។
- យល់ថា ការបណ្តុះបណ្តាលនេះអាចកែសម្រួលបាន អាស្រ័យទៅតាមព័ត៌មានត្រលប់ដែលផ្តល់ដោយអ្នកចូលរួម។ ចុងក្រោយការបណ្តុះបណ្តាលនេះ នឹងឆ្លើយតបចំពោះតម្រូវការនៃការរៀនសូត្ររបស់អ្នកចូលរួម។

## ២. ការបង្កើតបទបញ្ជាផ្ទៃក្នុង

ការបង្កើតបរិយាកាសរៀនសូត្រតាមបែបចូលរួម គឺជាសមាសភាគមួយក្នុងចំណោមសមាសភាគសំខាន់ៗនានាសម្រាប់ការសម្របសម្រួលការបណ្តុះបណ្តាល។ ជាទូទៅ អ្នកចូលរួមរៀបចំបទដ្ឋានសម្រាប់ការបណ្តុះបណ្តាលជាមួយគ្នា ហើយធ្វើការពិភាក្សាពីមូលហេតុដែលបទដ្ឋានទាំងនេះមាន សារៈសំខាន់។ អ្នកបណ្តុះបណ្តាលអាចឱ្យអ្នកចូលរួមណាម្នាក់ស្ម័គ្រចិត្តសួរអ្នកចូលរួមផ្សេងទៀត ឱ្យលើកឡើងពីបទបញ្ជាផ្ទៃក្នុងសម្រាប់វគ្គបណ្តុះបណ្តាលនេះ។

នៅពេលដែលអ្នកចូលរួមលើកឡើងពីបទបញ្ជាទាំងនេះ ក្រុមអាចសម្រេចចិត្តថាតើព្រមព្រៀងយកដែរឬទេ។ ប្រសិនបើ ពួកគាត់ព្រមព្រៀងយក គ្រូបណ្តុះបណ្តាលអាចសរសេរបទបញ្ជានេះនៅលើក្រដាសមួយសន្លឹក ឬប្រើរូបភាពណាមួយ ដូចជា រូបភាពនៅក្នុងឧបសម្ព័ន្ធទី២ជាដើម។ បន្តរក្សាបទបញ្ជាទាំងនេះនៅលើជញ្ជាំងនៅក្នុងអំឡុងពេលបណ្តុះបណ្តាលនេះ ដើម្បីឱ្យគ្រប់គ្នាអាចមើលឃើញ។

**ឧបសម្ព័ន្ធ ទី២**

បទបញ្ជាផ្ទៃក្នុងគួរមានដូចជា ៖

១. ប្រតិបត្តិចំពោះគ្នាទៅវិញទៅមកដោយការគោរព

២. ចូលរួមឱ្យបានសកម្ម

៣. និយាយមួយៗនិងច្បាស់លាស់

៤. ដាក់ទូរស័ព្ទកុំឱ្យឮសម្លេង

៥. ត្រូវមកចូលរួមឱ្យបានទាន់ពេលវេលា







### ៣. ការងាររដ្ឋបាល និងការរៀបចំចាត់ចែង

ប្រាប់អ្នកចូលរួមទាំងអស់អំពីការងាររដ្ឋបាល និងភស្តុភារសម្រាប់ការបណ្ដុះបណ្ដាល ដូចជា ៖

- សម្រាកអាហារសម្រន់ និងអាហារថ្ងៃត្រង់ ត្រូវបានផ្ដល់ជូន(បើសិនជាមាន)
- អ្នកតមអាហារពិសេស
- តម្រូវការគាំទ្រពិសេស
- បញ្ជាក់ពីអ្នកទទួលខុសត្រូវ ចំពោះសំណួរពាក់ព័ន្ធនឹងតម្រូវការខាងរដ្ឋបាល និងភស្តុភារ
- ម៉ោងពេលចាប់ផ្ដើម និងបញ្ចប់របស់វគ្គបណ្ដុះបណ្ដាលនេះ

### ៤. ការរំពឹងទុករបស់សិក្ខាកាម

ចែកក្រដាសកាតពណ៌ទៅឱ្យអ្នកចូលរួម និងសូមឱ្យគាត់សរសេរពីការរំពឹងទុករបស់ពួកគាត់ម្នាក់ៗសម្រាប់ការបណ្ដុះបណ្ដាលនេះ។ មានន័យថា "តើអ្នកចង់ដឹង ឬរៀនអ្វីនៅចុងវគ្គបណ្ដុះបណ្ដាល?" ប្រមូលក្រដាសកាតពណ៌ទាំងនេះ និងមើលត្រួសៗ ដើម្បីបានគំនិតអំពីការរំពឹងទុករបស់ពួកគាត់។ រៀបចំ និងបែងចែកក្រដាសកាតពណ៌ទាំងនេះជាក្រុមក្នុងពេលសម្រាក ហើយធ្វើការប្រៀបធៀបជាមួយនឹងកម្មវិធី ថាតើត្រូវគ្នាដែរឬទេ ៖ សូមធ្វើការវិនិច្ឆ័យ ថាតើអ្នកចង់ធ្វើការកែសម្រួលចំណុចអ្វីមួយដែរឬទេប្រសិនបើចាំបាច់ ។ សូមប្រាប់អ្នកចូលរួមវិញពីអ្វីដែលអ្នកបានរកឃើញ។

### ៥. បង្ហាញគោលបំណង គោលដៅ និងកាលវិភាគនៃវគ្គបណ្ដុះបណ្ដាល

គ្រូបណ្ដុះបណ្ដាលបង្ហាញគោលបំណង គោលដៅ និងកាលវិភាគវគ្គបណ្ដុះបណ្ដាល តាមរយៈស្លាយ ឬក្រដាសផ្ទាំងធំ(សូមជ្រើសរើសគោលដៅជាក់លាក់សម្រាប់កម្រិតនៃអ្នកចូលរួម ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត)

**កំណត់សម្គាល់ ៖**

ជំពូកដំបូងនេះ គឺមានសារៈសំខាន់ណាស់ ដើម្បីបង្កើតនូវបរិយាកាសរាក់ទាក់ និងបើកចំហដែលផ្ដល់លទ្ធភាពឱ្យមានការលើកឡើងពីការយល់ឃើញផ្សេងៗគ្នារបស់អ្នកចូលរួម។ បញ្ជាក់ប្រាប់អ្នកចូលរួមថា ការបណ្ដុះបណ្ដាលនេះតម្រូវឱ្យមានការចូលរួម និងការជជែកពិភាក្សាគ្នាផុលផុស ដូច្នេះចាំបាច់ត្រូវតែមានការចូលរួមឱ្យបានសកម្ម។

## ៦. ការវាយតម្លៃចំណេះដឹងអ្នកចូលរួមមុនវគ្គបណ្តុះបណ្តាល



- ផ្តល់ឱ្យអ្នកចូលរួមនូវបញ្ជីសំណួរវាយតម្លៃចំណេះដឹងមុនវគ្គបណ្តុះបណ្តាល។ ទុកពេលសមស្របដើម្បីឱ្យអ្នកចូលរួមឆ្លើយនឹងសំណួរ។ គ្រូបណ្តុះបណ្តាលគួរជួយអ្នកដែលជួបការលំបាកក្នុងការឆ្លើយសំណួរ។
- ឱ្យអ្នកចូលរួមបំពេញទម្រង់នេះរៀងៗខ្លួន ដោយរំលឹកប្រាប់ពួកគាត់ថា ចំណេះដឹងរបស់ពួកគាត់ប្រហែលជាដូចគ្នា ឬច្រើនជាងអ្វីដែលអ្នកអង្គុយជិតពួកគាត់ដឹង។

**ឧបសម្ព័ន្ធទី ១០និង១១**

- ពន្យល់ប្រាប់អ្នកចូលរួមថា ពួកគាត់ក៏នឹងធ្វើសំណួរវាយតម្លៃក្រោយការបណ្តុះបណ្តាលនៅចុងវគ្គផងដែរ ហើយលទ្ធផលនឹងយកមកប្រៀបធៀបជាមួយនឹងសំណួរវាយតម្លៃមុនការបណ្តុះបណ្តាលនេះ ដើម្បីពិនិត្យមើលកម្រិតនៃការយល់ដឹងដែលទទួលបានពីការរៀនសូត្រក្នុងវគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃនេះ។

**កំណត់សម្គាល់ ៖**

ក្រៅពីប្រៀបធៀបលទ្ធផល នៅចុងវគ្គបណ្តុះបណ្តាលនេះ គ្រូបណ្តុះបណ្តាលអាចស្វែងយល់ពីកម្រិតចំណេះដឹងបច្ចុប្បន្នអំពីការបញ្ចូលពិការភាពរបស់អ្នកចូលរួម និងជួយឱ្យអ្នកចូលរួមអាចចំណាំពីជំពូក និងមេរៀនដែលពិបាកៗផងដែរ។

## ៧. សេចក្តីពន្យល់ពីសៀវភៅណែនាំបណ្តុះបណ្តាល

ពន្យល់ពីខ្លឹមសារនៃសៀវភៅណែនាំសម្រាប់អ្នកចូលរួម និងរបៀបប្រើប្រាស់សៀវភៅណែនាំ ៖

- សូមមើលកំណត់សម្គាល់ផ្ទាល់ខ្លួន ឃោបល់។ល។
- លើកឡើងថា គ្រូបណ្តុះបណ្តាលនឹងមើលតាមសៀវភៅណែនាំនេះ ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលនេះ
- សៀវភៅណែនាំសម្រាប់អ្នកចូលរួម គឺជាធនធានមួយ ដែលអ្នកចូលរួមអាចយកត្រលប់ទៅវិញ និងប្រើប្រាស់ក្នុងការងាររបស់ខ្លួន

| មេរៀន១.៣<br>ការស្គាល់គ្នា តាមរយៈលំហាត់គូរបាតដៃ | |
|---|---|
| គោលដៅ៖ | បង្កើតការស្គាល់គ្នា និងបរិយាកាសស្និទ្ធស្នាល ដើម្បីឱ្យអ្នកចូលរួមកាន់តែចែករំលែក និងការចូលរួមកាន់តែច្រើន |
| រយៈពេល | ២៥នាទី |

១. ពន្យល់ពីលំហាត់ ៖ យើងនឹងធ្វើលំហាត់មួយ ដើម្បីឱ្យយើងកាន់តែស្គាល់គ្នា។

២. ឱ្យអ្នកចូលរួមទាំងអស់គូររូបបាតដៃរបស់ពួកគាត់ នៅលើក្រដាសមួយសន្លឹក ហើយសរសេរឈ្មោះរបស់ពួកគាត់នៅចំកណ្ដាលបាតដៃ។

៣. ឱ្យអ្នកចូលរួមទាំងអស់សរសេរ៥ចំណុចអំពីខ្លួនគាត់ ដោយសរសេរមួយចំណុចដាក់លើម្រាមនីមួយៗ។ ក្នុងនាមជាអ្នកបណ្ដុះបណ្ដាល សូមធ្វើដូចគ្នា។




៤. បង្ហាញបាតដៃរបស់អ្នកទៅកាន់ក្រុម។ បន្ទាប់មក ឱ្យអ្នកចូលរួមបង្ហាញបាតដៃរបស់ពួកគាត់ទៅកាន់ក្រុម ហើយបិទបាតដៃនេះនៅលើជញ្ជាំង ដូចរូបពិពណ៌ដូច្នោះដែរ។

**កំណត់សម្គាល់ ៖**

សូមឱ្យអ្នកចូលរួមបង្ហាញពីបាតដៃរបស់ពួកគាត់ ក្នុងក្រុមដែលមានអ្នកចូលរួមតិចជាង៨នាក់ប៉ុណ្ណោះ។ សម្រាប់ក្រុមដែលមានអ្នកចូលរួមច្រើនជាងនេះ ឱ្យក្រុមបិទបាតដៃរបស់ពួកគាត់លើទ្រូង ហើយដើរជុំវិញ និងធ្វើការផ្លាស់ប្ដូរការចាប់ដៃរបស់ពួកគាត់។

# ជំពូកទី២

# ចំណេះដឹងជាមូលដ្ឋានអំពី ពិការភាព និងការដាក់បញ្ចូលពិការភាព

# ជំពូកទី២

# ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាព

## ក). សេចក្តីពិពណ៌នា

ខ្លឹមសារនៃមេរៀននេះ ផ្តោតលើចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាពនៅក្នុងការងារអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ដោយមានគោលបំណងជួយឱ្យអ្នកចូលរួម ៖

- យល់ដឹងនូវការសន្មតផ្ទាល់ខ្លួនអំពីពិការភាព និងជនពិការ
- យល់ដឹងអំពីពិការភាព
- យល់ដឹងពីភាពខ្សោយ និងឧបសគ្គនានាដែលរារាំងដល់ការចូលរួមរបស់ជនពិការនៅក្នុងសង្គម
- ឱ្យតម្លៃស្មើគ្នានៅក្នុងសង្គមរវាងជនពិការ និងជនមិនពិការ
- ឆ្លុះបញ្ចាំងពីការយល់ដឹងលើការសន្មតផ្ទាល់ខ្លួន ដោយធ្វើការប្រៀបធៀបនឹងគំនិតថ្មីៗ អំពីពិការភាព ឧបសគ្គ និងការដាក់បញ្ចូលពិការភាពនៅក្នុងការងារអភិបាលកិច្ចមូលដ្ឋាន។

## ខ). មាតិកាមេរៀន

| លរ | មេរៀន | រយៈពេល | សម្ភារៈ និងឯកសារ |
|---|---|---|---|
| ២.១. | និយមន័យនៃពិការភាព | ៣០នាទី | ផ្ទាំងរូបភាពទំហំA2 ដែលបង្ហាញពីករណី ស្រីមុំ សុផល ថាវី មករា និងបុប្ផា |
| ២.២. | ប្រភេទផ្សេងៗនៃភាពខ្សោយ | ៣០នាទី | រូបគំនូរជនពិការ ទម្រង់ឯកសារសម្ភាស ក្រដាសផ្ទាំងធំ |
| ២.៣. | ពិការភាពក្នុងប្រទេសកម្ពុជា | ៣០នាទី | |
| ២.៤. | "ល្បែងដំណើរជីវិត" | ៣០នាទី | |
| ២.៥. | ឧបសគ្គដែលជនពិការជួបប្រទះ | ៣០នាទី | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កាត |
| ២.៦. | សារៈសំខាន់ការដាក់បញ្ចូលពិការភាពក្នុងអភិបាលកិច្ចមូលដ្ឋាន | ២៥នាទី | ក្រដាសផ្ទាំងធំ |
| ២.៧. | សង្ខេបមេរៀនជំពូកទី២ | ១០នាទី | សូមមើលសៀវភៅណែនាំអ្នកចូលរួម |
| ២.៨. | ការវាយតម្លៃប្រចាំថ្ងៃ | ១០នាទី | ក្រដាសកាតពណ៌/ក្រដាស |
| **សរុប** | | **១៩៥នាទី** | |

## គ). ដំណើរការសម្របសម្រួល

<table>
<tr><td colspan="2">មេរៀន ២.១<br>និយមន័យនៃពិការភាព</td></tr>
<tr><td colspan="2">គោលដៅ ៖<br>• អ្នកចូលរួមបានសិក្សាពីករណីសិក្សានីមួយៗដែលពាក់ព័ន្ធនឹងពិការភាព<br>• អ្នកចូលរួមអាចគិតពិចារណាអំពីពិការភាព ធៀបនឹងការសន្មតផ្ទាល់ខ្លួនរបស់ពួកគាត់ និង<br>• ពន្យល់ពីភាពខុសប្លែកគ្នារវាងពិការភាព និងភាពខ្សោយ</td></tr>
<tr><td>រយៈពេល</td><td>៣០នាទី</td></tr>
</table>

១. ធ្វើការពន្យល់ ដោយលើកយកតួអង្គ៥នាក់ មកបង្ហាញសម្រាប់វគ្គបណ្តុះបណ្តាលនេះ។ ខាងក្រោមនេះ គឺជាករណីសិក្សាទាំង៥ ដែលនឹងយកមកប្រើក្នុងវគ្គបណ្តុះបណ្តាលទាំងមូល។

**ឧបសម្ព័ន្ធ ទី៣**

២. បង្ហាញករណីសិក្សារបស់ស្រីមុំ នៅក្នុងឧបសម្ព័ន្ធទី៣។ សួរអ្នកចូលរួម តើពួកគាត់សង្កេតឃើញអ្វីខ្លះក្នុងរូបភាពនេះ។ រៀបរាប់ពីរឿងរ៉ាវរបស់ស្រីមុំឱ្យអ្នកចូលរួមស្តាប់។

**១. ស្រីមុំ**



សួរអ្នកចូលរួម ថាតើពួកគាត់ចង់ស្តាប់សាច់រឿងនេះម្តងទៀតដែរឬទេ។ ប្រសិនបើចង់ សូមអានម្តងទៀត។ សួរថាតើពួកគាត់មានសំណួរអ្វីដែរឬទេ។ បិទផ្ទាំងរូបភាពនៅលើជញ្ជាំង ហើយទុកវានៅទីនោះ សម្រាប់មើលក្នុងវគ្គបណ្តុះបណ្តាលនេះទាំងមូល។

៣. ធ្វើដូចខាងលើ សម្រាប់ករណីសិក្សា៤ផ្សេងទៀត រហូតដល់សាច់រឿងទាំងអស់ ត្រូវអានចប់រួចរាល់ ហើយផ្ទាំងរូបភាពទាំងអស់ត្រូវបានបិទនៅលើជញ្ជាំង។ សូមមើលសៀវភៅណែនាំអ្នកចូលរួមដែលមានបង្ហាញពីសាច់រឿងទាំងអស់នេះផងដែរ។

**២. ថាវី**



**៣. សុផល**



**៤. មករា**



**៥. បុប្ផា**



៤. ការណែនាំពីលំហាត់នេះ៖ សូមឱ្យអ្នកចូលរួមបំបែកជា៤ក្រុម ប៉ុន្តែជាដំបូងត្រូវចាប់ផ្តើមសកម្មភាពនេះ ជាមួយនឹងអ្នកចូលរួមនៅក្នុងក្រុមធំសិន។ ពន្យល់ថា ក្រុមនីមួយៗត្រូវឆ្លើយនឹងសំណួរមួយ ចំនួន អំពីករណីសិក្សាទាំង៤នេះ។ ផ្តល់ឱ្យក្រុមនីមួយៗនូវករណីសិក្សាមួយ។ ដើម្បីបង្ហាញក្រុមពីរបៀបធ្វើលំហាត់នេះ សូមធ្វើតាមជំហានបន្ទាប់។

៥. ចង្អុលទៅរូបភាពរបស់ស្រីមុំ និងរំលឹកអ្នកចូលរួមពីសាច់រឿងរបស់នាង។

៦. សម្របសម្រួលការពិភាក្សាអំពីករណីសិក្សានេះនៅក្នុងក្រុមធំ ឱ្យអ្នកចូលរួម ឆ្លើយនឹងសំណួរអំពីសាច់រឿងនេះដូចខាងក្រោម ៖

- នៅក្នុងសាច់រឿងនេះ តើស្រីមុំមានភាពខ្សោយលើផ្នែកអ្វី? (ចម្លើយ ៖ ភាពខ្សោយផ្នែករាងកាយ ដោយលលាដ៍ក្បាលធំខុសធម្មតា ហើយជើងទាំងពីររបស់នាងមានសភាពទន់ដែលមិនអាចដើរបាន)។
- ហេតុអ្វីបានជាស្រីមុំមិនអាចទៅសាលារៀនបាន? (ចម្លើយ ៖ ម្តាយរបស់នាងគិតថា ស្រីមុំ រៀនមិនចេះ ប៉ុន្តែនេះមិនមែនជាការពិតឡើយ)។
- តើមនុស្សផ្សេងទៀតមើលមកស្រីមុំយ៉ាងដូចម្តេច? (ចម្លើយ ៖ នៅក្នុងករណីនេះ នាងត្រូវបានគេជួយទើបអាចទៅរៀនបាន)។

ពិភាក្សាចម្លើយដែលអ្នកចូលរួមផ្តល់ឱ្យ។ ផ្តល់ចម្លើយដែលត្រឹមត្រូវក្រោយពីបានពិភាក្សារួច។ រៀបចំការពិភាក្សាតាមគុ ដោយប្រើប្រាស់ក្រដាសកាតពណ៌ចម្រុះពណ៌ ៖

១). សរសេរឈ្មោះស្រីមុំ នៅលើក្រដាសកាតពណ៌លឿង

២). ភាពខ្សោយរបស់នាងនៅលើក្រដាសកាតពណ៌បៃតង

៣). ការលំបាកដែលនាងជួបប្រទះនៅលើក្រដាសកាតពណ៌ពណ៌ទឹកក្រូច និង

៤). ការយល់ឃើញរបស់អ្នកដទៃលើក្រដាសកាតពណ៌ពណ៌ខៀវ។

សូមមើលតារាងខាងក្រោម ៖

| ឈ្មោះ | ភាពខ្សោយ | ការលំបាកដែលពួកគាត់ជួបប្រទះ | ការយល់ឃើញរបស់អ្នកដទៃ |
|---|---|---|---|
| ស្រីមុំ | ជើងមានសភាពទន់ (មិនអាចដើរបាន)។ | មិនអាចទៅសាលារៀនបាន ដោយសារតែម្តាយគិតថានាងរៀនមិនចេះ។ | អង្គការជនពិការ និងអង្គការមិនមែនរដ្ឋាភិបាលជឿថា នាងអាចរៀនចេះដូចអ្នកដទៃដែរ។ |

**កំណត់សម្គាល់៖**

ជាការសំខាន់ ដែលអ្នកចូលរួមត្រូវយល់ពីអ្វីដែលពួកគាត់ត្រូវធ្វើ ដូច្នេះ នៅពេលដែលចាំបាច់ សូមពន្យល់លំហាត់នេះម្តងទៀត រហូតដល់អ្នកចូលរួមងាយស្រួលធ្វើលំហាត់នេះ។

៧. ឥឡូវនេះ អ្នកចូលរួមយល់ពីរបៀបធ្វើលំហាត់។ សូមធ្វើលំហាត់ស្រដៀងគ្នានេះ នៅតាមក្រុមជាមួយនឹងករណីសិក្សារបស់សុផល ថាវី មករា និងបុប្ផា។ ឱ្យក្រុមអានករណីសិក្សាឱ្យបានឮៗនៅក្នុងក្រុម ហើយពិភាក្សាសំណួរខាងក្រោម ៖

- នៅក្នុងករណីសិក្សានេះ តើ(តួអង្គ...) មានភាពខ្សោយលើផ្នែកអ្វី?
- តើ(តួអង្គ...) ជួបប្រទះនឹងបញ្ហាប្រឈមអ្វីខ្លះ?
- តើអ្នកដទៃមើលមក(តួអង្គ...)យ៉ាងដូចម្តេច? តើ(តួអង្គ...) ត្រូវបានចាត់ទុកថា ជាបុគ្គលដែលមានតម្លៃក្នុងសង្គមដែរឬទេ?

ឱ្យអ្នកចូលរួមសរសេរចម្លើយរបស់ពួកគាត់លើក្រដាសកាតពណ៌ឱ្យត្រូវពណ៌ ៖

| ឈ្មោះ (លឿង) | ភាពខ្សោយ (បៃតង) | ការលំបាកដែលពួកគាត់ជួបប្រទះ (ទឹកក្រូច) | ការយល់ឃើញរបស់អ្នកដទៃ (ខៀវ) |
|---|---|---|---|

៨. សម្របសម្រួលការពិភាក្សាអំពីពិការភាពនៅក្នុងក្រុមធំ ដោយស្នើឱ្យគ្រប់ក្រុមទាំងអស់ផ្តល់នូវចម្លើយរបស់ពួកគាត់ដែលបានសរសេរលើក្រដាសកាតពណ៌។ បន្ទាប់មក យកក្រដាសកាតពណ៌ទាំងនោះបិតនៅលើក្រដាសផ្ទាំងធំដែលបានរៀបចំទុក។

| ឈ្មោះ | ភាពខ្សោយ | ការលំបាកដែលគាត់ជួបប្រទះ | ការយល់ឃើញរបស់អ្នកដទៃ |
|---|---|---|---|
| **ស្រីមុំ** | ពិការជើងទាំងពីរមានសភាពទន់ (មិនអាចដើរបាន) | • មិនបានទៅសាលារៀនបានដោយសារតែ ម្តាយគិតថា នាងរៀនមិនចេះ | • អង្គការជនពិការ និងអង្គការមិនមែនរដ្ឋាភិបាលជឿថា<br>• នាងអាចរៀនចេះ ដូចអ្នកដទៃ |
| **ថាវី** | ពិការភ្នែក (មើលមិនឃើញ) | • មិនបានទៅចូលរួមក្នុង កិច្ចប្រជុំសហគមន៍ | • គិតថាការចូលរួមរបស់ថាវីនៅក្នុងកិច្ចប្រជុំសហគមន៍ថាជារឿងមិនសំខាន់<br>• ឥឡូវនេះ សមាជិកគ្រួសារយល់ថាថាវីអាចរួមចំណែកក្នុងសកម្មភាពសេដ្ឋកិច្ចគ្រួសារ |
| **សុផល** | គ-ថ្លង់(មិនអាចស្តាប់ឮ) | • មិនទទួលបានព័ត៌មាននៅសាលារៀន<br>• មិនអាចដើរតាមផ្លូវបានដោយសុវត្ថិភាព<br>• មិនអាចទៅមណ្ឌលសុខភាពបាន | • អ្នកដទៃមិនខ្វល់នឹងគាត់<br>• ឥឡូវនេះ អ្នកគ្រប់គ្រងនៅកន្លែងជួសជុលម៉ូតូគាំទ្រដល់និយោជិតរបស់គាត់ |
| **មករា** | ខ្សោយប្រព័ន្ធចលករខួរក្បាល(មិនអាចបញ្ជាសាច់ដុំបាន) | • ត្រូវបានគេវាយធ្វើបាប នៅសាលារៀន បោះបង់ចោលការសិក្សា និងនៅផ្ទះ | • គេមើលមក មករា ថាជាមនុស្សឆ្កួត |
| **បុប្ផា** | ខ្សោយសតិបញ្ញាពិបាកក្នុងការរៀន (មិនអាចវិភាគព័ត៌មានបានល្អ) | • មិនអាចចុះហត្ថលេខាលើគណនីធនាគារបាន(ប៉ុន្តែអ្នកគ្រប់គ្រងធនាគារអនុញ្ញាតឱ្យគាត់ផ្តិតមេដៃ) | • ចាត់ទុកបុប្ផាថាជាមនុស្សឆ្កួត<br>• ប៉ុន្តែអ្នកគ្រប់គ្រងចាត់ទុកបុប្ផាថាជាអតិថិជន |

៩. ផ្តោតការយកចិត្តទុកដាក់លើការលំបាក ដែលជនពិការជួបប្រទះ។ សូមអានចម្លើយត្រឹមត្រូវឱ្យបានឮៗម្តងទៀត។ នេះផ្តល់នូវព័ត៌មានល្អៗ ដើម្បីបង្ហាញពីចំណុចខុសប្លែកគ្នារវាងពិការភាព និងភាពខ្សោយ។ សូមលើកឡើងថា ការបណ្តុះបណ្តាលនេះនិយាយពីការដាក់

បញ្ចូលពិការភាព ប៉ុន្តែយើងមិនទាន់ពិភាក្សាគ្នានៅឡើយពី"ពិការភាព" នោះទេ។ សូមពិនិត្យមើលតារាងនេះ តើអ្នកគិតថាអ្វីទៅដែលហៅថា"ពិការភាព"?។

ឥឡូវនេះ ពន្យល់ពីសារគន្លឹះនៃមេរៀន ដោយពន្យល់ពីភាពខុសប្លែកគ្នារវាង ភាពខ្សោយ និងពិការភាព តាមរយៈ ការបង្ហាញស្លាយ ឬក្រដាសផ្ទាំងធំនូវសារគន្លឹះ ៖

- ភាពខ្សោយគឺជាការបាត់បង់មុខងារណាមួយរបស់រាងកាយ
- ពិការភាពមិនមែនជាការបាត់បង់មុខងារណាមួយរបស់រាងកាយនោះទេ
- ពិការភាពគឺពាក់ព័ន្ធជាមួយនឹងឧបសគ្គក្នុងបរិស្ថាន ឬឥរិយាបថរបស់មនុស្ស ដែលរារាំងជនពិការក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ

**ភាពខ្សោយ គឺជាការបាត់បង់មុខងារណាមួយរបស់រាងកាយ។ ឧទាហរណ៍ ៖** សុផល មានភាព ខ្សោយ គឺថ្លង់។ ដោយសារតែភាពខ្សោយរបស់គាត់ គាត់មិនអាចស្តាប់ឮឡើយ។

**ពិការភាព គឺនៅពេលដែលមនុស្សម្នាក់មានភាពខ្សោយ ហើយជួបប្រទះនឹងឧបសគ្គរាំងមិនឱ្យគេធ្វើសកម្មភាពអ្វីមួយ។ ឧទាហរណ៍** ៖ សុផលស្តាប់មិនឮ ប្រសិនបើ អ្នកដទៃទៀត អាចប្រាស្រ័យទាក់ទងជាមួយគាត់បាន នៅសាលារៀនក្តី និងនៅមណ្ឌលសុខភាពក្តី នោះវាមិនមែនជាបញ្ហាសម្រាប់ សុផល ឡើយ។ ឥឡូវនេះ ដោយសារតែការប្រាស្រ័យទាក់ទងគ្នា គឺជាការលំបាក គាត់មិនអាចចូលរួម ដូចអ្នកផ្សេងទៀត នៅក្នុងសាលារៀន ឬទៅមណ្ឌលសុខភាពឡើយ។

ដូច្នេះ ភាពខ្សោយមិនមែនជាបញ្ហាខ្លួនឯងនោះទេ ប៉ុន្តែគឺឧបសគ្គទៅវិញទេ ដែលធ្វើឱ្យអ្នកដែលមានភាពខ្សោយជួបប្រទះនឹងបញ្ហាក្នុងការចូលរួមក្នុងសកម្មភាពផ្សេងៗ ដូចអ្នកដទៃ។

១០. បិទផ្ទាំងរូបភាព ឬក្រដាសនៅលើជញ្ជាំង ដែលសរសេរខ្លឹមសារដូចខាងក្រោម ហើយរក្សាផ្ទាំងរូបភាពនេះនៅជញ្ជាំង សម្រាប់រំលឹកដល់អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាល។

**ឧបសម្ព័ន្ធ ទី៤**

**ភាពខ្សោយ + ឧបសគ្គ = ពិការភាព**

១១. សួរអ្នកចូលរួម តើពួកគាត់មានសំណួរអ្វីទេកន្លងមក។ ប្រាប់អ្នកចូលរួមម្តងទៀតថា វាជាការសំខាន់ណាស់ ដែលត្រូវយល់ថា ភាពខ្សោយ និងពិការភាព មិនដូចគ្នានោះទេ។ សាធារណជនទូទៅយល់ឃើញថា ពាក្យ ពិការភាព និងភាពខ្សោយ តែងតែត្រូវបានគេឱ្យន័យដូចគ្នា ប៉ុន្តែគឺវាខុសគ្នា ៖

- ភាពខ្សោយ គឺជាការបាត់បង់មុខងាររបស់រាងកាយ
- ពិការភាព គឺនៅពេលដែលអ្នកមានភាពខ្សោយ ជួបប្រទះនឹងឧបសគ្គអ្វីមួយ ហើយមិនអាចធ្វើសកម្មភាពបាន
- រូបមន្តសាមញ្ញ ៖ ភាពខ្សោយ + ឧបសគ្គ = ពិការភាព

**កំណត់សម្គាល់ ៖**

ក្នុងករណីភាគច្រើនអ្នកដែលមានភាពខ្សោយ ក៏ជាជនពិការផងដែរ ដោយសារតែមានឧបសគ្គជាច្រើននៅក្នុងសង្គម។ ដូច្នេះហើយ បានជាយើងនឹងប្រើពាក្យជនពិការសម្រាប់វគ្គបណ្ដុះបណ្ដាលនេះ។

<table>
<tr><td colspan="2">មេរៀន២.២<br>ប្រភេទផ្សេងៗនៃភាពខ្សោយ</td></tr>
<tr><td colspan="2">គោលដៅ ៖ អ្នកចូលរួមយល់ដឹងពីប្រភេទខុសៗគ្នានៃភាពខ្សោយ និងកម្រិតនៃការលំបាកផ្សេងៗ ដែលជនពិការជួបប្រទះ</td></tr>
<tr><td>រយៈពេល</td><td>៣០នាទី</td></tr>
</table>

១. ការណែនាំពីលំហាត់ ៖ ប្រាប់អ្នកចូលរួមថា ឥឡូវនេះ យើងនឹងគិតពីប្រភេទនៃភាពខ្សោយសិន។ បន្ទាប់មកយើងនឹងធ្វើលំហាត់ ដើម្បីកំណត់រកអ្នកដែលមានភាពខ្សោយអ្វីមួយ។

២. ប្រាប់អ្នកចូលរួមថា ភាពខ្សោយមានច្រើនប្រភេទ។ **ឧទាហរណ៍** ៖ មនុស្សមួយចំនួនអាចមានការលំបាកក្នុងការស្ដាប់ ដូចជា សុផល នៅក្នុងសាច់រឿងខាងលើនេះជាដើម។ ឱ្យអ្នកចូលរួមរៀបរាប់ពីប្រភេទផ្សេងៗនៃភាពខ្សោយ។

ចម្លើយអាចមានដូចជា ៖ អ្នកដែលមើលមិនឃើញ អ្នកដែលបាត់បង់ដៃជើង អ្នកដែលប្រើរទេះរុញ អ្នកដែលខ្សោយសតិបញ្ញា អ្នកគ-ថ្លង់ អ្នកដែលមានវិបល្លាសស្មារតី។

ប្រសិនបើ អ្នកចូលរួមពិបាកឆ្លើយ សូមបង្ហាញរូបភាព ដែលបង្ហាញពីប្រភេទភាពខ្សោយផ្សេងៗគ្នា។ ហើយសូមចងចាំថា មិនមែនពិការភាពទាំងអស់សុទ្ធតែអាចមើលឃើញ ឬស្ដែងចេញច្បាស់នោះទេ។



សូមសរសេរភាពខ្សោយខាងក្រោម (ផ្អែកតាមប្រភេទនៃភាពខ្សោយដែលមានចែងក្នុងឯកសារក្រុមវ៉ាស៊ីងតោន)នៅលើក្រដាសផ្ទាំងធំ ៖ ដោយពិភាក្សាជាមួយនឹងអ្នកចូលរួម ៖

**ឧបសម្ព័ន្ធ ទី៥**

១. ពិបាកក្នុងការមើល ៖ ខ្សោយគំហើញ (ដូចជា ថាវី ជាដើម)

២. ពិបាកក្នុងការស្តាប់ ៖ ខ្សោយខាងការស្តាប់(ដូចជា សុផល ជាដើម)

៣. ពិបាកក្នុងការធ្វើចលនា ឬប្រើប្រាស់ផ្នែកណាមួយនៃរាងកាយ ៖ ខ្សោយផ្នែករាងកាយ (ដូចជា ស្រីមុំ ឬមករា ជាដើម)

៤. ពិបាកក្នុងការចងចាំ ឬផ្ចង់ស្មារតី ឬពិបាកថែទាំខ្លួនឯង៖ ខ្សោយផ្នែក បញ្ញាស្មារតី (ដូចជា បុប្ផា ជាដើម)

៥. ពិបាកក្នុងការនិយាយ៖ ខ្សោយផ្នែកនិយាយ

**កំណត់សម្គាល់ ៖**

សូមបិទក្រដាសផ្ទាំងធំលើជញ្ជាំង និងបិទរូបភាពទំហំ A4 ដែលបង្ហាញឧទាហរណ៍ពីភាពខ្សោយលើក្រដាសផ្ទាំងធំ។ រូបភាពទាំងនេះ គឺដូចគ្នានឹងរូបក្នុងស្លាយ ឬឧបសម្ព័ន្ធទី៥ ដែរ។

៣. សួរទៅអ្នកចូលរួមថាតើពួកគាត់ស្គាល់ជនពិការណាខ្លះនៅក្នុងគ្រួសារ ឬអ្នកជិតខាងរបស់ពួកគាត់ដែរឬទេ? ដើម្បីជួយឱ្យអ្នកចូលរួមស្វែងរកឧទាហរណ៍ ពីជនពិការដែលពួកគាត់ស្គាល់ច្បាស់ជាងឧទាហរណ៍ ដែលបានបង្ហាញខាងលើ។

៤. សួរអ្នកចូលរួមថាតើភូមិឃុំដែលពួកគាត់រស់នៅមានទិន្នន័យស្ថិតិអំពីចំនួនជនពិការដែរឬទេ។ ប្រសិនបើមាន តើទិន្នន័យនេះត្រូវបានគេប្រមូល និងប្រើប្រាស់យ៉ាងដូចម្តេច? តើទិន្នន័យអំពីចំនួនជនពិការត្រូវបានគេបូកសរុបនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តដែរឬទេ? តើគេប្រើប្រាស់ទិន្នន័យនេះសម្រាប់ការធ្វើផែនការដែរឬទេ?

៥. **ការធ្វើបង្ហាញ** ៖ ពន្យល់ថា គោលបំណងរបស់លំហាត់នេះ គឺដើម្បីស្វែងយល់ឱ្យបានកាន់តែប្រសើរថែមទៀតអំពីរបៀបកំណត់រកជនពិការ។ គ្រូបណ្តុះបណ្តាលលើកឡើងពីឯកសារចែកដែលមានសំណួរ ដូចក្នុងសៀវភៅណែនាំសម្រាប់អ្នកចូលរួម។ អ្នកចូលរួមគួរមានឯកសារចែកនេះនៅខាងមុខខ្លួន ក្នុងអំឡុងពេលនៃការធ្វើបង្ហាញនេះ។ ការធ្វើបង្ហាញនេះត្រូវធ្វើឡើង ដោយគ្រូបណ្តុះបណ្តាល និងអ្នកស្ម័គ្រចិត្តម្នាក់។ គ្រូបណ្តុះបណ្តាលសរសេរលើក្រដាសផ្ទាំងធំ ៖

**ឧបសម្ព័ន្ធ ទី៦**

ក). ទេ - ពុំមានការលំបាកអ្វីឡើយ

ខ). បាទ/ចាស - មានការលំបាកខ្លះ

គ). បាទ/ចាស - មានការលំបាកច្រើន

ឃ).មិនអាចធ្វើបានតែម្តង

គ្រូបណ្តុះបណ្តាលសួរសំណួរដែលមាននៅក្នុងទម្រង់(ឧបសម្ព័ន្ធទី៦) ហើយអ្នកស្ម័គ្រចិត្តឆ្លើយ។ អ្នកបណ្តុះបណ្តាលគូសសញ្ញាលើ សំណួរ និងចម្លើយនៅលើក្តារខៀន។ សូមធ្វើលំហាត់នេះម្តងទៀតជាមួយនឹងអ្នកស្ម័គ្រចិត្តម្នាក់ទៀត។

គ្រូបណ្តុះបណ្តាលពន្យល់ថា គេអាចប្រើប្រាស់ទម្រង់នេះ ដើម្បីកំណត់រកជនពិការ។ វាក៏ បង្ហាញផងដែរថា មានភាពខ្សោយជាច្រើនប្រភេទ ហើយភាពខ្សោយមួយចំនួនអាចមើលឃើញជាក់ស្តែង និងមួយចំនួនទៀតមិនបានស្តែងចេញច្បាស់ឡើយ។

៦. **ការពិភាក្សាក្នុងក្រុមធំ ដើម្បីការឆ្លុះបញ្ចាំងពីលំហាត់ ៖** មានជនពិការមួយចំនួនអាចមើលដឹង និងមួយចំនួនទៀតមិនអាចមើល ដឹងតាមរយៈរូបរាងខាងក្រៅ។ តើអ្នកចូលរួមធ្លាប់ជួបប្រទះបែបនេះដែរឬទេ? ហេតុអ្វីបានជាដូច្នេះ តើគេអាចធ្វើអ្វីខ្លះបានចំពោះបញ្ហានេះ?

៧. **បង្ហាញសារគន្លឹះ តាមរយៈស្លាយ ឬក្រដាសផ្ទាំងធំ ៖** ភាពខ្សោយមានច្រើនប្រភេទ ភាពខ្សោយមួយចំនួនអាចមើលឃើញជាក់ស្តែង និងមួយចំនួនទៀតមិនបានស្តែងចេញច្បាស់ឡើយ។

| | |
|---|---|
| **មានការលំបាកខ្លះ** | **ចាត់ទុកថាមានភាពខ្សោយ ដូច្នេះជាជនពិការ** |
| **មានការលំបាកច្រើន** | |
| **មិនអាចធ្វើបានតែម្តង** | |

| **មេរៀន២.៣**<br>**ពិការភាពនៅប្រទេសកម្ពុជា** | |
|---|---|
| **គោលដៅ ៖** | អ្នកចូលរួមអាចរៀបរាប់បាននូវព័ត៌មានអំពីទិន្នន័យពិការភាព ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធក្នុងប្រទេសកម្ពុជា។ |
| **រយៈពេល** | ៣០នាទី |

មុនពេលធ្វើការពិភាក្សាពីនិយមន័យ និងទិន្នន័យជនពិការក្នុងប្រទេសកម្ពុជា គួរមានការបង្ហាញពីទស្សនៈជាសកលសិន។

១. បង្ហាញនិយមន័យជនពិការ ក្នុងអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងទិន្នន័យជនពិការទូទាំងពិភពលោក។

២. ក្នុងក្រុមធំ សួរទៅអ្នកចូលរួម តើពួកគាត់គិតថា ១៥% នៃប្រជាជនសរុបក្នុងពិភពលោកជាចំនួនច្រើនដែរឬទេ? ហេតុអ្វី? តើមានមូលហេតុអ្វីខ្លះ ដែលនាំឱ្យមានជនពិការរស់នៅក្នុងភាពក្រីក្រច្រើនបែបនេះ? សូមសរសេរ ចម្លើយរបស់ពួកគាត់លើក្រដាសផ្ទាំងធំ។

**កំណត់សម្គាល់ ៖**

ក្នុងមេរៀន២.៦ នឹងពន្យល់ពីវដ្តនៃភាពក្រីក្រ ប៉ុន្តែយកល្អ គួរប្រាប់អ្នកចូលរួមនាពេលនេះ អំពីទំនាក់ទំនងរវាងភាពក្រីក្រ និងពិការភាព។

៣. ឥឡូវនេះ ផ្តោតការយកចិត្តទុកដាក់មកប្រទេសកម្ពុជាវិញម្តង។ ឱ្យអ្នកចូលរួមប៉ាន់ស្មានពីភាគរយជនពិការក្នុងប្រទេសកម្ពុជា ពីប្រភេទភាពខ្សោយដែលមានជាទូទៅ និងមូលហេតុដែលនាំឱ្យមានភាពខ្សោយ។ បន្ទាប់មកបង្ហាញស្លាយ ឬក្រដាសផ្ទាំងធំ តាមខ្លឹមសារខាងក្រោម ៖

**តើមានជនពិការប៉ុន្មាននាក់រស់នៅក្នុងប្រទេសកម្ពុជា?**

តាមការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ២០១២ អត្រាប្រេវ៉ាឡង់ពិការភាពក្នុងប្រទេសកម្ពុជាមាន៥% ភាពខ្សោយដែលមានជាទូទៅ នៅក្នុងប្រទេសកម្ពុជា ៖

- ភាពខ្សោយផ្នែកគំហើញ
- ភាពខ្សោយផ្នែករាងកាយ និង
- ភាពខ្សោយក្នុងការស្តាប់

ជនពិការភាគច្រើនក្នុងប្រទេសកម្ពុជា ចាប់ផ្តើមមានភាពខ្សោយ ក្រោយកំណើត។ មូលហេតុទូទៅដែលនាំឱ្យមានភាពខ្សោយ គឺវ័យជរា និងជំងឺ។ មូលហេតុផ្សេងទៀតរួមមានគ្រោះថ្នាក់ដោយសារគ្រាប់មីន ឬការរងរបួសដោយសារសង្គ្រាម និងគ្រោះថ្នាក់ចរាចរណ៍ ឬគ្រោះថ្នាក់ការងារ។

៤. ពន្យល់ថា ៥% ធៀបនឹង១៥% ទូទាំងពិភពលោកហាក់បីដូចជានៅមានកម្រិតទាប។ អត្រានេះអាចដោយសារតែមានការប្រើប្រាស់និយមន័យពិការភាពខុសគ្នា ហើយក៏អាចដោយសារតែវិធីសាស្ត្រ ដែលគេប្រើសម្រាប់ប្រមូលទិន្នន័យ និងការមាក់ងាយដែលមានជុំវិញបញ្ហាពិការភាពផងដែរ។ បង្ហាញនិយមន័យជនពិការ ដែលប្រើប្រាស់ក្នុងប្រទេសកម្ពុជា តាមរយៈស្លាយ ឬក្រដាសផ្ទាំងធំ។

**"ជនពិការ សំដៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬសតិបញ្ញាបណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬសកម្មភាពនានាប្រចាំថ្ងៃ ដូចជា ជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងទៀតដែលបណ្តាលឱ្យមានលក្ខណៈមិនប្រក្រតី"** (មាត្រា៤នៃច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ឆ្នាំ ២០០៩)។

៥. ឱ្យអ្នកចូលរួមធ្វើការជាគូ និងពិភាក្សាពីគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានដែលលើកឡើងពីជនពិការ? សូមមើលក្នុងសៀវភៅណែនាំសម្រាប់អ្នកចូលរួម និងពិភាក្សារយៈពេលពី ៣ ទៅ ៥នាទី។

**កំណត់សម្គាល់៖**

នៅក្នុងការបណ្តុះបណ្តាលនៅថ្នាក់ខេត្ត សូមពិភាក្សាពីច្បាប់របស់ប្រទេសកម្ពុជា ស្ថាប័នដែលធ្វើការងារពាក់ព័ន្ធនឹងជនពិការ និងតួនាទីរបស់ស្ថាប័នទាំងនោះ និងពីគោលនយោបាយដែលពាក់ព័ន្ធនឹងពិការភាព។



**៦. បង្ហាញសារគន្លឹះ ៖**

- ក្នុងចំណោមប្រជាជនកម្ពុជាសរុប មាន ៥% មានពិការភាព។
- ភាពខ្សោយដែល មានជាទូទៅ នៅក្នុងប្រទេសកម្ពុជា រួមមាន៖
  - ភាពខ្សោយផ្នែកគំហើញ
  - ភាពខ្សោយផ្នែករាងកាយ និង
  - ភាពខ្សោយផ្នែកការស្តាប់
- ច្បាប់របស់ប្រទេសកម្ពុជាពន្យល់ពីសិទ្ធិរបស់ជនពិការ និងអ្នកដែលមានតួនាទីបំពេញសិទ្ធិទាំងនេះ។ សិទ្ធិរបស់ជនពិការ គឺជាភារកិច្ចរបស់រដ្ឋាភិបាលដែលត្រូវគោរពច្បាប់ក្នុងគ្រប់គោលនយោបាយ កម្មវិធី និងសេវាទាំងអស់របស់ខ្លួន។

| មេរៀន២.៤<br>ល្បែងដំណើរជីវិត | |
|---|---|
| **គោលដៅ** ៖ យល់ដឹងពីឧបសគ្គនានាដែលរាំងជនពិការក្នុងការចូលរួមនៅក្នុងសង្គមដូចជនមិនពិការ។ | |
| **រយៈពេល** | ៣០នាទី |



១. **ពន្យល់លំហាត់ មុននឹងរៀបចំបន្ទប់** ៖ "ការលេងល្បែងដើរតួ" ជម្រើស និងការចូលរួមរបស់អ្នកក្នុងសង្គមត្រូវបានទទួលរងឥទ្ធិពលយ៉ាងដូចម្តេច ដោយការឆ្លុះបញ្ចាំងពីស្ថានភាពរបស់អ្នកផ្ទាល់

២. ជ្រើសរើសអ្នកស្ម័គ្រចិត្តចំនួន៤នាក់(ប្រុស២នាក់ និងស្រី២នាក់) ដើម្បីចូលរួមលេងល្បែងនេះដែលមានរយៈពេល៣០នាទី។ តួអង្គទាំងនេះ តំណាងឱ្យក្រុមខាងក្រោម ៖

- បុរសមិនពិការ
- បុរសពិការ(តំណាងឱ្យមករា)
- ស្ត្រីមិនពិការ
- ស្ត្រីពិការ(តំណាងឱ្យថាវី)

៣. ការរៀបចំបន្ទប់ ៖ អ្នកត្រូវការកន្លែងធំគ្រប់គ្រាន់ សម្រាប់ឱ្យមនុស្សបួននាក់នៅទន្ទឹមគ្នា ដោយអ្នកចូលរួមផ្សេងទៀត អង្គុយនៅជុំវិញអ្នកសម្តែង បែរមុខទៅរកអ្នកស្ម័គ្រចិត្តទាំងនេះ។ សរសេរការណែនាំអំពីការលេងល្បែងនៅលើក្រដាសផ្ទាំងធំ(បោះជំហានទៅមុខ២ជំហាន។ល។)។ សរសេរតួអង្គផ្សេងៗលើក្រដាសកាតពណ៌ (អាចអានបានសម្រាប់ទាំងអស់គ្នា)។

៤. ឱ្យអ្នកស្ម័គ្រចិត្តមកនៅចំកណ្តាល ហើយបិទក្រដាសកាតពណ៌ដែលមានសរសេរពីតួអង្គ នៅលើខ្លួនរបស់ពួកគាត់។ ពន្យល់ថាអ្នកនឹងនិទានរឿងរ៉ាវពីជីវិតពិតមួយ ដោយបង្ហាញពីតួអង្គចាប់ពីពេលកើតដល់វ័យចាស់។ នៅពេលដែលអ្នកនិទានដល់ព្រឹត្តិការណ៍សំខាន់ៗនីមួយៗក្នុងជីវិត អ្នកត្រូវឱ្យពួកគាត់ឆ្លើយនៅពេលដែលពួកគាត់គិតថា តួអង្គដែលពួកគាត់សំដែង(ឬគ្រួសាររបស់ពួកគាត់)នឹងត្រូវប្រតិកម្មតបមកវិញ។ ពួកគាត់ត្រូវ ៖

- បោះជំហានទៅមុខ ២ជំហាន សម្រាប់បទពិសោធន៍ដែលរីជ្ជមានខ្លាំង ឬជោគជ័យខ្លាំង
- បោះជំហានទៅមុខ ១ជំហាន សម្រាប់បទពិសោធន៍ដែលវិជ្ជមាន ឬជោគជ័យបង្គួរ
- បោះជំហានទៅក្រោយ ១ជំហានសម្រាប់បទពិសោធន៍ដែលមិនសូវវិជ្ជមាន ឬមិនសូវជោគជ័យ
- បោះជំហានទៅក្រោយ ២ជំហានសម្រាប់បទពិសោធន៍ដែលអវិជ្ជមាន ឬមិនទទួលបានជោគជ័យ

គូសបញ្ជាក់ម្តងទៀតថា ជាការសំខាន់ណាស់ ដែលពួកគាត់ត្រូវឆ្លើយសំណួរក្នុងនាមពួកគាត់ជាតួអង្គសំដែង។

៥. កំណត់ពីទីកន្លែង ហើយចាត់ទុកថា រឿងនេះកើតឡើងនៅក្នុងភូមិមួយ។ ចូររៀបរាប់ឱ្យបានលម្អិតបំផុតតាមដែលអាចធ្វើបានដោយពន្យល់ថាជាទូទៅភាពក្រីក្រកើតឡើងដោយ កត្តាប្រាក់ចំណូលមានកម្រិតទាប បើទោះបី ជាគ្រួសារភាគច្រើនមានដីធ្លី និងទឹកស្អាតប្រើប្រាស់ក៏ដោយ។



៦. ការនិទានរឿង ដោយចាប់ផ្តើមជាមួយនឹងព្រឹត្តិការណ៍ដំបូងនៃដំណើរជីវិត

**ក). តួអង្គរបស់អ្នកបានចាប់កំណើត ៖**

- នៅពេលដែលអ្នកកើតក្នុងស្ថានភាពបែបហ្នឹង តើគ្រួសាររបស់អ្នកមានអារម្មណ៍យ៉ាងណា?
- សូមធ្វើការបោះជំហាន។

**កំណត់សម្គាល់ ៖**

**តើមានអ្វីអាចកើតឡើង ៖**

- គ្រួសារសប្បាយចិត្តខ្លាំង(កូនប្រុសមិនពិការ) បោះជំហានទៅមុខ ២ជំហាន
- សប្បាយចិត្តបង្គួរ(កូនប្រុសពិការ ឬកូនស្រីមិនពិការ) បោះជំហានទៅមុខ ១ជំហាន
- មិនសប្បាយចិត្ត(កូនប្រុសពិការ) បោះជំហានទៅក្រោយ ១ជំហាន
- មិនសប្បាយចិត្តខ្លាំង(កូនស្រីពិការ) បោះជំហានទៅក្រោយ ២ជំហាន

ក្រោយព្រឹត្តិការណ៍ធំៗក្នុងជីវិត និងក្រោយពីមានការឆ្លើយតបរបស់អ្នកស្ម័គ្រចិត្តរួចហើយ ទុកពេលឱ្យអ្នកចូលរួមផ្សេងទៀតប្រតិកម្មតប និងផ្តល់យោបល់។ ប្រសិនបើមានចំណុចមិនឯកភាពគ្នា អ្នកចូលរួមគួរសម្រេចចិត្តជាឯកច្ឆ័ន្ទ ហើយអ្នកស្ម័គ្រចិត្តអាចត្រូវបានស្នើឱ្យផ្លាស់ប្តូរជំហានរបស់ខ្លួន។ តួនាទីរបស់គ្រូបណ្តុះបណ្តាល គឺត្រូវវាយតម្លៃពេលដែលត្រូវធ្វើអន្តរាគមន៍ និងផ្តល់យោបល់ ដើម្បីបញ្ជាក់ឱ្យបានកាន់តែច្បាស់ពីមូលហេតុដែលនាំឱ្យមានការសម្រេចចិត្តបែបនេះ និងធ្វើការពិភាក្សាពីចំណុចពាក់ព័ន្ធនឹងបុរេនិច្ឆ័យ។ ភាពខ្សោយជាក់លាក់មិនពាក់ព័ន្ធជាមួយនឹងចំណុចសំខាន់នៃលំហាត់នេះឡើយ ដូច្នេះសូមកុំព្យាយាមផ្តោតលើចំណុចនេះខ្លាំងពេក។

ខ). ឥឡូវនេះ អ្នកដល់អាយុត្រូវទៅរៀន ៖

- តើអ្នកទំនងជា អាចទៅរៀន ឬ យ៉ាងណា?
- សូមបោះជំហាន!

គ). ឥឡូវនេះ អ្នកដល់អាយុរៀបការ ៖

- តើអ្នកទំនងជា អាចរៀបការ ឬយ៉ាងណា?
- សូមបោះជំហាន!

ឃ). អ្នកចង់រកលុយឱ្យគ្រួសាររបស់អ្នក (អ្នកព្យាយាមរកការងារធ្វើ) ៖

- តើវាមានភាពងាយស្រួលសម្រាប់អ្នកក្នុងការរកការងារធ្វើបានកម្រិតណា?
- សូមបោះជំហាន!

ង). អ្នកចង់មានកូន ៖

- តើអ្នកអាចមានលទ្ធភាព មានកូនកម្រិតណា?
- សូមបោះជំហាន!

**កំណត់សម្គាល់ ៖**

ពិនិត្យមើលថាតើស្ត្រីពិការបោះ២ជំហានទៅក្រោយដែរឬទេ ឬត្រូវបានអ្នកចូលរួមប្រាប់ឱ្យធ្វើបែបនេះ។ ហេតុអ្វីបានជាដូច្នេះ? ពួកគាត់អាចនិយាយថា ដោយសារតែស្ត្រីពិការភាគច្រើនពុំមានលទ្ធភាពកាយសម្បទា ដើម្បីមានកូន នេះជាការយល់ខុសដែលតែងតែកើតមាន។ ការបោះជំហានទៅក្រោយ២ជំហាន អាចជាការឆ្លើយតបត្រឹមត្រូវ ដោយសារមូលហេតុផ្សេងទៀត គឺជារឿយៗស្ត្រីពិការអាចមិនមានកូន ដោយសារតែសង្គមគិតថា ពួកគាត់មិនគួរមានកូន។

ច). ឥឡូវនេះ អ្នកស្ថិតនៅក្នុងវ័យ៤០ឆ្នាំ(អ្នកមានបទពិសោធន៍ច្រើនក្នុងជីវិត) ៖

- អ្នកចង់ជួយសហគមន៍របស់អ្នកតាមរយៈការចូលរួមក្នុងនយោបាយនៅមូលដ្ឋាន។
- តើអ្នកទំនងជាអាចចូលរួមក្នុងការងាររបស់អាជ្ញាធរមូលដ្ឋានឬការងារនយោបាយមូលដ្ឋានក្នុងកម្រិតណា?
- សូមបោះជំហាន



៧. សួរទៅអ្នកចូលរួម ៖

- អ្នកណាដែលស្ថិតនៅក្នុងស្ថានភាពល្អបំផុតនាពេលឥឡូវនេះ ? តើអ្នកណាស្ថិតក្នុងស្ថានភាពអាក្រក់បំផុត ?
- អ្នកសម្ដែងតួ ៖ តើស្ថានភាពនេះធ្វើឱ្យអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ?
- តើអ្វីខ្លះដែលធ្វើឱ្យអ្នកមានការភ្ញាក់ផ្អើល ?



៨. បង្ហាញពីសារគន្លឹះ

- គម្លាតរវាងបុរសមិនពិការ និងស្ត្រីពិការ មានទំហំធំធេង
- ជនពិការ បោះជំហានថយក្រោយ ដោយសារមូលហេតុអ្វីមួយ
- គេហៅមូលហេតុទាំងនេះថាជាឧបសគ្គ៖ ឧបសគ្គរាំងជនពិការក្នុងការចូលរួមក្នុងសង្គម

គូសបញ្ជាក់ម្ដងទៀតពីទំនាក់ទំនងរវាងតថភាពជាក់ស្ដែង និងល្បែងនេះ។ ល្បែងនេះបង្ហាញពីអារម្មណ៍របស់ជនពិការ ៖ ពួកគាត់ចង់ទៅរៀន ចង់រៀបការ ចង់បានការងារធ្វើ។ ប៉ុន្តែពួកគាត់ធ្វើមិនបាន ដោយសារតែឧបសគ្គនានា។ វាធ្វើឱ្យពួកគាត់មានអារម្មណ៍ឯកោ កណ្ដោចកណ្ដែង ពុំមានទំនុកចិត្តលើខ្លួនឯង។ល។

នៅក្នុងមេរៀនបន្ទាប់ គេត្រូវធ្វើការវិភាគឱ្យបានកាន់តែស៊ីជម្រៅបន្ថែមទៀត ដើម្បីស្វែងយល់ថា តើឧបសគ្គទាំងនេះមានអ្វីខ្លះ។

<table>
<tr><td colspan="2">មេរៀន២.៥<br>ឧបសគ្គដែលជនពិការជួបប្រទះ</td></tr>
<tr><td colspan="2">គោលដៅ ៖ អ្នកចូលរួមបានយល់ដឹងពីឧបសគ្គរាំងនានា ដើម្បីពួកគាត់អាចកាត់បន្ថយ ឬលុបបំបាត់ឧបសគ្គទាំងនោះ។</td></tr>
<tr><td>រយៈពេល</td><td>៣០នាទី</td></tr>
</table>



១. អ្នកចូលរួមធ្វើការងារជាគូ ហើយគ្រូបណ្ដុះបណ្ដាលចាត់តាំងតួអង្គម្នាក់ ក្នុង ចំណោមតួអង្គទាំង៤ទៅកាន់គូនីមួយៗ។ អាចមានលើសពីមួយគូធ្វើការងារ ជាមួយនឹងតួអង្គដូចគ្នា។ ទុកពេលឱ្យគូនីមួយៗគិតពីឧបសគ្គនានា ដែលតួអង្គទាំងនេះអាចប្រឈម ក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់។ ផ្ដល់ ក្រដាសកាតពណ៌ ឬក្រដាសស្អិតសម្រាប់បិទ(post-its)ដល់ពួកគាត់។ ឱ្យដៃគូនីមួយៗសរសេរឧបសគ្គនៅលើក្រដាសកាតពណ៌ទាំងនេះ។



បញ្ជាក់ថា ពួកគាត់ត្រូវគិតឱ្យបានទូលំទូលាយបំផុត តាមដែលអាចធ្វើបាន ពោលគឺ កុំផ្ដោតតែលើរាងកាយ ឬអ្វីដែលមានលក្ខណៈរូបវន្ត។

**កំណត់សម្គាល់ ៖**

ពេលដែលអ្នកចូលរួមកំពុងសរសេរលើក្រដាសកាតពណ៌ គ្រូបណ្តុះបណ្តាលរៀបចំក្រដាសផ្ទាំងធំចំនួន៤ផ្ទាំង និងសរសេរប្រភេទឧបសគ្គខាងក្រោមនៅលើក្រដាសផ្ទាំងធំនីមួយៗ ៖

១. ឥរិយាបថ

២. ការប្រាស្រ័យទាក់ទង

៣. ការបង្កភាពងាយស្រួល

៤. ការចូលរួម

២. ពន្យល់ថា ឧបសគ្គចែកជា ៤ ប្រភេទ និងចង្អុលបង្ហាញក្រដាសផ្ទាំងធំ។

- **ឥរិយាបថ ៖** នៅពេលដែលគេគិតបែបអវិជ្ជមានពីជនពិការ។
- **ការប្រាស្រ័យទាក់ទង ៖** ថាតើជនពិការអាចចែករំលែកនូវព័ត៌មាន គំនិត និងអារម្មណ៍ ក៏ដូចជាការទទួលបាននូវព័ត៌មាន ដូចជនដែលមិនពិការដែរឬ ទេ។
- **ការបង្កភាពងាយស្រួល ៖** ថាតើគេអាច ចេញចូលអគារ ឬទទួលបាន សេវាដែរឬទេ។ ឧទាហរណ៍ ថាតើជនពិការអាចប្រើប្រាស់បង្គន់ ឬទៅមណ្ឌលសុខភាពបានដែរ ឬទេ។
- **ការចូលរួម ៖** ថាតើជនពិការអាចចូលរួមឬចែករំលែកនូវអ្វីមួយ នៅក្នុងសកម្មភាពសង្គមដែរ ឬទេ។

៣. អញ្ជើញដៃគូនីមួយៗឱ្យឡើងមកខាងមុខ ដើម្បីបង្ហាញពីក្រដាសកាតពណ៌របស់ពួកគាត់ និងឱ្យពួកគាត់បិទក្រដាសកាតពណ៌ទាំងនេះ ក្រោមប្រភេទឧបសគ្គ ដែលពួកគាត់គិតថាស័ក្តិសមបំផុត។ លើកទឹកចិត្តអ្នកចូលរួមឱ្យសួរសំណួរគ្នាទៅវិញទៅមក។ ពិភាក្សាជាមួយអ្នកចូលរួមអំពីឧបសគ្គផ្សេងៗ។ តើវាជាឧបសគ្គពិតប្រាកដឬ?

ឧទាហរណ៍ **ស្រីមុំ មិនអាចទៅរៀនបាន ដោយសារតែម្តាយរបស់នាង គិតថា នាងរៀន មិនចេះ។** នេះមិនពាក់ព័ន្ធជាមួយនឹងភាពខ្សោយ(ពិការអវៈយវៈជើងទាំងពីរមានសភាពទន់)របស់នាងឡើយ ប៉ុន្តែវាពាក់ព័ន្ធជាមួយនឹងឥរិយាបថម្តាយរបស់នាង។ **មករា** លែងទៅរៀនទៀត ដោយសារតែគាត់ត្រូវបានគេវាយ។ តើអ្វីជាឧបសគ្គ? (ចម្លើយ៖ ឥរិយាបថមិនល្អរបស់គ្រូ)។

៤. ក្រោយពីបានស្តាប់បទបង្ហាញ និងការពិភាក្សាទាំងអស់រួចហើយ គ្រូបណ្តុះបណ្តាលបង្ហាញ **ឧទាហរណ៍** ៖ មួយចំនួនអំពីឧបសគ្គ ក្នុងតារាងខាងក្រោម ៖

| ប្រភេទ | ឧបសគ្គ | ឧទាហរណ៍ |
|---|---|---|
| **ឥរិយាបថ** | ឥរិយាបថ<br>អវិជ្ជមាន<br>ចំពោះជនពិការ | • ស្រីមុំ មិនអាចទៅរៀនបាន ដោយសារតែម្តាយ របស់នាង គិតថា នាងរៀនមិនចេះ<br>• មករា ត្រូវបានគេវាយ នៅសាលារៀន<br>• បុប្ផា មិនត្រូវបានគេអនុញ្ញាតឱ្យបើកគណនីនៅធនាគារ ឡើយ ដោយសារតែបុគ្គលិក គិតថា គាត់ជាមនុស្សខុសគេ |

| ប្រភេទ | ឧបសគ្គ | ឧទាហរណ៍ |
|---|---|---|
| **ការប្រាស្រ័យទាក់ទង** | ការប្រាស្រ័យទាក់ទងពុំមានប្រសិទ្ធភាពជាមួយជនពិការ | • សុផល មិនអាចទៅជួប វេជ្ជបណ្ឌិតបាន ដោយសារតែវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកមិនចេះប្រើភាសាសញ្ញា<br>• បុប្ផាមិនអាចបើកគណនីធនាគារបាន ដោយសារតែនាងមិនចេះសរសេរឈ្មោះខ្លួនឯង។ |
| **ការបង្កភាពងាយស្រួល** | អគារមិនអាចចេញចូលបានសម្រាប់ជនពិការ | • ស្រីមុំមិនអាចទៅរៀនបាន ដោយសារតែ គាត់ប្រើរទេះរុញហើយពុំមានជម្រាល នៅសាលារៀន។ |
| **ការចូលរួម** | ដំណើរការដែលធ្វើឱ្យជនពិការនៅឯកោពីគេ | • ថារីនៅតែផ្ទះ ដោយសារតែនាងមិន ដឹងពី កិច្ចប្រជុំក្នុងសហគមន៍ ហើយមិនត្រូវបាន គេនាំទៅចូលរួមនឹងគេ<br>• មករាមិនទៅរៀន ដោយសារតែគ្រូវាយគាត់។ |

តើអ្នកចូលរួមដឹងពីរឿងរ៉ាវល្អៗពីជនគំរូ ឬជនល្បីៗដែលជាជនពិការ ប្រសិន បើអ្នកចូលរួមមានរឿងខ្លះលើកមកនិយាយ គួសបញ្ជាក់សារជាថ្មីថា ជនពិការអាចទទួលបានជោគជ័យ ប្រសិនបើមានការដកឧបសគ្គទាំងនេះចេញ។

៥. **បង្ហាញសារគន្លឹះ** តាមរយៈស្លាយ ឬក្រដាសផ្ទាំងធំ ៖

- ឧបសគ្គអាចរារាំងជនពិការ ក្នុងការរស់នៅមានជីវភាពដូចអ្នកដទៃ
- ឧបសគ្គទាំងនេះអាចកើតឡើងដោយសារ៖
  - ការមិនបង្កភាពងាយស្រួល សម្រាប់ជនពិការ
  - ការប្រាស្រ័យទាក់ទងដែលពុំមានប្រសិទ្ធភាព
  - ឥរិយាបថអវិជ្ជមាន
  - ការរស់នៅឯកោ គ្មានការរាប់រកពី អ្នកដទៃ
- ជនពិការអាចរស់នៅក្នុងជីវិតពេញលេញ និងជោគជ័យ នៅពេលដែលឧបសគ្គនានាត្រូវបានដកចេញ

| មេរៀន២.៦<br>សារៈសំខាន់ការដាក់បញ្ចូលពិការភាពក្នុងអភិបាលកិច្ចមូលដ្ឋាន | |
|---|---|
| **គោលដៅ ៖** អ្នកចូលរួមអាចយល់ដឹងពីសារៈប្រយោជន៍នៃការដាក់បញ្ចូលពិការភាពក្នុងការងារអភិបាលកិច្ចមូលដ្ឋាន | |
| **រយៈពេល** | ២៥នាទី |



១. ចែកអ្នកចូលរួមជា២ក្រុម ហើយឱ្យពួកគាត់រៀបរាប់ពីសារៈប្រយោជន៍សង្គមនៅពេលដែលជនពិការ ត្រូវបានគេផ្តល់ឱកាសឱ្យចូលរួមក្នុងសេវាសុខភាព (មួយក្រុម) និងការអប់រំ(មួយក្រុមទៀត)។ ទុកពេល១០នាទី ឱ្យក្រុមធ្វើការពិភាក្សាគ្នា។ ពិនិត្យតាមដានក្រុម និងផ្តល់ការលើកទឹកចិត្តដល់អ្នកចូលរួម។

២. សរសេរចម្លើយលើក្រដាសកាតពណ៌ ហើយបិទនៅលើជញ្ជាំង ក្រោមចំណងជើងការអប់រំ និងសេវាសុខភាព។ ក្រដាសកាតពណ៌ទាំងនេះគួរមានសរសេរ ដូចខាងក្រោម៖

- ចំណូលគ្រួសារខ្ពស់ជាងមុន
- កាត់បន្ថយភាពក្រីក្រ
- ការអភិវឌ្ឍសេដ្ឋកិច្ច (ដោយសារមនុស្សភាគច្រើនមានការងារធ្វើ)
- ចំណាយតិចជាងមុន ទៅលើកម្មវិធីសុខុមាលភាពសង្គម
- ចំណាយតិចជាងមុនលើសេវាសុខភាព
- ផលិតភាពខ្ពស់ជាងមុន ដោយសារតែពួកគាត់រហ័សជាសះស្បើយពីជំងឺ
- ចំណាយតិចជាងមុនលើសេវាសុខភាព



នៅក្នុងការពិភាក្សាសូមគូសបញ្ជាក់ចំណុចដូចខាងក្រោម៖

- ការដាក់បញ្ចូលពិការភាពបានធ្វើឱ្យជនពិការបង្កើនការឱ្យតម្លៃដល់ខ្លួនឯង។ ជាពិសេសនៅពេលដែលជនពិការបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចពួកគាត់មានតួនាទី ដែលសង្គមផ្តល់តម្លៃឱ្យដូចជា "សិស្ស" "និយោជិត" "ម្ចាស់ហាង" "ជាងជួសជុលម៉ូតូ"។
- ការដាក់បញ្ចូលពិការភាពមិនត្រឹមតែផ្តល់ប្រយោជន៍ដល់ជនពិការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់សមាជិកគ្រួសាររបស់ជនពិការថែមទៀតផង។ តើអ្នកនៅចាំទេពីរឿងរបស់ថាវី តើសមាជិក គ្រួសារមានមោទនភាពយ៉ាងណានៅពេលដែលនាងអាចរកចំណូលបាន។
- ការដាក់បញ្ចូលពិការភាពក៏ផ្តល់ប្រយោជន៍ដល់សង្គមទាំងមូលផងដែរ។ នៅពេលដែលមានមនុស្សកាន់តែច្រើន មានសកម្មភាពសេដ្ឋកិច្ច នោះការចំណាយលើកម្មវិធីពិសេសនឹងមានការថយចុះ។

៣. ចាប់ផ្តើមពន្យល់ ដោយបង្ហាញស្លាយ ឬក្រដាសផ្ទាំងធំតាមខ្លឹមសារខាងក្រោម។ លំហូរនៃដ្យាក្រាមទាំងនេះ ត្រូវបានរៀបចំឡើង ផ្អែកតាមការស្រាវជ្រាវដែលធ្វើឡើងដោយមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវរកភស្តុតាងក្នុងវិស័យពិការភាព។

## អត្ថប្រយោជន៍នៃការដាក់បញ្ចូលពិការភាពក្នុងវិស័យអប់រំ

**ការចូលរួមក្នុងការអប់រំ**

- ការអភិវឌ្ឍជំនាញ
- ការបង្កើតបណ្តាញសង្គម
- ការទទួលយកពិការភាពកាន់តែច្រើនជាងមុន
- កាត់បន្ថយតម្រូវការក្នុងការផ្តល់ការថែទាំ

ការបង្កើនការចូលរួមក្នុងការងារ និងសកម្មភាពរកចំណូលផ្សេងទៀត
បង្កើនផលិតភាពរបស់កម្លាំងពលកម្ម

<u>ចំណេញ សម្រាប់គ្រួសារ/បុគ្គល</u>

- បង្កើនចំណូលផ្ទាល់ខ្លួន និងចំណូលសម្រាប់គ្រួសារ
- កាត់បន្ថយភាពក្រីក្រ

<u>ចំណេញ សម្រាប់សង្គម/រដ្ឋាភិបាល</u>

- កាត់បន្ថយចំណាយលើកម្មវិធីការពារសង្គម និងកម្មវិធីកាត់បន្ថយភាពក្រីក្រ
- កំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង

## អត្ថប្រយោជន៍នៃការដាក់បញ្ចូលពិការភាពក្នុងវិស័យសុខាភិបាល

**ការចូលរួមក្នុងកម្មវិធីសុខភាពសាធារណៈ**

- លើកកម្ពស់លទ្ធផលសុខភាពសម្រាប់ជនពិការ
- បង្កើនការគ្របដណ្តប់នៃកម្មវិធី

- លើកកម្ពស់សុខភាពរបស់ប្រជាពលរដ្ឋ
- កាត់បន្ថយវិសមភាពនៃការទទួលបានសេវាសុខភាព

<u>ចំណេញសម្រាប់គ្រួសារ/បុគ្គល (ទាំងពិការ ទាំងមិនពិការ)</u>

- បញ្ចៀសចំណាយសុខភាព
- កាត់បន្ថយការបាត់បង់ការងារ/ចំណូលដោយសារជំងឺ/ការថែទាំ

<u>ចំណេញសម្រាប់រដ្ឋាភិបាល</u>

- កាត់បន្ថយចំណាយកម្មវិធី ក្នុងរយៈពេលវែង
- កាត់បន្ថយការចំណាយលើកម្មវិធីផ្តល់ការថែទាំ និងការព្យាបាលស្របគ្នា

៤. ពន្យល់ពីយន្តការដែលបានចង្អុលបង្ហាញក្នុងវដ្តនៃភាពក្រីក្រ តាមខ្លឹមសារខាងក្រោម ៖ ការផាត់ចេញបែបនេះបង្កើនឱ្យមានភាពងាយរងគ្រោះកាន់តែខ្លាំងបន្ថែមទៀត។ ផ្ទុយទៅវិញ ការដាក់បញ្ចូលពិការភាពនាំឱ្យភាពងាយរងគ្រោះមានការថយចុះ។ អត្ថប្រយោជន៍មួយទៀតនៃការបញ្ចូលពិការភាពគឺថា វាធ្វើឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ បង្ហាញ និងពន្យល់ថា ពុំចាំបាច់មានគម្រោងពិសេសឡើយ ប្រសិនបើ សេវានានាមានការដាក់បញ្ចូលពិការភាពរួចហើយ។

## ការដាក់បញ្ចូលពិការភាពកាត់បន្ថយភាពងាយរងគ្រោះ

ដោយសារតែការផាត់ចេញ៖ ជនពិការក្លាយជាជនក្រីក្រ។ ជនក្រីក្រកាន់តែងាយរងគ្រោះ។ នៅពេលដែលពួកគេងាយរងគ្រោះ ពួកគេងាយនឹងមានពិការភាព។ ការដាក់បញ្ចូលពិការភាពអាចបញ្ចប់វដ្តនៃភាពក្រីក្របាន។




Source: DFID, (2002)

## ការដាក់បញ្ចូលពិការភាពនាំឲ្យប្រសិទ្ធភាពមានការកើនឡើង

"ជនពិការមានតម្រូវការជាធម្មតា ដើម្បីសុខភាព និងសុខុមាលភាព ដើម្បីសន្តិសុខ សេដ្ឋកិច្ច និងសង្គម ដើម្បីរៀនសូត្រ និងអភិវឌ្ឍជំនាញ និងរស់នៅក្នុងសហគមន៍របស់ពួកគេ។ តម្រូវការទាំងនេះអាច និងគួរបំពេញក្នុងកម្មវិធី និងសេវាទូទៅ។ ការបញ្ជ្រាបពិការភាព មិនត្រឹមតែសម្រេចនូវសិទ្ធិមនុស្សប៉ុណ្ណោះទេ វាថែមទាំងបង្កើនប្រសិទ្ធភាពទៀតផង"

របាយការណ៍ពិភពលោកស្តីពីពិការភាព ឆ្នាំ ២០១១

៥. គូសបញ្ជាក់ថា មេរៀនដែលនៅសល់ ក្នុងការបណ្តុះបណ្តាលនេះនឹងផ្តល់ការណែនាំបន្ថែមអំពីរបៀបដាក់បញ្ចូលជនពិការ។ ការបណ្តុះបណ្តាលនេះនឹងផ្តោតការយកចិត្តទុកដាក់លើការដកចេញនូវឧបសគ្គដែលជនពិការជួបប្រទះ ជាពិសេស ពាក់ព័ន្ធជាមួយនឹង ៖

- **ឥរិយាបថ** ៖ បង្ហាញពីការគោរពគ្នាទៅវិញទៅមក និងសេចក្តីថ្លៃថ្នូរ
- **ការប្រាស្រ័យទាក់ទង** ៖ របៀបប្រាស្រ័យទាក់ទងជាមួយជនពិការ
- **ការបង្កភាពងាយស្រួល** ៖ បង្កើតបរិស្ថានដែលគ្មានឧបសគ្គ ដើម្បីបង្កភាពងាយស្រួលដល់ការប្រើប្រាស់សេវាផ្សេងៗសម្រាប់ជនពិការ
- **ការចូលរួម ៖** ធានាឱ្យមានការចូលរួមយ៉ាងសកម្មពីជនពិការ

៦. **បង្ហាញសារគន្លឹះ**លើស្លាយ ឬក្រដាសផ្ទាំងធំ តាមខ្លឹមសារខាងក្រោម ៖

- អត្ថប្រយោជន៍នៃការដាក់បញ្ចូលពិការភាព រួមមាន ៖
  - ចំណូលគ្រួសារខ្ពស់ជាងមុន កាត់បន្ថយចំណាយលើសេវាសុខភាព និងកាត់បន្ថយភាពក្រីក្រ
  - បង្កើនផលិតភាព និងការអភិវឌ្ឍសេដ្ឋកិច្ច កាត់បន្ថយចំណាយលើកម្មវិធីសុខុមាលភាពសង្គម និងសុខភាព
- គំនិតគួរចងចាំ ៖
  - ការដាក់បញ្ចូលពិការភាព ផ្តល់ប្រយោជន៍ដល់យើងទាំងអស់គ្នា
  - ការដាក់បញ្ចូលពិការភាព កាត់បន្ថយភាពងាយរងគ្រោះ
  - ការដាក់បញ្ចូលពិការភាព បង្កើនប្រសិទ្ធភាពថែមទៀត (សេដ្ឋកិច្ច សង្គមកិច្ច និងការទទួលបានសិទ្ធិ)។

| មេរៀន២.៧<br>សង្ខេបមេរៀនជំពូកទី២ | |
|---|---|
| **គោលដៅ** ៖ រំលឹកអ្នកចូលរួមពីអ្វីដែលអ្នកបានរៀនថ្ងៃនេះ និងផ្តល់ការបញ្ជាក់ពីសំណួរដែលនៅសល់។ | |
| **រយៈពេល** | ១០នាទី |

១. បែងចែកអ្នកចូលរួមជាគូ។ ឱ្យពួកគាត់ធ្វើការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល និងធ្វើការពិភាក្សាជាមួយ នឹងដៃគូដូចខាងក្រោម៖

- តើយើងបានរៀនអ្វីខ្លះនៅក្នុងជំពូកនេះ?
- តើខ្ញុំនឹងប្រើប្រាស់អ្វីដែលខ្ញុំបានរៀននេះ នៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំទាំងនៅផ្ទះ ទាំងនៅកន្លែងការងាររបស់ខ្ញុំ?
- តើខ្ញុំអាចធ្វើអ្វីម៉្យាងបានទេ ដើម្បីលុបចោលឧបសគ្គចំនួន៤ ដែលយើងបានរៀនពីខាងដើមសម្រាប់អ្នកដែលខ្ញុំស្គាល់?

២. ក្រោយ៥នាទីមក ឱ្យអ្នកចូលរួមចែករំលែកគំនិតរបស់ពួកគាត់នៅក្នុងក្រុមធំជាមួយនឹងអ្នកចូលរួមទាំងអស់។ សម្របសម្រួលការពិភាក្សានៅក្នុងក្រុមធំ។ ព្យាយាមឱ្យការពិភាក្សានេះផ្សារភ្ជាប់នឹងបទពិសោធន៍ផ្ទាល់ខ្លួន ៖ "តើអ្នកបានរៀនអ្វីខ្លះ?" "តើអ្នកនឹងប្រើប្រាស់អ្វីដែលបានរៀននេះនៅផ្ទះ និងនៅកន្លែងការងាររបស់អ្នកយ៉ាងដូចម្តេចខ្លះ?"

ប្រសិនបើ ការបណ្តុះបណ្តាលដំណើរការទៅបានល្អ ការឆ្លុះបញ្ចាំងអាចមានលក្ខណៈ ដូចខាងក្រោម ៖

**"ខ្ញុំធ្លាប់តែសន្មតថា ជនពិការមានការលំបាក ដោយសារតែភាពខ្សោយខាងរាងកាយរបស់ ពួកគាត់។ ឥឡូវនេះ ខ្ញុំអាចមើលឃើញថា យើងខ្លួនឯងទៅវិញទេ ដែលអាចធ្វើឱ្យជនពិការជួបការលំបាក ដោយសារតែប្រតិកម្មរបស់យើងចំពោះពួកគាត់ ដូចអ្វីដែលម្តាយស្រីមុំធ្វើចំពោះស្រីមុំ ដោយសារតែគាត់សន្មតខុសថា ស្រីមុំ មិនអាចឆ្លាតនោះទេ"។**

ជាការសំខាន់ ដែលត្រូវទាញចេញនូវមេរៀន ដូចខាងក្រោម ៖

- ឧបសគ្គមិនមែនរូបវន្ត (ជាពិសេសឥរិយាបថ) អាចមានផលប៉ះពាល់ខ្លាំងក្លាជាងឧបសគ្គរូបវន្តទៅទៀត
- "យើងទាំងអស់គ្នា" អាចជាអ្នកធ្វើឱ្យមានការលំបាកទាំងនោះកើតឡើង ទោះដោយអចេតនាក្តី
- យើងអាចធ្វើឱ្យមានការផ្លាស់ប្តូរ តាមរយៈការធ្វើសកម្មភាពតាមរបៀបផ្សេង
- បុគ្គលម្នាក់ៗនៅក្នុងសង្គម មិនថាពួកគាត់ជាអ្នកណានោះទេ មានសិទ្ធិរស់រានមានជីវិត សិទ្ធិមានសេចក្តីថ្លៃថ្នូរ សិទ្ធិចូលរួមចំណែក និងទទួលបានប្រយោជន៍ពីសង្គម ហើយយើងគួរធ្វើសកម្មភាពតាមរបៀបដែលគាំទ្រដល់គ្នាទៅវិញទៅមក ដើម្បីសម្រេចនូវសិទ្ធិទាំងនេះ។

ធ្វើការសង្ខេបនៅចុងបញ្ចប់នៃមេរៀន និងមើលតាមសៀវភៅណែនាំនេះ។ បង្ហាញស្លាយ ឬក្រដាសផ្ទាំងធំ នូវចំណុចសង្ខេបដូចខាងក្រោម ៖

- ភាពខ្សោយ គឺជាការបាត់បង់មុខងាររបស់រាងកាយ
- ពិការភាពកើតឡើង នៅពេលដែលមនុស្សម្នាក់មានភាពខ្សោយ ហើយជួបប្រទះនឹងឧបសគ្គ ក្នុងការធ្វើសកម្មភាពអ្វីមួយ
- ភាពខ្សោយ + ឧបសគ្គ = ពិការភាព
- មនុស្សអាចមានពិការភាពក្នុងកម្រិតផ្សេងៗពីគ្នា និងប្រភេទខុសៗគ្នា
- ក្នុងចំណោមមនុស្ស ៧នាក់ មានម្នាក់ជាជនពិការ (ទិន្នន័យពិភពលោក) និងក្នុងចំណោមមនុស្ស២០នាក់ មានម្នាក់ជាជនពិការ (ទិន្នន័យក្នុងប្រទេសកម្ពុជា)
- ឧបសគ្គគឺពាក់ព័ន្ធនឹងការបង្កភាពងាយស្រួល ការប្រាស្រ័យទាក់ទង ឥរិយាបថ និងការចូលរួម។
- ការដាក់បញ្ចូលពិការភាពកាត់បន្ថយភាពងាយរងគ្រោះ។ ការដាក់បញ្ចូលជនពិការផ្តល់ប្រយោជន៍ដល់ជនពិការ គ្រួសារ និងសង្គមរបស់ពួកគាត់ ក៏ដូចជាបង្កើនប្រសិទ្ធភាព (សេដ្ឋកិច្ច សង្គមកិច្ច និងការទទួលបានសិទ្ធិ)។
- ការដាក់បញ្ចូលពិការភាពមានសារៈសំខាន់ និងអាចលើកកម្ពស់ តាមរយៈការលុបបំបាត់ឧបសគ្គ ដែលជនពិការជួបប្រទះ ៖
  - ឥរិយាបថ ៖ បង្ហាញពីការគោរព និងសេចក្តីថ្លៃថ្នូរ
  - ការបង្កភាពងាយស្រួល ៖ ការបង្កភាពងាយស្រួលសម្រាប់ជនពិការដោយគ្មានពុំឧបសគ្គ
  - ការប្រាស្រ័យទាក់ទង ៖ ចែករំលែកព័ត៌មាន និងគំនិតនានា
  - ការចូលរួម ៖ ធានាឱ្យមានការចូលរួម

| **មេរៀន២.៨**<br>**ការវាយតម្លៃប្រចាំថ្ងៃ** | |
|---|---|
| **គោលដៅ ៖** ដើម្បីឱ្យគ្រូបង្គោលទទួលបានព័ត៌មានត្រឡប់ពីសិក្ខាកាមនូវអ្វីដែលពួកគាត់ពេញចិត្ត និង មិនពេញចិត្តកែលម្អការបណ្តុះបណ្តាលនៅថ្ងៃបន្ទាប់។ | |
| **រយៈពេល** | ១០នាទី |



១. ការអនុវត្តលំហាត់វាយតម្លៃ ៖

- គ្រូបណ្តុះបណ្តាលគូរតារាងរូបភាពដូចខាងក្រោមលើក្រដាសផ្ទាំង រួចបិទលើក្តារខៀន
- ចែកក្រដាសកាតពណ៌ ឱ្យសិក្ខាកាមម្នាក់២សន្លឹក បន្ទាប់មក ឱ្យពួកគាត់សរសេរនៅលើក្រដាសកាតពណ៌ ដោយ ៖
  - ក្រដាសកាតពណ៌ទី១ សរសេរចំណុចចូលចិត្តអំពីការបណ្តុះបណ្តាលនៅថ្ងៃនេះ
  - ក្រដាសកាតពណ៌ទី២ សរសេរអំពីអ្វីដែលអាចកែលម្អ។
- ឱ្យអ្នកចូលរួមយកក្រដាសកាតពណ៌របស់ខ្លួនបិទលើតារាងរូបភាព

**កំណត់សម្គាល់ ៖**

ឱ្យអ្នកចូលរួមសរសេរឱ្យបានជាក់លាក់ និងពន្យល់ពីមូលហេតុ ដែលពួកគាត់ចូលចិត្ត ឬចង់កែលម្អអ្វីមួយ។

|  |  |
|---|---|
| | |



២. ជម្រាបអ្នកចូលរួម ដែលត្រូវរំលឹកមេរៀនឡើងវិញនៅព្រឹកថ្ងៃបន្ទាប់ ដើម្បីឱ្យពួកគាត់ត្រៀមខ្លួនឱ្យហើយសម្រាប់ព្រឹកថ្ងៃស្អែក។

៣. អរគុណដល់អ្នកចូលរួមសម្រាប់ការចូលរួមថ្ងៃនេះ។

៤. នៅពេលដែលអ្នកចូលរួមចេញទៅផ្ទះអស់ហើយ គ្រូបណ្តុះបណ្តាលសូមមើលក្រដាសកាតពណ៌( លទ្ធផល )វាយតម្លៃ។ ផ្អែកទៅតាមព័ត៌មានត្រឡប់នេះ សូមគិតពីអ្វីដែលអ្នកអាចធ្វើបានតាមរបៀបផ្សេងទៀត នៅពេលក្រោយ។

# ជំពូកទី៣

# ការបញ្ជាញពីការគោរព និង

# សេចក្តីថ្លៃថ្នូរ

# ជំពូកទី៣

# ការបង្ហាញពីការគោរព និងសេចក្ដីថ្លៃថ្នូរ

## ក). សេចក្ដីពិពណ៌នា

ជំពូកនេះនឹងផ្ដោតការយកចិត្តទុកដាក់លើឥរិយាបថរបស់មនុស្សនៅពេលនិយាយ និងគិតពីពិការភាព។ នៅចុងបញ្ចប់នៃជំពូកនេះអ្នកចូលរួមនឹង ៖

- កំណត់អំពីឥរិយាបថអវិជ្ជមានដែលជាឧបសគ្គមួយ ក្នុងចំណោមឧបសគ្គធំៗជាងគេនៃការដាក់បញ្ចូលពិការភាព
- រៀបរាប់អំពីរបៀបនិយាយដោយការគោរពអំពីជនពិការ និងជាមួយជនពិការ។

## ខ). មាតិកាមេរៀន

| លរ | មេរៀន | រយៈពេល | សម្ភារៈ និងឯកសារ |
|---|---|---|---|
| ៣.១. | រំលឹកមេរៀនថ្ងៃទី១ឡើងវិញ | ៣៥នាទី | |
| ៣.២. | ឥរិយាបថចំពោះជនពិការ | ៦០នាទី | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាតពណ៌ ផ្ទៃទឹកមុខ២ ៖ វិជ្ជមាន និងអវិជ្ជមាន |
| ៣.៣. | ភាសាដែលសម្ដែងពីការគោរពចំពោះពិការភាព | ៤៥នាទី | ក្រដាសផ្ទាំងធំ ប៊ិច កន្ត្រៃ ស្កុត ផ្ទៃទឹកមុខ៣ (ញញឹម ធម្មតា និងស្រពាប់ស្រពោន) |
| ៣.៤. | គោលការណ៍ណែនាំសម្រាប់និយាយជាមួយជនពិការ | ១៥នាទី | ក្រដាសផ្ទាំងធំ |
| ៣.៥. | សង្ខេបមេរៀនជំពូកទី៣ | ៥នាទី | សូមមើលសៀវភៅណែនាំសម្រាប់អ្នកចូលរួម |
| **សរុប** | | **១៦៥នាទី** | |

**កំណាត់សម្គាល់ ៖**

ជំពូកទី៣នេះ មិនត្រូវការពេលវេលាពេញមួយព្រឹកឡើយ។ នៅពេលចប់មេរៀនជំពូកទី៣ គ្រូបណ្ដុះបណ្ដាលអាចចាប់ផ្ដើមជំពូកទី៤ មុនអាហារថ្ងៃត្រង់។

## គ). ដំណើរការសម្របសម្រួល

| មេរៀន៣.១<br>ការរំលឹកមេរៀនថ្ងៃទី១ឡើងវិញ | |
|---|---|
| **គោលដៅ ៖**<br>• ឆ្លុះបញ្ចាំង និងកំណត់ពីអ្វីដែលថ្មីៗ ដែលអ្នកចូលរួមបានរៀនសូត្រ<br>• បញ្ជាក់សារជាថ្មីអំពីសារគន្លឹះៗនៅថ្ងៃទី១ ដើម្បីឱ្យអ្នកចូលរួមនឹកឃើញមេរៀនសំខាន់ៗជាងគេ<br>• ពិនិត្យមើលថាតើអ្នកចូលរួមបានយល់មេរៀនពីថ្ងៃទី១ ដែរឬទេ | |
| **រយៈពេល** | ៣៥នាទី |

១. ដើម្បីរំលឹកព័ត៌មាន ដែលបានរៀននៅថ្ងៃនីមួយៗ ពន្យល់ថា នឹងមានវគ្គរំលឹកឡើងវិញរៀងរាល់ព្រឹក ដែលមានរយៈពេលកន្លះម៉ោង។ ការរំលឹកឡើងវិញនេះមានគោលបំណងរំលឹកឡើងវិញនូវអ្វីដែលបានរៀនកាលពីម្សិល និងឆ្លើយសំណួរនានា ដែលនៅសេសសល់។ គ្រូបណ្តុះបណ្តាលនឹងធ្វើការរំលឹកមេរៀនឡើងវិញនៅថ្ងៃនេះ ប៉ុន្តែការរំលឹកមេរៀននៅថ្ងៃក្រោយៗ អញ្ជើញអ្នកចូលរួមជាអ្នករំលឹកមេរៀនទៅតាមវិធីសាស្ត្រផ្សេងៗ។ អ្នកចូលរួមនឹងត្រូវបានអញ្ជើញឱ្យស្ម័គ្រចិត្តនៅចុងថ្ងៃនេះ ដើម្បីដឹកនាំការរំលឹកមេរៀននៅថ្ងៃស្អែកពេលព្រឹក។

២. ពន្យល់ថា ការរំលឹកមេរៀនថ្ងៃនេះគឺជាសំណួរ ហើយពួកគាត់អាចរកឃើញសំណួរនេះក្នុងសៀវភៅណែនាំរបស់ពួកគាត់។

៣. ចែកអ្នកចូលរួមជាក្រុមតូចៗ(ក្នុងមួយក្រុមមានគ្នា៣-៤នាក់)។ ឱ្យក្រុមនីមួយៗធ្វើការពិភាក្សាថាតើចម្លើយមួយណាដែលជាចម្លើយត្រឹមត្រូវ ហើយបន្ទាប់មកសរសេរចម្លើយដាក់លើក្រដាសកាតពណ៌។

| សំណួរ | ចម្លើយត្រឹមត្រូវ |
|---|---|
| **១. តើតួអង្គមួយណា ដែលពិការគ-ថ្លង់?**<br>ក). ថាវី<br>ខ). ស្រីមុំ<br>គ). សុផល<br>ឃ).មករា | គ). សុផល |
| **២. តើពិការភាពមាននិយមន័យយ៉ាងដូចម្តេច?**<br>ក). ពិការភាព គឺជាបញ្ហាកាយសម្បទា<br>ខ). ពិការភាព គឺដូចគ្នានឹងភាពខ្សោយដែរ<br>គ). ពិការភាព គឺនៅពេលដែលមនុស្សណាម្នាក់ ដែលមានភាពខ្សោយជួបប្រទះនឹងឧបសគ្គ<br>ឃ). ពិការភាព គឺនៅពេលដែលអ្នកចាំបាច់ត្រូវ ទៅជួបវេជ្ជបណ្ឌិត | **គ). ពិការភាព=ភាពខ្សោយ+ឧបសគ្គ**<br>ជាពិសេស ឧបសគ្គ ដែលធ្វើពិការភាពខុសពីភាពខ្សោយ |

| | |
|---|---|
| **៣. តើអ្នកណាខ្លះដែលមានពិការភាព?**<br>ក). គ្រប់គ្នាមានពិការភាព ក្នុងកម្រិតណាមួយ<br>ខ). ប្រជាជនត្រឹមតែ៥% ប៉ុណ្ណោះដែលមានពិការភាព<br>គ). មានតែទាហានប៉ុណ្ណោះ ដែលរងរបួសនៅក្នុងអំឡុងមានសង្គ្រាមកើតមានឡើង<br>ឃ). មនុស្សមានការលំបាកខ្លះ ការលំបាកច្រើន ឬ មិនអាចធ្វើបានតែម្តង ក្នុងការបំពេញ មុខងារមួយ ឬច្រើន | ឃ). មុខងារទាំងនេះ រួមមាន ការមើលឃើញ ស្តាប់ឮ ផ្លាស់ទីចងចាំ ការថែទាំខ្លួនឯង និងការនិយាយ នៅទូទាំងសកលលោកទាំងមូល មានមនុស្ស ១៥% ដែលជាជនពិការ មិនត្រឹមតែទាហាននោះទេ អ្នកផ្សេងទៀតក៏មានពិការភាពដែរ ដូចជា ពិការពីកំណើត ពិការដោយជំងឺ ឬគ្រោះថ្នាក់ ជាដើម |
| **៤. តើជនពិការអាចទទួលបានជោគជ័យដែរឬទេ?**<br>ក). អាច<br>ខ). មិនអាច | ក). **អាច** មានឧទាហរណ៍ជាច្រើនពីជនពិការ ដែលទទួលបានជោគជ័យ ដូចជា ជនពិការដែលចាប់ផ្តើមជំនួញដោយខ្លួនឯង ឬបង្កើតអង្គការអ្វីមួយ ជាដើម។ |
| **៥. តើអ្នកណាខ្លះដែលមានឱកាសច្រើននៅក្នុងជីវិត?**<br>ក). បុរសមិនពិការ<br>ខ). ស្ត្រីពិការ<br>គ). បុរសពិការ<br>ឃ). ស្ត្រីមិនពិការ | ក). **បុរសមិនពិការ** បើទោះបីជាគាត់មានជីវិត ក្រីក្រក៏ដោយ ក៏មានឱកាសច្រើន ដើម្បីអភិវឌ្ឍខ្លួនជាងអ្នកដទៃទៀត។ ស្ត្រីពិការមានឱកាសតិចតួចជាងគេបំផុត |
| **៦. សូមជ្រើសរើសយកជម្រើសដែលមិនមែនជាឧបសគ្គ ៖**<br>ក). ឥរិយាបថអវិជ្ជមានរបស់គ្រូ<br>ខ). អគារ ដែលពិបាកចេញចូល<br>គ). អ្នកដែលស្រែកខ្លាំងៗដាក់ជនពិការថ្លង់<br>ឃ). អ្នកដែលពិការអវៈយវៈដែលមិនអាចផ្លាស់ទីបាន | ឃ). **ពិការអវៈយវៈមិនមែនជាឧបសគ្គនោះទេ។** របៀបដែលមជ្ឈដ្ឋានជុំវិញមានទំនាក់ទំនងជាមួយនឹងមនុស្សដែលមានភាពខ្សោយ អាចជាឧបសគ្គ ដូចជា ជម្រើស ក) ខ) និង គ) ជាដើម។ |
| **៧. តើឧបសគ្គមានដូចៗ គ្នាចំពោះជនពិការដែរឬទេ?**<br>ក). ដូចគ្នា<br>ខ). មិនដូចគ្នាទេ | ខ). **ទេ** ឧបសគ្គអាចមានលក្ខណៈខុសៗគ្នា។ មនុស្សម្នាក់ ដែលត្រូវការរទេះរុញ (ដូចស្រីមុំ ជាដើម) ជួបប្រទះនឹងឧបសគ្គផ្សេងខុសពីជនពិការគ-ថ្លង់ (សុផល) |

| | |
|---|---|
| **សំណួរបន្ថែម ៖ តើអ្នកយល់ស្រប ឬមិនយល់ស្រប នឹងប្រយោគខាងក្រោម ៖ ជនពិការគួរមើលថែខ្លួនឯង វាមិនមែនជាការទទួលខុសត្រូវរបស់សហគមន៍នោះទេ ៖**<br>ក). យល់ស្រប<br>ខ). មិនយល់ស្រប | • ក្រុមយកចម្លើយ ក) ឬ ខ) មិនសំខាន់នោះទេ។ អ្វីដែលសំខាន់គឺការចាប់ផ្តើមការពិភាក្សា។ ហេតុអ្វីបានជាក្រុមជ្រើសរើសយកជម្រើសទាំងនេះ?<br>• អ្វីដែលគួរចេញពីការពិភាក្សានេះ គឺគំនិតយល់ឃើញដែលថា ឧបសគ្គនានាមិនអាចដកចេញដោយជនពិការម្នាក់ឯងនោះទេ ប៉ុន្តែត្រូវការអន្តរាគមន៍ពីអ្នកដទៃ ឧទាហរណ៍ អគារ ដែលជនពិការមិនអាចចេញចូលបានជាដើម។ |

៤. នៅពេលដែលក្រុមបានឆ្លើយនឹងសំណួរទាំងអស់រួចហើយ សូមផ្តល់ចម្លើយត្រឹមត្រូវដោយចាប់ផ្តើមពីសំណួរទីមួយទៅ។ សូមចំណាយពេល ដើម្បីកែចម្លើយដែលមិនត្រឹមត្រូវ និងពន្យល់ពីមូលហេតុដែលចម្លើយទាំងនោះមិនត្រឹមត្រូវ។

៥. ព្យាយាមភ្ជាប់ទំនាក់ទំនងចម្លើយទាំងអស់ជាមួយនឹងសារគន្លឹះៗកាលពីម្សិល។ ឆ្លើយនឹងសំណួរដែលអ្នកចូលរួមនៅមាន។

| **មេរៀន៣.២**<br>**ឥរិយាបថចំពោះពិការភាព** | |
|---|---|
| **គោលដៅ ៖**<br>• យល់ដឹងពីភាពអវិជ្ជមាន និងរបៀបលើកកម្ពស់ភាពវិជ្ជមានដែលពាក់ព័ន្ធជនពិការ<br>• យល់ដឹងពីផលប៉ះពាល់ដោយសារការសម្តែងឥរិយាបថអវិជ្ជមានចំពោះជនពិការ។ | |
| **រយៈពេល** | ៦០នាទី |

**កំណត់សម្គាល់ ៖**

មុនមេរៀននេះ សូមរៀបចំក្រដាសផ្ទាំងធំដែលមាន២ជួរឈរ(ទឹកមុខរីករាយ និងទឹកមុខសោកសៅ)

១. ឧបសគ្គមួយក្នុងចំណោមឧបសគ្គនានា ដែលត្រូវបានលើកឡើងនៅថ្ងៃទី១ គឺឥរិយាបថអវិជ្ជមាន។ ពន្យល់ពីមូលហេតុ ដែលយើងនិយាយពីឥរិយាបថ តាមរយៈ ការបង្ហាញស្លាយ ដែលមានខ្លឹមសារដូចខាងក្រោម។ ចាប់ផ្តើមដោយផ្តល់ឧទាហរណ៍អំពីឥរិយាបថ ដែលមិនជាប់ពាក់ព័ន្ធជាមួយនឹងពិការភាព ដើម្បីឱ្យអ្នកចូលរួមយល់ថា ឥរិយាបថមានន័យយ៉ាងដូចម្តេច។ **ឧទាហរណ៍** ៖ ឥរិយាបថរបស់អ្នកក្នុងនាមជាគ្រូបង្វាត់កីឡាអ្វីមួយ ការងារអ្វីមួយ ឬមនុស្សមួយក្រុម។ ផ្តល់ឧទាហរណ៍អំពីឥរិយាបថវិជ្ជមាន និងអវិជ្ជមាន។

- ឥរិយាបថ៖
  - គឺជារបៀបដែលយើងគិតពីអ្វីមួយ ឬនរណាម្នាក់
  - អាចវិជ្ជមាន ឬអវិជ្ជមាន
  - អាចដោយចេតនា ឬអចេតនា
  - មានឥទ្ធិពលលើការធ្វើសកម្មភាពរបស់យើង
- ពាក់ព័ន្ធនឹងពិការភាព និងជនពិការ៖
  - មានគំនិតអវិជ្ជមានជាច្រើន ឧទាហរណ៍ ជនពិការគឺជាមនុស្សមិនប្រក្រតី ឬពិការភាពកើតដោយសារការត្រូវបណ្តាសាជាដើម
  - ជនពិការនិយាយថា ឥរិយាបថអវិជ្ជមានចំពោះពិការភាព គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗជាងគេ ដែលពួកគាត់ជួបប្រទះកន្លងមក
  - ជនពិការផ្តល់តម្លៃទាបដល់ខ្លួនឯង និងមានអារម្មណ៍ថា ពួកគាត់គ្មានតម្លៃ។

២. ដើរទៅរកក្រដាសផ្ទាំងធំ ដែលសល់ពីមេរៀន២.១ ថ្ងៃទី១ ៖ ក្រដាសផ្ទាំងធំដែលមានបិទក្រដាសកាតពណ៌វិភាគពីតួអង្គ(ស្រីមុំ ថារី សុផល និងមករា) និងភាពខ្សោយ ក៏ដូចជាការលំបាកដែលពួកគាត់ជួបប្រទះ។ល។ រំលឹកឡើងវិញ ពីអ្វីដែលបានធ្វើកាលពីម្សិលមិញ។ ផ្តោតលើជួរឈរចុងក្រោយ ៖ "ការយល់ឃើញរបស់មនុស្សផ្សេងទៀត"។ និងសួរសំណួរ៖ "តើគេមើលមកជនពិការយ៉ាងដូចម្តេច? តើជនពិការត្រូវបានគេចាត់ទុកថាជាសមាជិកមានតម្លៃក្នុងសង្គមដែរឬទេ?"



៣. សួរថាហេតុអ្វីបានជាអ្នកដទៃមើលមកជនពិការខុសប្លែកពីគេ? ហេតុអ្វីបានជាមានភាពខុសគ្នាក្នុងការមើលមកជនពិការ និងអ្នកដែលមិនមែនជាជនពិការ? កត់ត្រាមូលហេតុទាំងនេះលើក្រដាសផ្ទាំងធំ។ សួរបន្ថែម ដើម្បីរកការសន្និដ្ឋានដែលនៅពីក្រោយ៖

- ហេតុអ្វីបានជាគេមានឥរិយាបថអវិជ្ជមានចំពោះជនពិការ?
- តើឥរិយាបថអវិជ្ជមានចំពោះជនពិការមានផលប៉ះពាល់អ្វីខ្លះ?



> ប្រសិនបើ អ្នកចូលរួម មិនទាន់បានលើកឡើងពីចំណុចទាំងនេះទេ ព្យាយាមលើកយ៉ាងហោច ណាស់ចំណុចខាងក្រោមក្នុងការពិភាក្សា៖
>
> - លើសពីនេះ មានភាពខុសប្លែកគ្នាខាងឋានៈក្នុងសង្គមរវាងអ្នកពិការដោយសារសង្គ្រាម(អតីតយុទ្ធជន)និងអ្នកពិការពីកំណើត
> - មានការភ័យខ្លាចជនពិការ ហើយការភ័យខ្លាចនេះនាំឱ្យមានបុរេវិនិច្ឆ័យ និងការរើសអើង។
> - ការនៅឯកោ នាំឱ្យមានការភ័យខ្លាចបែបនេះ ហើយការភ័យខ្លាចនាំឱ្យមានការនៅឯកោ ហើយជាលទ្ធផលជនពិការ និងអ្នកដែលមិនមែនជាជនពិការអាចមានការយល់ឃើញ និងការរំពឹង

ទុក ដែលមិនប្រាកដនិយមពីគ្នាទៅវិញទៅមក។

- ជារឿយៗ គេមានចិត្តអាណិតអាសូរជនពិការ ហើយមិនមើលឃើញសមត្ថភាពរបស់ជនពិការនោះឡើយ។
- ប្រព័ន្ធផ្សព្វផ្សាយ និងទស្សនៈយល់ឃើញនានានៅផ្ទះក្តី ឬនៅសាលារៀនក្តី អាចពង្រឹងការយល់ ឃើញទាំងនេះបន្ថែមទៀត។
- ពិការភាពត្រូវបានគេចាត់ទុកថាជាភាពមិនល្អឥតខ្ចោះ ដូច្នេះជនពិការមិនត្រូវបានគេចាត់ទុកថាជាមនុស្ស"ពេញលេញ" ឡើយនេះ នាំឱ្យពិការភាពក្លាយជាស្រមោលអន្ធកាលដែលគ្របដណ្តប់មកលើភាពជាមនុស្សរបស់មនុស្ស ដោយសារតែជនពិការត្រូវបានគេសម្គាល់ត្រឹមតែដោយសារភាពខ្សោយរបស់ពួកគាត់តែប៉ុណ្ណោះ។

**កំណត់សម្គាល់ ៖**

ធានាថា អ្នកចូលរួមពុំមានអារម្មណ៍មិនល្អចំពោះចម្លើយរបស់ពួកគាត់ឡើយ និងធ្វើការបញ្ជាក់សារជាថ្មីថា ជារឿយៗ គំនិតទាំងនេះត្រូវបានគេចាត់ទុកថាជារឿងធម្មតាក្នុងសង្គមមួយ។ ប៉ុន្តែត្រូវបញ្ជាក់ឱ្យច្បាស់ថា គំនិតទាំងនេះមានឥទ្ធិពលមកលើរបៀបដែលយើងគិត និងធ្វើសកម្មភាព ហើយយើងនឹងត្រលប់មកជជែកគ្នាពីការសន្មតទាំងនេះម្តងទៀតក្នុងការបណ្តុះបណ្តាល។

៤. ចែកអ្នកចូលរួមជាក្រុម ដោយក្នុងមួយក្រុមមានគ្នាពី៤-៦នាក់។ ពន្យល់ថា លំហាត់នេះមានគោលបំណងធ្វើការស្វែងយល់ថាតើភាពពាក់ព័ន្ធណាខ្លះ ដែលមានន័យអវិជ្ជមាន និងថាតើមានជម្រើសវិជ្ជមានអ្វីខ្លះ?

៥. ឱ្យអ្នកចូលរួមម្នាក់ៗសរសេរពាក្យពេចន៍ ដែលគេភ្ជាប់ទំនាក់ទំនងទៅនឹងជនពិការ(ទាំងវិជ្ជមាន ទាំងអវិជ្ជមាន)។ "តើពាក្យពេចន៍អ្វីខ្លះ ដែលអ្នកគិតឃើញនៅពេលដែលអ្នកនិយាយ ឬគិតពីពាក្យថា "**ជនពិការ**" ?។ នេះអាចជាពាក្យពេចន៍ធម្មតាដែលគេប្រើសម្រាប់ជនពិការក្នុងប្រទេសកម្ពុជា ឬជាទូទៅ។ ទុកពេល២ ឬ ៣នាទីឱ្យអ្នកចូលរួមគិតដោយខ្លួនឯង។



៦. ឱ្យអ្នកចូលរួមនិយាយពីពាក្យពេចន៍ ដែលពួកគាត់គិតឃើញនៅក្នុងក្រុម។ ឱ្យក្រុមសរសេរពាក្យពេចន៍ដាក់នៅលើក្រដាសកាតពណ៌។

៧. ឱ្យក្រុមតូចចែករំលែកនៅក្នុងក្រុមធំដោយពិភាក្សា ៖ តើពាក្យពេចន៍ និងរូបភាពទាំងនេះមានលក្ខណៈវិជ្ជមាន ឬអវិជ្ជមាន? រៀបចំក្រដាសផ្ទាំងធំចំនួន២ ៖ ក្រដាសផ្ទាំងធំមួយវិជ្ជមាន (ដែលមានសញ្ញាមុខរីករាយ) និងក្រដាសផ្ទាំងធំមួយទៀតអវិជ្ជមាន(សញ្ញាមុខស្រពាប់ស្រពោន)។ បិទក្រដាសកាតពណ៌ទាំងនេះឱ្យត្រូវនឹងក្រដាសផ្ទាំងធំវិជ្ជមាន ឬអវិជ្ជមាន។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួន ៖



|  |  |
|---|---|
| មិនអាចធ្វើការងារបាន | មនុស្សល្អ |
| ឆោតល្ងង់ | មានតម្លៃ |
| ជនរងគ្រោះ | មានការប្តេជ្ញាចិត្ត |

ឱ្យអ្នកចូលរួមឆ្លើយ ៖

- តើអ្វីដែលធ្វើឱ្យពាក្យពេចន៍ទាំងនេះមានលក្ខណៈវិជ្ជមាន ឬអវិជ្ជមាន?
- តើមនុស្សមានឥរិយាបថអ្វីខ្លះទៅលើពិការភាព ឬជនពិការ ដោយប្រើប្រាស់ទំនាក់ទំនងនឹងហេតុផលខាងលើ?

៨. អ្នកចូលរួមចាំបាច់ត្រូវឮពីអ្វីដែលគ្រូបណ្តុះបណ្តាលគិតពីទំនាក់ទំនងនឹងហេតុផលខាងលើ។ គ្រូបណ្តុះបណ្តាលដែលជាជនពិការ គឺស័ក្តិសមបំផុតនឹងផ្តល់ព័ត៌មានលម្អិតជាក់លាក់អំពីបញ្ហានេះ និងផ្តល់នូវឧទាហរណ៍ជាក់ស្តែង (និងឧទាហរណ៍ផ្ទាល់ខ្លួន) ពីមូលហេតុដែលពាក្យពេចន៍មួយចំនួនវិជ្ជមាន និងមួយចំនួនទៀតមានលក្ខណៈអវិជ្ជមាន និងអារម្មណ៍នៅពេលដែលគេហៅមកខ្លួនតាមបែបអវិជ្ជមាន។ បន្ទាប់មក បង្ហាញស្លាយ តាមខ្លឹមសារខាងក្រោម ៖





- ពាក្យពេចន៍**អវិជ្ជមាន** គឺជាពាក្យដែលរៀបរាប់ពីជនពិការថាជនរងគ្រោះ ប៉ុន្តែវាក៏ជាពាក្យពេចន៍ ដែលបន្ទោសដល់ជនពិការ ខ្លាចរអែង ឬខ្ពើមរអើមពួកគាត់ ឬបង្ហាញពីការស្អប់ពួកគាត់ជាដើម។



- ពាក្យពេចន៍**វិជ្ជមាន** គឺជាពាក្យដែលផ្តោតលើអ្វីដែលមនុស្សម្នាក់អាចធ្វើបាន។ ចាត់ទុកជនពិការ ដូចមនុស្សដទៃដែរ ហើយពិការភាពរបស់ពួកគាត់ គឺគ្រាន់តែជាចំណុចមួយរបស់ពួកគាត់ប៉ុណ្ណោះ។ ចាត់ទុកជនពិការថាមានភាពស្មើភាពគ្នា និងអាចធ្វើកិច្ចការបានជាច្រើន។

៩. បញ្ចប់ដោយនិយាយថា របៀបដែលយើងគិតអំពីអ្វីមួយ មានឥទ្ធិពលលើរបៀបដែលយើងធ្វើសកម្មភាព និងពាក្យពេចន៍ដែលយើងប្រើ។ ដូចដែលអ្នកអាចមើលឃើញនៅក្នុងលំហាត់នេះ មានគំនិតអវិជ្ជមានជាច្រើនមកលើជនពិការ។ ជារឿយៗ ជនពិការត្រូវបានគេផាត់ចេញ ដោយសារតែមនុស្សផ្សេងទៀតមានគំនិតអវិជ្ជមាន ឬគំនិតខុសឆ្គងអំពីពួកគាត់ ដែលនាំឱ្យមានការរើសអើង និងការផាត់ចេញ។ ការដាក់បញ្ចូលពិការភាព មានន័យថា ឧបសគ្គជាឥរិយាបថអវិជ្ជមានចំពោះជនពិការត្រូវបានបំបែក ។ សូមត្រលប់ទៅមើលតួអង្គរបស់យើងវិញ ៖



**ឧទាហរណ៍ទី១ ៖** ម្ដាយស្រីមុំ គិតថាស្រីមុំ រៀនមិនចេះ ដោយសារតែនាងជាជនពិការ។ ដោយសារតែម្ដាយគិតបែបនេះ គាត់មិនបានបញ្ជូនកូនទៅ សាលារៀនឡើយ។ ប៉ុន្តែ នៅពេលដែលគាត់យល់ថា កូនស្រីរបស់គាត់ អាចរៀនចេះដូចគេដូចឯង គាត់បានគាំទ្រឱ្យនាងទៅរៀននឹងគេដែរ។

**ឧទាហរណ៍ទី២ ៖** មករា បានបោះបង់ចោលការសិក្សា ដោយសារតែត្រូវគ្រូវាយ។ នេះក៏ធ្វើឱ្យមករា គិតមិនល្អចំពោះខ្លួនឯងថាជា "ជនពិការ"ផងដែរ។ បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលមួយបានអញ្ជើញ មករា ឱ្យមកមជ្ឈមណ្ឌល ៖ "យើងឃើញថា មករា ដឹងច្រើនរួចទៅហើយ ដូច្នេះយើងបានសួរគាត់ ថាតើគាត់អាចជួយបង្រៀនក្មេងតូចៗជាមួយយើងបានដែរឬទេ។ ដំបូងគាត់និយាយថា គាត់មិនអាចបង្រៀនបានឡើយ ដោយសារតែគាត់ជា "ជនពិការ"។ អង្គការមិនមែនរដ្ឋាភិបាលនេះ បានលើកទឹកចិត្តគាត់ ដោយប្រាប់គាត់ថា មានជនពិការច្រើនណាស់ ដែលអាចធ្វើកិច្ចការបានយ៉ាងច្រើន។ គាត់យល់ព្រមចាប់ផ្ដើមជួយក្មេងៗតូចៗទាំងនោះ ហើយឥឡូវនេះ គាត់មានលក្ខណៈផ្សេងខុសពីមុន ដោយគាត់មានទំនុកចិត្តច្រើនជាងមុន។"



១០.**បង្ហាញសារអប់រំសំខាន់ៗ** តាមរយៈស្លាយ ឬក្រដាសផ្ទាំងធំ ដែលមានខ្លឹមសារដូចខាងក្រោម ៖



- ជនពិការនិយាយថា ឥរិយាបថអវិជ្ជមានចំពោះ ពិការភាព គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗជាងគេ ដែលពួកគាត់ជួបប្រទះ។
- ជនពិការចង់ឱ្យគេស្វាគមន៍ខ្លួន គេធ្វើល្អដាក់ខ្លួន ដោយផ្ដល់នូវ**ការគោរព និងសេចក្ដីថ្លៃថ្នូរ។**
- ជាការសំខាន់ ត្រូវប្រើប្រាស់ភាសាឱ្យបានសមស្រប នៅពេលដែលនិយាយអំពីជនពិការ។

| មេរៀន៣.៣<br>ភាសាដែលមានការគោរពអំពីពិការភាព | |
|---|---|
| **គោលដៅ ៖** យល់ដឹងពីរបៀបនិយាយទៅកាន់ជនពិការ ដើម្បីឱ្យពួកគាត់មានអារម្មណ៍ថា ពួកគាត់ត្រូវបានគេគោរព និងឱ្យតម្លៃ។ | |
| **រយៈពេល** | ៤៥នាទី |

១. ក្នុងមេរៀនមុន ភាពពាក់ព័ន្ធ និងឥរិយាបថចំពោះពិការភាពជាច្រើន ត្រូវបានលើកយកមកពិភាក្សា។ នៅក្នុងលំហាត់នេះ អ្នកចូលរួមនឹងរៀនពីការប្រើប្រាស់ជម្រើសវិជ្ជមាន សម្រាប់ជំនួសឱ្យពាក្យ ដែលមិនផ្តល់ការគោរព។ ពន្យល់ថា ឥឡូវនេះ យើងនឹងគិតពីរបៀបនិយាយអំពីជនពិការ ដែលផ្តល់នូវការគោរពចំពោះពួកគាត់។ សរសេរពាក្យពេចន៍ផ្តល់ការគោរព និងមិនផ្តល់ការគោរពដាក់លើកាតពីរសន្លឹកផ្សេងគ្នា ហើយបិទលើក្រដាសផ្ទាំងធំ ដែលមានពាក្យពេចន៍វិជ្ជមាន និងអវិជ្ជមាន។

២. មើលក្រដាសផ្ទាំងធំ ដែលសរសេរពាក្យអវិជ្ជមាន និងសួរអ្នកចូលរួមថា តើត្រូវប្តូរពាក្យ និងន័យអវិជ្ជមានយ៉ាងដូចម្តេច ដើម្បីឱ្យទៅជាភាសាដែលផ្តល់ការគោរពវិញ។ ឧទាហរណ៍ ជំនួសឱ្យការនិយាយថាអ្នកនេះជា"មនុស្សឆ្កួត" គេអាចប្រើពាក្យគាត់ជា"**ជនដែលមានបញ្ហាផ្លូវចិត្ត**"។ ទុកពេលឱ្យអ្នកចូលរួមសរសេរចម្លើយនៅលើកាតផ្សេង ហើយបិទកាតទាំងនោះលើក្រដាសផ្ទាំងធំដែលវិជ្ជមាន។

នៅពេលរៀបរាប់ ឬនិយាយពីជនពិការ សូមប្រើភាសា"ហៅចំឈ្មោះ"។ **ឧទាហរណ៍** ៖ ហៅឈ្មោះ មករា ឬនិយាយថាក្មេងប្រុសដែលខ្សោយគំហើញ មិនមែនក្មេងប្រុសខ្វាក់ភ្នែកនោះទេ។

**កំណត់សម្គាល់ ៖**

បង្ហាញអំពីអត្ថន័យនៃពាក្យអវិជ្ជមាន និងវិជ្ជមាន ដូចមានខ្លឹមសារក្នុងសកម្មភាពទី៨ នៃមេរៀន ២.៣ តាមរយៈស្លាយ ឬក្រដាសផ្ទាំងធំ អមដោយសេចក្តីពន្យល់ពីក្នុងមេរៀននេះទាំងមូល។ សូមប្រើប្រាស់តារាងខាងក្រោម សម្រាប់ពាក្យភាសាខ្មែរ ស្នើឡើងដែលផ្តល់ការគោរពដល់ ជនពិការ ៖

| ប្រភេទនៃភាពខ្សោយ | ពាក្យដែលមិនគួរប្រើ | ពាក្យដែលសម្តែងការគោរព |
|---|---|---|
| ភាពខ្សោយខាងរាងកាយ | • អាកាបាក់ | • ពិការជើង |
| | • អាកាបុត | • ពិការដៃ |
| | • អាខ្វិន | • ពិការជើង |
| | • អាដាច់ | • ពិការជើងឬ ដៃ |
| | • អាកាង៉ែវ | • ពិការដៃ |
| | • អាពៀច | • ពិការជើង |
| | • អាក្រង៉ែង | • ពិការដៃ |
| | • អាខ្វេ | • ពិការជើងឬ ដៃ |
| | • អាគម | • ពិការខ្នង |

| **ប្រភេទនៃភាពខ្សោយ** | **ពាក្យដែលមិនគួរប្រើ** | **ពាក្យដែលសម្តែងការគោរព** |
|---|---|---|
| | • អាស្គន់ជាន់ | • ពិការចលករខួរក្បាល |
| | • អាប្រកាច់ | • ពិការចលករខួរក្បាល ឬប្រកាច់ |
| **ភាពខ្សោយគំហើញ** | • អាខ្វាក់ | • ពិការភ្នែក |
| | • អាងងឹត | • ពិការក្នុងការមើល |
| | • អាឡេវ | • ពិការភ្នែក |
| **ភាពខ្សោយខាងការស្តាប់** | • អាគ | • ពិការគ-ថ្លង់ |
| | • អាថ្លង់ | • ពិការក្នុងការស្តាប់ |
| | • អាតម្លង់ | • ពិការក្នុងការស្តាប់ |
| | • អាកាង្ធូរ | • ពិការក្នុងការនិយាយ |
| | • អាតាឡាន់ | • ពិការក្នុងការនិយាយ |
| **ភាពខ្សោយខាងបញ្ញាស្មារតី** | • អាឆ្កួត | • ពិការខ្សោយសតិបញ្ញា |
| | • អាឡប់ | |
| | • អាភ្លើ | |
| | • អាឆ្កួតជ្រូក | |
| | • អាអត់គ្រប់ទឹក | |
| | • អាគ្រាសក្រឡុង | |
| | • អាប្រសៃប្រសាទ | |
| | • អាឡឺកឺ | |
| | • អាតក់ឡក់ | |



៣. បង្ហាញសារគន្លឹះសម្រាប់មេរៀននេះ តាមរយៈស្លាយ ឬក្រដាសផ្ទាំងធំ ដែលមានខ្លឹមសារដូចខាងក្រោម ៖

- ភាសាផ្តល់នូវការគោរព គឺជាភាសា ដែលមិនធ្វើឱ្យឈឺចាប់ ប៉ុន្តែមានន័យអព្យាក្រឹត ឬ វិជ្ជមាន
- ប្រើប្រាស់ភាសា ដែលចាប់ផ្តើមពីពាក្យមនុស្ស ឬជននៅខាងដើម។

**មេរៀន ៣.៤**

**គោលការណ៍ណែនាំសម្រាប់និយាយជាមួយជនពិការ**

| | |
|---|---|
| **គោលដៅ ៖** | ផ្តល់ឱ្យអ្នកចូលរួមនូវគោលការណ៍ណែនាំ និងដំបូន្មានអំពីរបៀបនិយាយប្រកបដោយការគោរពចំពោះជនពិការ |
| **រយៈពេល** | ១៥នាទី |

១. ផ្តល់ការណែនាំអំពីរបៀបនិយាយជាមួយជនពិការដែលផ្តល់ការគោរព ដូចមានបង្ហាញនៅចំណុចខាងក្រោមម្តងមួយៗ។ សកម្មភាពនេះអាចធ្វើបានល្អបំផុត ដោយគ្រូបណ្តុះបណ្តាលដែលជាជនពិការ ដោយសារតែគាត់អាចបង្ហាញជាមួយនឹងឧទាហរណ៍ជាក់ស្តែង(និងឧទាហរណ៍ផ្ទាល់ខ្លួន)។ បង្ហាញតាមរយៈស្លាយ ឬក្រដាសផ្ទាំងធំដែលមានខ្លឹមសារដូចខាងក្រោម ៖



- ហៅជនពិការចំឈ្មោះ
- កុំសម្លក់សម្លឹង និងកុំចង្អុល
- និយាយទៅកាន់ជនពិការដោយផ្ទាល់
- សួរទៅជនពិការថាតើពួកគាត់ចង់ប្រើពាក្យអ្វី ប្រសិនបើពួកគាត់មានពិការភាព
- ប្រើពាក្យ"ជនមិនពិការ" កុំប្រើពាក្យថា "មនុស្សធម្មតា" ឬ "មនុស្សមានសុខភាពល្អ"
- ប្រើភាសាដែលសម្តែងការគោរព និងចៀសវាងប្រើពាក្យដែលមិនផ្តល់ការគោរព

**សេចក្តីពន្យល់ពិស្តារ ៖**

- ហៅជនពិការចំឈ្មោះ និងលើកឡើងពីពិការភាពរបស់ជននោះ តែនៅពេលដែលវាពាក់ព័ន្ធជាមួយនឹងអ្វី ដែលអ្នកកំពុងគិត។ ឧទាហរណ៍ កុំសួរថា "តើអ្នកមានបញ្ហាអ្វី? "កុំលើកពីមនុស្សទូទៅ ឬប្រើប្រាស់ពាក្យពេចន៍ទូទៅ ដូចជា "ក្មេងស្រីប្រើរទេះរុញ" ជាដើម។
- កុំសម្លក់សម្លឹង និងកុំចង្អុល។ ចាត់ទុកជនពិការ ដូចមនុស្សដទៃៗទៀតដែរ។
- និយាយទៅកាន់ជនពិការដោយផ្ទាល់ មិនមែនទៅកាន់អ្នកជំនួយការ ឬសមាជិកគ្រួសាររបស់គាត់នោះទេ នៅពេលដែលអ្នកចង់និយាយទៅកាន់ជនពិការ។
- វាមិនថ្មីនោះទេ ក្នុងការប្រើពាក្យ ឬឃ្លា ដូចជា "ពិការ" "ពិការភាព" ឬ "ជនពិការ" ជាដើម នៅពេលនិយាយអំពីបញ្ហាពិការភាព។ សួរទៅជនពិការថាតើពាក្យណា ដែលពួកគាត់ចង់ប្រើប្រាស់នៅពេលដែលពួកគាត់មានពិការភាព។
- នៅពេលនិយាយពីអ្នកដែលពុំមានពិការភាព វាមិនថ្មីទេ ក្នុងការនិយាយថា"អ្នកមិនពិការ"។ ប៉ុន្តែសូមកុំហៅពួកគាត់ថាជាមនុស្ស "ធម្មតា" ឬ "មានសុខភាពល្អ"។ ពាក្យពេចន៍ទាំងនេះអាចធ្វើឱ្យជនពិការមានអារម្មណ៍ថាពួកគាត់មានអ្វីមួយខុស ហើយពួកគាត់គឺជាមនុស្ស"ខុសធម្មតា"។
- ជានិច្ចកាល ប្រើភាសាដែលសម្តែងពីការគោរព និងចៀសវាងប្រើប្រាស់ពាក្យដែលមិនសម្តែងពីការគោរព។

២. បញ្ចប់ដោយនិយាយថា អ្នកចូលរួមអាចមានអារម្មណ៍ថា ទទួលបានព័ត៌មានលើសលប់តាមការករណីណែនាំជាច្រើន។ សូមមើលសៀវភៅណែនាំសម្រាប់អ្នកចូលរួម និងគូសបញ្ជាក់ពីសារគន្លឹះខាងក្រោមសម្រាប់មេរៀននេះ ៖

- ពិការភាពមិនកំណត់ពីមនុស្សទេ វាគ្រាន់តែជាទិដ្ឋភាពមួយរបស់មនុស្ស តែប៉ុណ្ណោះ។
- ការគោរព និងសេចក្តីថ្លៃថ្នូរ គឺជាភាសាសំខាន់ ដែលត្រូវប្រើអំពីជនពិការ និងជាមួយជនពិការ។

| មេរៀន ៣.៥<br>សង្ខេបមេរៀនជំពូកទី ៣ | |
|---|---|
| **គោលដៅ ៖** រំលឹកអ្នកចូលរួមអំពីអ្វីដែលយើងបានរៀននៅថ្ងៃនេះ និងបញ្ជាក់ពីសំណួរនានា ដែលនៅសេសសល់។ | |
| **រយៈពេល** | ៥នាទី |

១. ផ្តល់ការសង្ខេបនៅចុងមេរៀន និងមើលសៀវភៅណែនាំសម្រាប់អ្នកចូលរួមតាមខ្លឹមសារខាងក្រោម ៖

- អ្វីដែលមនុស្សគិត (ឥរិយាបថ) កំណត់ពីរបៀបដែលមនុស្សធ្វើសកម្មភាព និងភាសាដែលពួកគាត់ប្រើប្រាស់។
- ឥរិយាបថអវិជ្ជមាន គឺជាឧបសគ្គធំជាងគេ ដែលជនពិការជួបប្រទះ។
- ឥរិយាបថអវិជ្ជមានចំពោះជនពិការ នឹងមានផលប៉ះពាល់មកលើការផ្តល់តម្លៃដល់ពួកគាត់ ហើយពួកគាត់នឹងចាប់ផ្តើមជឿថា ពួកគាត់ពុំមានតម្លៃ ហើយត្រូវការការគាំទ្រ។
- សូមកុំប្រើពាក្យដែលនាំឱ្យអាប់ឱន ប៉ុន្តែប្រើភាសាអព្យាក្រឹតដែលអាចធ្វើទៅបាន ដូចពេលដែលអ្នកនិយាយពីជនមិនពិការដែរ។
- សូមប្រាស្រ័យទាក់ទងជាមួយ ជនពិការដូចមនុស្សទូទៅដែរ ព្រោះពិការភាពគ្រាន់តែជាទិដ្ឋភាពមួយនៃជីវិតរបស់គាត់តែប៉ុណ្ណោះ។
- ប្រសិនបើអ្នកមិនដឹងពីអ្វីដែលសមស្រប សូមសួរទៅកាន់ជនពិការ។ ជានិច្ចកាលត្រូវប្រើពាក្យដែលផ្អែកទៅតាមការគោរព និងសេចក្តីថ្លៃថ្នូរ។

២. លើកឡើងថា នៅពេលបន្ទាប់នេះ យើងនឹងយកចំណុចដែលបានរៀនសូត្រនៅពេលនេះទៅអនុវត្តជាក់ស្តែង។ យើងនឹងអញ្ជើញភ្ញៀវចំនួន៣នាក់ ជាជនពិការមកចែករំលែកបទពិសោធន៍។

# ជំពូកទី៤
# ការប្រាស្រ័យទាក់ទង
# ជាមួយជនពិការ

# ជំពូកទី៤

# ការប្រាស្រ័យទាក់ទងជាមួយជនពិការ

## ក). សេចក្តីពិពណ៌នា

ជំពូកនេះផ្តោតលើការប្រាស្រ័យទាក់ទងជាមួយជនពិការ របៀបដែលជនពិការអាចបញ្ចេញគំនិតយោបល់ ដោយប្រើប្រាស់វិធីសាស្ត្រប្រាស្រ័យទាក់ទងផ្សេងៗគ្នា និងរបៀបដែលពួកគាត់អាចធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកមិនពិការ។

នៅចុងបញ្ចប់នៃជំពូកនេះ អ្នកចូលរួមនឹង ៖

- កំណត់អំពីវិធីសាស្ត្រសមស្របសម្រាប់ធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកដែលមានពិការភាពផ្សេងៗគ្នា
- រៀបរាប់អំពីរបៀបប្រាស្រ័យទាក់ទងជាមួយជនពិការ
- ស្គាល់ស្ថាប័នពាក់ព័ន្ធនានាដែលធ្វើការ និងគាំទ្រដល់ជនពិការទៅតាមប្រភេទផ្សេងៗ

## ខ). មាតិកាមេរៀន

| លរ | មេរៀន | រយៈពេល | សម្ភារៈ និងឯកសារ |
|---|---|---|---|
| ៤.១. | ការប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាព | ២៥នាទី | |
| ៤.២. | របៀបប្រាស្រ័យទាក់ទង ជាមួយជនពិការគថ្លង់ និងអ្នកដែលពិបាកស្តាប់ | ៥០នាទី | ក្រដាសផ្ទាំងធំសម្រាប់កត់ត្រាដំបូន្មាន ឬយោបល់ |
| ៤.៣. | របៀបប្រាស្រ័យទាក់ទងជាមួយជនពិការខ្សោយសតិបញ្ញា | ៥០នាទី | ក្រដាសផ្ទាំងធំសម្រាប់កត់ត្រាដំបូន្មាន ឬយោបល់ |
| ៤.៤. | របៀបប្រាស្រ័យទាក់ទងជាមួយជនពិការខ្សោយគំហើញ | ៥០នាទី | ក្រដាសផ្ទាំងធំសម្រាប់កត់ត្រាដំបូន្មាន |
| ៤.៥. | ការសង្ខេបមេរៀនជំពូកទី៤ | ៥នាទី | មើលសៀវភៅណែនាំសម្រាប់អ្នកចូលរួម |
| ៤.៦. | ការវាយតម្លៃបញ្ចប់ប្រចាំថ្ងៃ | ១៥នាទី | |
| **សរុប** | | **១៩៥នាទី** | |

មេរៀនទាំងនេះនិយាយពីការប្រាស្រ័យទាក់ទងជាមួយមនុស្សដែលជាជនពិការ។ អ្នកអាចសម្របសម្រួលមេរៀននេះដោយខ្លួនឯង ប៉ុន្តែបទពិសោធន៍ជាមួយនឹងមេរៀននេះកាន់តែប្រសើរថែមទៀត ប្រសិនបើមានអ្នកចូលរួមជួយដែលមានភាពខ្សោយខាងការស្តាប់ខាងគំហើញ និងខាងសតិបញ្ញា។

នៅមុនការបណ្តុះបណ្តាលអញ្ជើញអ្នកជនពិការគ-ថ្លង់ និង/ឬពិបាកស្តាប់ មកពីសហគមន៍ ដើម្បីមកជាវាគ្មិនសម្រាប់ការបណ្តុះបណ្តាលនេះ។ ប្រសិនបើធ្វើបែបនេះមិនបានទេ សូមអញ្ជើញអ្នកណាម្នាក់មកពីអង្គការ ដែលធ្វើការងារជាមួយនឹងជនពិការគ-ថ្លង់។ លក្ខខណ្ឌតម្រូវសម្រាប់ភ្ញៀវគឺថា ពួកគាត់ត្រូវបើកចំហ និងសុខចិត្តចែករំលែកពីបទពិសោធន៍របស់ខ្លួន។ សួរពួកគាត់ថាតើពួកគាត់នឹងនាំអ្នកបកប្រែ ឬសមាជិកគ្រួសារ ដែលអាចបកប្រែរវាងពួកគាត់ និងអ្នកចូលរួមបានដែរឬទេ។ ធ្វើដូចគ្នានេះ សម្រាប់អ្នកដែលខ្សោយគំហើញ និងអ្នកដែលមានពិការភាពខាងសតិបញ្ញា (ឬសមាជិកគ្រួសាររបស់អ្នកដែលមានពិការភាពខាងសតិបញ្ញា)។

ការរៀបចំ និងការសម្របសម្រួលជំពូកនេះបានល្អ គឺជាគន្លឹះសម្រាប់ទទួលបានជោគជ័យ ៖

- ប្រាប់ភ្ញៀវដែលត្រូវបានអញ្ជើញឱ្យបានច្បាស់ជាមុន អំពីអ្វីដែលនឹងកើតមានឡើង
- ត្រៀមសំណួរជាមុន និងគិតរកសំណួរបន្ថែម
- បង្កើតបរិយាកាសវិជ្ជមាន និងទទួលស្វាគមន៍ភ្ញៀវ ឱ្យគាត់អង្គុយនៅផ្នែកម្ខាងនៃបន្ទប់
- អ្នកត្រូវស្គាល់ឈ្មោះពួកគាត់ ហើយណែនាំពួកគាត់ក្នុងក្រុមជំសិន
- ក្នុងពេលធ្វើលំហាត់ទាំងនេះ ត្រូវធានាថា អ្នកចូលរួមមិននិយាយអំពីជនពិការឡើយ ប៉ុន្តែត្រូវនិយាយជាមួយនឹងជនពិការ។

ត្រៀមសំណួរសម្ភាសសម្រាប់ភ្ញៀវរូបនេះ។ សួរសំណួរដូចជា ៖

- តើអ្នកមកពីណា? អ្នករស់នៅកន្លែងណា?
- តើអ្នកប្រកបមុខរបរអ្វី ដើម្បីចិញ្ចឹមជីវិត?
- តើអ្នកប្រាស្រ័យទាក់ទងជាមួយមនុស្សផ្សេងទៀតយ៉ាងដូចម្តេច?
- តើមានការលំបាកអ្វីខ្លះក្នុងការប្រាស័យទាក់ទងជាមួយអ្នកដទៃ?
- តើអ្នកចង់ឱ្យគេប្រាស្រ័យទាក់ទងជាមួយអ្នកដោយរបៀបណា?
- តើអ្នកមានដំបូន្មានអ្វីខ្លះ សម្រាប់អ្នកដែលមិនសូវមានបទពិសោធន៍ច្រើនក្នុងការប្រាស្រ័យទាក់ទងជាមួយមនុស្សដូចអ្នក?

## គ). ដំណើរការសម្របសម្រួល

| មេរៀន៤.១<br>ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព | |
|---|---|
| **គោលដៅ** ៖ មេរៀននេះបង្កឱ្យអ្នកចូលរួមមានភាពសកម្ម និងចាប់ផ្តើមគិតអំពីប្រធានបទការប្រាស្រ័យទាក់ទង។ | |
| **រយៈពេល** | ២៥នាទី |

១. ឱ្យអ្នកចូលរួមអង្គុយជារង្វង់។ ខ្សឹបប្រយោគមួយ "ច្រកចូលសម្រាប់រទេះរុញ គឺនៅខាងក្រោយអគារ" ដាក់ត្រចៀកអ្នកដែលអង្គុយជិតអ្នក ហើយឱ្យអ្នកនោះធ្វើដូចគ្នារហូតដល់គ្រប់គ្នា ហើយប្រយោគនេះបានត្រលប់មកវិញ។ បន្ទាប់មកឱ្យអ្នកចុងក្រោយនិយាយឮៗអំពីអ្វីដែលបានឮពីការខ្សឹប។

២. ពន្យល់ពីមេរៀនដែលទទួលបានពីលំហាត់ ៖

- ការប្រាស្រ័យទាក់ទង ក៏ជាការស្តាប់ផងដែរ។
- នៅពេលដែលមនុស្សកាន់តែច្រើន ការបកស្រាយសារទំនងជាមានការប្រែប្រួល។ នៅពេលដែលអ្នកនៅកាន់តែកៀកនឹងប្រភពនៃសារអ្នកកាន់តែអាចស្តាប់ឮសារដែលគេចង់និយាយ។
- គេត្រូវការពេលវេលា ដើម្បីបកស្រាយសារទៅកាន់មនុស្សផ្សេងទៀត។ ប្រសិនបើអ្នកចង់ឱ្យមានការចូលរួមពិតប្រាកដ អ្នកចាំបាច់ត្រូវគិតគូរពីចំណុចនេះ ទើបគេអាចធ្វើការឆ្លើយតបបាន។



៣. ពន្យល់ ៖ ការប្រាស្រ័យទាក់ទង គឺជាដំណើរការមួយ សម្រាប់ឈានទៅដល់ការយល់គ្នាទៅវិញទៅមក ដោយអ្នកចូលរួមត្រូវចែករំលែកព័ត៌មាន គំនិត និងអារម្មណ៍។ បន្ទាប់មកបង្ហាញ តាមរយៈស្លាយ ឬក្រដាសផ្ទាំងធំ។

៤. បញ្ចប់ ដោយនិយាយថា ការប្រាស្រ័យទាក់ទង គឺជាដំណើរការទ្វេទិស។ ការប្រាស្រ័យទាក់ទងអាចកើតឡើងតាមវិធីច្រើនយ៉ាង។

- ការប្រើពាក្យសម្តី ដូចជា ភាសានិយាយ
- ការមិនប្រើពាក្យសម្តី ដូចជា កាយវិការ ទឹកមុខ ទំនាក់ទំនងតាមខ្សែភ្នែក ។ល។
- ការសរសេរ

នៅពេលនិយាយទៅកាន់មនុស្សដែលមានភាពខ្សោយអ្វីមួយ ពេលខ្លះមានការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយពួកគាត់។ ប៉ុន្តែនៅពេលដែលការប្រាស្រ័យទាក់ទងតាមវិធីមួយហាក់បីដូចជាពិបាក គេនៅតែអាចរិះរកវិធីផ្សេងទៀត សម្រាប់ធ្វើការប្រាស្រ័យទាក់ទង។ ឧទាហរណ៍ ប្រសិនបើការប្រាស័យទាក់ទងដោយសរសេរ និងដោយមិនប្រើពាក្យសម្តី ពុំមានប្រសិទ្ធភាពសម្រាប់អ្នកដែលខ្សោយខាងគំហើញនោះ គេអាចប្រើសារជាពាក្យសម្តីឬសំឡេងបាន។ សម្រាប់ជនពិការគ-ថ្លង់ គេអាចប្រើសារជាលាយលក្ខណ៍អក្សរ ឬ គំនូរ ឬកាយវិការដែលអាចមានប្រសិទ្ធភាព។



សារគន្លឹះនៃមេរៀននេះ៖

- ការប្រាស្រ័យទាក់ទង គឺជាដំណើរការទ្វេទិស ហើយក៏តម្រូវឱ្យមានការស្តាប់ផងដែរ។
- មានវិធី ៣ យ៉ាង សម្រាប់ធ្វើការប្រាស្រ័យទាក់ទង ៖
  - ការប្រើពាក្យសម្តីឬការនិយាយ
  - ការប្រើសញ្ញា
  - ការសរសេរ
- ត្រូវមានភាពច្នៃប្រឌិត ប្រសិនបើ របៀបប្រាស្រ័យទាក់ទងមួយពុំមានប្រសិទ្ធភាព សូមសាកល្បងរបៀបមួយផ្សេងទៀត។

នៅមេរៀនបន្តបន្ទាប់ យើងនឹងរៀនសូត្របន្ថែមទៀតពីរបៀបប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលមានភាពខ្សោយប្រភេទខុសៗគ្នា។

| | |
|---|---|
| **មេរៀន៤.២**<br>**របៀបប្រាស្រ័យទាក់ទងជាមួយជនពិការគ-ថ្លង់** | |
| **គោលដៅ ៖** ផ្តល់ឱ្យអ្នកចូលរួមនូវដំបូន្មាន និងវិធីសាស្ត្រសម្រាប់ប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សដែលខ្សោយខាងការស្តាប់។ | |
| **រយៈពេល** | ៥០នាទី |

១. ណែនាំពីលំហាត់នេះ។ ពន្យល់ថា យើងនឹងឆ្លុះបញ្ចាំងពីរបៀបប្រាស្រ័យទាក់ទងជាមួយនឹងជនពិការគ-ថ្លង់ ឬអ្នកដែលមានភាពខ្សោយខាងការស្តាប់ ។



២. ឱ្យអ្នកចូលរួមបែងចែកជាដៃគូ និងធ្វើការចែករំលែកបទពិសោធន៍អំពីការប្រាស្រ័យទាក់ទងជាមួយនឹងជនពិការគ-ថ្លង់ ឬអ្នកដែលពិបាកស្តាប់។ តើពួកគាត់បានធ្វើអ្វីខ្លះ? តើអ្វីខ្លះដែលពួកគាត់គិតថាពិបាក?

៣. ប្រមាណ៥នាទីក្រោយមក ឱ្យអ្នកចូលរួមផ្តល់ព័ត៌មានត្រលប់នៅក្នុងក្រុមធំ។ ពិភាក្សាពីចម្លើយផ្សេងៗ។ គូសបញ្ជាក់ថា ភាពខ្សោយខាងការស្តាប់ពុំមានន័យថា ពួកគាត់មិនអាចប្រាស្រ័យទាក់ទងនោះទេ។ វាមានន័យថា ពួកគាត់ប្រាស្រ័យទាក់ទងតាមបែបផ្សេងខុសពីអ្នកដែលអាចស្តាប់ឮ។ ការប្រាស្រ័យទាក់ទងដោយមិនប្រើពាក្យសម្តី ដូចជា តាមរយៈការសរសេរ ឬការប្រើប្រាស់ភាសាសញ្ញាជាដើម ជាមធ្យោបាយដែលអ្នកខ្សោយខាងការស្តាប់តែងតែចូលចិត្តប្រើ។

៤. សម្ភាសជាមួយនឹងអ្នកដែលខ្សោយខាងការស្តាប់។ ប្រសិនបើអាចធ្វើបាន អញ្ជើញអ្នកដែលខ្សោយខាងការស្តាប់ឱ្យចូលរួម។ ធ្វើការសម្ភាសខ្លីជាមួយពួកគាត់ ដោយអ្នកត្រូវរៀបចំទុកជាមុន។ (សូមមើលសំណួរជាឧទាហរណ៍ នៅខាងដើមជំពូកនេះ)។ ការសម្ភាសនេះមានគោលដៅ ៖

- ដើម្បីស្វែងយល់ថាតើអ្នកដែលខ្សោយខាងការស្តាប់ ប្រាស្រ័យទាក់ទងយ៉ាងដូចម្តេច
- ដើម្បីស្វែងយល់ពីឧបសគ្គធំៗ ដែលពួកគាត់ជួបប្រទះក្នុងការប្រាស្រ័យទាក់ទង
- ដើម្បីស្វែងយល់ពីរបៀបល្អបំផុតក្នុងការនិយាយ និងស្តាប់ចំពោះអ្នកដែលខ្សោយខាងការស្តាប់។

**កំណាត់សម្គាល់ ៖**

ក្រោយការសម្ភាសចប់ ឱ្យអ្នកចូលរួមសួរសំណួរ ដែលពួកគាត់បានសួរទៅកាន់វាគ្មិន។

៥. ពិនិត្យលើផ្ទាំងក្រដាសដែលកត់ត្រាដំបូន្មាន អ្វីដែលល្អបំផុត គឺឱ្យគ្រូបណ្តុះបណ្តាល ដែលជាជនពិការ



ពិនិត្យទៅលើដំបូន្មាន គំនិតយោបល់ នៅលើផ្ទាំងក្រដាសធំ និងបន្ថែមឧទាហរណ៍ងាយៗមួយចំនួន។ ប្រសិនបើអាចឱ្យអ្នកដែលពិការគ-ថ្លង់ ឬពិបាកស្តាប់ រំលេចពីដំបូន្មានសំខាន់ៗជាងគេនៅលើក្រដាសសរសេរដំបូន្មាននេះ។

**ក្រដាសជំនួយស្មារតី ៖ របៀបប្រាស្រ័យទាក់ទងជាមួយនឹងជនពិការគ-ថ្លង់ ឬអ្នកដែលពិបាកស្តាប់**



- ទាក់ទាញការយកចិត្តទុកដាក់របស់ជនពិការគថ្លង់ប្រសិនបើគាត់មិនប្រតិកម្មតបទេនោះសូមប៉ះដៃឬស្មារបស់គាត់ថ្នមៗឬបក់ដៃហៅគាត់។
- សួរថាតើគាត់ចង់បានការប្រាស្រ័យទាក់ទងដោយរបៀបណា។
- ឈរបែរមុខទៅកាន់គាត់។ អ្នកដែលមានពិការភាពខាងការស្តាប់ចង់ឃើញមុខរបស់អ្នក ដើម្បីពួកគាត់អាចអាន(មើល)បបូរមាត់របស់អ្នក និងមើលទឹកមុខរបស់អ្នក។ ឈរត្រឹមកម្ពស់ស្មើគ្នានឹងគាត់(ឧទាហរណ៍ ៖ សូមអង្គុយចុះ ប្រសិនបើគាត់អង្គុយ) កុំដាក់ដៃរបស់អ្នក បាំងមុខរបស់អ្នក។
- ផ្លាស់ទៅកន្លែងស្ងាត់ ដើម្បីកុំឱ្យមានសម្លេងរំខាន ឬមានសម្លេងរំខានតិចតួច។
- ឈរក្បែរគាត់ ដើម្បីឱ្យអ្នកដែលពិបាកស្តាប់ អាចស្តាប់ឮអ្នកនិយាយបានប្រសើរបំផុត។
- មានភ្លើងបំភ្លឺគ្រប់គ្រាន់ ដើម្បីឱ្យគាត់អាចមើលឃើញអ្នកបានច្បាស់។
- និយាយច្បាស់ៗ និងក្នុងកម្រិតសំឡេងធម្មតា។ សូមកុំស្រែក។
- សួរថា តើគាត់យល់ពីអ្វីដែលអ្នកបាននិយាយដែរឬទេ ដូចជាឱ្យគាត់ផ្តល់ព័ត៌មានត្រលប់។
- និយាយសារសំខាន់ៗឡើងវិញ ដូចជា សរសេរសារទាំងនេះ ជាដើម។
- ប្រើប្រាស់ទឹកមុខ និងកាយវិការ ដើម្បីគាំទ្រដល់អ្វីដែលអ្នកនិយាយ។
- និយាយទៅជនពិការគ-ថ្លង់ដោយផ្ទាល់សូមកុំនិយាយទៅកាន់សមាជិកគ្រួសារឬអ្នកបកប្រែរបស់គាត់។
- នៅក្នុងអគាររបស់អ្នក សូមដាក់សញ្ញាឱ្យបានច្បាស់ ដើម្បីជួយឱ្យជនពិការគ-ថ្លង់និងអ្នកពិបាកស្តាប់ដឹងពីកន្លែងដែលត្រូវទៅ។
- ផ្តល់ព័ត៌មានជាលាយល័ក្ខណ៍អក្សរ ប្រសិនបើគាត់អាចអាន និងសរសេរបាន។ ត្រៀមប៊ិច និងក្រដាស ក្នុងករណីដែលអ្នកចាំបាច់ត្រូវប្រាស្រ័យទាក់ទងដោយសរសេរ។

៦. ប្រសិនបើអាចធ្វើបាន សូមអញ្ជើញវាគ្មិនឱ្យបង្រៀនអ្នកចូលរួមពីសញ្ញាមួយចំនួន ដែលគេឧស្សាហ៍ប្រើក្នុងមូលដ្ឋាន។ សញ្ញាទាំងនេះមិនគ្រប់គ្រាន់ ដើម្បីឱ្យមានការសន្ទនាស៊ីជម្រៅនោះឡើយ ប៉ុន្តែធ្វើឱ្យគេងាយស្រួលក្នុងការចូលរួម។

៧. ប្រាប់អ្នកចូលរួមពីទីកន្លែង ដែលអង្គការមួយចំនួនធ្វើការជាមួយនឹងអ្នកដែលខ្សោយខាងការស្តាប់ ៖

**អង្គការគ្រួសារថ្មី**

http://www.krousar-thmey.org/

ផ្ទះលេខ៤ ផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ២២០ ២៦៣

**កម្មវិធីអភិវឌ្ឍន៍ជនពិការថ្លង់** (DDP):

http://www.ddp-cambodia.org/

ផ្ទះលេខ៧អា ផ្លូវលេខ១០១ សង្កាត់បឹងត្របែក រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៩៨៧ ៩៣១/០១៧ ៩៩៣ ៣២១

| មេរៀន៤.៣<br>របៀបប្រាស្រ័យទាក់ទងជាមួយជនពិការខាងសតិបញ្ញា | |
|---|---|
| **គោលដៅ** ៖ ផ្តល់ឱ្យអ្នកចូលរួមនូវគំនិត និងរបៀបប្រាស្រ័យទាក់ទងជាមួយជនពិការខាងសតិបញ្ញា។ | |
| **រយៈពេល** | ៥០នាទី |

១. ណែនាំពីលំហាត់។ ពន្យល់ថា នៅក្នុងលំហាត់នេះ យើងនឹងរៀនសូត្របន្ថែមទៀតអំពីរបៀបប្រាស្រ័យទាក់ទងជាមួយនឹងជនពិការខាងសតិបញ្ញា។



២. ឱ្យអ្នកចូលរួមបែងចែកជាគូ និងចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងជាមួយជនពិការខាងសតិបញ្ញា។ តើពួកគាត់បានធ្វើអ្វីខ្លះ? តើចំណុចអ្វីខ្លះដែលពិបាកសម្រាប់ពួកគាត់? ៥នាទីក្រោយមកឱ្យអ្នកចូលរួមផ្តល់ព័ត៌មានត្រលប់ក្នុងក្រុមធំ។ ពិភាក្សាចម្លើយ។

៣. ការសម្ភាសជាមួយនឹងឪពុកម្តាយរបស់អ្នកដែលមានពិការភាពខាងសតិបញ្ញា។ ប្រសិនបើ អាចឱ្យឪពុកម្តាយរបស់អ្នកដែលមានពិការភាពខាងសតិបញ្ញា ចូលរួមនៅក្នុងការបណ្តុះបណ្តាលត្រង់មេរៀននេះ។ រៀបចំការសម្ភាសមុនមេរៀននេះ (សូមមើលសំណួរជាឧទាហរណ៍ នៅខាងដើមជំពូកនេះ)។ បន្ទាប់មក រៀបចំការសម្ភាសតូចមួយ។ ការសម្ភាសនេះមានគោលដៅ៖

- ស្វែងយល់ថាតើអ្នកដែលខ្សោយខាងសតិបញ្ញាប្រាស្រ័យទាក់ទងយ៉ាងដូចម្តេច
- ស្វែងយល់ពីឧបសគ្គធំៗបំផុត ដែលពួកគាត់ជួបប្រទះ ក្នុងការប្រាស្រ័យទាក់ទង
- ស្វែងយល់ពីរបៀបនិយាយទៅកាន់អ្នកដែលខ្សោយខាងសតិបញ្ញាឱ្យបានល្អបំផុត។

**កំណត់សម្គាល់ ៖**

ក្រោយការសម្ភាសន៍ចប់ ស្នើអ្នកចូលរួមឱ្យសួរសំណួរដែលពួកគាត់មានទៅកាន់វាគ្មិន។



៤. ពិនិត្យក្រដាសជំបូន្មាន។ ឱ្យគ្រូបណ្តុះបណ្តាលដែលជាជនពិការបង្ហាញជំបូន្មាន ដែលសរសេរលើក្រដាស ហើយភ្ជាប់ជំបូន្មានទាំងនេះជាមួយនឹងការសម្ភាសជាមួយនឹងឪពុកម្តាយ។

**ក្រដាសជំបូន្មាន ៖ របៀបប្រាស្រ័យទាក់ទងជាមួយអ្នកដែលមានពិការភាពខាងសតិបញ្ញា**

- ត្រូវបង្ហាញនូវភាពជាក់ស្តែង
- ចំណាយពេលតាមសម្រួល ហើយបង្កើតនូវការជឿទុកចិត្តគ្នាសិន ដើម្បីឱ្យគាត់មានអារម្មណ៍កក់ក្តៅជាមួយអ្នក
- និយាយឱ្យបានច្បាស់ៗ និងប្រើប្រាស់ប្រយោគខ្លី និងពាក្យពេចន៍ងាយៗ
- និយាយឡើងវិញពីអ្វីដែលអ្នកបាននិយាយ ឬប្រើពាក្យពេចន៍ផ្សេង ដើម្បីបញ្ជាក់ពីអ្វីដែលអ្នកបាននិយាយ

- ប្រើប្រាស់រូបភាព
- កុំប្រើសំឡេងដូចក្មេង ឬនិយាយបំផ្លើស
- ប្រើឯកសារដែលងាយស្រួលអាន អមដោយសារងាយៗ និងប្រយោគខ្លីៗ
- រកកន្លែងស្ងាត់ សម្រាប់និយាយ
- ប្រើកាយវិការ និងទឹកមុខ ឧទាហរណ៍ ៖ ធ្វើទឹកមុខសោកសៅ នៅពេលដែលអ្នកកំពុងនិយាយអ្វីមួយដែលមិនសប្បាយចិត្ត
- បញ្ជាក់ជាមួយគាត់ថាតើគាត់យល់ពីអ្វីដែលអ្នកកំពុងនិយាយដែរឬទេ

៥. អ្នកដែលមានជំនាញធ្វើការជាមួយនឹងកុមារ ដែលមានពិការភាពខាងការរៀនសូត្រ ៖ បង្ហាញអំពីអង្គការសង្គមស៊ីវិល ដែលមានជំនាញខ្ពស់ក្នុងការធ្វើការជាមួយនឹងកុមារ ដែលមានពិការភាពខាងសតិបញ្ញា។ គេអាចទំនាក់ទំនងអង្គការទាំងនេះ ដើម្បីទទួលបានព័ត៌មានបន្ថែម ៖

**មូលនិធិកុមារពិការ**

http://www.komarpikar.org/

កុដលេខ៤៣(ក្នុងវត្តសារាវ័ន្ត) ផ្លូវលេខ១៧៨ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ២១០ ៤៤៧

**អង្គការ** DDSP

http://ddspcambodia.org/

ប្រអប់សំបុត្រ ៩២០៦ ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា

ទូរស័ព្ទ ៖ ០៥២ ៩៥១ ៤៩៥

**អង្គការមនុស្សលោកថ្មី**

ផ្ទះលេខ១៩ ផ្លូវលេខ៣១៧ សង្កាត់បឹងកក់១ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ២២០ ២៦៣

| មេរៀន ៤.៤<br>របៀបប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលខ្សោយគំហើញ | |
|---|---|
| **រយៈពេល** | ៥០នាទី |

១. គ្រូបណ្តុះបណ្តាលពន្យល់ថា នៅក្នុងលំហាត់នេះយើងនឹងរៀនសូត្របន្ថែមទៀតអំពីរបៀបប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលខ្សោយខាងគំហើញ។

២. ឱ្យអ្នកចូលរួមបែកចែកជាដៃគូ និងចែករំលែកពីបទពិសោធន៍ពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលខ្សោយខាងគំហើញ។ តើពួកគាត់បានធ្វើអ្វីខ្លះ? តើចំណុចអ្វីខ្លះដែលពិបាកសម្រាប់ពួកគាត់?(ដៃគូនីមួយៗពិភាក្សារយៈពេល៥នាទី)។ ដៃគូនីមួយៗចែករំលែកលទ្ធផលដល់ក្រុមធំ។



៣. ការសម្ភាសជាមួយនឹងឪពុកម្តាយរបស់អ្នកដែលខ្សោយខាងគំហើញ(ប្រសិនបើ អាចអញ្ជើញអ្នកដែលខ្សោយខាងគំហើញឱ្យចូលរួមនៅក្នុងការបណ្តុះបណ្តាលត្រង់វគ្គនេះ។ គ្រូបណ្តុះបណ្តាលត្រូវសាកល្បងសម្ភាសជាមួយវាគ្មិន(អ្នកខ្សោយខាងគំហើញ)ជាមុនសិន មុននឹងសម្ភាសន៍ជាផ្លូវការនៅចំពោះមុខអ្នកចូលរួម(សូមមើលសំណួរជាឧទាហរណ៍ នៅខាងដើមជំពូកនេះ)។ ការសម្ភាសនេះមានគោលដៅ ៖

- ស្វែងយល់ថាតើអ្នកដែលខ្សោយខាងគំហើញធ្វើការប្រាស្រ័យទាក់ទងយ៉ាងដូចម្តេច
- ស្វែងយល់ពីឧបសគ្គធំៗ ដែលពួកគាត់ជួបប្រទះក្នុងការប្រាស្រ័យទាក់ទង
- ស្វែងយល់ពីរបៀបនិយាយទៅកាន់អ្នកដែលខ្សោយខាងគំហើញឱ្យបានល្អបំផុត

**កំណត់សម្គាល់ ៖**

ក្រោយការសម្ភាសចប់ អញ្ជើញអ្នកចូលរួមឱ្យសួរសំណួរ ដែលពួកគាត់មានទៅកាន់វាគ្មិន។

៤. ពិនិត្យក្រដាសជំបូន្មាន។ ឱ្យគ្រូបណ្តុះបណ្តាលដែលជាជនពិការបង្ហាញជំបូន្មានដែលសរសេរលើក្រដាស និងបន្ថែមឧទាហរណ៍ជាក់ស្តែង ហើយភ្ជាប់ជំបូន្មានទាំងនេះជាមួយនឹងអ្វីដែលត្រូវបាន លើកឡើងនៅក្នុងការសម្ភាសនេះ។ អញ្ជើញវាគ្មិនឱ្យចែករំលែកគំនិតរបស់ខ្លួនអំពីជំបូន្មានសំខាន់ៗ។



**ក្រដាសជំបូន្មាន ៖ របៀបប្រាស្រ័យទាក់ទងជាមួយអ្នកដែលខ្សោយគំហើញ**

- ណែនាំខ្លួនអ្នក ដើម្បីឱ្យអ្នកដែលខ្សោយខាងគំហើញស្គាល់ថា អ្នកជាអ្នកណា។
- ប្រាប់គាត់ ប្រសិនបើអ្នកទៅឆ្ងាយពីគាត់។ សូមកុំចាកចេញពីគាត់ដោយមិនបានប្រាប់គាត់ថាអ្នកនឹងចាកចេញពីគាត់។
- រៀបរាប់ពីទីកន្លែងដែលអ្នកកំពុងនៅ និងអ្វីដែលអ្នកឃើញឱ្យគាត់ដឹង។
- ត្រូវរៀបរាប់ឱ្យបានជាក់លាក់។ និយាយថា "តុនៅចំពីមុខអ្នក" មិនមែន "តុនៅទីនេះ" នោះទេ។

- នៅពេលដែលអ្នកស្ថិតនៅក្នុងក្រុម សូមប្រាប់ពួកគាត់ពីអ្នកដែលកំពុងមានវត្តមាននៅក្នុងក្រុម។
- សូមកុំផ្លាស់ប្តូរទីតាំងរបស់វត្ថុនានា ឬទុកអ្វីមួយនៅលើផ្លូវដែលអាចធ្វើឱ្យគេដើរជាន់។
- នៅពេលដែលអ្នកនិយាយក្នុងក្រុម សូមប្រើប្រាស់ឈ្មោះរបស់គាត់នៅពេលដែលអ្នកចង់និយាយទៅគាត់។
- ជានិច្ចកាល សូមនិយាយដោយផ្ទាល់ទៅគាត់។ សូមកុំប្រើមនុស្សទីពីឱ្យឆ្លើយសំណួររបស់អ្នក។
- និយាយបែបធម្មតា និងច្បាស់ៗ។ អ្នកមិនចាំបាច់ស្រែកនោះទេ។
- ចៀសវាងកន្លែងដែលមានសំឡេងរំខាន ដើម្បីឱ្យគាត់អាចស្តាប់អ្នកបានច្បាស់។



- ជានិច្ចកាល ត្រូវសួរសិនថាតើគាត់ចង់ឱ្យគេជួយដែរឬទេ។ សូមកុំជួយអ្នកណាម្នាក់ដោយមិនបានសួរគាត់ជាមុន។
- សម្រាប់អ្នកដែលខ្សោយខាងគំហើញ សូមប្រើប្រាស់សញ្ញា និងឯកសារដែលច្បាស់ៗ អាចជា អក្សរធំៗ ឬអក្សរដែលអ្នកអាចស្ទាបដឹងបាន។
- សម្រាប់អ្នកដែលពិការភ្នែក ហើយអាចអានអក្សរស្ទាបបាន អ្នកអាចផ្តល់ព័ត៌មានលាយលក្ខណ៍អក្សរដោយប្រើអក្សរស្ទាប។
- បច្ចេកទេសក្នុងការនាំផ្លូវអ្នកពិការគំហើញ ដូចជាការដើរទន្ទឹមគាត់ក្នុងទីធ្លាទូលាយ និងដើរពីមុខគាត់ក្នុងទីធ្លាចង្អៀតក្នុងករណីឡើងជណ្តើរ ឬចូលជណ្តើរយន្តត្រូវពន្យល់គាត់ឱ្យបានច្បាស់ និងនិយាយមួយៗរៀបរាប់ប្រាប់គាត់។

៥. អ្នកដែលមានជំនាញធ្វើការជាមួយនឹងអ្នកដែលខ្សោយគំហើញ ៖ ពន្យល់ថា មានអង្គការសង្គមស៊ីវិលជាច្រើន ដែលមានជំនាញខ្ពស់ក្នុងការធ្វើការងារជាមួយនឹងមនុស្សធំ និងកុមារ ដែលខ្សោយខាងគំហើញ។ គេអាចទំនាក់ទំនងអង្គការទាំងនេះ ដើម្បីទទួលបានព័ត៌មានបន្ថែម។

**អង្គការគ្រួសារថ្មី**

http://www.krousar-thmey.org/

ផ្ទះលេខ ៤ ផ្លូវលេខ ២៥៧ ទឹកល្អក់ ១ ទួលគោក ភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ២២០ ២៦៣

**សមាគមជនពិការភ្នែកនៅកម្ពុជា** (ABC)

http://www.cambodianblindassociation.org/

ផ្ទះលេខ ១១ F ផ្លូវលេខ ៦០C សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦១៨ ៨៨២

**មូលនិធិ ហ្វ្រេដ ហូឡូវ** Fred Hollows

http://cambodia.hollows.org/

ទូរស័ព្ទ ៖ ០២៣ ៩៨៧ ៨៣១

| មេរៀន៤.៥<br>សង្ខេបមេរៀនជំពូកទី៤ | |
|---|---|
| រយៈពេល | ៥នាទី |



១. ផ្តល់ការសង្ខេបនៅចុងមេរៀន និងមើលតាមសៀវភៅណែនាំសម្រាប់អ្នកចូលរួម។ បង្ហាញតាមរយៈ ស្លាយ ឬក្រដាសផ្ទាំងធំ តាមខ្លឹមសារដូចខាងក្រោម ៖

- ការប្រាស្រ័យទាក់ទងគឺជាដំណើរការ ដើម្បីឱ្យមានការយល់គ្នាទៅវិញទៅមក ជាមួយនឹងអ្នកចូលរួម ដែលធ្វើការចែករំលែកព័ត៌មាន គំនិត និងអារម្មណ៍នានា។ ការប្រាស្រ័យទាក់ទង គឺជាដំណើរការទ្វេទិស។
- ការប្រាស្រ័យទាក់ទង អាចកើតឡើងតាមវិធី៣ ដោយប្រើជាពាក្យសម្តីឬនិយាយ ប្រើជាសញ្ញា និងប្រើជាលាយលក្ខណ៍អក្សរ។
- មានអង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ដែលមានជំនាញខ្ពស់ផ្នែកពិការភាពប្រភេទខុសៗគ្នា។ អង្គការទាំងនេះអាចផ្តល់ព័ត៌មានបន្ថែមទៀតបាន។
- ចំណុចដែលសំខាន់ គឺត្រូវប្រុងប្រយ័ត្ននៅពេលដែលយើងប្រតិកម្មតបចំពោះជនពិការ។ ដោយសារតែការប្រាស្រ័យទាក់ទងជារឿងពិបាក ប៉ុន្តែមិនមែនមានន័យថា យើងមិនអាចប្រាស្រ័យទាក់ទងនោះទេ។

| មេរៀន៤.៦<br>ការវាយតម្លៃប្រចាំថ្ងៃ | |
|---|---|
| គោលដៅ ៖ | ដើម្បីឱ្យគ្រូបង្គោលទទួលបានព័ត៌មានត្រលប់ពីអ្នកចូលរួមនូវអ្វីដែលពួកគាត់ចេញចិត្ត និងមិនពេញចិត្តកែលម្អការបណ្តុះបណ្តាលនៅថ្ងៃបន្ទាប់។ |
| រយៈពេល | ១៥នាទី |



១. ការអនុវត្តលំហាត់វាយតម្លៃ ៖

- គ្រូបណ្តុះបណ្តាលគូរតារាងដែលមានរូបភាពដូចខាងក្រោម ដាក់លើក្រដាសផ្ទាំងរួចបិទលើក្តារខៀន
- ចែកក្រដាសកាតពណ៌ឱ្យសិក្ខាកាមម្នាក់២សន្លឹក បន្ទាប់មកឱ្យពួកគាត់សរសេរ ៖
  - ក្រដាសកាតពណ៌ទី១ អំពីអ្វីដែលគាត់ចូលចិត្តនៅថ្ងៃនេះ និង
  - ក្រដាសកាតពណ៌ទី២ អំពីអ្វីដែលអាចកែលម្អ។
- អញ្ជើញអ្នកចូលរួមឱ្យយកក្រដាសកាតពណ៌របស់ខ្លួនទៅបិទលើក្រដាសផ្ទាំងធំដែលបានត្រៀមរួច។

**កំណត់សម្គាល់ ៖**

សូមតម្រូវឱ្យពួកគាត់សរសេរឱ្យបានជាក់លាក់ និងពន្យល់ពីមូលហេតុដែលពួកគាត់ចូលចិត្ត ឬចង់កែលម្អអ្វីមួយ។

|  |  |
| --- | --- |
| | |



២. ជម្រាបអ្នកចូលរួម ដែលត្រូវរំលឹកមេរៀនឡើងវិញនៅព្រឹកថ្ងៃបន្ទាប់ ដើម្បីឱ្យពួកគាត់ត្រៀមខ្លួនឱ្យហើយសម្រាប់ព្រឹកថ្ងៃស្អែក។

៣. ស្នើឱ្យអ្នកចូលរួមដែលមានលទ្ធផលភាពអាចឱ្យយកកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ខ្លួនមកជាមួយផងសម្រាប់ថ្ងៃស្អែក។

៤. អរគុណដល់អ្នកចូលរួម និងវាគ្មិនសម្រាប់ការចូលរួមថ្ងៃនេះ។

៥. នៅពេលដែលអ្នកចូលរួមចេញទៅផ្ទះអស់ហើយ គ្រូបណ្តុះបណ្តាលសូមមើលក្រដាសកាតពណ៌( លទ្ធផល )វាយតម្លៃ។ ផ្អែកទៅតាមព័ត៌មានត្រលប់នេះ សូមគិតពីអ្វីដែលអ្នកអាចធ្វើបានតាមរបៀបផ្សេងទៀតនៅពេលក្រោយ។

# ជំពូកទី៥

# ការបង្កើតបរិស្ថានដែលគ្មាន

# ឧបសគ្គរាំងដល់ជនពិការ

# ជំពូកទី៥

# ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ជនពិការ

## ក). សេចក្តីពិពណ៌នា

ជំពូកនេះនឹងផ្តោតជាសំខាន់លើការបង្កភាពងាយស្រួលក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់ជនពិការ។ អ្នកចូលរួមដែលមានឥទ្ធិពល និងកាតព្វកិច្ច ត្រូវធានាថា ទីកន្លែងសាធារណៈក្នុងមូលដ្ឋានរបស់ខ្លួន មានភាពងាយស្រួលប្រើប្រាស់សម្រាប់ជនពិការ។

នៅចុងបញ្ចប់នៃជំពូកនេះ អ្នកចូលរួមនឹង ៖

- យល់ដឹងអំពីបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ការប្រើប្រាស់សេវាសម្រាប់ជនពិការ
- អាចបង្ហាញអំពីហេដ្ឋារចនាសម្ព័ន្ធដែលមានការបង្កភាពងាយស្រួលសម្រាប់ជនពិការ
- អាចគិតរកដំណោះស្រាយដែលអាចអនុវត្តបាន ដើម្បីលើកកម្ពស់ដល់ការបង្កភាពងាយស្រួលសម្រាប់ជនពិការ
- កំណត់បានពីតួនាទីផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងការលើកកម្ពស់ដល់ការបង្កភាពងាយស្រួលសម្រាប់ជនពិការ

## ខ). មាតិកាមេរៀន

| លរ | មេរៀន | រយៈពេល | សម្ភារៈ និងឯកសារ |
|---|---|---|---|
| ៥.១. | ការរំលឹកមេរៀន | ២០នាទី | |
| ៥.២. | អត្ថន័យនៃការបង្កភាពងាយស្រួលសម្រាប់ជនពិការ | ៤០នាទី | ក្រដាសផ្ទាំងធំ |
| ៥.៣. | ការអនុវត្តជាក់ស្តែងលើការបង្កភាពងាយស្រួលសម្រាប់ជនពិការ | ៦០នាទី | បញ្ជីសម្រាប់ផ្ទៀងផ្ទាត់<br>ម៉ែត្រសម្រាប់វាស់ចំនួន ៣ |
| ៥.៤. | ដំណោះស្រាយជាក់ស្តែង ដើម្បីកែលម្អឱ្យមានការបង្កភាពងាយស្រួលសម្រាប់ជនពិការ | ៤០នាទី | ក្រដាសផ្ទាំងធំ |
| ៥.៥. | សង្ខេបមេរៀនជំពូកទី៥ | ០៥នាទី | សៀវភៅណែនាំសម្រាប់អ្នកចូលរួម |
| **សរុប** | | **១៦៥នាទី** | |

នៅក្នុងជំពូកនេះ អ្នកចូលរួមនឹងធ្វើការពិនិត្យលើការបង្កភាពងាយស្រួលក្នុងការប្រើប្រាស់អគារ ដែលស្ថិតនៅជិតទីកន្លែងបណ្តុះបណ្តាល។ គោលដៅរបស់ជំពូកនេះ គឺដើម្បីឱ្យអ្នកចូលរួមយល់ថាមនុស្សផ្សេងៗគ្នាមានបទពិសោធន៍ខុសៗគ្នា ទោះជាស្ថិតក្នុងមជ្ឈដ្ឋានតែមួយក៏ដោយ។ អ្នកចូលរួមអាចប្រើប្រាស់បទពិសោធន៍នេះម្តងទៀតនៅកន្លែងធ្វើការរបស់ពួកគេ។

ការត្រៀមរៀបចំជាមុន ៖

- អញ្ជើញជនពិការ ដូចជា អ្នកដែលមានទំនាក់ទំនងជាមួយនឹងអង្គការជនពិការ ឱ្យចូលរួមនៅក្នុងវគ្គនេះ។ ពន្យល់ប្រាប់ពួកគេពីគោលដៅរបស់វគ្គនេះ និងរបៀបដែលពួកគេនឹងត្រូវស្នើឱ្យជួយបង្ហាញពីឧបសគ្គទាក់ទងនឹងផ្នែករូបវន្ត ដែលជនពិការជួបប្រទះ។
- ស្វែងរកអគារសម្រាប់ធ្វើការអនុវត្តលើការបង្កភាពងាយស្រួលក្នុងការប្រើប្រាស់។ អគារនេះ គួរតែជាអគារសាធារណៈ។ ឧទាហរណ៍ អគាររបស់ឃុំ ឬស្រុក អគារសាលារៀន ឬបង្គន់ ឬអគារផ្សេងទៀត ស្ថិតនៅក្បែរទីកន្លែងបណ្តុះបណ្តាល។
- បើមិនមានអគារនៅក្បែរទីកន្លែងបណ្តុះបណ្តាលទេនោះ ត្រូវគ្រោងត្រៀមរៀបចំមធ្យោបាយធ្វើដំណើរ ឬក៏ពេលវេលាសម្រាប់ធ្វើការអនុវត្តសាកល្បងនេះ។
- ធ្វើការអនុវត្តសាកល្បងខ្លួនឯង ដើម្បីឱ្យដឹងថា តើអគារនេះមានទំហំធំគ្រប់គ្រាន់សម្រាប់ឱ្យជនពិការអាចផ្លាស់ទី(ចេញចូល)ដែរឬទេ។
- ការអនុវត្តសាកល្បងនេះ អាចជួយឱ្យអ្នកចូលរួមដឹងថា មនុស្សផ្សេងៗគ្នាមានបទពិសោធន៍ផ្សេងៗគ្នា និងមានតម្រូវការផ្សេងៗគ្នា។

**គ). ដំណើរការសម្របសម្រួល**

| **មេរៀន៥.១**<br>**ការរំលឹកមេរៀន** | |
|---|---|
| **គោលដៅ ៖**<br>• លើកទឹកចិត្តអ្នកចូលរួមឱ្យប្រើប្រាស់វិធីសាស្ត្របែបច្នៃប្រឌិត ដើម្បីផ្តល់សាររំលឹកមេរៀនឡើងវិញ<br>• ផ្តល់សារគន្លឹះរបស់មេរៀនមុនៗ ដើម្បីរំលឹកអ្នកចូលរួមពីមេរៀនសំខាន់ៗបំផុត<br>• ពិនិត្យមើលថាអ្នកចូលរួមបានយល់មេរៀនមុនៗដែរឬទេ | |
| **រយៈពេល** | ២០នាទី |

១. គ្រូបណ្តុះបណ្តាលស្វាគមន៍អ្នកចូលរួម ព្រមទាំង ជម្រាបអ្នកចូលរួមជាមុនថា ជាដំបូងយើងនឹងរំលឹកមេរៀនពីថ្ងៃមុនឡើងវិញ។

២. គ្រូបណ្តុះបណ្តាលឱ្យអ្នកចូលរួមស្ម័គ្រចិត្តចំនួនពីរនាក់ រំលឹកមេរៀនពីថ្ងៃមុនឡើងវិញ ដើម្បីបង្ហាញទៅកាន់ក្រុម។ បន្ទាប់មក គ្រូបណ្តុះបណ្តាលត្រូវកត់សម្គាល់អំពីសារគន្លឹះទាំងអស់ដែលបានបង្ហាញ។ ប្រសិនបើ មានការខ្វះខាតលើសារគន្លឹះណាមួយ គ្រូបណ្តុះបណ្តាលអាចបំពេញបន្ថែម និងសួរសំណួរទៅអ្នកចូលរួមផ្សេងទៀត ដើម្បីបំពេញបន្ថែម។

| មេរៀន៥.២<br>អត្ថន័យនៃការបង្កភាពងាយស្រួលសម្រាប់ជនពិការ | |
|---|---|
| **គោលដៅ ៖** ស្វែងយល់អំពីអត្ថន័យនៃការបង្កភាពងាយស្រួលសម្រាប់ជនពិការ។ | |
| **រយៈពេល** | ៤០នាទី |

១. គ្រូបណ្តុះបណ្តាលពន្យល់លំហាត់នេះ ដោយប្រាប់អ្នកចូលរួមថា យើងនឹងគិតពីការបង្កភាពងាយស្រួលសម្រាប់ជនពិការ និងពិភាក្សាថាតើវាមានន័យយ៉ាងដូចម្តេច។ ដូចដែលបានពិភាក្សាគ្នានៅមេរៀនពាក់ព័ន្ធនឹងឧបសគ្គ(ចង្អុលក្រដាសផ្ទាំងធំពាក់ព័ន្ធនឹងឧបសគ្គ) ការបង្កភាពងាយស្រួលសម្រាប់ជនពិការគឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គនានាដែលជនពិការតែងតែជួបប្រទះ។

២. គ្រូបណ្តុះបណ្តាលប្រមូលគំនិតអំពីលទ្ធភាព និងការបង្កភាពងាយស្រួលសម្រាប់ជនពិការ ដោយឱ្យអ្នកចូលរួមផ្តល់គំនិតអំពីអ្វីដែលហៅថា លទ្ធភាព និងការបង្កភាពងាយស្រួលសម្រាប់ជនពិការ។ ផ្អែកទៅតាមគំនិតដែលផ្តល់ដោយអ្នកចូលរួម រួចពិភាក្សាអំពីអ្វីដែលគិតថាជាការបង្កភាពងាយស្រួលសម្រាប់ជនពិការសម្រាប់ការធ្វើដំណើរចេញ ឬចូលនៅអាគារសាធារណៈ។



និយមន័យនៃការបង្កភាពងាយស្រួលសម្រាប់ជនពិការសម្រាប់ការធ្វើដំណើរចេញ ឬចូលនៅអាគារសាធារណៈ មានន័យថា មនុស្សម្នាក់អាច ៖

- ផ្លាស់ទីដោយសេរីដោយពុំមានឧបសគ្គ
- ផ្លាស់ទីដោយម្ចាស់ការខ្លួនឯង(ដោយពុំមានជំនួយផ្ទាល់ពីអ្នកដទៃ)
- ផ្លាស់ទីដោយមានទំនុកចិត្ត និងប្រកបដោយការគោរព។

៣. ការបំផុសគំនិត



- គ្រូបណ្តុះបណ្តាលសួរសំណួរទៅអ្នកចូលរួមក្នុងក្រុមធំ "តើជនដែលមានភាពខ្សោយផ្នែករាងកាយត្រូវការការបង្កភាពងាយស្រួលយ៉ាងដូចម្តេច ?"
- ចម្លើយរបស់អ្នកចូលរួមអាចលើកឡើងថា៖ អ្នកប្រើប្រាស់រទេះត្រូវការជម្រាលដើម្បីចូលទៅក្នុងអគារ។
- បន្ទាប់មក គ្រូបណ្តុះបណ្តាលលើកឡើងថា "ពេលខ្លះ បើទោះបីជាមានជម្រាលក៏ដោយ ក៏ជម្រាលទាំងនេះប្រហែលជាមិនអាចប្រើបាន" ដូចជាជម្រាលមួយចំនួនខាងក្រោម មិនអាចប្រើប្រាស់បាន និងជម្រាលមួយចំនួនទៀតងាយស្រួលប្រើប្រាស់។

## ឧទាហរណ៍ ៖ មិនអាចចេញចូលបាន



**មូលហេតុ៖**

- ជម្រាលចោទពេក
- ពុំមានបង្កាន់ដៃ
- ផ្ទៃមិនរាបស្មើ

**លទ្ធផល៖**

- ពុំអាចប្រើប្រាស់បាន សម្រាប់ជនពិការ
- អាចបង្កឱ្យមានគ្រោះថ្នាក់

## ឧទាហរណ៍ ៖ មានភាពងាយស្រួលចេញចូល



៤. គ្រូបណ្តុះបណ្តាលសួរថា តើការបង្កភាពងាយស្រួលសម្រាប់ជនពិការ ដែលខ្សោយគំហើញត្រូវការជាអ្វី? តើការបង្កភាពងាយស្រួលសម្រាប់ជនពិការដែលខ្សោយបញ្ញាត្រូវការជាអ្វី? ផ្អែកលើ ចម្លើយរបស់អ្នកចូលរួម គ្រូបណ្តុះបណ្តាលទាញជាសេចក្តីសន្និដ្ឋានអំពីតម្រូវការនៃការបង្កភាពងាយស្រួលសម្រាប់ប្រភេទពិការនីមួយៗ បន្ទាប់មក បង្ហាញខ្លឹមសារមេរៀន "តម្រូវការក្នុងការបង្កភាពងាយស្រួល" តាមរយៈស្លាយ។

**កំណត់សម្គាល់** ៖

ចំណាយពេលខ្លះ ដើម្បីពិភាក្សាអំពីតម្រូវការផ្សេងៗពាក់ព័ន្ធនឹងការបង្កភាពងាយស្រួលសម្រាប់ជនពិការដែលមានពិការភាពខុសៗគ្នា និងលើកទឹកចិត្តអ្នកចូលរួមលើកឡើងពីតម្រូវការពាក់ព័ន្ធនឹងលទ្ធភាពទទួលបាន និងការបង្កភាពងាយស្រួល។

៥. គ្រូបណ្តុះបណ្តាលបញ្ជាក់ប្រាប់អ្នកចូលរួមថា ការដោះស្រាយចំពោះការបង្កភាពងាយ ស្រួលសម្រាប់ជនពិការ នៅដំណាក់កាលរៀបចំផែនការគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ដូចជា អគារ ឬអណ្តូង ត្រូវការចំណាយថវិកាតិចជាង ការចំណាយទៅលើការកែលម្អឱ្យប្រសើរនូវការបង្កភាពងាយស្រួលសម្រាប់ជនពិការក្នុងអគារដែលសាងសង់រួច។ ដើម្បីពិនិត្យមើលថា តើកន្លែងអ្វីមួយមានភាពងាយស្រួលប្រើប្រាស់ ឬអត់នោះ គេអាចធ្វើការត្រួតពិនិត្យងាយៗមួយចំនួនបាន។ ពេលខ្លះ ការបង្កភាពងាយស្រួលសម្រាប់ជនពិការអាចកែលម្អ តាមរយៈការផ្លាស់ប្តូរសំណង់ **ឧទាហរណ៍ ៖** ការសាងសង់ជម្រាលបេតុង។ ពេលខ្លះគេអាចកែលម្អភាពងាយស្រួលចេញចូល តាមរយៈការធ្វើការផ្លាស់ប្តូរដាក់លាក់សម្រាប់មនុស្សណាម្នាក់ **ឧទាហរណ៍ ៖** ការរៀបចំក្តារសម្រាប់ដាក់ជាប់នឹងជណ្តើរ នៅពេលដែលមានអ្នកជិះរទេះចូលមក។

៦. គ្រូបណ្តុះបណ្តាលឱ្យអ្នកចូលរួមអានរៀងៗខ្លួននូវ "បញ្ជីផ្ទៀងផ្ទាត់លើការបង្កភាពងាយស្រួលសម្រាប់ជនពិការ ក្នុងសៀវភៅណែនាំសម្រាប់អ្នកចូលរួម។ គ្រូបណ្តុះបណ្តាលបញ្ជាក់ថា បញ្ជីផ្ទៀងផ្ទាត់ការបង្កភាពងាយស្រួលសម្រាប់ជនពិការនេះ ផ្អែកទៅតាមគោលការណ៍ណែនាំស្តីពីការបង្កភាពងាយស្រួលសម្រាប់ជនពិការរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ។

**ឧបសម្ព័ន្ធ ទី៧**

៧. ការបង្ហាញ**សារគន្លឹះ**របស់មេរៀនតាមរយៈស្លាយ ដែលមានខ្លឹមសារដូចខាងក្រោម ៖

- ការបង្កភាពងាយស្រួលសម្រាប់ជនពិការក្នុងការចេញចូល មានន័យថាមនុស្សម្នាក់អាច ៖
  - អាចផ្លាស់ទីដោយសេរី ដោយពុំមានឧបសគ្គ
  - អាចផ្លាស់ទី ដោយម្ចាស់ការខ្លួនឯង(ដោយពុំមានជំនួយពីអ្នកដទៃ)
  - អាចផ្លាស់ទីដោយមានទំនុកចិត្ត និងប្រកបដោយការគោរព។
- តម្រូវការនូវការបង្កភាពងាយស្រួលសម្រាប់ជនពិការ ប្រែប្រួលខុសៗគ្នាតាមមនុស្សម្នាក់ៗ

- ការដោះស្រាយតម្រូវការបង្កភាពងាយស្រួលនៅដំណាក់កាលរៀបចំផែនការនៃគម្រោងសាងសង់គឺមានភាពងាយស្រួលជាង និងចំណាយអស់តិចជាងការកែសម្រួលបង្កភាពងាយស្រួលលើសំណង់ដែលបានសាងសង់រួច។

| **មេរៀន៥.៣**<br>**ការប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ការបង្កភាពងាយស្រួលសម្រាប់ជនពិការ** | |
|---|---|
| **គោលដៅ** ៖ អ្នកចូលរួមអាចកំណត់ពីឧបសគ្គរូបវ័ន្ត ដែលជនពិការជួបប្រទះ | |
| **រយៈពេល** | ៦០នាទី |

**កំណាត់សម្គាល់ ៖**

! ក្នុងមេរៀននេះ អ្នកចូលរួមនឹងធ្វើការអនុវត្តជាក់ស្តែងលើការបង្កភាពងាយស្រួលសម្រាប់ជនពិការក្នុងចេញចូលនៅក្នុងអគារ ដែលស្ថិតនៅជិតទីតាំងបណ្តុះបណ្តាល។ ការអនុវត្តជាក់ស្តែងនេះ មានគោលដៅឱ្យអ្នកចូលរួមយល់ដឹងថាក្នុងស្ថានភាពតែមួយ មនុស្សផ្សេងគ្នាមានបទពិសោធន៍ផ្សេងៗគ្នា ទោះជាស្ថិតក្នុងបរិស្ថានតែមួយ។ លើសពីនេះ ឱកាសនៃការអនុវត្តជាក់ស្តែងលើការបង្កភាពងាយស្រួលសម្រាប់ជនពិការ និងជួយឱ្យអ្នកចូលរួមចេះអនុវត្តន៍បែបនេះម្តងទៀត នាពេលអនាគត។

១. ប្រសិនបើ មានភ្ញៀវកិត្តិយសជាជនពិការ ឬអ្នកចូលរួមដែលជាជនពិការចូលរួម សូមណែនាំភ្ញៀវកិត្តិយសមកពីអង្គការជនពិការក្នុងមូលដ្ឋានដល់អ្នកចូលរួម តាមរយៈ ឱ្យពួកគេប្រាប់ថា តើពួកគេជាអ្នកណា និងមកពីអង្គការណា។ អរគុណភ្ញៀវកិត្តិយស ចំពោះការចូលរួម និងចំណាយពេលវេលា។ គ្រូបណ្តុះបណ្តាលគួសបញ្ជាក់ប្រាប់អ្នកចូលរួមថា ពួកគេអាចរៀនសូត្របានច្រើនពីភ្ញៀវកិត្តិយសទាំងនេះ។ លើសពីនេះ សូមថ្លែងអំណរគុណចំពោះម្ចាស់អគារនេះ ដែលបានផ្តល់ឱកាសឱ្យមានការអនុវត្តជាក់ស្តែងអំពីការបង្កភាពងាយស្រួលសម្រាប់ជនពិការនេះ។

២. គ្រូបណ្តុះបណ្តាលពន្យល់ពីលំហាត់ ៖ យើងនឹងធ្វើការអនុវត្តសាកល្បងមួយ ដើម្បីស្វែងយល់ថាតើអគារដែលជាកន្លែងរៀបចំការបណ្តុះបណ្តាល(ឬក៏អគារផ្សេងៗទៀត) មានការបង្កភាពងាយស្រួលសម្រាប់ជនពិការក្នុងកម្រិតណាដែរ។ លំហាត់នេះមានគោលបំណងធ្វើការស្វែងយល់ និងកំណត់ថាតើជនពិការអាចជួបប្រទះនឹងឧបសគ្គរូបវ័ន្តអ្វីខ្លះ។ គ្រូបណ្តុះបណ្តាលពន្យល់ថា អ្នកចូលរួមនឹងផ្លាស់ទីជាមួយនឹងភ្ញៀវដែលជាជនពិការ និងដើរកាត់តាមអគារនេះ ដើម្បីពិនិត្យមើលថា តើមានឧបសគ្គអ្វីខ្លះ។ គ្រូបណ្តុះបណ្តាលគួសបញ្ជាក់ថា លំហាត់នេះផ្តោតលើឧបសគ្គរូបវ័ន្ត ដែលពាក់ព័ន្ធជាមួយនឹងការបង្កភាពងាយស្រួលសម្រាប់ជនពិការ មិនមែនឧបសគ្គដែលពាក់ព័ន្ធនឹងឥរិយាបថ ការចូលរួម និងការប្រាស្រ័យទាក់ទងឡើយ។ ស្នើឱ្យក្រុមធ្វើលំហាត់នេះ ដោយផ្តល់នូវការគោរពគ្នាទៅវិញទៅមក ។

៣. ត្រៀមរៀបចំការអនុវត្តជាក់ស្តែងលើការបង្កភាពងាយស្រួលសម្រាប់ជនពិការ។ បែងចែកអ្នកចូលរួមជា៥ក្រុម។ ចែកឱ្យក្រុមនីមួយៗនូវម៉ែត្រសម្រាប់វាស់ និងឱ្យភ្ញៀវកិត្តិយសជាជនពិការចូលរួមនៅក្នុងក្រុមណាមួយ។ ផ្តល់ការណែនាំឱ្យបានច្បាស់លាស់ដល់ក្រុមអំពីអ្វីដែលពួកគេត្រូវធ្វើ ពោលគឺការអនុវត្តជាក់ស្តែងលើការបង្កភាពងាយស្រួលសម្រាប់ជនពិការក្នុងការប្រើប្រាស់អគារ និងបរិវេណជុំវិញអគារ។ គ្រប់ក្រុមទាំងអស់ចាំបាច់ត្រូវចាប់ផ្តើមនៅច្រកចូលក្នុងបរិវេណអគារ។ ក្រុមនីមួយៗមានពេល៣០នាទី សម្រាប់ដើរមើលជុំវិញអគារ និងឆ្លើយសំណួរដែលមាននៅលើបញ្ជីផ្ទៀងផ្ទាត់ការបង្កភាពងាយស្រួលសម្រាប់ជនពិការក្នុងសៀវភៅណែនាំសម្រាប់អ្នកចូលរួម។ សំណួរទាំងនេះអាចឆ្លើយថា បាទ/ចាស ទេ ឬមិនពាក់ព័ន្ធ។ សមាជិកក្រុមក៏អាចសរសេរមូលហេតុ ដែលនាំឱ្យពួកគេជ្រើសរើសយកចម្លើយណាមួយ ឬកត់ត្រាអ្វីដែលពួកគេបានសង្កេតឃើញនៅលើក្រដាសដោយឡែក។



៤. គ្រូបណ្តុះបណ្តាលឱ្យអ្នកចូលរួមធ្វើការអនុវត្តសាកល្បងលើការបង្កភាពងាយស្រួលសម្រាប់ជនពិការ តាមក្រុមរៀងៗខ្លួន។ ការអនុវត្តជាក់ស្តែងមានរយៈពេល៣០នាទី។

៥. បន្ទាប់មក ក្រុមនីមួយៗត្រូវត្រលប់មកវិញ។ ក្រុមនីមួយៗ ចាត់តំណាងក្រុមម្នាក់បង្ហាញលទ្ធផលរកឃើញរបស់ខ្លួន។

នៅពេលដែលក្រុមទាំងអស់បានឡើងបង្ហាញរួចហើយ សួរទៅអ្នកចូលរួម ៖ "តើលទ្ធផលរកឃើញទាំងនេះស្រដៀងគ្នាដែរឬទេ ឬតើមានភាពខុសប្លែកគ្នារវាងលទ្ធផលរកឃើញទាំងនេះ?" ប្រសិនបើមានភាពខុសប្លែកគ្នា ឱ្យក្រុមពន្យល់ពីមូលហេតុ ដែលមានភាពខុសប្លែកគ្នា ដើម្បីឈានដល់ការឯកភាពគ្នាជារួម។



គ្រូបណ្តុះបណ្តាលសួរអ្នកចូលរួម ៖ "តើការផ្លាស់ទីរបស់ភ្ញៀវជាជនពិការក្នុងអគារមានលក្ខណៈយ៉ាងដូចម្តេចដែរ? តើវាមានលក្ខណៈខុសប្លែកពីបទពិសោធន៍ដែលពួកគេធ្លាប់បានជួបប្រទះ ជាមួយនឹងអគារផ្សេងៗដែរឬទេ? តើមានកន្លែងណាខ្លះក្នុងអគារ ឬបរិវេណនេះ ដែលជនពិការមិនអាចទៅដល់បាន?

គ្រូបណ្តុះបណ្តាលសួរភ្ញៀវកិត្តិយសជាជនពិការ ៖ "តើមានការពិភាក្សាអ្វីខ្លះនៅក្នុងក្រុមទាំងនេះ? តើក្រុមនេះបានរកឃើញគំនិតថ្មីៗអ្វីខ្លះ?"

៦. គ្រូបណ្តុះបណ្តាលឱ្យអ្នកចូលរួមគិតពីអ្វីដែលពួកគេបានរៀននៅក្នុងលំហាត់នេះ។ រំលឹកប្រាប់ពួកគេ



ថា វាមិនមែនត្រឹមតែជាការពិនិត្យលើបញ្ជីនេះនោះទេ ប៉ុន្តែវាជាការយល់អំពីរបៀបដែលជនពិការ អាចមានបទពិសោធន៍ដោយផ្ទាល់ជាមួយនឹងការចេញចូលអគារសាធារណៈ ដូចជាសាលាឃុំ វត្តអារាម មណ្ឌលសុខភាព សាលារៀន និងអគារសាធារណៈផ្សេងទៀត។

៧. គ្រូបណ្តុះបណ្តាលបញ្ជាក់ថា មិនត្រឹមតែជនពិការនោះទេ ពោលគឺគ្រប់គ្នាអាចយល់បានអំពីការបង្កភាពងាយស្រួលសម្រាប់ជនពិការ បន្ទាប់មក គ្រូបណ្តុះបណ្តាលបង្ហាញសារគន្លឹះរបស់មេរៀនដូចខាងក្រោម ៖



- មនុស្សផ្សេងគ្នាអាចមានបទពិសោធន៍តាមបែបខុសៗគ្នា ទោះជាស្ថិតក្នុងបរិស្ថានដូចគ្នាក៏ដោយ។
- ជាការសំខាន់ណាស់ ដែលត្រូវកែសម្រួលមជ្ឈដ្ឋានជុំវិញ ដើម្បីឱ្យមានមនុស្សផ្សេងៗគ្នាអាចប្រើប្រាស់ទីកន្លែងនោះ។
- គ្រប់គ្នាអាចទទួលបានប្រយោជន៍ពីការបង្កភាពងាយស្រួលសម្រាប់ជនពិការ ដែលត្រូវបានកែលម្អ ពោលគឺមិនត្រឹមតែជនពិការនោះទេ។
- គ្រប់គ្នាអាចចូលរួមចំណែកលើកកម្ពស់ការបង្កភាពងាយស្រួលសម្រាប់ជនពិការ ព្រោះការបង្កភាពងាយស្រួលសម្រាប់ជនពិការ គឺជាបញ្ហារបស់គ្រប់គ្នា។

| មេរៀន៥.៤<br>ដំណោះស្រាយជាក់ស្តែង ដើម្បីកែលម្អ ឱ្យមានការបង្កភាពងាយស្រួលសម្រាប់ជនពិការ | |
|---|---|
| **គោលដៅ** ៖ ស្វែងយល់ពីរបៀបប្រើប្រាស់ដំណោះស្រាយងាយៗ ដើម្បីធ្វើឱ្យបរិស្ថានកាន់តែបង្កភាពងាយស្រួលសម្រាប់ជនពិការ | |
| **រយៈពេល** | ៤០នាទី |



១. គ្រូបណ្តុះបណ្តាលណែនាំអំពីលំហាត់ ដោយពន្យល់ថា យើងបានដឹងពីឧបសគ្គរបស់ជនពិការដែលមាននៅក្នុងបរិស្ថាន។ យើងអាចធ្វើការផ្លាស់ប្តូរតាមរបៀបងាយៗមួយចំនួន ដើម្បីកែលម្អសម្រាប់ការបង្កភាពងាយស្រួលសម្រាប់ជនពិការ និងការផ្តល់ការបង្កភាពងាយស្រួលដល់មនុស្សគ្រប់រូបឱ្យអាចប្រើប្រាស់ និងចេញចូលក្នុងអគារនោះបាន។

២. គ្រូបណ្តុះបណ្តាលបែងចែកអ្នកចូលរួមទៅតាមរដ្ឋបាលរបស់ពួកគាត់(ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត)។ ឱ្យអ្នកចូលរួមពិភាក្សាអំពីអ្វីដែលពួកគេអាចធ្វើបាន ដើម្បីកែលម្អ ឱ្យមានការបង្កភាពងាយស្រួលក្នុងការប្រើប្រាស់សាលាឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តរបស់ពួកគេ ឬអគារផ្សេងៗទៀតដែលពាក់ព័ន្ធជាមួយនឹងពួកគេ។ ប្រើប្រាស់តារាងខាងក្រោម ដើម្បីឱ្យការពិភាក្សាកាន់តែមានភាពជាក់លាក់បន្ថែមទៀត។ ប្រើប្រាស់តារាងនេះ ជាឧទាហរណ៍ និងឱ្យអ្នកចូលរួមបន្ថែមដំណោះស្រាយរបស់ខ្លួន។

**ឧទាហរណ៍ ៖ បង្ហាញពីដំណោះស្រាយជាក់ស្តែង**

| ឧបសគ្គ | ដំណោះស្រាយ | អ្នកទទួលខុសត្រូវ | ចំណាយ (ខ្ពស់ មធ្យម ទាប) |
|---|---|---|---|
| **ផ្លូវដើរដាក់រដុប** | ជួសជុលក្រឡុក និងកន្លែងដែលមិនរាបស្មើ | មេឃុំរួមជាមួយនឹងសហគមន៍មូលដ្ឋាន | ទាប |
| **សញ្ញាពុំអាចមើលបានច្បាស់** | ប្រើប្រាស់សញ្ញា និងអក្សរទំហំធំៗ ប្រើប្រាស់ពណ៌ដែលលេច | ស្មៀនឃុំ រួមនឹងសិល្បករ ក្នុងមូលដ្ឋាន | ទាប |
| **ជម្រាលចោតពេក** | ជួសជុល ឬរៀបចំឡើងវិញ ជម្រាលដែលឡើងផ្លូវដែលចោត | មេឃុំ រួមជាមួយនឹងជាងឥដ្ឋ ក្នុងមូលដ្ឋាន | មធ្យម |

៣. ឆ្លុះបញ្ចាំងពីតួនាទីផ្ទាល់ខ្លួនរបស់អ្នកចូលរួម។ ទុកពេល២-៣នាទី ឱ្យអ្នកចូលរួមគិតអំពីអ្វីដែលពួកគេអាចធ្វើបាន ដើម្បីកែលម្អ ឱ្យមានការបង្កភាពងាយស្រួលសម្រាប់ជនពិការ ក្នុងតួនាទីរបស់ពួកគេជាមេភូមិ ស្មៀនឃុំ មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ ឬក្រុមប្រឹក្សា គណៈអភិបាល មន្ត្រីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬក្រុមប្រឹក្សា គណៈអភិបាល មន្ត្រីរបស់រដ្ឋបាលរាជធានី ខេត្ត។ ឱ្យអ្នកចូលរួមកត់ត្រាគំនិតរបស់ពួកគេក្នុងក្រុម។

គ្រប់គ្នាអាចរួមចំណែកក្នុងការកែលម្អឱ្យមានការបង្កភាពងាយស្រួលសម្រាប់ជនពិការ ហើយការកែលម្អឱ្យមានការបង្កភាពងាយស្រួលសម្រាប់ជនពិការនេះ គឺជាបញ្ហារបស់មនុស្សគ្រប់ៗគ្នា។

**កំណត់សម្គាល់ ៖**

សូមកត់សម្គាល់ផងដែរថា អ្នកចូលរួមគួរលើកទឹកចិត្ត ដើម្បីពិភាក្សាពីបញ្ហាទាំងនេះ នៅក្នុងការបណ្តុះបណ្តាល ប៉ុន្តែសមត្ថកិច្ច និងតួនាទីភារកិច្ចរបស់ពួកគេ អាចនឹងមិនអនុញ្ញាតឱ្យពួកគេអាចធ្វើការសម្រេចចិត្តលើគ្រប់ដំណោះស្រាយ ដែលបានស្នើឡើងឡើយ។ នៅក្នុងជំពូកទី៧ អំពីការរៀបចំផែនការ ដើម្បីការដាក់បញ្ចូលពិការភាពគ្រង់ចំណុចនៃរបៀបរកដំណោះស្រាយ ដើម្បីដោះស្រាយឧបសគ្គនានា នឹងមានការពិភាក្សាលម្អិតបន្ថែមទៀត។

៤. គ្រូបណ្តុះបណ្តាលឱ្យក្រុមនីមួយៗ បង្ហាញដោយសង្ខេបពីអាទិភាពធំៗ តាមតុរបស់ពួកគេ ដើម្បីឱ្យក្រុមផ្សេងទៀតអាចទទួលបានគំនិត។

**កំណត់សម្គាល់ ៖**

ប្រសិនបើពុំមានពេលគ្រប់គ្រាន់ សម្រាប់បង្ហាញនោះទេ សូមឱ្យក្រុមបិទក្រដាសផ្ទាំងធំរបស់ពួកគេលើជញ្ជាំង ដើម្បីឱ្យគ្រប់គ្នាបានមើល។

| **មេរៀន៥.៥<br>សង្ខេបមេរៀនជំពូកទី៥** | |
|---|---|
| **គោលដៅ ៖** | រំលឹកអ្នកចូលរួមអំពីអ្វីដែលយើងបានរៀននៅថ្ងៃនេះ និងបញ្ជាក់ឱ្យបានច្បាស់ពីសំណួរដែលនៅសេសសល់នានា។ |
| **រយៈពេល** | ៥នាទី |

គ្រូបណ្តុះបណ្តាលសង្ខេបមេរៀនជំពូកទី៥នេះ ផ្អែកតាមសៀវភៅណែនាំសម្រាប់អ្នកចូលរួម។ ការសង្ខេបនេះ បង្ហាញតាមរយៈស្លាយដែលមានខ្លឹមសារ ដូចខាងក្រោម ៖

១. ការបង្កភាពងាយស្រួលចេញចូលរូបវ័ន្ត គឺពាក់ព័ន្ធជាមួយនឹងការផ្លាស់ទីដោយសេរី ដោយគ្មានឧបសគ្គ ដោយម្ចាស់ការខ្លួនឯង និងប្រកបដោយទំនុកចិត្ត និងការគោរព។

២. តម្រូវការក្នុងការបង្កភាពងាយស្រួលសម្រាប់ជនពិការមានលក្ខណៈផ្សេងៗពីគ្នា ទៅ តាមមនុស្សម្នាក់ៗ។

៣. ការកែលម្អការបង្កភាពងាយស្រួលសម្រាប់ជនពិការ ផ្តល់ប្រយោជន៍មិនត្រឹមតែដល់ជនពិការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ប្រយោជន៍ដល់មនុស្សជាច្រើនទៀតផង ។

៤. សូមពិចារណាលើការបង្កភាពងាយស្រួលសម្រាប់ជនពិការ នៅដំណាក់កាលរៀបចំប្លង់អគារ ដើម្បីបញ្ចៀសចំណាយខ្ពស់លើការជួសជុល ឬការកែសម្រួលនៅពេលក្រោយ។

៥. ការធ្វើការអនុវត្តជាក់ស្តែងតាមរបៀបសាមញ្ញៗលើការបង្កភាពងាយស្រួលសម្រាប់ជនពិការ ដែលមានការចូលរួម បង្ហាញឱ្យឃើញពីឧបសគ្គ ដែលត្រូវដោះស្រាយបន្ទាន់ជាងគេ នៅក្នុងអគារដែលមានស្រាប់។

៦. ដំណោះស្រាយ ដែលអាចអនុវត្តបាន មិនមែនជានិច្ចកាល ត្រូវការចំណាយខ្ពស់នោះទេ។

៧. គ្រប់គ្នាអាចរួមចំណែកកែលម្អការបង្កភាពងាយស្រួលសម្រាប់ជនពិការ។

# ជំពូកទី៦

# ការធានាឱ្យមានការចូលរួមយ៉ាងសកម្ម

# ជំពូកទី៦

# ការធានាឱ្យមានការចូលរួមយ៉ាងសកម្ម

## ក). សេចក្តីពិពណ៌នា

ជំពូកនេះនឹងផ្តោតលើការចូលរួមយ៉ាងសកម្មរបស់ជនពិការ។ នៅចុងបញ្ចប់នៃជំពូកនេះ អ្នកចូលរួមនឹង ៖

- យល់ដឹងអំពីរបៀបរៀបចំកិច្ចប្រជុំដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំងប្រជាពលរដ្ឋ
- យល់ពីអត្ថន័យនៃពាក្យ "ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើពុំមានការចូលរួមពីយើងនោះ"
- ដឹងពីរបៀបរៀបចំកិច្ចប្រជុំដែលមានការចូលរួមពីជនពិការ និងចាត់វិធានការជាក់ស្តែង ដើម្បីបង្កើនការចូលរួមពីជនពិការ

## ខ). មាតិកាមេរៀន

| លរ | មេរៀន | រយៈពេល | សម្ភារៈ និងឯកសារ |
|---|---|---|---|
| ៦.១ | រៀបចំកិច្ចប្រជុំ និងវេទិកាពិគ្រោះយោបល់ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការ | ៩៥នាទី | ក្រដាសផ្ទាំងធំ |
| ៦.២ | សង្ខេបមេរៀនជំពូកទី៦ | ១០នាទី | សូមមើលសៀវភៅណែនាំសម្រាប់អ្នកចូលរួម |
| **សរុប** | | **១០៥នាទី** | |

**កំណត់សម្គាល់ ៖**

ក្នុងមេរៀន៦.១ នេះ ត្រូវបានកែសម្រួលឱ្យស្របតាមកម្រិតទាំង៣របស់រដ្ឋបាលថ្នាក់ក្រោមជាតិ( ថ្នាក់ឃុំ សង្កាត់ ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់រាជធានី ខេត្ត) នេះមានន័យថា៖

- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ ត្រូវដំណើរការជាមួយនឹងកិច្ចពិគ្រោះយោបល់ក្នុងជំហាននៃការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវប្រើប្រាស់ឧទាហរណ៍ជាក់ស្តែងចេញពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។
- ការបណ្តុះបណ្តាលនៅថ្នាក់រាជធានី ខេត្ត ត្រូវប្រើប្រាស់ឧទាហរណ៍ជាក់ស្តែងចេញពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ។

ប្រអប់អត្ថបទ( ក្នុងមេរៀន៦.១ ) មានព័ត៌មានសារតារអំពីកិច្ចប្រជុំទាំងនេះ ត្រូវបានផ្តល់បន្ថែមសម្រាប់អ្នកបណ្តុះបណ្តាល។ សូមអានព័ត៌មាននេះដោយប្រុងប្រយ័ត្នមុននឹងសម្របសម្រួលជំពូកនេះ។

នៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាលនេះ ក្នុងមេរៀន៦.១ មានខ្លឹមសារចំនួនបីផ្នែក ទៅតាមថ្នាក់ឃុំ សង្កាត់ ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់រាជធានី ខេត្ត)។ និមិត្តសញ្ញា ខាងក្រោមបង្ហាញថា តើមេរៀន៦.១ មួយណាត្រូវបណ្តុះបណ្តាលនៅថ្នាក់ក្រោមជាតិណាមួយ។

**ថ្នាក់ឃុំ សង្កាត់** **ថ្នាក់ក្រុង ស្រុក ខណ្ឌ** **ថ្នាក់រាជធានី ខេត្ត**





**គ.១). ដំណើរការសម្របសម្រួលក្រុមគោលដៅនៅថ្នាក់ឃុំ សង្កាត់**



**មេរៀន៦.១**

**ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការ**

| | |
|---|---|
| **គោលដៅ** ៖ | អ្នកចូលរួមយល់ដឹងអំពីរបៀបរៀបចំកិច្ចប្រជុំក្នុងជំហានការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់ ដែលមិនបានផាត់ចេញគ្រប់អ្នកពាក់ព័ន្ធ រួមទាំងជនពិការ។ |
| **រយៈពេល** | ៩៥នាទី |

១. គ្រូបណ្តុះបណ្តាលណែនាំអំពីទស្សនទាននៃកិច្ចប្រជុំពិគ្រោះយោបល់ ក្នុងជំហានការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់។ ទោះជា អ្នកចូលរួមភាគច្រើនបានដឹងអំពីកិច្ចប្រជុំពិគ្រោះយោបល់ហើយ (ជំហានការវិភាគស្ថានភាព និងការកំណត់តម្រូវការ) ក៏គ្រូបណ្តុះបណ្តាលគួររំលឹកប្រាប់អ្នកចូលរួមម្តងទៀត។ ជាព័ត៌មានសម្រាប់គ្រូបណ្តុះបណ្តាល សូមមើលប្រអប់ខាងក្រោម ដែលមានព័ត៌មានសំខាន់ៗ ជាឧទាហរណ៍អំពីកិច្ចប្រជុំ ដែលប្រជាពលរដ្ឋអាចចូលរួមបាន។

២. គ្រូបណ្តុះបណ្តាល សួរអ្នកចូលរួមថា ៖



- តើអ្នកណាខ្លះដែលធ្លាប់បានចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីវិភាគស្ថានភាព និងការកំណត់តម្រូវការនៅថ្នាក់ឃុំ សង្កាត់?
- តើកត្តាអ្វីខ្លះ ដែលធ្វើឱ្យកិច្ចប្រជុំទាំងនោះជាកិច្ចប្រជុំពិគ្រោះយោបល់? តើវាមានន័យយ៉ាងដូចម្តេច?
- ហេតុអ្វីបានជាមានការរៀបចំកិច្ចប្រជុំទាំងនេះ? តើគេពិភាក្សាអ្វីខ្លះ?



គោលដៅនៃកិច្ចប្រជុំពិគ្រោះយោបល់គឺដើម្បីស្វែងយល់អំពីបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ កិច្ចប្រជុំពិគ្រោះយោបល់អាចធានាឱ្យមានការពិចារណាលើតម្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ ដើម្បីឱ្យពួកគេមានឱកាសទទួលបានប្រយោជន៍ពីសកម្មភាពដែលបានគ្រោងទុក ហើយពួកគេមានសំឡេងក្នុងដំណើរការនេះ។

## ប្រអប់អត្ថបទព័ត៌មានសាចតារអំពីកិច្ចប្រជុំ

**កិច្ចប្រជុំពិគ្រោះយោបល់ដើម្បីវិភាគស្ថានភាព និងការកំណត់តម្រូវការធ្វើឡើងនាំងក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់**

១. **ដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ធ្វើឡើងរៀងរាល់៥ឆ្នាំម្តង។** នៅក្នុងជំហានទី ១ ៖ ការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់( សម្គាល់ ៖ ជំហាននេះ ជាជំហានដែលពាក់ព័ន្ធជាមួយនឹងការប្រជុំពិគ្រោះយោបល់ )

- **គោលបំណង** ៖ ដើម្បីកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយជាអាទិភាពសម្រាប់ជា មូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- **លទ្ធផលរំពឹងទុក** ៖ គឺ ការកំណត់បាននូវបញ្ហា តម្រូវការ និងដំណោះស្រាយជាអាទិភាពរបស់ប្រជាពលរដ្ឋ។
- **ដំណើរការ ៖**

ក). ប្រជុំនៅឃុំ សង្កាត់ ៖

- គណៈកម្មាធិការផែនការ និងថវិកា( គ.ផ.ថ )ជួបប្រជុំនៅឃុំ សង្កាត់ ដើម្បីវិភាគទិន្នន័យភូមិ ទិន្នន័យឃុំ សង្កាត់ និងឯកសារស្ថានភាពឃុំ សង្កាត់
- អ្នកចូលរួមទាំងអស់អាចជួយផ្តល់ព័ត៌មានឬទិន្នន័យថ្មីៗ
- គ.ផ.ថ. អាចវិភាគស្ថានភាព ឬវិភាគបញ្ហានានាដែលឃុំ សង្កាត់កំពុងជួបប្រទះ
- គ.ផ.ថ.ស្រង់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយទាំងនេះចូលក្នុងតារាង១.១

ខ). ប្រជុំតាមភូមិនីមួយៗ ៖

- តំណាងភូមិដែលជាសមាជិក គ.ផ.ថ. ត្រូវស្រង់បញ្ហា ទីតាំងបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយទាំងឡាយដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនចេញពីតារាង១.១ សម្រាប់ប្រជុំពិភាក្សាជាមួយប្រជាពលរដ្ឋនៅតាមភូមិនីមួយៗ
- ការប្រជុំនៅតាមភូមិនីមួយៗត្រូវមានតំណាងគ្រួសារចូលរួមយ៉ាងតិច៦០%នៃគ្រួសារសរុបក្នុងភូមិ (ស្ត្រីយ៉ាងតិច៣០%)។ អ្នកភូមិដែលត្រូវចូលរួមប្រជុំរួមមាន ប្រជាពលរដ្ឋក្រីក្រ ជនពិការ កុមារ យុវជន ចាស់ព្រឹទ្ធាចារ្យ ជនងាយរងគ្រោះ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត
- តំណាង គ.ផ.ថ. បង្ហាញអំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយដល់ប្រជាពលរដ្ឋ ដើម្បីពិភាក្សា និងធ្វើសុពលភាព
- គ.ផ.ថ. បែងចែកអ្នកចូលរួមជាក្រុមបុរស ក្រុមស្ត្រី និងក្រុមផ្សេងៗទៀត ដូចជា ក្រុមជនពិការ ក្រុមកុមារ ក្រុមយុវវ័យ និងក្រុមជនងាយរងគ្រោះផ្សេងៗទៀតជាដើម ដើម្បីពិភាក្សា និងកំណត់អំពីបញ្ហា ទីតាំងបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ ឧបសគ្គ និងដំណោះស្រាយនានាបន្ថែម

គ). ប្រជុំនៅឃុំ សង្កាត់ ៖

- គ.ផ.ថ. ជួបប្រជុំនៅថ្នាក់ឃុំ សង្កាត់ ដើម្បីបូកសរុបបញ្ហា ទីតាំងបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយដែលមកពីបណ្តាលភូមិនានា។ គ.ផ.ថ ត្រូវពិនិត្យ និងបន្សីគ្នានូវរាល់បញ្ហា តម្រូវការនានាតាមភូមិ
- គ.ផ.ថ. ស្រង់លទ្ធផលនៃការពិនិត្យ ពិភាក្សាទាំងនេះចូលក្នុងតារាង ១.២. ការបូកសរុបបញ្ហា ទីតាំងបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយរបស់ឃុំ សង្កាត់។

២. **ដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ត្រូវបានធ្វើឡើងសម្រាប់រយៈពេលបីឆ្នាំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។** ជំហានទី១ ៖ ការប្រមូលព័ត៌មាន និងតម្រូវការរបស់មូលដ្ឋានសម្រាប់រៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់

- គោលបំណង ៖ ដើម្បីប្រមូលព័ត៌មានបឋមស្តីពីតម្រូវការអភិវឌ្ឍន៍របស់មូលដ្ឋានសម្រាប់ជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គម្រោងថវិកាប្រចាំឆ្នាំ និងសម្រាប់ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត។
- លទ្ធផលរំពឹងទុក ៖បញ្ជីគម្រោង ដែលជាតម្រូវការអភិវឌ្ឍន៍ក្នុងមូលដ្ឋានឃុំ សង្កាត់នៅឆ្នាំខាងមុខធ្វើបញ្ជីគម្រោងទៅក្រុមការងារកសាងផែនការស្រុក ដើម្បីធ្វើការសម្រិតសម្រាំងរួចផ្ញើទៅរាជធានី ខេត្តសម្រាប់ធ្វើជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងរៀបចំយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។
- ដំណើរការ ៖

ក). គ.ផ.ថ. រៀបចំប្រជុំ ដែលមានសមាជិក សមាជិកា គ.ផ.ថ ស្មៀនឃុំ សង្កាត់ ប្រធានភូមិ ឬតំណាងភូមិ ជនបង្គោលនានាក្នុងឃុំ សង្កាត់ ក្រុមការងារគណនេយ្យភាពសង្គម ក្រុមយុវជន តំណាងការិយាល័យជំនាញ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា។ ពិនិត្យ និងវិភាគលើស្ថានភាពទូទៅនៅក្នុងឃុំ សង្កាត់។

ខ). មេភូមិនីមួយៗស្រង់យកបញ្ហា តម្រូវការ និងដំណោះស្រាយដែលពាក់ព័ន្ធនៅតាមភូមិរៀងៗខ្លួនទៅបង្ហាញ និងពិគ្រោះយោបល់មួយតំណាងគ្រួសារប្រជាពលរដ្ឋឱ្យក្នុងភូមិរបស់ខ្លួន។ មេភូមិនីមួយៗត្រូវខិតខំជួប និងពិភាក្សាជាមួយតំណាងគ្រួសារប្រជាពលរដ្ឋឱ្យបាន៦០% នៃចំនួនគ្រួសារសរុបក្នុងភូមិ (ប្រុស ស្រី កុមារ ជនពិការ និងក្រុមជនងាយរងគ្រោះ)។

គ). មេភូមិទាំងអស់ត្រូវយកលទ្ធផលនៃការជួប និងពិភាក្សាជាមួយប្រជាពលរដ្ឋខ្លួនមកសាលាឃុំ សង្កាត់ ដើម្បី គ.ផ.ថ ធ្វើការប្រជុំបូកសរុប ផ្ទៀងផ្ទាត់ និងកែសម្រួលតារាងបញ្ហា តម្រូវការ និងដំណោះស្រាយ។

ឃ). គ.ផ.ថ ត្រូវពិនិត្យពិចារណា និងកំណត់សកម្មភាពនានានៃការអនុវត្តមុខងារកាតព្វកិច្ចដែលរដ្ឋបាលឃុំ សង្កាត់បានទទួល និងឬគម្រោងនានាដែលត្រូវប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ។ គ.ផ.ថ ត្រូវស្រង់សកម្មភាពឬគម្រោងទាំងនោះចូលក្នុងតារាង១.១.ក។

**ដកស្រង់ចេញពី ៖** សេចក្តីណែនាំបច្ចេកទេសអំពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ខែមីនា ឆ្នាំ២០១៧

៣. ការពិភាក្សាជាក្រុម ៖ បែងចែកអ្នកចូលរួមជាក្រុមដែលមានសមាជិក៥នាក់ក្នុងមួយក្រុម ដើម្បីពិភាក្សាអំពីរបៀបរៀបចំកិច្ចប្រជុំពិគ្រោះយោបល់។ ឱ្យក្រុមនីមួយៗសរសេរចម្លើយឆ្លើយតបនឹងសំណួរខាងក្រោមនៅលើក្រដាសផ្ទាំងធំ។ រយៈពេលពិភាក្សា១៥នាទី សំណួរពិភាក្សាខាងក្រោម ៖

- តើអ្នកណាជាអ្នកផ្តួចផ្តើមគំនិតឱ្យមានការប្រជុំ?
- តើរបៀបវារៈ និងកាលបរិច្ឆេទនៃកិច្ចប្រជុំត្រូវបានព្រមព្រៀងគ្នា ដោយរបៀបណា?
- តើអ្នកណាជាអ្នកអញ្ជើញអ្នកភូមិ?
- តើកិច្ចប្រជុំនេះរៀបចំនៅកន្លែងណា?
- តើកិច្ចប្រជុំនេះចំណាយថេរវេលាប៉ុន្មាន និងធ្វើឡើងនៅពេលណា(ព្រឹក ឬរសៀល)?
- តើអ្នកណាជាប្រធានកិច្ចប្រជុំ និងតើអ្នកណាសម្របសម្រួលការពិភាក្សា?
- តើតម្រូវការនានាត្រូវបានកំណត់យ៉ាងដូចម្តេច នៅក្នុងកិច្ចប្រជុំនេះ?
- តើកិច្ចប្រជុំនេះត្រូវបានរៀបចំឡើងដោយរបៀបណា ដើម្បីឱ្យប្រជាពលរដ្ឋមកពីក្រុមផ្សេងៗគ្នាអាចចូលរួមនៅក្នុងកិច្ចប្រជុំនេះ(ដូចជា បុរស ស្ត្រី ក្រុមជនជាតិដើមភាគតិច ក្រុមជនងាយរងគ្រោះ និងជនពិការ ជាដើម)?
- តើអ្នកមិនអាចចូលរួម ត្រូវបានផ្តល់ព័ត៌មានពីលទ្ធផលកិច្ចប្រជុំដោយរបៀបណា?

៤. បន្ទាប់មក ពិភាក្សាក្រុមធំ គ្រូបណ្តុះបណ្តាលផ្តោតការយកចិត្តទុកដាក់លើសំណួរចុងក្រោយ ដោយរទៅក្រុមទាំងអស់សួថា ហេតុអ្វីបានជាការចូលរួមពីប្រជាពលរដ្ឋក្នុងកិច្ចប្រជុំពិគ្រោះយោបល់មានសារៈសំខាន់?។ ចុងបញ្ចប់គ្រូបណ្តុះបណ្តាលសង្ខេប ដោយបង្ហាញស្លាយនូវខ្លឹមសារ ៖

ក). ជនពិការ អាចចូលរួមជាមួយសមាជិកផ្សេងទៀតរបស់សហគមន៍ ដើម្បីរួមចំណែកក្នុងការផ្តល់ជាគំនិត ដើម្បីអភិវឌ្ឍន៍មូលដ្ឋាន ឬសហគមន៍របស់ពួកគេ។

ខ). ការបង្កើនការចូលរួម ទាមទារឱ្យមានការស្វែងរកដំណោះស្រាយជាក់ស្តែង ដែលអាចជម្នះនូវឧបសគ្គនានា។

គ). ការបង្កើនការចូលរួមមិនមែនមានន័យត្រឹមតែថាមានវត្តមានជនពិការប៉ុណ្ណោះទេ ប៉ុន្តែពួកគេអាចរួមចំណែកដូចអ្នកដទៃទៀតផងដែរ។ គ្រូបណ្តុះបណ្តាលពន្យល់ថា ចំណុចខាងលើ គឺស្ថិតក្នុងចលនាពិការភាព និងត្រូវបានក្តោបក្នុងពាក្យស្លោក ៖ "ពុំមាន អ្វីសម្រាប់យើងឡើយ ប្រសិនបើ ពុំមានការចូលរួមពីយើងនោះ" មានន័យថា ៖



- ជនពិការគួរអាចនិយាយ និងធ្វើការសម្រេចចិត្តដោយខ្លួនឯងលើបញ្ហាដែលមានផលប៉ះពាល់មកលើពួកគេ។
- ចាំបាច់ត្រូវតែធានាឱ្យមានការចូលរួមដ៏សកម្មរបស់ជនពិការ។
- ជនពិការអាចចូលរួមតាមបែបផែនផ្សេងៗគ្នា ៖
  - ចូលរួម ក្នុងការរៀបចំផែនការ និងកម្មវិធីនានា
  - ទទួលបានប្រយោជន៍ពីកម្មវិធី និងសេវានានា
  - ចូលរួមក្នុងការងារគ្រប់គ្រង និងដឹកនាំ។

៥. គ្រូបណ្ដុះបណ្ដាលណែនាំអ្នកចូលរួម ទៅតាមបញ្ជីផ្ទៀងផ្ទាត់សម្រាប់កិច្ចប្រជុំដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ រួមទាំងជនពិការដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់អ្នកចូលរួម។



គ្រូបណ្ដុះបណ្ដាលសួរសំណួរ ៖ សូមគិតពីកិច្ចប្រជុំពិគ្រោះយោបល់ចុងក្រោយដែលអ្នកបានចូលរួម និងបំពេញបញ្ជីផ្ទៀងផ្ទាត់ ផ្អែកតាមបទពិសោធន៍ក្នុងកិច្ចប្រជុំនោះ។ ក្រោយពីបានបំពេញបញ្ជីផ្ទៀងផ្ទាត់នេះហើយ សួរសំណួរ ៖

**ឧបសម្ព័ន្ធ ទី៨**

- តើអ្នកណាខ្លះ ដែលឆ្លើយថា "ទេ" ចំពោះសំណួរទី១ ? ហេតុអ្វីបានជាដូច្នេះ ?
- តើមានចំណុចណាក្នុងបញ្ជីផ្ទៀងផ្ទាត់នេះ ដែលអ្នកមិនបានដឹងកន្លងមកទេ ? ប្រសិនបើមាន តើចំណុចណាខ្លះ ?

**កំណត់សម្គាល់ ៖**

ក្រុមជួយខ្លួនឯង ឬអង្គការជនពិការអាចកៀរគរជនពិការក្នុងតំបន់ ដែលពួកគេមានសកម្មភាព។ អ្នកចូលរួមគួរដឹងថា ក្នុងឃុំ សង្កាត់របស់ពួកគេមានវត្តមានអង្គការជនពិការផ្សេងៗប៉ុន្មាន។ ក្នុងជំពូកទី៨នៃសៀវភៅណែនាំសម្រាប់អ្នកចូលរួម ក៏ដូចជានៅក្នុងប្រអប់ឧបករណ៍ សម្រាប់ការបញ្ចូលពិការភាពនៅកម្ពុជា "**អនឡាញ**" មានបញ្ជីឈ្មោះអង្គការទាំងនេះ។



៦. គ្រូបណ្ដុះបណ្ដាលសួរអ្នកចូលរួម តើពួកគេស្គាល់អង្គការជនពិការណាខ្លះ ដែលអាចជួយពួកគេ ក្នុងការកៀរគរជនពិការក្នុងឃុំ សង្កាត់របស់ពួកគេបាន ?

៧. បញ្ចប់ ដោយបង្ហាញពីសារគន្លឹះរបស់មេរៀននេះ។ សូមបញ្ជាក់ឱ្យបានច្បាស់ថា បើទោះបីជាខ្លឹមសារនៃកិច្ចប្រជុំពិគ្រោះយោបល់អាចមានលក្ខណៈផ្សេងៗគ្នាក៏ដោយ បញ្ជីផ្ទៀងផ្ទាត់ ដើម្បីឱ្យកិច្ចប្រជុំមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការ អាចយកទៅអនុវត្តបានចំពោះគ្រប់កិច្ចប្រជុំទាំងអស់។



គ្រូបណ្ដុះបណ្ដាលបង្ហាញសារគន្លឹះក្នុងមេរៀនជំពូកទី៦ តាមរយៈស្លាយនូវខ្លឹមសារដូចខាងក្រោម ៖

- ជនពិការ គឺជាប្រជាពលរដ្ឋ ដូចគេឯងដែរ ដូច្នេះផែនការ និងកម្មវិធីនានារបស់រដ្ឋាភិបាលមានឥទ្ធិពលលើពួកគេ។
- ជនពិការត្រូវការការលើកទឹកចិត្តក្នុងការនិយាយ និងសម្រេចចិត្តសម្រាប់ខ្លួនឯង
- ដើម្បីឱ្យជនពិការអាចចូលរួមបានយ៉ាងសកម្ម ចាំបាច់ត្រូវមានការត្រៀមរៀបចំមុនកិច្ចប្រជុំ។
- ប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ ដើម្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ រួមទាំងជនពិការ។

## គ.២). ដំណើរការសម្របសម្រួលក្រុមគោលដៅនៅថ្នាក់ក្រុង ស្រុក ខណ្ឌ

|  | **មេរៀន៦.១**<br>**ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់**<br>**ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការ** |
|---|---|
| **គោលដៅ** ៖ | អ្នកចូលរួមយល់ដឹងអំពីរបៀបរៀបចំកិច្ចប្រជុំ ដែលមិនបានផាត់ចេញគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការ។ |
| **រយៈពេល** | ៩៥នាទី |

១. គ្រូបណ្តុះបណ្តាលណែនាំអំពីទស្សនទាននៃវេទិកាផ្សព្វផ្សាយ និងគ្រោះយោបល់។ ទោះជាអ្នកចូលរួមភាគច្រើនបានដឹងអំពីវេទិកាហើយ ក៏គ្រូបណ្តុះបណ្តាលគួររំលឹកប្រាប់អ្នកចូលរួមម្តងទៀត។ ជាព័ត៌មានសម្រាប់គ្រូបណ្តុះបណ្តាល សូមមើលប្រអប់ខាងក្រោម ដែលមានព័ត៌មានសំខាន់ៗ ជាឧទាហរណ៍អំពីវេទិកាដែលប្រជាពលរដ្ឋអាចចូលរួមបាន។

២. គ្រូបណ្តុះបណ្តាលសួរអ្នកចូលរួមថា ៖

**?**

- តើអ្នកណាខ្លះដែលធ្លាប់បានចូលរួមនៅក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅថ្នាក់ក្រុង ស្រុក ខណ្ឌ?
- តើកត្តាអ្វីខ្លះ ដែលធ្វើឱ្យវេទិកាទាំងនោះជាវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់? តើវាមានន័យយ៉ាងដូចម្តេច?
- ហេតុអ្វីបានជាមានការរៀបចំវេទិកាទាំងនេះ? តើគេពិភាក្សាអ្វីខ្លះ?



គោលដៅនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ គឺដើម្បីចែករំលែកផែនការរបស់ក្រុមប្រឹក្សាក៏ដូចជាស្វែងយល់ពីមតិត្រលប់ និងយោបល់ផ្សេងៗដែលពាក់ព័ន្ធនឹងផែនការនេះ។ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ គឺធានាឱ្យមានការពិចារណាលើតម្រូវការរបស់គ្រប់ក្រុមទាំងអស់ ដើម្បីឱ្យពួកគេមានឱកាសទទួលបានប្រយោជន៍ពីសកម្មភាពដែលបានគ្រោងទុក។

ពិនិត្យមើលថាតើចំណុចខាងលើត្រូវបានលើកឡើងដោយអ្នកចូលរួមដែរឬទេ។ ប្រសិនបើមិនបានលើកឡើងទេ សូមលើកឡើងពីចំណុចនេះ និងសុំឱ្យអ្នកចូលរួមបញ្ជាក់។ សូមសរសេរពីគោលដៅនៃកិច្ចប្រជុំទាំងនេះលើក្រដាសផ្ទាំងធំ ទុកសម្រាប់មើលនាពេលក្រោយទៀត។

| |
|---|
| **វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ** |
| នៅខែមិថុនា រៀងរាល់ឆ្នាំ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅក្នុងក្រុង ស្រុក ខណ្ឌរបស់ខ្លួន ។ |

- **វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ទាំងនេះមានគោលដៅ ៖** ផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធផ្សេងទៀតអំពីសកម្មភាពនានារបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលឆ្លើយតបទៅនឹងសំណើនានារបស់ប្រជាពលរដ្ឋ និងពិភាក្សាពីសំណើ និងសំណូមពរសម្រាប់សកម្មភាពនាឆ្នាំបន្ទាប់។
- **អ្នកចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ៖** ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ គណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ តំណាងសហគមន៍ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ប្រចាំឆ្នាំ គឺជាឧបករណ៍ដ៏សំខាន់មួយ ដើម្បីលើកកម្ពស់គណនេយ្យភាព តម្លាភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការនៃអភិបាលកិច្ចល្អរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

វេទិកានេះមានគោលដៅ ៖

- **ផ្តល់ព័ត៌មាន ៖** ក្រុមប្រឹក្សារាយការណ៍ពីសកម្មភាពនានាក្នុងឆ្នាំកន្លងទៅ និងទិសដៅសម្រាប់ឆ្នាំបន្ទាប់
- **ផ្តល់ដំបូន្មាន ៖** ឱ្យអ្នកចូលរួមពិភាក្សាពីរបាយការណ៍ ផ្តល់ព័ត៌មានត្រលប់អំពីការអនុវត្តការងាររបស់ក្រុមប្រឹក្សា និងលើកសំណើសម្រាប់ឆ្នាំបន្ទាប់។
- **លើកកម្ពស់ការចូលរួម ៖** ប្រជាពលរដ្ឋអាចចូលរួមក្នុងការងារអភិបាលកិច្ចមូលដ្ឋាន តាមរយៈការលើកជាសំណើ និងការចែករំលែកការព្រួយបារម្ភរបស់ពួកគេ។
- **បង្កើនកិច្ចសហការ ៖** ក្រុមប្រឹក្សាទទួលបានព័ត៌មានបានប្រសើរជាងមុនពីតម្រូវការរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋមានការយល់ដឹងកាន់តែប្រសើរអំពីការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាបង្កើនការសហការគ្នារវាងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ និងរួមចំណែកស្វែងរកដំណោះស្រាយ ដើម្បីប្រយោជន៍របស់ប្រជាពលរដ្ឋ។

ការរៀបចំវេទិកាមួយ មាន ៣ ផ្នែកសំខាន់ៗ៖

១. **ការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់** ៖ ការកំណត់ពីរបៀបវារៈ ការអញ្ជើញប្រជាពលរដ្ឋ ការរៀបចំអ្នកសម្របសម្រួល និងអ្នកកត់កំណត់ហេតុ និងការរៀបចំសេចក្តីព្រាងឯកសារសម្រាប់ការពិភាក្សា។

២. **ការប្រារព្ធវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់** ៖ ការធានាយ៉ាងណាឱ្យប្រជាពលរដ្ឋទាំងអស់អាចចូលរួមដោយស្មើភាពគ្នា និងត្រូវបានលើកទឹកចិត្តឱ្យចូលរួមឱ្យបានសកម្មក្នុងការពិភាក្សា។

៣. **កិច្ចការដែលត្រូវធ្វើក្រោយវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់រួច** ៖ ការបូកសរុបការពិភាក្សា ផ្តល់ការអនុម័តលើសំណើដែលត្រូវបានលើកឡើង និងធ្វើការផ្សព្វផ្សាយរបាយការណ៍របស់វេទិកានេះជាសាធារណៈ។

**ដកស្រង់ចេញពី ៖** ឯកសារបច្ចេកទេសស្តីពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សម្រាប់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌឆ្នាំ ២០១២។

៣. ការពិភាក្សាជាក្រុម ៖ គ្រូបណ្តុះបណ្តាលបែងចែកអ្នកចូលរួមជាក្រុម មានសមាជិក ៥នាក់ក្នុងមួយក្រុម ដើម្បីពិភាក្សាអំពីរបៀបរៀបវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់។ ឱ្យក្រុមនីមួយៗសរសេរចម្លើយរបស់ពួកគេ ឆ្លើយនឹងសំណួរខាងក្រោមលើក្រដាសផ្ទាំងធំ។ ការពិភាក្សាមានរយៈពេល១៥នាទី។ សំណួរពិភាក្សាមានដូចខាងក្រោម ៖

- តើអ្នកណាជាអ្នកផ្តួចផ្តើមគំនិតឱ្យមានជាវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់?
- តើរបៀបវារៈ និងកាលបរិច្ឆេទនៃកិច្ចប្រារព្ធវេទិកាត្រូវបានព្រមព្រៀងគ្នា ដោយរបៀបណា?
- តើអ្នកណាជាអ្នកអញ្ជើញប្រជាពលរដ្ឋ?
- តើកិច្ចប្រារព្ធវេទិកា នេះរៀបចំនៅកន្លែងណា?
- តើកិច្ចប្រារព្ធវេទិកានេះចំណាយពេលវេលាប៉ុន្មាន និងធ្វើឡើងនៅពេលណា(ព្រឹកឬរសៀល)?
- តើអ្នកណាជាប្រធានវេទិកា និងតើអ្នកណាសម្របសម្រួលការពិភាក្សា?
- តើតម្រូវការនានាត្រូវបានកំណត់យ៉ាងដូចម្តេច នៅក្នុងវេទិកានេះ?
- តើវេទិកានេះត្រូវបានរៀបចំឡើងដោយរបៀបណា ដើម្បីឱ្យប្រជាពលរដ្ឋ មកពីក្រុមផ្សេងៗគ្នាអាចរួមចំណែក នៅក្នុងវេទិកានេះ(ដូចជា បុរស ស្ត្រី ក្រុមជនជាតិដើមភាគតិច ក្រុមងាយរងគ្រោះ និងជនពិការជាដើម)?
- តើអ្នកដែលមិនអាចចូលរួមបាននឹងត្រូវបានផ្តល់ព័ត៌មានពីលទ្ធផលនៃវេទិកានេះដោយរបៀបណា?

៤. បន្ទាប់មក ពិភាក្សាក្រុមធំ ផ្តោតការយកចិត្តទុកដាក់លើសំណួរចុងក្រោយ។ គ្រូបណ្តុះបណ្តាល សួរទៅក្រុមទាំងអស់ថា ហេតុអ្វីបានជាការចូលរួមពីប្រជាពលរដ្ឋគ្រប់ៗគ្នាក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់មានសារៈសំខាន់?។ ចុងបញ្ចប់គ្រូបណ្តុះបណ្តាលសង្ខេប ដោយបង្ហាញស្លាយនូវខ្លឹមសារ ៖

ក). ជនពិការ អាចចូលរួមជាមួយសមាជិកផ្សេងទៀតរបស់សហគមន៍ ដើម្បីរួមចំណែកក្នុងការផ្តល់ជាគំនិត ដើម្បីអភិវឌ្ឍន៍មូលដ្ឋាន ឬសហគមន៍របស់ពួកគេ។

ខ). ការបង្កើនការចូលរួម ទាមទារឱ្យមានការស្វែងរកដំណោះស្រាយជាក់ស្តែង ដែលអាចជំនះនូវឧបសគ្គនានា។

គ). ការបង្កើនការចូលរួមមិនមែនមានន័យត្រឹមតែថា មានវត្តមានជនពិការប៉ុណ្ណោះទេ ប៉ុន្តែពួកគេអាចរួមចំណែកដូចអ្នកដទៃទៀតផងដែរ។ គ្រូបណ្តុះបណ្តាលពន្យល់ថា ចំណុចខាងលើ គឺស្ថិតក្នុងចលនាពិការភាព និងត្រូវបានក្តោបក្នុងពាក្យស្លោក ៖ "ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើ ពុំមានការចូលរួមពីយើងនោះ" ដែលមានន័យថា ៖



- ជនពិការគួរអាចនិយាយ និងធ្វើការសម្រេចចិត្តដោយខ្លួនឯងលើបញ្ហាដែលមានផលប៉ះពាល់មកលើពួកគេ។
- ចាំបាច់ត្រូវតែធានាឱ្យមានការចូលរួមដ៏សកម្មរបស់ជនពិការ។
- ជនពិការអាចចូលរួមតាមបែបផែនផ្សេងៗគ្នា ៖
  - ចូលរួម ក្នុងការរៀបចំផែនការ និងកម្មវិធីនានា

– ទទួលបានប្រយោជន៍ពីកម្មវិធី និងសេវានានា
– ចូលរួមក្នុងការងារគ្រប់គ្រង និងដឹកនាំ។

៥. គ្រូបណ្តុះបណ្តាលណែនាំអ្នកចូលរួម ទៅតាមបញ្ជីផ្ទៀងផ្ទាត់សម្រាប់កិច្ចប្រជុំ(វេទិកា)ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់អ្នកចូលរួម។ គ្រូបណ្តុះបណ្តាលសួរសំណួរ ៖ សូមគិតពីកិច្ចប្រជុំ(វេទិកា)ពិគ្រោះយោបល់ចុងក្រោយដែលអ្នកបានចូលរួម និងបំពេញបញ្ជីផ្ទៀងផ្ទាត់ ផ្អែកតាមបទពិសោធន៍ក្នុងកិច្ចប្រជុំ(វេទិកា)នោះ។ ក្រោយពីបានបំពេញបញ្ជីផ្ទៀងផ្ទាត់នេះហើយ សួរសំណួរ ៖



ឧបសម្ព័ន្ធ ទី៨

- តើអ្នកណាខ្លះ ដែលឆ្លើយថា "ទេ" ចំពោះសំណួរទី១? ហេតុអ្វីបានជាដូច្នេះ?
- តើមានចំណុចណាក្នុងបញ្ជីផ្ទៀងផ្ទាត់នេះ ដែលអ្នកមិនបានដឹងកន្លងមកទេ? ប្រសិនបើ មានតើចំណុចណាខ្លះ?

**កំណត់សម្គាល់ ៖**

ក្រុមជួយខ្លួនឯង ឬអង្គការជនពិការអាចកៀរគរជនពិការក្នុងតំបន់ ដែលពួកគេមានសកម្មភាព។ អ្នកចូលរួមគួរដឹងថា ក្នុងក្រុង ស្រុក ខណ្ឌរបស់ពួកគេមានវត្តមានអង្គការជនពិការផ្សេងៗប៉ុន្មាន។ ក្នុងជំពូកទី*៨* នៃសៀវភៅណែនាំសម្រាប់អ្នកចូលរួម ក៏ដូចជានៅក្នុងប្រអប់ឧបករណ៍សម្រាប់ការបញ្ចូលពិការភាពនៅកម្ពុជា "**អនឡាញ**" មានបញ្ជីឈ្មោះអង្គការទាំងនេះ។



៦. គ្រូបណ្តុះបណ្តាលសួរអ្នកចូលរួម តើពួកគេស្គាល់អង្គការជនពិការណាខ្លះ ដែលអាចជួយពួកគេ ក្នុងការកៀរគរជនពិការក្នុងក្រុង ស្រុក ខណ្ឌរបស់ពួកគេបាន?

៧. បញ្ចប់ដោយបង្ហាញពីសារគន្លឹះរបស់មេរៀននេះ។ សូមបញ្ជាក់ឱ្យបានច្បាស់ថា បើទោះបីជាខ្លឹមសារនៃកិច្ចប្រជុំពិគ្រោះយោបល់អាចមានលក្ខណៈផ្សេងៗគ្នាក៏ដោយ បញ្ជីផ្ទៀងផ្ទាត់ ដើម្បីឱ្យកិច្ចប្រជុំមាន ការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការ អាចយកទៅអនុវត្តបានចំពោះគ្រប់កិច្ចប្រជុំ(វេទិកា)ទាំងអស់។ គ្រូបណ្តុះបណ្តាលបង្ហាញសារគន្លឹះក្នុងមេរៀនជំពូកទី៦ តាមរយៈស្លាយនូវខ្លឹមសារដូចខាងក្រោម ៖



- ជនពិការ គឺជាប្រជាពលរដ្ឋ ដូចគេឯងដែរ ដូច្នេះផែនការ និងកម្មវិធីនានារបស់រដ្ឋាភិបាលមានឥទ្ធិពលលើពួកគេ។
- ជនពិការត្រូវការការលើកទឹកចិត្តក្នុងការនិយាយ និងសម្រេចចិត្តសម្រាប់ខ្លួនឯង
- ដើម្បីឱ្យជនពិការអាចចូលរួមបានយ៉ាងសកម្ម ចាំបាច់ត្រូវមានការត្រៀមរៀបចំ មុនកិច្ចប្រជុំ(វេទិកា)។
- ប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ ដើម្បីរៀបចំកិច្ចប្រជុំ(វេទិកា)ពិគ្រោះយោបល់ ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ រួមទាំងជនពិការ។

## គ.៣). ដំណើរការបណ្ដុះបណ្ដាលក្រុមគោលដៅនៅថ្នាក់រាជធានី ខេត្ត

| | |
|---|---|
| **មេរៀន៦.១**<br>**ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់**<br>**ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការ** | |
| **គោលដៅ ៖** អ្នកចូលរួមយល់ដឹងអំពីរបៀបរៀបចំកិច្ចប្រជុំ ដែលមិនបានផាត់ចេញគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការ។ | |
| **រយៈពេល** | ៩៥នាទី |

១. គ្រូបណ្ដុះបណ្ដាលណែនាំអំពីទស្សនទាននៃវេទិកាផ្សព្វផ្សាយ និងគ្រោះយោបល់។ ទោះជា អ្នកចូលរួមភាគច្រើនបានដឹងអំពីកិច្ចប្រជុំពិគ្រោះយោបល់ហើយ ក៏គ្រូបណ្ដុះបណ្ដាលគួររំលឹកប្រាប់អ្នកចូលរួមម្ដងទៀត។ ជាព័ត៌មានសម្រាប់គ្រូបណ្ដុះបណ្ដាល សូមមើលប្រអប់ខាងក្រោម ដែលមានព័ត៌មានសំខាន់ៗ ជាឧទាហរណ៍អំពីវេទិកាដែលប្រជាពលរដ្ឋអាចចូលរួមបាន។

២. គ្រូបណ្ដុះបណ្ដាលសួរអ្នកចូលរួមថា៖

- តើអ្នកណាខ្លះដែលធ្លាប់បានចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅថ្នាក់រាជធានី ខេត្ត?
- តើកត្តាអ្វីខ្លះ ដែលធ្វើឱ្យវេទិកាទាំងនោះជាវេទិកាពិគ្រោះយោបល់? តើវាមានន័យយ៉ាងដូចម្ដេច?
- ហេតុអ្វីបានជាមានការរៀបចំវេទិកាទាំងនេះ? តើគេពិភាក្សាអ្វីខ្លះ?

គោលដៅនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ គឺដើម្បីចែករំលែកផែនការរបស់ក្រុមប្រឹក្សាក៏ដូចជា ស្វែងយល់ពីមតិត្រលប់ និងយោបល់ផ្សេងៗដែលពាក់ព័ន្ធនឹងផែនការនេះ។ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ គឺធានាឱ្យមានការពិចារណាលើតម្រូវការរបស់គ្រប់ក្រុមទាំងអស់ដើម្បីឱ្យពួកគេមានឱកាសទទួលបានប្រយោជន៍ពីសកម្មភាពដែលបានគ្រោងទុក។

ពិនិត្យមើលថាតើចំណុចខាងលើត្រូវបានលើកឡើងដោយអ្នកចូលរួមដែរឬទេ។ ប្រសិនបើមិនបានលើកឡើងទេ សូមលើកឡើងពីចំណុចនេះ និងសុំឱ្យអ្នកចូលរួមបញ្ជាក់។ សូមសរសេរពីគោលដៅនៃកិច្ចប្រជុំទាំងនេះលើក្រដាសផ្ទាំងធំ ទុកសម្រាប់មើលនាពេលក្រោយទៀត។

**វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានី ខេត្ត**

នៅខែមិថុនា រៀងរាល់ឆ្នាំ ក្រុមប្រឹក្សារាជធានី ខេត្តត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅក្នុងរាជធានី ខេត្តរបស់ខ្លួន ។

- **វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ទាំងនេះមានគោលដៅ ៖** ផ្ដល់ព័ត៌មានដល់ក្រុមប្រឹក្សារាជធានី ខេត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀតអំពីសកម្មភាពនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដែលឆ្លើយតបទៅនឹងសំណើនានារបស់ប្រជាពលរដ្ឋ និងពិភាក្សាពីសំណើ និងសំណូមពរសម្រាប់សកម្មភាពនាឆ្នាំ

បន្ទាប់។

- **អ្នកចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ៖** ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ គណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ តំណាងសហគមន៍ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ប្រចាំឆ្នាំ គឺជាឧបករណ៍ដ៏សំខាន់មួយ ដើម្បីលើកកម្ពស់គណនេយ្យភាព តម្លាភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការនៃអភិបាលកិច្ចល្អរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

វេទិកានេះមានគោលដៅ ៖

- **ផ្តល់ព័ត៌មាន ៖** ក្រុមប្រឹក្សារាយការណ៍ពីសកម្មភាពនានាក្នុងឆ្នាំកន្លងទៅ និងទិសដៅសម្រាប់ឆ្នាំបន្ទាប់
- **ផ្តល់ដំបូន្មាន ៖** ឱ្យអ្នកចូលរួមពិភាក្សាពីរបាយការណ៍ ផ្តល់ព័ត៌មានត្រលប់អំពីការអនុវត្តការងាររបស់ក្រុមប្រឹក្សា និងលើកសំណើសម្រាប់ឆ្នាំបន្ទាប់។
- **លើកកម្ពស់ការចូលរួម ៖** ប្រជាពលរដ្ឋអាចចូលរួមក្នុងការងារអភិបាលកិច្ចមូលដ្ឋាន តាមរយៈការលើកជាសំណើ និងការចែករំលែកការព្រួយបារម្ភរបស់ពួកគេ។
- **បង្កើនកិច្ចសហការ ៖** ក្រុមប្រឹក្សាទទួលបានព័ត៌មានបានប្រសើរជាងមុនពីតម្រូវការរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋមានការយល់ដឹងកាន់តែប្រសើរអំពីការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាបង្កើនការសហការគ្នារវាងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ និងរួមចំណែកស្វែងរកដំណោះស្រាយ ដើម្បីប្រយោជន៍របស់ប្រជាពលរដ្ឋ។

ការរៀបចំវេទិកាមួយ មាន ៣ ផ្នែកសំខាន់ៗ៖

១. **ការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់** ៖ ការកំណត់ពីរបៀបវារៈ ការអញ្ជើញប្រជាពលរដ្ឋ ការរៀបចំអ្នកសម្របសម្រួល និងអ្នកកត់កំណត់ហេតុ និងការរៀបចំសេចក្តីព្រាងឯកសារសម្រាប់ការពិភាក្សា។

២. **ការប្រារព្ធវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់** ៖ ការធានាយ៉ាងណាឱ្យប្រជាពលរដ្ឋទាំងអស់អាចចូលរួមដោយស្មើភាពគ្នា និងត្រូវបានលើកទឹកចិត្តឱ្យចូលរួមឱ្យបានសកម្មក្នុងការពិភាក្សា។

៣. **កិច្ចការដែលត្រូវធ្វើក្រោយវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់រួច** ៖ ការបូកសរុបការពិភាក្សា ផ្តល់ការអនុម័តលើសំណើដែលត្រូវបានលើកឡើង និងធ្វើការផ្សព្វផ្សាយរបាយការណ៍របស់វេទិកានេះជាសាធារណៈ។

**ដកស្រង់ចេញពី ៖** ឯកសារបច្ចេកទេសស្តីពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សម្រាប់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ឆ្នាំ២០១២។

៣. ការពិភាក្សាជាក្រុម ៖ គ្រូបណ្តុះបណ្តាលបែងចែកអ្នកចូលរួមជាក្រុម មានសមាជិក ៥នាក់ក្នុងមួយក្រុម ដើម្បីពិភាក្សាអំពីរបៀបរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់។ ឱ្យក្រុមនីមួយៗសរសេរចម្លើយរបស់ពួកគេ ឆ្លើយនឹងសំណួរខាងក្រោមលើក្រដាសផ្ទាំងធំ។ ការពិភាក្សាមាន រយៈពេល១៥នាទី។ សំណួរពិភាក្សាមានដូចខាងក្រោម ៖

- តើអ្នកណាជាអ្នកផ្តួចផ្តើមគំនិតឱ្យមានជាវេទិកា ?

- តើរបៀបវារៈ និងកាលបរិច្ឆេទនៃកិច្ចប្រារព្ធវេទិកាត្រូវបានព្រមព្រៀងគ្នា ដោយរបៀបណា ?
- តើអ្នកណាជាអ្នកអញ្ជើញប្រជាពលរដ្ឋ ?
- តើកិច្ចប្រារព្ធវេទិកា នេះរៀបចំនៅកន្លែងណា ?
- តើកិច្ចប្រារព្ធវេទិកានេះចំណាយពេលវេលាប៉ុន្មាន និងធ្វើឡើងនៅពេលណា ( ព្រឹក ឬរសៀល ) ?
- តើអ្នកណាជាប្រធានវេទិកា និងតើអ្នកណាសម្របសម្រួលការពិភាក្សា ?
- តើតម្រូវការនានាត្រូវបានកំណត់យ៉ាងដូចម្ដេច នៅក្នុងវេទិកានេះ ?
- តើវេទិកានេះត្រូវបានរៀបចំឡើងដោយរបៀបណា ដើម្បីឱ្យប្រជាពលរដ្ឋមកពីក្រុមផ្សេងៗគ្នា អាចរួមចំណែក នៅក្នុងវេទិកានេះ( ដូចជា បុរស ស្ត្រី ក្រុមជនជាតិដើមភាគតិច ក្រុមងាយរងគ្រោះ និងជនពិការជាដើម ) ?
- តើអ្នកដែលមិនអាចចូលរួមបាននឹងត្រូវបានផ្ដល់ព័ត៌មានពីលទ្ធផលនៃវេទិកានេះដោយរបៀបណា ?

៤. បន្ទាប់មក ពិភាក្សាក្រុមធំ ផ្ដោតការយកចិត្តទុកដាក់លើសំណួរចុងក្រោយ។ គ្រូបណ្ដុះបណ្ដាល សួរទៅក្រុមទាំងអស់ថា ហេតុអ្វីបានជាការចូលរួមពីប្រជាពលរដ្ឋគ្រប់ៗគ្នា ក្នុងកិច្ចប្រជុំវេទិកាពិគ្រោះយោបល់ មានសារៈសំខាន់ ?។ ចុងបញ្ចប់គ្រូបណ្ដុះបណ្ដាលសង្ខេបដោយបង្ហាញស្លាយនូវខ្លឹមសារ ៖

ក ). ជនពិការ អាចចូលរួមជាមួយសមាជិកផ្សេងទៀតរបស់សហគមន៍ ដើម្បីរួមចំណែកក្នុងការផ្ដល់ជាគំនិត ដើម្បីអភិវឌ្ឍន៍មូលដ្ឋាន ឬសហគមន៍របស់ពួកគេ។

ខ ). ការបង្កើនការចូលរួម ទាមទារឱ្យមានការស្វែងរកដំណោះស្រាយជាក់ស្ដែង ដែលអាចជំនះនូវឧបសគ្គនានា។

គ ). ការបង្កើនការចូលរួមមិនមែនមាននន័យត្រឹមតែថា មានវត្តមានជនពិការប៉ុណ្ណោះទេ ប៉ុន្តែពួកគេអាចរួមចំណែកដូចអ្នកដទៃទៀតផងដែរ។



គ្រូបណ្ដុះបណ្ដាលពន្យល់ថា ចំណុចខាងលើ គឺស្ថិតក្នុងចលនាពិការភាព និងត្រូវបានក្តោបក្នុងពាក្យស្លោក ៖ "ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើពុំមានការចូលរួមពីយើងនោះ" ដែលមានន័យថា ៖

- ជនពិការគួរអាចនិយាយ និងធ្វើការសម្រេចចិត្តដោយខ្លួនឯងលើបញ្ហាដែលមានផលប៉ះពាល់មកលើពួកគេ។
- ចាំបាច់ត្រូវតែធានាឱ្យមានការចូលរួមដ៏សកម្មរបស់ជនពិការ។
- ជនពិការអាចចូលរួមតាមបែបផែនផ្សេងៗគ្នា ៖
  - ចូលរួម ក្នុងការរៀបចំផែនការ និងកម្មវិធីនានា
  - ទទួលបានប្រយោជន៍ពីកម្មវិធី និងសេវានានា
  - ចូលរួមក្នុងការងារគ្រប់គ្រង និងដឹកនាំ។

៥. គ្រូបណ្ដុះបណ្ដាលណែនាំអ្នកចូលរួម ទៅតាមបញ្ជីផ្ទៀងផ្ទាត់សម្រាប់កិច្ចប្រជុំដែលមាន ការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ រួមទាំងជនពិការ ដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់អ្នកចូលរួម។

គ្រូបណ្តុះបណ្តាលសួរសំណួរ ៖ សូមគិតពីកិច្ចប្រជុំ(វេទិកា)ពិគ្រោះយោបល់ចុងក្រោយដែលអ្នកបានចូលរួម និងបំពេញបញ្ជីផ្ទៀងផ្ទាត់ ផ្អែកតាមបទពិសោធន៍ក្នុងកិច្ចប្រជុំ(វេទិកា)នោះ។ ក្រោយពីបានបំពេញបញ្ជីផ្ទៀងផ្ទាត់នេះហើយ សួរសំណួរ ៖

**ឧបសម្ព័ន្ធ ទី៨**

- តើអ្នកណាខ្លះ ដែលឆ្លើយថា"ទេ" ចំពោះសំណួរទី១? ហេតុអ្វីបានជាដូច្នេះ?
- តើមានចំណុចណាក្នុងបញ្ជីផ្ទៀងផ្ទាត់នេះ ដែលអ្នកមិនបានដឹងកន្លងមកទេ? ប្រសិនបើ មានតើចំណុចណាខ្លះ?

**កំណត់សម្គាល់ ៖**

ក្រុមជួយខ្លួនឯង ឬអង្គការជនពិការអាចកៀរគរជនពិការក្នុងតំបន់ ដែលពួកគេមានសកម្មភាព។ អ្នកចូលរួមគួរដឹងថា ក្នុងរាជធានី ខេត្តរបស់ពួកគេមានវត្តមានអង្គការជនពិការផ្សេងៗប៉ុន្មាន។ ក្នុងជំពូកទី៨នៃសៀវភៅណែនាំសម្រាប់អ្នកចូលរួម ក៏ដូចជានៅក្នុងប្រអប់ឧបករណ៍ សម្រាប់ការបញ្ចូលពិការភាពនៅកម្ពុជា "**អនឡាញ**" មានបញ្ជីឈ្មោះអង្គការទាំងនេះ។

៦. គ្រូបណ្តុះបណ្តាលសួរអ្នកចូលរួម តើពួកគេស្គាល់អង្គការជនពិការណាខ្លះ ដែលអាចជួយពួកគេ ក្នុងការកៀរគរជនពិការក្នុងរាជធានី ខេត្តរបស់ពួកគេបាន?

៧. បញ្ចប់ ដោយបង្ហាញពីសារគន្លឹះរបស់មេរៀននេះ។ សូមបញ្ជាក់ឱ្យបានច្បាស់ថា បើទោះបីជាខ្លឹមសារនៃកិច្ចប្រជុំ(វេទិកា)ពិគ្រោះយោបល់អាចមានលក្ខណៈផ្សេងៗគ្នាក៏ដោយ បញ្ជីផ្ទៀងផ្ទាត់ ដើម្បីឱ្យកិច្ចប្រជុំ(វេទិកា) មានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំងជនពិការ អាចយកទៅអនុវត្តបានចំពោះគ្រប់កិច្ចប្រជុំ(វេទិកា)ទាំងអស់។

គ្រូបណ្តុះបណ្តាលបង្ហាញសារគន្លឹះក្នុងមេរៀនជំពូកទី៦ តាមរយៈស្លាយនូវខ្លឹមសារដូចខាងក្រោម ៖

- ជនពិការ គឺជាប្រជាពលរដ្ឋ ដូចគេឯងដែរ ដូច្នេះផែនការ និងកម្មវិធីនានារបស់រដ្ឋាភិបាលមានឥទ្ធិពលលើពួកគេ។
- ជនពិការត្រូវការការលើកទឹកចិត្តក្នុងការនិយាយ និងសម្រេចចិត្តសម្រាប់ខ្លួនឯង
- ដើម្បីឱ្យជនពិការអាចចូលរួមបានយ៉ាងសកម្ម ចាំបាច់ត្រូវមានការត្រៀមរៀបចំមុនកិច្ចប្រជុំ(វេទិកា)។
- ប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ ដើម្បីរៀបចំកិច្ចប្រជុំ(វេទិកា)ពិគ្រោះយោបល់ ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ រួមទាំងជនពិការ។

<table>
<tr><td colspan="2">មេរៀន៦.២<br>សង្ខេបមេរៀនជំពូកទី៦</td></tr>
<tr><td colspan="2">គោលដៅ ៖ រំលឹកអ្នកចូលរួមអំពីអ្វីដែលយើងបានរៀននៅថ្ងៃនេះ និងបញ្ជាក់ឱ្យបានច្បាស់ពីសំណួរដែលនៅសេសសល់នានា។</td></tr>
<tr><td>រយៈពេល</td><td>១០នាទី</td></tr>
</table>

គ្រូបណ្តុះបណ្តាលផ្តល់សេចក្តីសង្ខេបនៅចុងជំពូកនេះ ដោយមើលតាមសៀវភៅណែនាំសម្រាប់អ្នកចូលរួម។ ការសង្ខេបត្រូវបានបង្ហាញតាមរយៈស្លាយ មានដូចខាងក្រោម ៖

១. ប្រសិនបើ ពុំមានការគិតគូរពីជនពិការនោះទេ ជារឿយៗពួកគេត្រូវបានគេផាត់ចេញពីសង្គម
២. ការចូលរួម គឺសំដៅលើការស្ថិតនៅក្នុងក្រុមមួយធំ មានវត្តមាន ត្រូវបានគេផ្តល់តម្លៃឱ្យ និងអាចរួមចំណែកបាន
៣. អ្នកដែលមានពិការភាពខុសៗគ្នាជួបនឹងឧបសគ្គខុសៗគ្នា ដែលរារាំងពួកគេមិនឱ្យចូលរួម។
៤. ប្រសិនបើ មានឧបសគ្គ ក៏មានដំណោះស្រាយផងដែរ
៥. "ពុំមានអ្វីសម្រាប់យើង ដោយពុំមានការចូលរួមពីយើងនោះទេ" មានន័យថាជនពិការគួរចូលរួមក្នុងគ្រប់សកម្មភាពទាំងអស់ ដែលមានផលប៉ះពាល់ដល់ពួកគេ។
៦. គេចាំបាច់ត្រូវធ្វើសកម្មភាពជាក់ស្តែង ដើម្បីឱ្យកិច្ចប្រជុំនានាមានការចូលរួមពីជនពិការ។

# ជំពូកទី៧

# ការដាក់បញ្ចូលពិការភាពនៅក្នុង
# ដំណើរការកសាងផែនការ

# ជំពូកទី៧
# ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ

## ក). សេចក្តីពិពណ៌នា

ជំពូកនេះមានគោលដៅធ្វើឱ្យដំណើរការអភិវឌ្ឍន៍មានការចូលរួមពីជនពិការ និងចាត់វិធានការដាក់ស្តែង ដើម្បីឱ្យមានការដាក់បញ្ចូលពិការភាព។

នៅចុងបញ្ចប់នៃជំពូកនេះ អ្នកចូលរួម ៖

- បានកំណត់ពីវិធានការដាក់ស្តែង ដើម្បីលើកកម្ពស់ការចូលរួមរបស់ជនពិការ
- យល់ដឹងពីចំណុចចាំបាច់ដែលត្រូវសហការជាមួយនឹងអង្គការធ្វើការផ្នែកពិការភាព។

## ខ). មាតិកាមេរៀន

| លរ | មេរៀន | រយៈពេល | សម្ភារៈ និងឯកសារ |
|---|---|---|---|
| ៧.១. | ការវិភាគលើគម្រោងដែលមានស្រាប់ | ៧០នាទី | • ក្រដាសផ្ទាំងធំ ក្រដាសកាតពណ៌<br>• ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលមានស្រាប់ |
| ៧.២. | សកម្មភាពជាក់លាក់ ដើម្បីឱ្យមានការចូលរួមពីជនពិការ | ៣០នាទី | |
| ៧.៣. | សង្ខេបមេរៀនជំពូកទី៧ | ៥នាទី | សូមមើលសៀវភៅណែនាំសម្រាប់អ្នកចូលរួម |
| **សរុប** | | ១០៥នាទី | |

! ជំពូកនេះ បើអាចគួរអញ្ជើញតំណាងពីអង្គការដែលធ្វើការផ្នែកពិការភាព។ ហេតុនេះ មុនការបណ្តុះបណ្តាល សូមជម្រាបដល់តំណាងអង្គការទាំងនោះអំពីកាលបរិច្ឆេទ និងពេលវេលា ដែលពួកគេគួរមក។ ពន្យល់ពួកគេថា វគ្គបណ្តុះបណ្តាលនេះមានគោលដៅធ្វើការវិភាគលើគម្រោងនានា ដើម្បីដាក់បញ្ចូលពិការភាព ហើយពួកគេនឹងត្រូវស្នើឱ្យផ្តល់គំនិតយោបល់ និងចូលរួមក្នុងការពិភាក្សាផងដែរ។

! ជំពូកនេះ យើងនឹងពិភាក្សាលើគម្រោងដែលមានស្រាប់ ដែលបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ឬគម្រោងទទួលបានការគាំទ្រថវិកាក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ។ មួយថ្ងៃមុនពេលបណ្តុះបណ្តាលជំពូកនេះ ប្រាប់សមាជិកក្រុមប្រឹក្សាឱ្យយកមកជាមួយនូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ឬបញ្ជីគម្រោងពីសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌចុងក្រោយ។

| |
|---|
| មេរៀន៧.១ ដល់មេរៀន៧.៣ នៅក្នុងជំពូកនេះ ត្រូវបានកែសម្រួលឱ្យស្របទៅតាមរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលរាជធានី ខេត្ត នេះមានន័យថា ៖<br>• ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ត្រូវដំណើរការជាមួយគម្រោងក្នុងផែនការឃុំ សង្កាត់<br>• ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់រាជធានី ខេត្ត ត្រូវប្រើប្រាស់គម្រោងដែលត្រូវបានស្នើឡើងក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់រាជធានី ខេត្ត។<br>មេរៀន៧.១ ដល់មេរៀន៧.៣ មានចំនួន៣ជង គឺរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលរាជធានី ខេត្ត ដែលមាននិមិត្តសញ្ញាដូចខាងក្រោម ដើម្បីបង្ហាញអំពីវគ្គណាដែលត្រូវបណ្តុះបណ្តាលនៅថ្នាក់ក្រោមជាតិមួយណា។<br>ប្រអប់អត្ថបទ ដែលមានព័ត៌មានសារតាអំពីកិច្ចប្រជុំទាំងនេះ ត្រូវបានផ្តល់បន្ថែមសម្រាប់អ្នកបណ្តុះបណ្តាល។ សូមអានព័ត៌មាននេះដោយប្រុងប្រយ័ត្ន មុននឹងសម្របសម្រួលជំពូកនេះ។<br>**ថ្នាក់ឃុំ សង្កាត់**  **ថ្នាក់ក្រុង ស្រុក ខណ្ឌ**  **ថ្នាក់រាជធានី ខេត្ត**  |

**គ.១). ដំណើរការសម្របសម្រួលក្រុមគោលដៅនៅថ្នាក់ឃុំ សង្កាត់**

| | |
|---|---|
|  | **មេរៀន៧.១**<br>**ការវិភាគលើកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដែលមានស្រាប់** |
| **គោលដៅ** ៖ វិភាគពីគម្រោងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដែលមានស្រាប់ ដើម្បីវាយតម្លៃថា តើគម្រោងទាំងនេះមានការដាក់បញ្ចូលពិការភាពយ៉ាងដូចម្តេច។ | |
| **រយៈពេល** | ៧០នាទី |

**កំណត់សម្គាល់ ៖**

គោលដៅមេរៀននេះ គឺដើម្បីឱ្យអ្នកចូលរួមគិតពីការដាក់បញ្ចូលពិការភាពនៅក្នុងគម្រោងទាំងអស់របស់រដ្ឋបាលឃុំ សង្កាត់។ ប្រជាពលរដ្ឋជាច្រើនគិតថា គម្រោងពិសេសសម្រាប់ជនពិការ ដូចជា គម្រោងស្តារលទ្ធភាពពលកម្ម ឬការអប់រំពិសេស គឺជាគម្រោងសម្រាប់ជនពិការ។ ប៉ុន្តែគម្រោងទាំងអស់ ដូចជា

ការអប់រំសាធារណៈ សកម្មភាពបង្កើនប្រាក់ចំណូល ឬព័ត៌មានសាធារណៈជាដើម ក៏ជាគម្រោងដែលមានភាពពាក់ព័ន្ធនឹងជនពិការផងដែរ នេះគឺជាសារដ៏សំខាន់ នៅចុងបញ្ចប់នៃមេរៀន៧.២នេះ។

**ជំហានទី១ ៖**

១. គ្រូបណ្តុះបណ្តាលណែនាំអំពីប្រធានបទមេរៀន និងគូសបញ្ជាក់ថា ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដែលមានស្រាប់ ត្រូវបានយកមកប្រើប្រាស់នៅក្នុងមេរៀននេះ ដើម្បីវិភាគឱ្យកាន់តែស៊ីជម្រៅអំពីអ្វីដែលអាចធ្វើបាន ដើម្បីធ្វើឱ្យផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ មានការដាក់បញ្ចូល និងគិតគូរដល់ជនពិការ។

២. គ្រូបណ្តុះបណ្តាលសួរទៅអ្នកចូលរួម តើអ្នកណាខ្លះ ចងចាំអំពីអត្ថន័យពាក្យស្លោក "ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើ ពុំមានការចូលរួមពីយើង" តើមានអត្ថន័យយ៉ាងដូចម្តេច? រួចឱ្យអ្នកចូលរួមស្ម័គ្រចិត្ត១-៣នាក់ផ្តល់ចម្លើយ។

| **"ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើពុំមានការចូលរួមពីយើង"** មានន័យថា ៖ |
|---|
| ជនពិការគួរចូលរួមបញ្ចេញមតិ នៅក្នុងគ្រប់សកម្មភាពទាំងអស់ ដែលមានផលប៉ះពាល់លើពួកគេ។ ជាពិសេស នៅពេលកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលមានការដាក់បញ្ចូលពិការភាព នោះជនពិការចាំបាច់ត្រូវតែអាចចូលរួមចំណែកក្នុងដំណើរការនោះ។ |

៣. គ្រូបណ្តុះបណ្តាលចែកអ្នកចូលរួមជាក្រុមទៅតាមរដ្ឋបាលរបស់ពួកគេ រួចឱ្យក្រុមនីមួយៗកំណត់ពីបញ្ជីគម្រោងដែលមានថវិកាគាំទ្រ ហើយដែលកំពុងត្រូវបានអនុវត្តក្នុងឃុំ សង្កាត់របស់ពួកគេ។ អ្នកចូលរួមសរសេរឈ្មោះគម្រោងទាំងនេះលើក្រដាសផ្ទាំងធំ។

៤. រួចក្រុមនីមួយៗពិភាក្សាទៅលើគម្រោងទាំងនោះ ផ្អែកតាមសំណួរ តើគម្រោងណាខ្លះក្នុងចំណោមគម្រោងទាំងនេះដែលពាក់ព័ន្ធជាមួយនឹងជនពិការ? ហេតុអ្វីបានជាគម្រោងទាំងនេះពាក់ព័ន្ធជាមួយនឹងជនពិការ?។ បន្ទាប់ពីពិភាក្សា រយៈពេល៥នាទី រួចឱ្យក្រុមចូលមកពិភាក្សាក្នុងក្រុមធំវិញ។

**កំណត់សម្គាល់ ៖**

ជាដំបូង អ្នកចូលរួមនឹងកំណត់រកគម្រោងដែលផ្តោតលើជនពិការ ដូចជាគម្រោងស្តារលទ្ធភាពពលកម្ម។ មូលហេតុដែលពួកគេលើកឡើងបែបនេះ ព្រោះតែអ្នកចូលរួមយល់ថា ជនពិការត្រូវការរទេះរុញ ហើយគម្រោងនេះនឹងត្រូវផ្តល់រទេះរុញ ឬដោយសារតែវាជាសាលារៀនពិសេសសម្រាប់កុមារពិការ។

៥. នៅក្នុងការពិភាក្សាក្នុងក្រុមធំ គ្រូបណ្តុះបណ្តាលសួរអ្នកចូលរួមនូវសំណួរខាងក្រោម ៖

- តើមានការពិគ្រោះយោបល់ជាមួយជនពិការដែរឬទេ នៅក្នុងអំឡុងពេលកំណត់ពីតម្រូវការ ឬបញ្ហារបស់ពួកគេ?
- តើមានជនពិការប៉ុន្មាននាក់ ដែលបានចូលរួមក្នុងសកម្មភាពគម្រោង?
- តើជនពិការគិតយ៉ាងដូចម្តេចអំពីគម្រោងនេះ? តើពួកគេចូលចិត្តគម្រោងនេះដែរឬទេ? តើធ្វើដូចម្តេច ដើម្បីដឹងថាពួកគេចូលចិត្ត ឬមិនចូលចិត្តគម្រោងនេះ?

**ជំហានទី២ ៖**

១. នៅក្នុងជំហានទី១ អ្នកចូលរួមបានលើកឡើងថា នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់មានតែគម្រោងមួយចំនួនប៉ុណ្ណោះ ដែលពាក់ព័ន្ធជាមួយនឹងជនពិការ។ គ្រូបណ្ដុះបណ្ដាលឱ្យអ្នកចូលរួមអានឈ្មោះគម្រោងដែលត្រូវបានលើកឡើងថា ជាគម្រោងសម្រាប់ជនពិការឱ្យបានឮៗ។

បន្ទាប់មក គ្រូបណ្ដុះបណ្ដាលឱ្យអ្នកចូលរួមពិនិត្យមើលគម្រោងផ្សេងទៀត ពីក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដែលពួកគេមិនបានលើកឡើងថាជាគម្រោងដែលពាក់ព័ន្ធជាមួយនឹងជនពិការ រួចសួរទៅអ្នកចូលរួម ៖

- តើគម្រោងទាំងនេះ ពុំបានផ្ដល់ប្រយោជន៍ដល់ជនពិការទេឬ? តើធ្វើដូចម្ដេច ដើម្បីដឹងថាគម្រោងពុំបានផ្ដល់ប្រយោជន៍ដល់ជនពិការ?
- តើជនពិការអាចចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោងទាំងនេះបានដែរឬទេ?
- តើគម្រោងទាំងនេះ ផ្ដល់ផលប្រយោជន៍សម្រាប់ជនពិការទាំងអស់ ឬក៏សម្រាប់តែពិការភាពតាមប្រភេទជាក់លាក់?

២. គ្រូបណ្ដុះបណ្ដាលចែកអ្នកចូលរួមជា៤ក្រុម ឱ្យក្រុមនីមួយៗជ្រើសរើសគម្រោងមួយក្នុងចំណោមគម្រោងដែលមិនត្រូវបានគេចាត់ទុកថាពាក់ព័ន្ធជាមួយនឹងជនពិការ។ ប្រសិនបើអាច ក្រុមនីមួយៗគួរជ្រើសរើសគម្រោងមួយក្នុងផ្នែកផ្សេងៗគ្នា ដូចជា ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងរដ្ឋបាលនិងសន្ដិសុខសណ្ដាប់ធ្នាប់សាធារណៈ។

៣. គ្រូបណ្ដុះបណ្ដាលពន្យល់អ្នកចូលរួមថា ៖ គ្មានទេដែលថា **មានគម្រោងមួយចំនួន ដែលពាក់ព័ន្ធជាមួយនឹងជនពិការ ហើយគម្រោងមួយចំនួនមិនពាក់ព័ន្ធជាមួយនឹងជនពិការ**។ ជនពិការ គឺជាផ្នែកមួយនៃសហគមន៍របស់យើង។ រាល់គម្រោងទាំងអស់ ដែលពាក់ព័ន្ធជាមួយនឹងប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់យើង ក៏ពាក់ព័ន្ធជាមួយជនពិការផងដែរ។ ដូច្នេះ គ្រប់គម្រោងទាំងអស់ **ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួលខុសត្រូវក្នុងការធានាឱ្យជនពិការអាចទទួលបានផលប្រយោជន៍ពីគម្រោងទាំងនោះ និងមិនត្រូវបានផាត់ចេញពីគម្រោងតទៅទៀតឡើយ** ហើយត្រូវតែដាក់បញ្ចូលជនពិការនៅរាល់គ្រប់ដំណើរការរបស់សហគមន៍ ដោយសារតែពួកគេក៏ជាផ្នែកមួយនៃសហគមន៍របស់យើង។



នៅពេលខ្លះជនពិការមិនអាចបានចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោង ដោយសារតែមានឧបសគ្គដែលរារាំងពួកគេ ដូចដែលយើងបានរៀនកន្លងមក បើទោះបីជា គម្រោងនោះ ពួកគេចូលចិត្ត ឬមានសារៈសំខាន់ខ្លាំងចំពោះពួកគេក៏ដោយ។

៤. គ្រូបណ្ដុះបណ្ដាលពន្យល់អ្នកចូលរួមថា ៖ យើងពិនិត្យលើគម្រោងដែលយើងបានជ្រើសរើសកន្លងមក។ ពីខាងដើមអ្នកចូលរួមមួយចំនួនបានលើកឡើងថា មិនមែនគម្រោងទាំងអស់សុទ្ធតែពាក់ព័ន្ធជាមួយនឹងជនពិការឡើយ ប៉ុន្តែតាមពិតគម្រោងទាំងអស់នេះពាក់ព័ន្ធនឹងពួកគេ ដោយសារតែជនពិការ គឺជាសមាជិកស្មើភាពក្នុងសហគមន៍។

យើងនឹងធ្វើការវិភាគថា តើឧបសគ្គណាខ្លះ ដែលរារាំងជនពិការមិនឱ្យចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោងឃុំ សង្កាត់? តើយើងអាចនឹងដកឧបសគ្គទាំងនេះ ដោយរបៀបណា?។

គ្រូបណ្តុះបណ្តាលឱ្យក្រុមនីមួយៗពិនិត្យមើលតារាងខាងក្រោម និងវិភាគគម្រោងរបស់ពួកគេ ដោយសរសេរពីឧបសគ្គទាំងនេះ ហើយឱ្យពួកគេគិតរកដំណោះស្រាយ តើអ្នកណាទទួលខុសត្រូវក្នុងការចាត់វិធានការដោះស្រាយ និងថាតើចំណាយសម្រាប់វិធានការនេះមានកម្រិតទាប មធ្យម ឬខ្ពស់។ លទ្ធផលពិភាក្សាត្រូវបានរៀបចំតាមទម្រង់តារាងខាងក្រោមលើក្រដាសផ្ទាំងធំ។ គ្រូបណ្តុះបណ្តាលអាចអញ្ជើញ តំណាងមកពីអង្គការជនពិការឱ្យចូលរួមក្នុងក្រុម និងផ្តល់គំនិត។

សូមមើលឧទាហរណ៍ក្នុងតារាងខាងក្រោម ៖

| **គម្រោង ៖ សាលាបឋមសិក្សាថ្មី** | | | | |
|---|---|---|---|---|
| **ប្រភេទ** | **ឧបសគ្គ** | **ដំណោះស្រាយ** | **អ្នកទទួលខុសត្រូវ** | **ចំណាយ** (ខ្ពស់ មធ្យម ទាប) |
| បង្កភាព ងាយស្រួល និងលទ្ធភាព ទទួលបាន | សាលារៀនមិនមានភាពងាយស្រួលសម្រាប់អ្នកប្រើរទេះរុញ | ត្រួតពិនិត្យលើភាពងាយស្រួល និងសង់ជម្រាល និងបង្គន់ដែលងាយស្រួលក្នុងការប្រើប្រាស់ | មេឃុំ រួមជាមួយការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ | មធ្យម |
| ឥរិយាបថ | កុមារពិការទទួលរងការសម្លុតឬធ្វើបាប ដោយក្មេងផ្សេងទៀត នៅសាលារៀន | លើកកម្ពស់ការយល់ដឹងនៅសាលារៀន | នាយកសាលា និងអង្គការជនពិការនៅមូលដ្ឋាន | ទាប |
| ការប្រាស្រ័យទាក់ទង | គ្រូបង្រៀនមិនដឹងពីរបៀបបង្រៀនកុមារដែលខ្សោយគំហើញ | បណ្តុះបណ្តាលគ្រូនូវជំនាញក្នុងការបង្រៀនកុមារពិការ | មេឃុំត្រូវសម្របសម្រួលជាមួយការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ និងអង្គការមិនមែនរដ្ឋាភិបាល | ទាប |
| ការចូលរួម | មិនដឹងពីចំនួនកុមារពិការ ដែលនាំឱ្យគេមិនអាចវាយតម្លៃ ថាតើមានកុមារប៉ុន្មាននាក់ដែល គួរចុះឈ្មោះចូលរៀនក្នុងសាលារៀន | រាប់ចំនួនកុមារពិការ និងអាយុរបស់ពួកគេ | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (តាមរយៈការរៀបចំផែនទីសេវាសង្គម) | ទាប |

៥. គ្រូបណ្តុះបណ្តាលដើរមើលជុំវិញ នៅពេលដែលក្រុមកំពុងធ្វើលំហាត់នេះ ដើម្បីពិនិត្យមើលថាតើពួកគេយល់ លំហាត់នេះ ដែរឬទេ ដើម្បីផ្តល់ការគាំទ្រ ឬឆ្លើយនឹងសំណួរនានា។

ប្រសិនបើ អ្នកចូលរួមមានការលំបាកក្នុងការចាប់ផ្តើមគិតពីចំណុចនេះ គ្រូបណ្តុះបណ្តាលអាចផ្តល់ក្រដាសកាតពណ៌សម្រាប់បំផុសគំនិត។ ក្រដាសកាតពណ៌សម្រាប់បំផុសគំនិតទាំងនេះ សរសេរជាស្រេចនូវខ្លឹមសារដូចមានក្នុងតារាងខាងក្រោម។ សមាជិក ក្រុមម្នាក់អាចអានខ្លឹមសារក្នុងក្រដាសកាតពណ៌។ ក្រដាសកាតពណ៌ទាំងនេះ(ក្រុមនីមួយៗមានក្រដាសកាតពណ៌សរុបចំនួន១០)មានសំណួរ ឬកំណត់សំគាល់ ផ្អែកលើរឿងនៃករណីសិក្សាទាំង៤។ ក្រដាសកាតពណ៌នេះ ក៏នឹងអាចជួយឱ្យក្រុមចាប់ផ្តើមគិតពីគម្រោង និងពីឧបសគ្គនានាចំពោះគម្រោង។

**ខ្លឹមសារនៅលើក្រដាសកាតពណ៌សម្រាប់បំផុសគំនិត ៖**

- ខ្ញុំអាចទៅដល់ទីនោះ ដោយប្រើរទេះរបស់ខ្ញុំ! (ស្រីមុំ)។
- គ្រូបានបណ្តោយឱ្យក្មេងឯទៀត សម្លុត ឬធ្វើបាបខ្ញុំ (មករា)។
- តើអ្នកដឹងថាតើបង្គន់នេះអាចប្រើប្រាស់បានដោយជនពិការដែរឬទេ?(ស្រីមុំ)។
- មេភូមិបានខិតខំដើម្បីឱ្យខ្ញុំទទួលបានលិខិតអញ្ជើញចូលរួមក្នុងកិច្ចប្រជុំទាន់ពេលវេលា(សុផល)។
- ខ្ញុំអាចតាមទាន់ការពិភាក្សាទាំងអស់ ដោយសារតែអ្នកបណ្តុះបណ្តាលបានខិតខំពន្យល់បានក្បោះក្បាយ ពីរូបភាពទាំងអស់(បុប្ផា)។
- ខ្ញុំចង់យល់ច្បាស់ ថាតើដំណាំណា ដែលខ្ញុំចាំបាច់ត្រូវដាំ ដើម្បីបានចំណេញ (មករា)។
- អ្វីដែលល្អគឺ អ្នកឯទៀតផ្តល់ពេលវេលាឱ្យខ្ញុំ ដើម្បីឱ្យខ្ញុំអាចផ្តល់នូវគំនិតយោបល់បាន(សុផល)។
- ជនពិការចង់ចូលរួមនៅក្នុងការអភិវឌ្ឍឃុំ ប៉ុន្តែយើងក៏មានតម្រូវការជាក់លាក់ ដើម្បីជួយឱ្យយើងចូលរួមក្នុងសកម្មភាពក្នុងឃុំដែរ។ ឧទាហរណ៍ ខ្ញុំត្រូវការរទេះរុញ(ស្រីមុំ) ។
- ស្ត្រីពិការជួបការលំបាកជាងបុរសពិការ(ថាវី)។
- មនុស្សផ្សេងទៀត រាប់អានខ្ញុំដោយការគោរព ពួកគេដឹងថា ខ្ញុំអាចរកស៊ីចិញ្ចឹមជីវិតបាន នាពេលឥឡូវនេះ (មករា)។

៦. បន្ទាប់ពីពិភាក្សារួច គ្រូបណ្តុះបណ្តាលឱ្យក្រុមនីមួយៗបិទតារាងលទ្ធផលពិភាក្សា(លើក្រដាសផ្ទាំងធំ) តាមក្រុមនីមួយៗ នៅកន្លែងផ្សេងៗពីគ្នាជុំវិញបន្ទប់ និងជ្រើសរើសតំណាងម្នាក់ឱ្យចាំនៅទីតាំងនៃក្រដាសផ្ទាំងធំ។ គ្រូបណ្តុះបណ្តាល អ្នកចូលរួមដែលនៅសល់ដើរពិនិត្យមើល និងសួរសំណួរឬផ្តល់យោបល់ផ្សេងៗ ដោយសរសេរលើក្រដាសកាតពណ៌ ហើយបិទលើក្រដាសផ្ទាំងធំទាំងនោះ។

គោលដៅរបស់លំហាត់នេះ គឺចង់ឱ្យអ្នកចូលរួមយល់ថា គម្រោងមួយចំនួននៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់មិនមានការដាក់បញ្ចូលពិការភាព និងមិនមានការចូលរួមពីជនពិការទេ ដោយសារតែឧបសគ្គនានាដូច ដែលបានបង្ហាញក្នុងមេរៀនមុនៗ។ គ្រូបណ្តុះបណ្តាលបញ្ជាក់ថា គេអាចធ្វើអ្វីមួយ ដើម្បីដោះស្រាយឧបសគ្គទាំងនេះបាន ដោយមិនចាំបាច់ចំណាយថវិកាច្រើននោះទេ គ្រាន់តែត្រូវការ ការវិនិយោគពេលវេលា និងការប្តេជ្ញាចិត្ត ដើម្បីការដាក់បញ្ចូលពិការភាព។

## មេរៀន៧.២
## សកម្មភាពជាក់លាក់សម្រាប់ការដាក់បញ្ចូលពិការភាព

| | |
|---|---|
| **គោលដៅ** ៖ | កំណត់សកម្មភាពជាក់លាក់ ដើម្បីឱ្យគម្រោងដែលបានលើឡើងក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដែលមានការដាក់បញ្ចូលពិការភាព។ |
| **រយៈពេល** | ៣០នាទី |

១. គ្រូបណ្ដុះបណ្ដាលប្រាប់អ្នកចូលរួមថា នៅក្នុងលំហាត់មុន យើងបានប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដែលមានស្រាប់ ដើម្បីពិនិត្យលើឧបសគ្គនានា ដែលជនពិការជួបប្រទះ និងអ្វីដែលយើងអាចធ្វើបាន ដើម្បីដកចេញនូវឧបសគ្គដែលរាំងដល់ការចូលរួមរបស់ពួកគេ។

ឥឡូវនេះ លើកអំពីគម្រោងថ្មីមួយ ដើម្បីបង្ហាញដល់អ្នកចូលរួម **ឧទាហរណ៍** ៖ គម្រោងសាងសង់សាលាបឋមសិក្សាថ្មីមួយ។

គ្រូបណ្ដុះបណ្ដាលសួរថា ៖ តើបញ្ហាពាក់ព័ន្ធនឹងការបង្កភាពងាយស្រួលសម្រាប់ជនពិការអាចដោះស្រាយបានល្អបំផុតនៅពេលណា ៖ មុន ឬក្រោយការសាងសង់? **ចម្លើយគឺ ៖ មុនពេលសាងសង់ ដោយសារតែនៅពេលនោះគេងាយស្រួលបញ្ចូលវាទៅក្នុងគម្រោង ដោយប្រើប្រាស់មាត្រដ្ឋានឱ្យបានត្រឹមត្រូវ។** បញ្ចប់ដោយនិយាយថា ឧបសគ្គមួយចំនួនអាចបញ្ចៀសបាន នៅពេលដែលជនពិការចូលរួមនៅក្នុងដំណាក់កាលដំបូងនៃការរៀបចំគ្រោងការគម្រោង។

២. គ្រូបណ្ដុះបណ្ដាលបង្ហាញពីវិធីសាស្ត្ររៀបចំ និងកសាងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដែលមាន៣ជំហាន ដោយពន្យល់ត្រួសៗពីសកម្មភាពក្នុងជំហាននីមួយៗ ដើម្បីឱ្យគ្រប់គ្នាដឹងពីអ្វីដែលកើតឡើងក្នុងជំហាននីមួយៗ។

### ជំហានទី១
### ការប្រមូលព័ត៌មានស្ដីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

សកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តក្នុងជំហានទី១នេះមាន ៖

- គ.ផ.ថ រៀបចំប្រជុំ ដែលមានសមាជិក សមាជិកា គ.ផ.ថ ស្មៀនឃុំ សង្កាត់ ប្រធានភូមិ ឬតំណាងភូមិ ជនបង្គោលនានាក្នុងឃុំ សង្កាត់ ក្រុមការងារគណនេយ្យភាពសង្គម ក្រុមយុវជន តំណាងការិយាល័យជំនាញ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា។ កិច្ចប្រជុំនេះរៀបចំឡើងដើម្បីពិនិត្យ និងវិភាគលើស្ថានភាពទូទៅនៅក្នុងឃុំ សង្កាត់។
- មេភូមិនីមួយៗស្រង់យកបញ្ហា តម្រូវការ និងដំណោះស្រាយដែលពាក់ព័ន្ធនៅតាមភូមិរៀងៗខ្លួនទៅបង្ហាញ និងពិគ្រោះយោបល់ជាមួយតំណាងគ្រួសារ ប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន។ មេភូមិនីមួយៗត្រូវខិតខំជួប និងពិភាក្សាជាមួយតំណាងគ្រួសារប្រជាពលរដ្ឋឱ្យបាន៦០ភាគរយនៃចំនួនគ្រួសារសរុបក្នុងភូមិ(ប្រុស ស្រី កុមារ និងក្រុមជនងាយរងគ្រោះ)។
- មេភូមិទាំងអស់ត្រូវយកលទ្ធផលនៃការជួប និងពិភាក្សាជាមួយប្រជាពលរដ្ឋខ្លួនមកសាលាឃុំ

សង្កាត់ ដើម្បី គ.ផ.ថ ធ្វើការប្រជុំបូកសរុប ផ្ទៀងផ្ទាត់ និងកែសម្រួលតារាងបញ្ហា តម្រូវការ និងដំណោះស្រាយ។

- គ.ផ.ថ ត្រូវពិនិត្យពិចារណា និងកំណត់សកម្មភាពនានានៃការអនុវត្តមុខងារកាតព្វកិច្ចដែលរដ្ឋបាលឃុំ សង្កាត់បានទទួល និងឬគម្រោងនានាដែលត្រូវប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ។ គ.ផ.ថ ត្រូវស្រង់ សកម្មភាពឬគម្រោងទាំងនោះចូលក្នុង តារាង១.១.ក។

## ជំហានទី២

## ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

សកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តក្នុងជំហានទី២នេះមាន ៖

- ការពិនិត្យគម្រោង និងសកម្មភាពអាទិភាពឡើងវិញ
- ការត្រៀមរៀបចំចូលរួមសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- ការងារក្រោយសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ
- ការចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

## ជំហានទី៣

## ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

សកម្មភាពសំខាន់ក្នុងជំហានទី៣នេះ រួមមាន៖

- កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

៣. គ្រូបណ្តុះបណ្តាលបញ្ជាក់ប្រាប់អ្នកចូលរួមថា ៖ យើងអាចធ្វើសកម្មភាពអនុវត្តនៅជំហាននីមួយៗនៃវិធីសាស្ត្ររៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដើម្បីធានាឱ្យមានការចូលរួមពីក្រុមជនពិការ និងសួរថា តើក្រុមប្រឹក្សាឃុំ សង្កាត់គួរធ្វើសកម្មភាពអ្វីខ្លះ ដើម្បីធានាឱ្យមានការចូលរួមពីជនពិការ និងបញ្ចៀសនូវរាល់ឧបសគ្គទាំងឡាយ? បន្ទាប់ពី អ្នកចូលរួមបានឆ្លើយសំណួរនេះរួច គ្រូបណ្តុះបណ្តាលផ្តល់ចម្លើយ(ដូចដែលបានរៀបចំជាស្រេចក្នុងតារាងខាងក្រោម)។

**ឧទាហរណ៍ ៖** តើសកម្មភាពជាក់លាក់អ្វីខ្លះ ក្នុងជំហានទី១ ដែលគេអាចធ្វើបាន ៖ ការពិនិត្យលើបញ្ហា ឬតម្រូវការជាមួយនឹងប្រជាពលរដ្ឋឡើងវិញ? រំលឹកប្រាប់ពីជំពូកទី៦ (គ.១. ដំណើរការសម្របសម្រួលក្រុមគោលដៅនៅថ្នាក់ឃុំ សង្កាត់)។ ប្រសិនបើ ជនពិការត្រូវបានគេបញ្ចូលទៅក្នុងដំណាក់កាលកំណត់ពីតម្រូវការ នោះគម្រោងដែលត្រូវបានជ្រើសរើសនឹងកាន់តែមានភាពពាក់ព័ន្ធចំពោះពួកគេ។ សកម្មភាពជាក់លាក់បន្ទាប់ គឺធានាថាជនពិការត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ និងមានលទ្ធភាពចូលរួមយ៉ាងសកម្ម និងចែករំលែកទស្សនៈយល់ឃើញរបស់ពួកគេ។

ឧទាហរណ៍មួយចំនួនអំពីសកម្មភាព ដែលមានការដាក់បញ្ចូល មានដូចខាងក្រោម ៖

**ជំហានទី១ ៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់**

- ប្រមូល និងចែករំលែកទិន្នន័យអំពីជនពិការនៅក្នុងឃុំ សង្កាត់
- អញ្ជើញជនពិការ និងគ្រួសាររបស់ពួកគេឱ្យចូលរួមនៅក្នុងកិច្ចប្រជុំភូមិ
- ធានាថា ទីតាំងសម្រាប់កិច្ចប្រជុំភូមិ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ
- ធ្វើការវិភាគលើឧបសគ្គនានាជាមួយនឹងជនពិការ
- កំណត់រកក្រុមជនពិការ និងបង្កើតបណ្តាញជាមួយពួកគេ
- កំណត់ទីតាំងអ្នកផ្តល់សេវាដល់ជនពិការ និងអង្គការដែលធ្វើការផ្នែកពិការភាព

**ជំហានទី២ ៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់**

- ក្នុងការជ្រើសរើសគម្រោង គ.ផ.ថ. គួរពិចារណារលើគម្រោងដែលឆ្លើយតបទៅនឹងតម្រូវការរបស់ជនពិការ ស្ត្រី កុមារ យុវជន និងជនងាយរងគ្រោះ(បរិយាប័ន្ន និងសមធម៌សង្គម)ទាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគម្រោងសេវាកម្មនានា
- រៀបចំផែនការសម្រាប់គម្រោងកសាងសមត្ថភាពអំពីការដាក់បញ្ចូលពិការភាពទៅក្នុងគម្រោងនៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់ភូមិ (ឧទាហរណ៍ ៖ ការលើកកម្ពស់ការយល់ដឹង)
- ធានាថា អគារសាធារណៈ និងសម្ភាររូបវន្តដែលមានស្រាប់ និងថ្មីៗ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ
- ធានាថាព័ត៌មានសាធារណៈ (ឧទាហរណ៍ ៖ សុខភាព កសិកម្ម ។ល។) អាចទទួលបាន និងអាចយល់ដឹងបានដោយជនពិការទៅតាមប្រភេទនៃពិការភាព
- រៀបចំសូចនាករដែលមានការដាក់បញ្ចូលពិការភាពនៅក្នុងគម្រោង ឧទាហរណ៍ ចំនួនជនពិការ

ចូលរួមក្នុងការផ្តល់យោបល់ និងចំនួនជនពិការទទួលផលប្រយោជន៍ពីគម្រោង។ល។
- ធានាឱ្យមានវិភាជន៍ថវិកាសម្រាប់ការបង្កភាពងាយស្រួលដល់ជនពិការ ដូចជា ជួលអ្នកបកប្រែភាសាសញ្ញា ឬការបង្កភាពងាយស្រួលដល់ការធ្វើដំណើរនៃជនពិការកាយសម្បទា។ល។
- ផ្តល់អាទិភាពដល់ក្រុមដែលទន់ខ្សោយជាងគេ ឬជាងគេបំផុត(ដូចជា ស្ត្រីពិការ)
- អញ្ជើញតំណាងអង្គការជនពិការឱ្យចូលរួមនៅក្នុងសិក្ខាសាលា
- ធ្វើឱ្យអង្គការមិនមែនរដ្ឋាភិបាលយល់ដឹង និងចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- ដាក់បញ្ចូលគម្រោង ឬសូចនាករដែលពាក់ព័ន្ធផ្ទាល់ទៅនឹងពិការភាពក្នុងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការដាក់បញ្ចូលពិការភាពក្នុងគម្រោងផ្អែកទៅតាមសូចនាករ និងការវាស់វែងលើផលប៉ះពាល់របស់គម្រោងទៅលើជនពិការ
- មានតំណាងជនពិការនៅក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

**ជំហានទី៣ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់**
- មានតំណាងជនពិការចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ធ្វើឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្តយល់ដឹង និងចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- មេឃុំ ចៅសង្កាត់ ឬ គ.ផ.ថ គប្បីណែនាំឱ្យមានការផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ជាពិសេសជនពិការ តាមរយៈកិច្ចប្រជុំនានា វេទិកាសាធារណៈ សារព័ត៌មាន វិទ្យុ និងមធ្យោបាយផ្សេងៗទៀត។

៤. គ្រូបណ្តុះបណ្តាលសួរទៅអ្នកចូលរួម តើពួកគេនឹងធ្វើអ្វីខ្លះ ដើម្បីធ្វើឱ្យវិធីសាស្ត្ររៀបចំ និងកសាងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ នាពេលបន្ទាប់ ឱ្យកាន់តែមានការដាក់បញ្ចូលពិការភាព។



**មេរៀន៧.៣**

**សង្ខេបមេរៀនជំពូកទី៧**

| | |
|---|---|
| **គោលដៅ** ៖ រំលឹកអ្នកចូលរួមអំពីអ្វីដែលពួកគេបានរៀននៅក្នុងមេរៀនជំពូកទី៧ និងបញ្ជាក់បំភ្លឺពីសំណួរនានាដែលនៅសេសសល់។ | |
| **រយៈពេល** | ៥នាទី |

គ្រូបណ្តុះបណ្តាលសង្ខេបមេរៀនក្នុងជំពូកទី៧ តាមខ្លឹមសារដូចខាងក្រោម ៖



១. គម្រោងដែលមានស្រាប់ នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ មិនមែនសុទ្ធតែមានការដាក់បញ្ចូលពិការភាពនោះទេ។
២. ដើម្បីឱ្យគម្រោងមានការដាក់បញ្ចូលពិការភាព គេចាំបាច់ត្រូវដឹងពីឧបសគ្គ និងដកឧបសគ្គទាំងនោះចេញ។
៣. ដំណោះស្រាយមួយចំនួន មិនចាំបាច់ត្រូវការចំណាយថវិកាច្រើននោះទេ គ្រាន់តែត្រូវការវិនិយោគពេលវេលា ការប្ដេជ្ញាចិត្ត និងត្រូវមានភាពច្បាស់លាស់ពីអ្នកដែលត្រូវចាត់វិធានការ។
៤. ការដោះស្រាយឧបសគ្គដែលអាចកើតមានក្នុងវដ្តនៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ទាមទារឱ្យមានការចូលរួមឱ្យបានខ្លាំងក្លាពីជនពិការ។
៥. ការលើកកម្ពស់ការចូលរួមរបស់ជនពិការ និងការដាក់បញ្ចូលពិការភាពទៅក្នុងគម្រោង អាចធ្វើឡើងនៅគ្រប់ជំហានទាំងអស់នៃដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**គ.២). ដំណើរការសម្របសម្រួលក្រុមគោលដៅនៅថ្នាក់ក្រុង ស្រុក ខណ្ឌ**



**មេរៀន៧.១**
**ការវិភាគលើគម្រោងដែលបានស្នើឡើងក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ សម្រាប់សិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ**

| | |
|---|---|
| **គោលដៅ៖** វិភាគពីគម្រោងដែលត្រូវបានស្នើឡើង ក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់រាជធានីខេត្ត និងធ្វើការវាយតម្លៃថា តើគម្រោងទាំងនេះមានការដាក់បញ្ចូលពិការភាពយ៉ាងដូចម្ដេច?។ | |
| **រយៈពេល** | ៧០នាទី |

**កំណត់សម្គាល់ ៖**

គោលដៅមេរៀននេះ គឺដើម្បីឱ្យអ្នកចូលរួមគិតពីការដាក់បញ្ចូលពិការភាពនៅក្នុងគម្រោងទាំងអស់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ មនុស្សជាច្រើនគិតថា គម្រោងពិសេសសម្រាប់ជនពិការ ដូចជាគម្រោងស្ដារលទ្ធភាពពលកម្ម ឬការអប់រំពិសេស គឺជាគម្រោងសម្រាប់ជនពិការ។ ប៉ុន្តែគម្រោងទាំងអស់ដូចជា ការអប់រំសាធារណៈ សកម្មភាពបង្កើនប្រាក់ចំណូល ឬព័ត៌មានសាធារណៈជាដើម ក៏ជាគម្រោងដែលមានភាពពាក់ព័ន្ធនឹងជនពិការផងដែរ នេះគឺជាសារដ៏សំខាន់ នៅចុងបញ្ចប់នៃមេរៀន៧.២នេះ។

**ជំហានទី១ ៖**

១. គ្រូបណ្ដុះបណ្ដាលណែនាំអំពីប្រធានបទមេរៀន និងគូសបញ្ជាក់ថា ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ដែលមានស្រាប់ ត្រូវបានយកមកប្រើប្រាស់នៅក្នុងមេរៀននេះ ដើម្បីវិភាគឱ្យកាន់តែស៊ីជម្រៅអំពីអ្វីដែលអាចធ្វើបាន ដើម្បីធ្វើឱ្យផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ មានការដាក់បញ្ចូល និងគិតគូរដល់ជនពិការ។

២. គ្រូបណ្តុះបណ្តាលសួរទៅអ្នកចូលរួម តើអ្នកណាខ្លះ ចងចាំអំពីអត្ថន័យពាក្យស្លោក "ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើ ពុំមានការចូលរួមពីយើង" តើមានអត្ថន័យយ៉ាងដូចម្តេច? រួចឱ្យអ្នកចូលរួមស្ម័គ្រចិត្ត១-៣នាក់ផ្តល់ចម្លើយ។

| |
|---|
| **"ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើពុំមានការចូលរួមពីយើង"** មានន័យថា ៖ |
| ជនពិការគួរចូលរួមបញ្ចេញមតិ នៅក្នុងគ្រប់សកម្មភាពទាំងអស់ ដែលមានផលប៉ះពាល់លើពួកគេ។ ជាពិសេស នៅពេលកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលមានការដាក់បញ្ចូលពិការភាព នោះជនពិការចាំបាច់ត្រូវតែអាចចូលរួមចំណែកក្នុងដំណើរការនោះ។ |

៣. គ្រូបណ្តុះបណ្តាលចែកអ្នកចូលរួមជាក្រុមទៅតាមរដ្ឋបាលរបស់ពួកគេ រួចឱ្យក្រុមនីមួយៗកំណត់ពីបញ្ជីគម្រោងដែលមានថវិកាគាំទ្រ ហើយដែលកំពុងត្រូវបានអនុវត្តក្នុងក្រុង ស្រុក ខណ្ឌរបស់ពួកគេ។ អ្នកចូលរួមសរសេរឈ្មោះគម្រោងទាំងនេះលើក្រដាសផ្ទាំងធំ។

៤. រួចក្រុមនីមួយៗពិភាក្សាទៅលើគម្រោងទាំងនោះ ផ្អែកតាមសំណួរ តើគម្រោងណាខ្លះ ក្នុងចំណោមគម្រោងទាំងនេះ ដែលពាក់ព័ន្ធជាមួយនឹងជនពិការ? ហេតុអ្វីបានជាគម្រោងទាំងនេះពាក់ព័ន្ធជាមួយនឹងជនពិការ។ បន្ទាប់ពីពិភាក្សា រយៈពេល៥នាទី រួចឱ្យក្រុមចូលមកពិភាក្សាក្នុងក្រុមធំវិញ។

**កំណត់សម្គាល់ ៖**

ជាដំបូង អ្នកចូលរួមនឹងកំណត់រកគម្រោងដែលផ្តោតលើជនពិការ ដូចជាគម្រោងស្តារលទ្ធភាពពលកម្ម។ មូលហេតុដែលពួកគេលើកឡើងបែបនេះ ព្រោះតែអ្នកចូលរួមយល់ថា ជនពិការត្រូវការរទេះរុញ ហើយគម្រោងនេះនឹងត្រូវផ្តល់រទេះរុញ ឬដោយសារតែវាជាសាលារៀនពិសេសសម្រាប់កុមារពិការ។

៥. នៅក្នុងការពិភាក្សាក្នុងក្រុមធំ គ្រូបណ្តុះបណ្តាលសួរអ្នកចូលរួមនូវសំណួរខាងក្រោម ៖

- តើមានការពិគ្រោះយោបល់ជាមួយជនពិការដែរឬទេ នៅក្នុងអំឡុងពេលកំណត់ពីតម្រូវការ ឬបញ្ហារបស់ពួកគេ?
- តើមានជនពិការប៉ុន្មាននាក់ ដែលបានចូលរួមក្នុងសកម្មភាពគម្រោង?
- តើជនពិការគិតយ៉ាងដូចម្តេចអំពីគម្រោងនេះ? តើពួកគេចូលចិត្តគម្រោងនេះដែរឬទេ? តើធ្វើដូចម្តេច ដើម្បីដឹងថាពួកគេចូលចិត្ត ឬមិនចូលចិត្តគម្រោងនេះ?

**ជំហានទី២ ៖**

១. នៅក្នុងជំហានទី១ អ្នកចូលរួមបានលើកឡើងថា នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ មានតែគម្រោងមួយចំនួនប៉ុណ្ណោះ ដែលពាក់ព័ន្ធជាមួយនឹងជនពិការ។ គ្រូបណ្តុះបណ្តាលឱ្យអ្នកចូលរួមអានឈ្មោះគម្រោងដែលត្រូវបានលើកឡើងថា ជាគម្រោងសម្រាប់ជនពិការឱ្យបានឮៗ។

បន្ទាប់មក គ្រូបណ្តុះបណ្តាលឱ្យអ្នកចូលរួមពិនិត្យមើលគម្រោងផ្សេងទៀត ពីក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ដែលពួកគេមិនបានលើកឡើងថាជាគម្រោងដែលពាក់ព័ន្ធជាមួយនឹងជនពិការ រួចសួរទៅអ្នកចូលរួម ៖

- តើគម្រោងទាំងនេះ ពុំបានផ្តល់ប្រយោជន៍ដល់ជនពិការទេឬ? តើធ្វើដូចម្តេច ដើម្បីដឹងថាគម្រោងពុំបានផ្តល់ប្រយោជន៍ដល់ជនពិការ?
- តើជនពិការអាចចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោងទាំងនេះបានដែរឬទេ?
- តើគម្រោងទាំងនេះ ផ្តល់ផលប្រយោជន៍សម្រាប់ជនពិការទាំងអស់ ឬក៏សម្រាប់តែពិការភាពតាមប្រភេទជាក់លាក់?

២. គ្រូបណ្តុះបណ្តាលចែកអ្នកចូលរួមជា៤ក្រុម ឱ្យក្រុមនីមួយៗជ្រើសរើសគម្រោងមួយក្នុងចំណោមគម្រោងដែលមិនត្រូវបានគេចាត់ទុកថាពាក់ព័ន្ធជាមួយនឹងជនពិការ។ ប្រសិនបើអាច ក្រុមនីមួយៗគួរជ្រើសរើសគម្រោងមួយក្នុងផ្នែកផ្សេងៗគ្នា ដូចជា ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

៣.គ្រូបណ្តុះបណ្តាលពន្យល់អ្នកចូលរួមថា ៖ គ្មានទេដែលថា មានគម្រោងមួយចំនួនដែលពាក់ព័ន្ធជាមួយនឹងជនពិការ ហើយគម្រោងមួយចំនួនមិនពាក់ព័ន្ធជាមួយនឹងជនពិការ។ ជនពិការ គឺជាផ្នែកមួយនៃសហគមន៍របស់យើង។ រាល់គម្រោងទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងមនុស្សនៅក្នុងសហគមន៍របស់យើង ក៏ពាក់ព័ន្ធជាមួយជនពិការផងដែរ។ ដូច្នេះ គ្រប់គម្រោងទាំងអស់ ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវ ក្នុងការធានាឱ្យជនពិការអាចទទួលបានផលប្រយោជន៍ពីគម្រោងទាំងនោះ និងមិនត្រូវបានផាត់ចេញពីគម្រោងតទៅទៀតឡើយ ហើយត្រូវតែដាក់បញ្ចូលជនពិការនៅរាល់គ្រប់ដំណើរការរបស់សហគមន៍ ដោយសារតែពួកគេក៏ជាផ្នែកមួយនៃសហគមន៍របស់យើង។

នៅពេលខ្លះជនពិការមិនអាចបានចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោង ដោយសារតែមានឧបសគ្គដែលរារាំងពួកគេ ដូចដែលយើងបានរៀនកន្លងមក បើទោះបីជា គម្រោងនោះ ពួកគេចូលចិត្ត ឬមានសារៈសំខាន់ខ្លាំងចំពោះពួកគេក៏ដោយ។

៤. គ្រូបណ្តុះបណ្តាលពន្យល់អ្នកចូលរួមថា ៖ យើងពិនិត្យលើគម្រោងដែលយើងបានជ្រើសរើសកន្លងមក។ ពីខាងដើមអ្នកចូលរួមមួយចំនួនបានលើកឡើងថា មិនមែនគម្រោងទាំងអស់សុទ្ធតែពាក់ព័ន្ធជាមួយនឹងជនពិការឡើយ ប៉ុន្តែតាមពិតគម្រោងទាំងអស់នេះពាក់ព័ន្ធនឹងពួកគេ ដោយសារតែជនពិការ គឺជាសមាជិកស្មើភាពក្នុងសហគមន៍។

យើងនឹងធ្វើការវិភាគថា តើឧបសគ្គណាខ្លះ ដែលរារាំងជនពិការមិនឱ្យចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោងក្រុង ស្រុក ខណ្ឌ តើយើងអាចនឹងដកឧបសគ្គទាំងនេះ ដោយរបៀបណា។

គ្រូបណ្តុះបណ្តាលឱ្យក្រុមនីមួយៗពិនិត្យមើលតារាងខាងក្រោម និងវិភាគគម្រោងរបស់ពួកគេដោយសរសេរពីឧបសគ្គទាំងនេះ ហើយឱ្យពួកគេគិតរកដំណោះស្រាយ តើអ្នកណាទទួលខុសត្រូវក្នុងការចាត់វិធានការដោះស្រាយ និងថាតើចំណាយសម្រាប់វិធានការនេះមានកម្រិតទាប មធ្យម ឬខ្ពស់។ លទ្ធផលពិភាក្សាត្រូវបានរៀបចំតាមទម្រង់តារាងខាងក្រោមលើក្រដាសផ្ទាំងធំ។ គ្រូបណ្តុះបណ្តាលអាចអញ្ជើញតំណាងមកពីអង្គការជនពិការឱ្យចូលរួមក្នុងក្រុម និងផ្តល់គំនិត។

សូមមើលឧទាហរណ៍ក្នុងតារាងខាងក្រោម ៖

| **គម្រោង ៖ សាលាបឋមសិក្សាថ្មី** | | | | |
|---|---|---|---|---|
| **ប្រភេទ** | **ឧបសគ្គ** | **ដំណោះស្រាយ** | **អ្នកទទួលខុសត្រូវ** | **ចំណាយ** (ខ្ពស់ មធ្យម ទាប) |
| ការបង្កភាពងាយស្រួល និងលទ្ធភាពទទួលបាន | សាលារៀនមិនមានភាពងាយស្រួលសម្រាប់អ្នកប្រើរទេះរុញ | ត្រួតពិនិត្យលើភាពងាយស្រួល និងសង់ជម្រាល និងបង្គន់ដែលងាយស្រួលក្នុងការប្រើប្រាស់ | មេឃុំ រួមជាមួយការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ | មធ្យម |
| ឥរិយាបថ | កុមារពិការទទួលរងការ សម្លុតឬធ្វើបាប ដោយក្មេងផ្សេងទៀត នៅសាលារៀន | លើកកម្ពស់ការយល់ដឹងនៅសាលារៀន | នាយកសាលា និងអង្គការជនពិការនៅមូលដ្ឋាន | ទាប |
| ការប្រាស្រ័យទាក់ទង | គ្រូបង្រៀនមិនដឹងពីរបៀបបង្រៀនកុមារដែលខ្សោយគំហើញ | បណ្តុះបណ្តាលគ្រូនូវជំនាញ ក្នុងការបង្រៀនកុមារពិការ | អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្របសម្រួលជាមួយការិយាល័យអប់រំ និងអង្គការមិនមែនរដ្ឋាភិបាល | ទាប |
| ការចូលរួម | មិនដឹងពីចំនួនកុមារពិការ ដែលនាំឱ្យគេមិនអាចវាយតម្លៃ ថាតើមានកុមារប៉ុន្មាននាក់ដែល គួរចុះឈ្មោះចូលរៀនក្នុងសាលារៀន | រាប់ចំនួនកុមារពិការ និងអាយុរបស់ពួកគេ | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ទាប |

៥. គ្រូបណ្តុះបណ្តាលដើរមើលជុំវិញ នៅពេលដែលក្រុមកំពុងធ្វើលំហាត់នេះ ដើម្បីពិនិត្យមើលថាតើពួកគេយល់លំហាត់នេះដែរឬទេ ដើម្បីផ្តល់ការគាំទ្រ ឬឆ្លើយនឹងសំណួរនានា។

ប្រសិនបើ អ្នកចូលរួមមានការលំបាកក្នុងការចាប់ផ្តើមគិតពីចំណុចនេះ គ្រូបណ្តុះបណ្តាលអាចផ្តល់ក្រដាសកាតពណ៌សម្រាប់បំផុសគំនិត។ ក្រដាសកាតពណ៌សម្រាប់បំផុសគំនិតទាំងនេះ សរសេរជាស្រេចនូវខ្លឹមសារដូចមានក្នុងតារាងខាងក្រោម។ សមាជិកក្រុមម្នាក់អាចអានខ្លឹមសារក្នុងក្រដាសកាតពណ៌។ ក្រដាសកាតពណ៌ទាំងនេះ(ក្រុមនីមួយៗមានក្រដាសកាតពណ៌សរុបចំនួន១០)មានសំណួរ ឬកំណត់សំគាល់ ផ្អែកលើរឿងនៃករណីសិក្សាទាំង៤។ ក្រដាសកាតពណ៌នេះ ក៏នឹងអាចជួយឱ្យក្រុមចាប់ផ្តើមគិតពីគម្រោង និងពីឧបសគ្គនានាចំពោះគម្រោង?

**ខ្លឹមសារនៅលើក្រដាសកាតពណ៌សម្រាប់បំផុសគំនិត ៖**

- ខ្ញុំអាចទៅដល់ទីនោះ ដោយប្រើរទេះរបស់ខ្ញុំ! (ស្រីមុំ)។
- គ្រូបានបណ្តោយឱ្យក្មេងឯទៀត សម្លុត ឬធ្វើបាបខ្ញុំ (មករា)។
- តើអ្នកដឹងថាតើបង្គន់នេះអាចប្រើប្រាស់បានដោយជនពិការដែរឬទេ?(ស្រីមុំ)។
- មេភូមិបានខិតខំដើម្បីឱ្យខ្ញុំទទួលបានលិខិតអញ្ជើញចូលរួមក្នុងកិច្ចប្រជុំទាន់ពេលវេលា(សុផល)។
- ខ្ញុំអាចតាមទាន់ការពិភាក្សាទាំងអស់ ដោយសារតែអ្នកបណ្តុះបណ្តាលបានខិតខំពន្យល់បានក្បោះក្បាយ ពីរូបភាពទាំងអស់(បុប្ផា)។
- ខ្ញុំចង់យល់ច្បាស់ ថាតើដំណាំណា ដែលខ្ញុំចាំបាច់ត្រូវដាំ ដើម្បីបានចំណេញ (មករា)។
- អ្វីដែលល្អគឺ អ្នកឯទៀតផ្តល់ពេលវេលាឱ្យខ្ញុំ ដើម្បីឱ្យខ្ញុំអាចផ្តល់នូវគំនិតយោបល់បាន(សុផល)។
- ជនពិការចង់ចូលរួមនៅក្នុងការអភិវឌ្ឍឃុំ ប៉ុន្តែយើងក៏មានតម្រូវការជាក់លាក់ ដើម្បីជួយឱ្យយើងចូលរួមក្នុងសកម្មភាពក្នុងឃុំដែរ។ ឧទាហរណ៍ ខ្ញុំត្រូវការរទេះរុញ(ស្រីមុំ) ។
- ស្ត្រីពិការជួបការលំបាកជាងបុរសពិការ(ថាវី)។
- មនុស្សផ្សេងទៀត រាប់អានខ្ញុំដោយការគោរព ពួកគេដឹងថា ខ្ញុំអាចរកស៊ីចិញ្ចឹមជីវិតបាន នាពេលឥឡូវនេះ (មករា)។

៦. បន្ទាប់ពីពិភាក្សារួច គ្រូបណ្តុះបណ្តាលឱ្យក្រុមនីមួយៗបិទតារាងលទ្ធផលពិភាក្សា(លើក្រដាសផ្ទាំងធំ) តាមក្រុមនីមួយៗ នៅកន្លែងផ្សេងៗពីគ្នាជុំវិញបន្ទប់ និងជ្រើសរើសតំណាងម្នាក់ឱ្យចាំនៅទីតាំងនៃក្រដាសផ្ទាំងធំ។ អ្នកបណ្តុះបណ្តាល អ្នកចូលរួមដែលនៅសល់ដើរពិនិត្យ មើល និងសួរសំណួរ ឬផ្តល់យោបល់ផ្សេងៗ ដោយសរសេរលើក្រដាសកាតពណ៌ ហើយបិទលើក្រដាសផ្ទាំងធំទាំងនោះ។

គោលដៅរបស់លំហាត់នេះ គឺចង់ឱ្យអ្នកចូលរួមយល់ថា គម្រោងមួយចំនួននៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ មិនមានការដាក់បញ្ចូលពិការភាព និងមិនមានការចូលរួមពីជនពិការទេ ដោយសារតែឧបសគ្គនានាដូចដែលបានបង្ហាញក្នុងមេរៀនមុនៗ។ គ្រូបណ្តុះបណ្តាលបញ្ជាក់ថា គេអាចធ្វើអ្វីមួយ ដើម្បីដោះស្រាយឧបសគ្គទាំងនេះបាន ដោយមិនចាំបាច់ចំណាយថវិកាច្រើននោះទេ គ្រាន់តែត្រូវការការវិនិយោគពេលវេលា និងការប្តេជ្ញាចិត្ត ដើម្បីការដាក់បញ្ចូលពិការភាព។

| | |
|---|---|
| | **មេរៀន៧.២**<br>**សកម្មភាពជាក់លាក់សម្រាប់ការដាក់បញ្ចូលពិការភាព** |
| **គោលដៅ** ៖ កំណត់សកម្មភាពដែលអាចធ្វើបាន ដើម្បីឱ្យគម្រោងដែលទទួលបានថវិកាគាំទ្រ ក្នុងសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ មានការដាក់បញ្ចូលពិការភាព។ | |
| **រយៈពេល** | ៣០នាទី |

១. គ្រូបណ្តុះបណ្តាលប្រាប់អ្នកចូលរួមថា នៅក្នុងលំហាត់មុន យើងបានប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌដែលមានស្រាប់ ដើម្បីពិនិត្យលើឧបសគ្គនានា ដែលជនពិការជួបប្រទះ និងអ្វីដែលយើងអាចធ្វើបាន ដើម្បីដកចេញនូវឧបសគ្គដែលរារាំងដល់ការចូលរួមរបស់ពួកគេ។

ឥឡូវនេះ លើកអំពីគម្រោងថ្មីមួយ ដើម្បីបង្ហាញដល់អ្នកចូលរួម ឧទាហរណ៍ ៖ គម្រោងសាងសង់សាលាបឋមសិក្សាថ្មីមួយ។

គ្រូបណ្តុះបណ្តាលសួរថា ៖ តើបញ្ហាពាក់ព័ន្ធនឹងការបង្កភាពងាយស្រួលសម្រាប់ជនពិការអាចដោះស្រាយបានល្អបំផុត នៅពេលណា ៖ មុន ឬក្រោយការសាងសង់? ចម្លើយគឺ ៖ មុនពេលសាងសង់ ដោយសារតែនៅពេលនោះគេងាយស្រួលបញ្ចូលវាទៅក្នុងគម្រោង ដោយប្រើប្រាស់មាត្រដ្ឋានឱ្យបានត្រឹមត្រូវ។ បញ្ចប់ដោយនិយាយថា ឧបសគ្គមួយចំនួនអាចបញ្ចៀសបាន នៅពេលដែលជនពិការចូលរួមនៅក្នុងដំណាក់កាលដំបូងនៃការរៀបចំគ្រោងការគម្រោង។

២. គ្រូបណ្តុះបណ្តាលបង្ហាញពីវិធីសាស្ត្ររៀបចំ និងកសាងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌដែលមាន៣ជំហាន ដោយពន្យល់ត្រួសៗពីសកម្មភាពក្នុងជំហាននីមួយៗ ដើម្បីឱ្យគ្រប់គ្នាដឹងពីអ្វីដែលកើតឡើងក្នុងជំហាននីមួយៗ។

**ជំហានទី១**

**ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ**

សកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តក្នុងជំហានទី១នេះ រួមមាន៖

- ប្រជុំណែនាំអំពីការប្រមូលតម្រូវការអាទិភាព
- ប្រជុំបូកសរុប និងរៀបចំបញ្ជីគម្រោង និងសកម្មភាពអាទិភាព(ដោយមានតម្លៃប៉ាន់ស្មាន)

**ជំហានទី២**

**ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ**

ក្នុងជំហានទី២នេះ សកម្មភាពសំខាន់ដែលត្រូវអនុវត្តមាន ៖

- កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ
- ចូលរួមវេទិកាពិគ្រោះយោបល់ក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅរាជធានី ខេត្ត
- រៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅក្រុង ស្រុក ខណ្ឌ
- ចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅក្រុង ស្រុក ខណ្ឌ
- ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ
- ការរៀបចំតារាងវិនិយោគខណ្ឌ សង្កាត់សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគរាជធានី (សម្រាប់តែខណ្ឌមួយប៉ុណ្ណោះ)
- ការពិនិត្យ និងផ្តល់យោបល់

## ជំហានទី៣

### ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

សកម្មភាពសំខាន់ក្នុងជំហានទី៣នេះ រួមមាន៖

- កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ
- ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

៣. គ្រូបណ្តុះបណ្តាលបញ្ជាក់ប្រាប់អ្នកចូលរួមថា ៖ យើងអាចធ្វើសកម្មភាពអនុវត្តនៅជំហាននីមួយៗនៃដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យមានការចូលរួមពីក្រុមជនពិការ និងសួរថា តើក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ គួរធ្វើសកម្មភាពអ្វីខ្លះ ដើម្បីធានាឱ្យមានការចូលរួមពីជនពិការ និងបញ្ចៀសនូវរាល់ឧបសគ្គទាំងឡាយ? បន្ទាប់ពីអ្នកចូលរួមបានឆ្លើយសំណួរនេះរួច គ្រូបណ្តុះបណ្តាលផ្តល់ចម្លើយ(ដូចដែលបានរៀបចំជាស្រេចក្នុងតារាងខាងក្រោម)។

**ឧទាហរណ៍ ៖** តើសកម្មភាពជាក់លាក់អ្វីខ្លះក្នុងជំហានទី១ ដែលគេអាចធ្វើបាន ៖ ការពិនិត្យលើបញ្ហា ឬតម្រូវការជាមួយនឹងប្រជាពលរដ្ឋឡើងវិញ? ប្រសិនបើ ជនពិការត្រូវបានគេបញ្ចូលទៅក្នុងដំណាក់កាលកំណត់ពីតម្រូវការ នោះគម្រោងដែលត្រូវបានជ្រើសរើសនឹងកាន់តែមានភាពពាក់ព័ន្ធចំពោះពួកគេ។ សកម្មភាពជាក់លាក់បន្ទាប់ គឺធានាថាជនពិការត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ និងមានលទ្ធភាពចូលរួមយ៉ាងសកម្ម និងចែករំលែកទស្សនៈយល់ឃើញរបស់ពួកគេ។

ឧទាហរណ៍មួយចំនួនអំពីសកម្មភាពដែលមានការដាក់បញ្ចូលមានដូចខាងក្រោម ៖

**ជំហានទី១ ៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ**

- រៀបចំផែនការសម្រាប់គម្រោងកសាងសមត្ថភាពអំពីការដាក់បញ្ចូលពិការភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ជាពិសេសក្រុមការងារកសាងផែនការ(តាមរយៈការលើកកម្ពស់ការយល់ដឹង)
- ចែករំលែកទិន្នន័យអំពីជនពិការនៅក្នុងក្រុង ស្រុក ខណ្ឌ នៅក្នុងកិច្ចប្រជុំណែនាំដើម្បីកំណត់ និងរៀបចំសំណើគម្រោងវិនិយោគ
- អញ្ជើញតំណាងជនពិការចូលរួមប្រជុំស្តីពីការប្រមូលតម្រូវការអាទិភាព និងប្រជុំបូកសរុប បញ្ជីគម្រោងអាទិភាព
- អញ្ជើញស្ថាប័នដែលធ្វើការផ្នែកពិការភាព ឬធ្វើការជាមួយជនពិការ ឱ្យចូលរួមនៅក្នុងកិច្ចប្រជុំណែនាំ និងចែករំលែកបញ្ហានានាទាក់ទងនឹងជនពិការ
- ធានាថា ទីតាំងសម្រាប់កិច្ចប្រជុំ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ។

**ជំហានទី២ ៖ ការរៀបចំសេចក្ដីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ**

- ធានាថា អគារសាធារណៈ និងសម្ភាររូបវន្តដែលមានស្រាប់ និងថ្មីៗ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ
- ធានាថាព័ត៌មានសាធារណៈ (ឧទាហរណ៍ ៖ សុខភាព កសិកម្ម ។ល។) អាចទទួលបាន និងអាចយល់ដឹងបានដោយជនពិការទៅតាមប្រភេទនៃពិការភាព
- រៀបចំសូចនាករដែលមានការដាក់បញ្ចូលពិការភាពនៅក្នុងគម្រោង ឧទាហរណ៍ ចំនួនជនពិការចូលរួមក្នុងការផ្ដល់យោបល់ និងចំនួនជនពិការទទួលផលប្រយោជន៍ពីគម្រោង។ល។
- ធានាឱ្យមានការវិភាជន៍ថវិកាសម្រាប់ការបង្កភាពងាយស្រួលដល់ជនពិការ ដូចជា ជួលអ្នកបកប្រែភាសាសញ្ញា ឬការបង្កភាពងាយស្រួលដល់ការធ្វើដំណើរនៃជនពិការកាយសម្បទា..
- ផ្ដល់អាទិភាពដល់ក្រុមដែលទន់ខ្សោយជាងគេ ឬជាងគេបំផុត(ដូចជា ស្ត្រីពិការ)
- អញ្ជើញតំណាងអង្គការជនពិការឱ្យចូលរួមនៅក្នុងសិក្ខាសាលា
- ធ្វើឱ្យអង្គការមិនមែនរដ្ឋាភិបាល យល់ដឹង ចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- ដាក់បញ្ចូលគម្រោង ឬសូចនាករដែលពាក់ព័ន្ធផ្ទាល់ទៅនឹងពិការភាពក្នុងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការដាក់បញ្ចូលពិការភាពក្នុងគម្រោងផ្អែកទៅតាមសូចនាករ និងការវាស់វែងលើផលប៉ះពាល់របស់គម្រោងទៅលើជនពិការ
- មានតំណាងជនពិការនៅក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

**ជំហានទី៣ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ**

- មានតំណាងជនពិការចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ
- ធ្វើឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ យល់ដឹង និងចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- អភិបាលក្រុង ស្រុក ខណ្ឌ ឬ ក្រុមការងារកសាងផែនការ គប្បីណែនាំឱ្យមានការផ្សព្វផ្សាយ ខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធ ជាពិសេសជនពិការ តាមរយៈកិច្ចប្រជុំនានា វេទិកាសាធារណៈ សារព័ត៌មាន វិទ្យុ និងមធ្យោបាយផ្សេងៗទៀត។

៤. គ្រូបណ្ដុះបណ្ដាលសួរទៅអ្នកចូលរួម តើពួកគេនឹងធ្វើអ្វីខ្លះ ដើម្បីធ្វើឱ្យដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ នាពេលបន្ទាប់ ឱ្យកាន់តែមានការដាក់បញ្ចូលពិការភាព។

| | |
|---|---|
| **មេរៀន៧.៣**<br>**សង្ខេបមេរៀនជំពូកទី៧** | |
| **គោលដៅ** ៖ រំលឹកអ្នកចូលរួមអំពីអ្វីដែលពួកគេបានរៀនក្នុងមេរៀនជំពូកទី៧ និងបញ្ជាក់បំភ្លឺពីសំណួរនានាដែលនៅសេសសល់។ | |
| **រយៈពេល** | ៥នាទី |

គ្រូបណ្តុះបណ្តាលសង្ខេបមេរៀនក្នុងជំពូកទី៧ តាមខ្លឹមសារដូចខាងក្រោម ៖

១. គម្រោងដែលមានស្រាប់ នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ មិនមែនសុទ្ធតែមានការដាក់បញ្ចូលពិការភាពនោះទេ។

២. ដើម្បីឱ្យគម្រោងមានការដាក់បញ្ចូលពិការភាព គេចាំបាច់ត្រូវតែដឹងពីឧបសគ្គ និងដកឧបសគ្គទាំងនោះចេញ។

៣. ដំណោះស្រាយមួយចំនួន មិនចាំបាច់ត្រូវការចំណាយថវិកាច្រើននោះទេ គ្រាន់តែត្រូវការវិនិយោគពេលវេលា ការប្តេជ្ញាចិត្ត និងត្រូវមានភាពច្បាស់លាស់ពីអ្នកដែលត្រូវចាត់វិធានការ។

៤. ការដោះស្រាយឧបសគ្គដែលអាចកើតមានក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ទាមទារឱ្យមានការចូលរួមឱ្យបានខ្លាំងក្លាពីជនពិការ។

៥. ការលើកកម្ពស់ការចូលរួមរបស់ជនពិការ និងការដាក់បញ្ចូលពិការភាពទៅក្នុងគម្រោង អាចធ្វើឡើងនៅគ្រប់ដំហានទាំងអស់នៃដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ។

## គ.៣). ដំណើរការសម្របសម្រួលក្រុមគោលដៅនៅថ្នាក់រាជធានី ខេត្ត

| | |
|---|---|
| **មេរៀន៧.១**<br>**ការវិភាគលើគម្រោង ដែលបានស្នើឡើងក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់លើគម្រោងវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត** | |
| **គោលដៅ**៖ វិភាគពីគម្រោងដែលត្រូវបានស្នើឡើងក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត សម្រាប់ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើគម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត និងធ្វើការវាយតម្លៃថា តើគម្រោងទាំងនេះមានការដាក់បញ្ចូលពិការភាពយ៉ាងដូចម្តេច? | |
| **រយៈពេល** | ៧០នាទី |

**កំណត់សម្គាល់ ៖**

គោលដៅមេរៀននេះ គឺដើម្បីឱ្យអ្នកចូលរួមគិតពីការដាក់បញ្ចូលពិការភាពនៅក្នុងគម្រោងទាំងអស់របស់រដ្ឋបាលរាជធានី ខេត្ត។ មនុស្សជាច្រើនគិតថា គម្រោងពិសេសសម្រាប់ជនពិការ ដូចជា គម្រោងស្តារលទ្ធភាពពលកម្ម ឬការអប់រំពិសេស គឺជាគម្រោងសម្រាប់ជនពិការ។ ប៉ុន្តែគម្រោងទាំងអស់ ដូចជា ការអប់រំសាធារណៈ សកម្មភាពបង្កើនប្រាក់ចំណូល ឬព័ត៌មានសាធារណៈជាដើម ក៏ជាគម្រោងដែលមានភាពពាក់ព័ន្ធនឹងជនពិការផងដែរ នេះគឺជាសារដ៏សំខាន់ នៅចុងបញ្ចប់នៃមេរៀន៧.២នេះ។

**ជំហានទី១ ៖**

១. គ្រូបណ្តុះបណ្តាលណែនាំអំពីប្រធានបទមេរៀន និងគូសបញ្ជាក់ថា ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដែលមានស្រាប់ ត្រូវបានយកមកប្រើប្រាស់នៅក្នុងមេរៀននេះ ដើម្បីវិភាគឱ្យកាន់តែស៊ីជម្រៅអំពីអ្វីដែលអាចធ្វើបាន ដើម្បីធ្វើឱ្យផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត មានការដាក់បញ្ចូល និងគិតគូរដល់ជនពិការ។

២. គ្រូបណ្តុះបណ្តាលសួរទៅអ្នកចូលរួម តើអ្នកណាខ្លះ ចងចាំអំពីអត្ថន័យពាក្យស្លោក "ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើ ពុំមានការចូលរួមពីយើង" តើមានអត្ថន័យយ៉ាងដូចម្តេច? រួចឱ្យអ្នកចូលរួមស្ម័គ្រចិត្ត១-៣នាក់ផ្តល់ចម្លើយ។

**"ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើពុំមានការចូលរួមពីយើង"** មានន័យថា ៖
ជនពិការគួរចូលរួមបញ្ចេញមតិ នៅក្នុងគ្រប់សកម្មភាពទាំងអស់ ដែលមានផលប៉ះពាល់លើពួកគេ។ ជាពិសេស នៅពេលកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលមានការដាក់បញ្ចូលពិការភាព នោះជនពិការចាំបាច់ត្រូវតែអាចចូលរួមចំណែកក្នុងដំណើរការនោះ។

៣. គ្រូបណ្តុះបណ្តាលចែកអ្នកចូលរួមជាក្រុមទៅតាមរដ្ឋបាលរបស់ពួកគេ រួចឱ្យក្រុមនីមួយៗកំណត់ពីបញ្ជីគម្រោងដែលមានថវិកាគាំទ្រ ហើយដែលកំពុងត្រូវបានអនុវត្តក្នុងរាជធានី ខេត្តរបស់ពួកគេ។ អ្នកចូលរួមសរសេរឈ្មោះគម្រោងទាំងនេះលើក្រដាសផ្ទាំងធំ។

៤. រួចក្រុមនីមួយៗពិភាក្សាទៅលើគម្រោងទាំងនោះ ផ្អែកតាមសំណួរ តើគម្រោងណាខ្លះ ក្នុងចំណោមគម្រោងទាំងនេះ ដែលពាក់ព័ន្ធជាមួយនឹងជនពិការ? ហេតុអ្វីបានជាគម្រោងទាំងនេះពាក់ព័ន្ធជាមួយនឹងជនពិការ។ បន្ទាប់ពីពិភាក្សា រយៈពេល៥នាទី រួចឱ្យក្រុមចូលមកពិភាក្សាក្នុងក្រុមធំវិញ។

**កំណត់សម្គាល់ ៖**



ជាដំបូង អ្នកចូលរួមនឹងកំណត់រកគម្រោងដែលផ្តោតលើជនពិការ ដូចជា គម្រោងស្តារលទ្ធភាពពលកម្ម។ មូលហេតុដែលពួកគេលើកឡើងបែបនេះ ព្រោះតែអ្នកចូលរួមយល់ថា ជនពិការត្រូវការរទេះរុញ ហើយគម្រោងនេះនឹងត្រូវផ្តល់រទេះរុញ ឬដោយសារតែវាជាសាលារៀនពិសេសសម្រាប់កុមារពិការ។

៥. នៅក្នុងការពិភាក្សាក្នុងក្រុមធំ គ្រូបណ្តុះបណ្តាលសួរអ្នកចូលរួមនូវសំណួរខាងក្រោម ៖
- តើមានការពិគ្រោះយោបល់ជាមួយជនពិការដែរឬទេ នៅក្នុងអំឡុងពេលកំណត់ពីតម្រូវការ ឬបញ្ហារបស់ពួកគេ?
- តើមានជនពិការប៉ុន្មាននាក់ ដែលបានចូលរួមក្នុងសកម្មភាពគម្រោង?
- តើជនពិការគិតយ៉ាងដូចម្តេចអំពីគម្រោងនេះ? តើពួកគេចូលចិត្តគម្រោងនេះដែរឬទេ? តើធ្វើដូចម្តេច ដើម្បីដឹងថាពួកគេចូលចិត្ត ឬមិនចូលចិត្តគម្រោងនេះ?

**ជំហានទី២ ៖**

១. នៅក្នុងជំហានទី១ អ្នកចូលរួមបានលើកឡើងថា នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត មានតែគម្រោងមួយចំនួនប៉ុណ្ណោះ ដែលពាក់ព័ន្ធជាមួយនឹងជនពិការ។ គ្រូបណ្តុះបណ្តាលឱ្យអ្នកចូលរួមអានឈ្មោះគម្រោងដែលត្រូវបានលើកឡើងថា ជាគម្រោងសម្រាប់ជនពិការឱ្យបានឮៗ។

បន្ទាប់មក គ្រូបណ្តុះបណ្តាលឱ្យអ្នកចូលរួមពិនិត្យមើលគម្រោងផ្សេងទៀត ពីក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដែលពួកគេមិនបានលើកឡើងថាជាគម្រោងដែលពាក់ព័ន្ធជាមួយនឹងជនពិការ រួចសួរទៅអ្នកចូលរួម ៖
- តើគម្រោងទាំងនេះ ពុំបានផ្តល់ប្រយោជន៍ដល់ជនពិការទេឬ? តើធ្វើដូចម្តេច ដើម្បីដឹងថាគម្រោងពុំបានផ្តល់ប្រយោជន៍ដល់ជនពិការ?
- តើជនពិការអាចចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោងទាំងនេះបានដែរឬទេ?
- តើគម្រោងទាំងនេះ ផ្តល់ផលប្រយោជន៍សម្រាប់ជនពិការទាំងអស់ ឬក៏សម្រាប់តែពិការភាពតាមប្រភេទជាក់លាក់?

២. គ្រូបណ្តុះបណ្តាលចែកអ្នកចូលរួមជា៤ក្រុម ឱ្យក្រុមនីមួយៗជ្រើសរើសគម្រោងមួយក្នុងចំណោមគម្រោងដែលមិនត្រូវបានគេចាត់ទុកថាពាក់ព័ន្ធជាមួយនឹងជនពិការ។ ប្រសិនបើអាច ក្រុមនីមួយៗគួរជ្រើសរើសគម្រោងមួយក្នុងផ្នែកផ្សេងៗគ្នា ដូចជាផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

៣. គ្រូបណ្តុះបណ្តាលពន្យល់អ្នកចូលរួមថា ៖ គ្មានទេដែលថា មានគម្រោងមួយចំនួន ដែលពាក់ព័ន្ធជាមួយនឹងជនពិការ ហើយគម្រោងមួយចំនួនមិនពាក់ព័ន្ធជាមួយនឹងជនពិការ។ ជនពិការ គឺជាផ្នែកមួយនៃសហគមន៍របស់យើង។ រាល់គម្រោងទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងមនុស្សនៅក្នុងសហគមន៍របស់យើង ក៏ពាក់ព័ន្ធជាមួយជនពិការផងដែរ។



ដូច្នេះ គ្រប់គម្រោងទាំងអស់ ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលខុសត្រូវ ក្នុងការធានាឱ្យជនពិការអាចទទួលបានផលប្រយោជន៍ពីគម្រោងទាំងនោះ និងមិនត្រូវបានផាត់ចេញពីគម្រោងតទៅទៀតឡើយ ហើយត្រូវតែដាក់បញ្ចូលជនពិការនៅរាល់គ្រប់ដំណើរការរបស់សហគមន៍ ដោយសារតែពួកគេក៏ជាផ្នែកមួយនៃសហគមន៍របស់យើង។

នៅពេលខ្លះជនពិការមិនអាចបានចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោង ដោយសារតែមានឧបសគ្គដែលរារាំងពួកគេ ដូចដែលយើងបានរៀនកន្លងមក បើទោះបីជា គម្រោងនោះ ពួកគេចូលចិត្ត ឬមានសារៈសំខាន់ខ្លាំងចំពោះពួកគេក៏ដោយ។

៤. គ្រូបណ្តុះបណ្តាលពន្យល់អ្នកចូលរួមថា ៖ យើងពិនិត្យលើគម្រោងដែលយើងបានជ្រើសរើសកន្លងមក។ ពីខាងដើមអ្នកចូលរួមមួយចំនួនបានលើកឡើងថា មិនមែនគម្រោងទាំងអស់សុទ្ធតែពាក់ព័ន្ធជាមួយនឹងជនពិការឡើយ ប៉ុន្តែតាមពិតគម្រោងទាំងអស់នេះពាក់ព័ន្ធនឹងពួកគេ ដោយសារតែជនពិការ គឺជាសមាជិកស្មើភាពក្នុងសហគមន៍។

យើងនឹងធ្វើការវិភាគថា តើឧបសគ្គណាខ្លះ ដែលរារាំងជនពិការមិនឱ្យចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោងរាជធានី ខេត្ត តើយើងអាចនឹងដកឧបសគ្គទាំងនេះ ដោយរបៀបណា។

គ្រូបណ្តុះបណ្តាលឱ្យក្រុមនីមួយៗពិនិត្យមើលតារាងខាងក្រោម និងវិភាគគម្រោងរបស់ពួកគេដោយសរសេរពីឧបសគ្គទាំងនេះ ហើយឱ្យពួកគេគិតរកដំណោះស្រាយ តើអ្នកណាទទួលខុសត្រូវក្នុងការចាត់វិធានការដោះស្រាយ និងថាតើចំណាយសម្រាប់វិធានការនេះមានកម្រិតទាប មធ្យម ឬខ្ពស់។ លទ្ធផលពិភាក្សាត្រូវបានរៀបចំតាមទម្រង់តារាងខាងក្រោមលើក្រដាសផ្ទាំងធំ។ គ្រូបណ្តុះបណ្តាលអាចអញ្ជើញតំណាងមកពីអង្គការជនពិការឱ្យចូលរួមក្នុងក្រុម និងផ្តល់គំនិត។

សូមមើលឧទាហរណ៍ក្នុងតារាងខាងក្រោម ៖

| **គម្រោង ÷ សាលាបឋមសិក្សាថ្មី** | | | | |
|---|---|---|---|---|
| **ប្រភេទ** | **ឧបសគ្គ** | **ដំណោះស្រាយ** | **អ្នកទទួលខុសត្រូវ** | **ចំណាយ** (ខ្ពស់ មធ្យម ទាប) |
| បង្កភាព ងាយស្រួល និងលទ្ធភាពទទួលបាន | សាលារៀនមិនមានភាពងាយស្រួលសម្រាប់អ្នកប្រើរទេះរុញ | ត្រួតពិនិត្យលើភាពងាយស្រួល និងសង់ជម្រាល និងបង្គន់ដែលងាយស្រួលក្នុងការប្រើប្រាស់ | ក្រុមប្រឹក្សា គណអភិបាល រួមជាមួយមន្ទីរអប់រំយុវជន និងកីឡា | មធ្យម |
| ឥរិយាបថ | កុមារពិការទទួលរងការសម្លុតឬធ្វើបាបដោយក្មេងផ្សេងទៀតនៅសាលារៀន | លើកកម្ពស់ការយល់ដឹងនៅសាលារៀន | នាយកសាលា និងអង្គការជនពិការនៅមូលដ្ឋាន | ទាប |
| ការប្រាស្រ័យទាក់ទង | គ្រូបង្រៀនមិនដឹងពីរបៀបបង្រៀនកុមារដែលខ្សោយគំហើញ | បណ្តុះបណ្តាលគ្រូនូវជំនាញ ក្នុងការបង្រៀនកុមារពិការ | អភិបាលរាជធានីខេត្ត ត្រូវសម្របសម្រួលជាមួយមន្ទីរអប់រំ យុវជន និងកីឡា និងអង្គការមិនមែនរដ្ឋាភិបាល | ទាប |

| គម្រោង ÷ សាលាបឋមសិក្សាថ្មី | | | | |
|---|---|---|---|---|
| ប្រភេទ | ឧបសគ្គ | ដំណោះស្រាយ | អ្នកទទួលខុសត្រូវ | ចំណាយ (ខ្ពស់ មធ្យម ទាប) |
| ការចូលរួម | មិនដឹងពីចំនួនកុមារពិការ ដែលនាំឱ្យគេមិនអាចវាយតម្លៃ ថាតើមានកុមារប៉ុន្មាននាក់ដែលគួរចុះឈ្មោះចូលរៀនក្នុងសាលារៀន | រាប់ចំនួនកុមារពិការ និងអាយុរបស់ពួកគេ | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ទាប |

៥. គ្រូបណ្តុះបណ្តាលដើរមើលជុំវិញ នៅពេលដែលក្រុមកំពុងធ្វើលំហាត់នេះ ដើម្បីពិនិត្យមើលថាតើពួកគេយល់លំហាត់នេះដែរឬទេ ដើម្បីផ្តល់ការគាំទ្រ ឬឆ្លើយនឹងសំណួរនានា។

➡ ប្រសិនបើ អ្នកចូលរួមមានការលំបាកក្នុងការចាប់ផ្តើមគិតពីចំណុចនេះ គ្រូបណ្តុះបណ្តាលអាចផ្តល់ក្រដាសកាតពណ៌សម្រាប់បំផុសគំនិត។ ក្រដាសកាតពណ៌សម្រាប់បំផុសគំនិតទាំងនេះ សរសេរជាស្រេចនូវខ្លឹមសារដូចមានក្នុងតារាងខាងក្រោម។ សមាជិកក្រុមម្នាក់អាចអានខ្លឹមសារក្នុងក្រដាសកាតពណ៌។ ក្រដាសកាតពណ៌ទាំងនេះ(ក្រុមនីមួយៗមានក្រដាសកាតពណ៌សរុបចំនួន១០)មានសំណួរ ឬកំណត់សំគាល់ ផ្អែកលើរឿងនៃករណីសិក្សាទាំង៤។ ក្រដាសកាតពណ៌នេះ ក៏នឹងអាចជួយឱ្យក្រុមចាប់ផ្តើមគិតពីគម្រោង និងពីឧបសគ្គនានាចំពោះគម្រោង?

**ខ្លឹមសារនៅលើក្រដាសកាតពណ៌សម្រាប់បំផុសគំនិត ៖**

- ខ្ញុំអាចទៅដល់ទីនោះ ដោយប្រើរទេះរបស់ខ្ញុំ! (ស្រីមុំ)។
- គ្រូបានបណ្តោយឱ្យក្មេងឯទៀត សម្លុត ឬធ្វើបាបខ្ញុំ (មករា)។
- តើអ្នកដឹងថាតើបង្គន់នេះអាចប្រើប្រាស់បានដោយជនពិការដែរឬទេ?(ស្រីមុំ)។
- មេភូមិបានខិតខំដើម្បីឱ្យខ្ញុំទទួលបានលិខិតអញ្ជើញចូលរួមក្នុងកិច្ចប្រជុំទាន់ពេលវេលា(សុផល)
- ខ្ញុំអាចតាមទាន់ការពិភាក្សាទាំងអស់ ដោយសារតែអ្នកបណ្តុះបណ្តាលបានខិតខំពន្យល់បានក្បោះក្បាយ ពីរូបភាពទាំងអស់(បុប្ផា)។
- ខ្ញុំចង់យល់ច្បាស់ ថាតើដំណាំណា ដែលខ្ញុំចាំបាច់ត្រូវដាំ ដើម្បីបានចំណេញ (មករា)។
- អ្វីដែលល្អគឺ អ្នកឯទៀតផ្តល់ពេលវេលាឱ្យខ្ញុំ ដើម្បីឱ្យខ្ញុំអាចផ្តល់នូវគំនិតយោបល់បាន(សុផល)។
- ជនពិការចង់ចូលរួមនៅក្នុងការអភិវឌ្ឍឃុំ ប៉ុន្តែយើងក៏មានតម្រូវការជាក់លាក់ ដើម្បីជួយឱ្យយើងចូលរួមក្នុងសកម្មភាពក្នុងឃុំដែរ។ ឧទាហរណ៍ ខ្ញុំត្រូវការរទេះរុញ(ស្រីមុំ) ។
- ស្ត្រីពិការជួបការលំបាកជាងបុរសពិការ(ថាវី)។
- មនុស្សផ្សេងទៀត រាប់អានខ្ញុំដោយការគោរព ពួកគេដឹងថា ខ្ញុំអាចរកស៊ីចិញ្ចឹមជីវិតបាន នាពេលឥឡូវនេះ (មករា)។

៦. បន្ទាប់ពីពិភាក្សារួច គ្រូបណ្តុះបណ្តាលឱ្យក្រុមនីមួយៗបិទតារាងលទ្ធផលពិភាក្សា(លើក្រដាសផ្ទាំងធំ)

តាមក្រុមនីមួយៗ នៅកន្លែងផ្សេងៗពីគ្នាជុំវិញបន្ទប់ និងជ្រើសរើសតំណាងម្នាក់ឱ្យចាំនៅទីតាំងនៃក្រដាសផ្ទាំងធំ។ អ្នកបណ្តុះបណ្តាល អ្នកចូលរួមដែលនៅសល់ដើរពិនិត្យ មើល និងសួរសំណួរ ឬផ្តល់យោបល់ផ្សេងៗ ដោយសរសេរលើក្រដាសកាតពណ៌ ហើយបិទលើក្រដាសផ្ទាំងធំទាំងនោះ។

គោលដៅរបស់លំហាត់នេះ គឺចង់ឱ្យអ្នកចូលរួមយល់ថា គម្រោងមួយចំនួននៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តមិនមានការដាក់បញ្ចូលពិការភាព និងមិនមានការចូលរួមពីជនពិការទេ ដោយសារតែឧបសគ្គនានាដូចដែលបានបង្ហាញក្នុងមេរៀនមុនៗ។ គ្រូបណ្តុះបណ្តាលបញ្ជាក់ថា គេអាចធ្វើអ្វីមួយ ដើម្បីដោះស្រាយឧបសគ្គទាំងនេះបាន ដោយមិនចាំបាច់ចំណាយថវិកាច្រើននោះទេ គ្រាន់តែត្រូវការការវិនិយោគពេលវេលា និងការប្តេជ្ញាចិត្ត ដើម្បីការដាក់បញ្ចូលពិការភាព។

| | |
|---|---|
| **មេរៀន៧.២**<br>**សកម្មភាពជាក់លាក់ សម្រាប់ការដាក់បញ្ចូលពិការភាព** | |
| **គោលដៅ** ៖ កំណត់សកម្មភាពដែលអាចធ្វើបាន ដើម្បីឱ្យគម្រោងដែលទទួលបានថវិកាគាំទ្រ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើគម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត មានការដាក់បញ្ចូលពិការភាព។ | |
| **រយៈពេល** | ៣០នាទី |

១. គ្រូបណ្តុះបណ្តាលប្រាប់អ្នកចូលរួមថា នៅក្នុងលំហាត់មុន យើងបានប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌដែលមានស្រាប់ ដើម្បីពិនិត្យលើឧបសគ្គនានាដែលជនពិការជួបប្រទះ និងអ្វីដែលយើងអាចធ្វើបាន ដើម្បីដកចេញនូវឧបសគ្គដែលរារាំងដល់ការចូលរួមរបស់ពួកគេ។

ឥឡូវនេះ លើកអំពីគម្រោងថ្មីមួយ ដើម្បីបង្ហាញដល់អ្នកចូលរួម **ឧទាហរណ៍** ៖ គម្រោងសាងសង់សាលាបឋមសិក្សាថ្មីមួយ។

គ្រូបណ្តុះបណ្តាលសួរថា ៖ តើបញ្ហាពាក់ព័ន្ធនឹងការបង្កភាពងាយស្រួលសម្រាប់ជនពិការអាចដោះស្រាយបានល្អបំផុត នៅពេលណា ៖ មុន ឬក្រោយការសាងសង់? **ចម្លើយគឺ ៖ មុនពេលសាងសង់ ដោយសារតែនៅពេលនោះគេងាយស្រួលបញ្ចូលវាទៅក្នុងគម្រោង ដោយប្រើប្រាស់មាត្រដ្ឋានឱ្យបានត្រឹមត្រូវ។** បញ្ចប់ដោយនិយាយថា ឧបសគ្គមួយចំនួនអាចបញ្ចៀសបាន នៅពេលដែលជនពិការចូលរួមនៅក្នុងដំណាក់កាលដំបូងនៃការរៀបចំគ្រោងការគម្រោង។

២. គ្រូបណ្តុះបណ្តាលបង្ហាញពីដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តដែលមាន៣ជំហាន ដោយពន្យល់ត្រួសៗពីសកម្មភាពក្នុងជំហាននីមួយៗ ដើម្បីឱ្យគ្រប់គ្នាដឹងពីអ្វីដែលកើតឡើងក្នុងជំហាន នីមួយៗ។

**ជំហានទី១**

**ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

សកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តក្នុងជំហានទី១នេះ រួមមាន៖

- ប្រជុំណែនាំពីការប្រមូលតម្រូវការអាទិភាព
- ប្រជុំបូកសរុបតម្រូវការគម្រោង សកម្មភាព និងចាត់អាទិភាព

**ជំហានទី២**

**ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

សកម្មភាពសំខាន់ៗដែលត្រូវអនុវត្តក្នុងជំហានទី២នេះ រួមមាន៖

- កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ការពិនិត្យ និងចាត់អាទិភាពគម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តឡើងវិញ
- រៀបចំវេទិកាពិគ្រោះយោបល់ក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅតាមបណ្តាក្រុង ស្រុក ខណ្ឌ
- ចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ការរៀបចំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ
- ការពិនិត្យ និងផ្តល់យោបល់

**ជំហានទី៣**

**ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

សកម្មភាពសំខាន់ក្នុងជំហានទី៣នេះ រួមមាន៖

- កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត។

៣. គ្រូបណ្តុះបណ្តាលបញ្ជាក់ប្រាប់អ្នកចូលរួមថា ៖ យើងអាចធ្វើសកម្មភាពអនុវត្តនៅជំហាននីមួយៗនៃដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដើម្បីធានាឱ្យមានការចូលរួមពីក្រុមជនពិការ និងសួរថា តើក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត គួរធ្វើសកម្មភាពអ្វីខ្លះ ដើម្បីធានាឱ្យមានការចូលរួមពីជនពិការ និងបញ្ចៀសនូវរាល់ឧបសគ្គទាំងឡាយ? បន្ទាប់ពី អ្នកចូលរួមបានឆ្លើយសំណួរនេះរួច គ្រូបណ្តុះបណ្តាលផ្តល់ចម្លើយ(ដូចដែលបានរៀបចំជាស្រេចក្នុងតារាងខាងក្រោម)។

**ឧទាហរណ៍ ៖** តើសកម្មភាពជាក់លាក់អ្វីខ្លះ ក្នុងជំហានទី១ ដែលគេអាចធ្វើបាន ៖ ការពិនិត្យលើបញ្ហា ឬតម្រូវការជាមួយនឹងប្រជាពលរដ្ឋឡើងវិញ? ប្រសិនបើ ជនពិការ ឬស្ថាប័នឬ/និងអង្គការសង្គមស៊ីវិលដែលធ្វើការងារពិការភាព ត្រូវបានគេបញ្ចូលទៅក្នុងដំណាក់កាលកំណត់ពីតម្រូវការ

នោះគម្រោងដែលត្រូវបានជ្រើសរើសនឹងកាន់តែមានភាពពាក់ព័ន្ធចំពោះពួកគេ។ សកម្មភាពជាក់លាក់បន្ទាប់ គឺធានាថាជនពិការត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ និងមានលទ្ធភាពចូលរួមយ៉ាងសកម្ម និងចែករំលែកទស្សនៈយល់ឃើញរបស់ពួកគេ។

ឧទាហរណ៍មួយចំនួនអំពីសកម្មភាពដែលមានការដាក់បញ្ចូលមានដូចខាងក្រោម ៖

**ជំហានទី១៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

- រៀបចំផែនការសម្រាប់គម្រោងកសាងសមត្ថភាពអំពីការដាក់បញ្ចូលពិការភាពនៅថ្នាក់រាជធានី ខេត្ត ជាពិសេសក្រុមការងារកសាងផែនការ(តាមរយៈការលើកកម្ពស់ការយល់ដឹង)
- ចែករំលែកទិន្នន័យអំពីជនពិការនៅក្នុងរាជធានី ខេត្ត នៅក្នុងកិច្ចប្រជុំណែនាំដើម្បីកំណត់ និងរៀបចំសំណើគម្រោងវិនិយោគ
- អញ្ជើញតំណាងជនពិការចូលរួមប្រជុំស្តីពីការប្រមូលតម្រូវការអាទិភាព និងប្រជុំបូកសរុប បញ្ជីគម្រោងអាទិភាព
- អញ្ជើញស្ថាប័នដែលធ្វើការផ្នែកពិការភាព ឬធ្វើការជាមួយជនពិការ ឱ្យចូលរួមនៅក្នុងកិច្ចប្រជុំណែនាំ និងចែករំលែកបញ្ហានានាទាក់ទងនឹងជនពិការ
- ធានាថា ទីតាំងសម្រាប់កិច្ចប្រជុំ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ។

**ជំហានទី២ ៖ ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

- ធានាថា អគារសាធារណៈ និងសម្ភាររូបវន្តដែលមានស្រាប់ និងថ្មីៗ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ
- ធានាថាព័ត៌មានសាធារណៈ (ឧទាហរណ៍ ៖ សុខភាព កសិកម្ម ។ល។) អាចទទួលបាន និងអាចយល់ដឹងបានដោយជនពិការទៅតាមប្រភេទនៃពិការភាព
- រៀបចំសូចនាករដែលមានការដាក់បញ្ចូលពិការភាពនៅក្នុងគម្រោង ឧទាហរណ៍ ចំនួនជនពិការចូលរួមក្នុងការផ្តល់យោបល់ និងចំនួនជនពិការទទួលផលប្រយោជន៍ពីគម្រោង។ល។
- ធានាឱ្យមានការវិភាជន៍ថវិកាសម្រាប់ការបង្កភាពងាយស្រួលដល់ជនពិការ ដូចជា ជួលអ្នកបកប្រែភាសាសញ្ញា ឬការបង្កភាពងាយស្រួលដល់ការធ្វើដំណើរនៃជនពិការកាយសម្បទា..
- ផ្តល់អាទិភាពដល់ក្រុមដែលទន់ខ្សោយជាងគេ ឬជាងគេបំផុត(ដូចជា ស្ត្រីពិការ)
- អញ្ជើញតំណាងអង្គការជនពិការឱ្យចូលរួមនៅក្នុងសិក្ខាសាលា
- ធ្វើឱ្យអង្គការមិនមែនរដ្ឋាភិបាល យល់ដឹង ចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- ដាក់បញ្ចូលគម្រោង ឬសូចនាករដែលពាក់ព័ន្ធផ្ទាល់ទៅនឹងពិការភាពក្នុងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការដាក់បញ្ចូលពិការភាពក្នុងគម្រោងផ្អែកទៅតាមសូចនាករ និងការវាស់វែងលើផលប៉ះពាល់របស់គម្រោងទៅលើជនពិការ
- មានតំណាងជនពិការនៅក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

**ជំហានទី៧ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

- មានតំណាងជនពិការចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ធ្វើឱ្យក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត យល់ដឹង និងចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- អភិបាលរាជធានី ខេត្ត ឬ ក្រុមការងារកសាងផែនការ គប្បីណែនាំឱ្យមានការផ្សព្វផ្សាយ ខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធជាពិសេសជនពិការ តាមរយៈកិច្ចប្រជុំនានា វេទិកាសាធារណៈ សារព័ត៌មាន វិទ្យុ និងមធ្យោបាយផ្សេងៗទៀត។

៤. គ្រូបណ្តុះបណ្តាលសួរទៅអ្នកចូលរួម តើពួកគេនឹងធ្វើអ្វីខ្លះ ដើម្បីធ្វើឱ្យដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត នាពេលបន្ទាប់ ឱ្យកាន់តែមានការដាក់បញ្ចូលពិការភាព។

**មេរៀន៧.៣**

**សង្ខេបមេរៀនជំពូកទី៧**

| | |
|---|---|
| **គោលដៅ** | ៖ រំលឹកអ្នកចូលរួមអំពីអ្វីដែលពួកគេបានរៀនក្នុងមេរៀនជំពូកទី៧ និងបញ្ជាក់បំភ្លឺពីសំណួរនានាដែលនៅសេសសល់។ |
| **រយៈពេល** | ៥នាទី |

គ្រូបណ្តុះបណ្តាលសង្ខេបមេរៀនក្នុងជំពូកទី៧ តាមខ្លឹមសារដូចខាងក្រោម ៖

១. គម្រោងដែលមានស្រាប់ នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត មិនមែនសុទ្ធតែមានការដាក់បញ្ចូលពិការភាពនោះទេ។

២. ដើម្បីឱ្យគម្រោងមានការដាក់បញ្ចូលពិការភាព គេចាំបាច់ត្រូវតែដឹងពីឧបសគ្គ និងដកឧបសគ្គទាំងនោះចេញ។

៣. ដំណោះស្រាយមួយចំនួន មិនចាំបាច់ត្រូវការចំណាយថវិកាច្រើននោះទេ គ្រាន់តែត្រូវការវិនិយោគពេលវេលា ការប្តេជ្ញាចិត្ត និងត្រូវមានភាពច្បាស់លាស់ពីអ្នកដែលត្រូវចាត់វិធានការ។

៤. ការដោះស្រាយឧបសគ្គដែលអាចកើតមានក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ទាមទារឱ្យមានការចូលរួមឱ្យបានខ្លាំងក្លាពីជនពិការ។

៥. ការលើកកម្ពស់ការចូលរួមរបស់ជនពិការ និងការដាក់បញ្ចូលពិការភាពទៅក្នុងគម្រោង អាចធ្វើឡើងនៅគ្រប់ជំហានទាំងអស់នៃដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត។

# ជំពូកទី៨

# ការវាយតម្លៃ និង

# បិនវត្តបណ្ដុះបណ្ដាល

# ជំពូកទី៨

# ការវាយតម្លៃ និងបិទវគ្គបណ្តុះបណ្តាល

## ក). សេចក្តីពិពណ៌នា

ជំពូកនេះមានគោលដៅធ្វើការឆ្លុះបញ្ចាំង និងវាយតម្លៃសម្រាប់អ្នកចូលរួមផង និងសម្រាប់អ្នកបណ្តុះបណ្តាលផង។ គោលដៅចម្បង គឺដើម្បី ៖

- លើកទឹកចិត្តឱ្យអ្នកចូលរួមយកអ្វីដែលពួកគេបានរៀនទៅអនុវត្តជាក់ស្តែង
- វាយតម្លៃលើកម្រិតយល់ដឹងរបស់អ្នកចូលរួមនៅមុន និងក្រោយការបណ្តុះបណ្តាល
- ទទួលព័ត៌មានត្រលប់ពីអ្នកចូលរួម ដើម្បីកែលម្អការបណ្តុះបណ្តាល
- ផ្តល់ព័ត៌មានត្រលប់ដល់គ្នាទៅវិញទៅមក ដើម្បីកែលម្អការបណ្តុះបណ្តាល
- ផ្តល់ព័ត៌មានត្រលប់ដល់គ្នាទៅវិញទៅមករវាងអ្នកបណ្តុះបណ្តាលទាំងពីរ ដើម្បីកែលម្អរបៀបធ្វើការរបស់អ្នកបណ្តុះបណ្តាលទាំងពីរ
- លើកទឹកចិត្តឱ្យអង្គការជនពិការនៅមូលដ្ឋាន និងអង្គការដែលធ្វើការងារផ្នែកពិការភាពធ្វើការតាមដានបន្តជាមួយអ្នកចូលរួម

## ខ). មាតិកាមេរៀន

| លរ | មេរៀន | រយៈពេល | សម្ភារៈ និងឯកសារ |
|---|---|---|---|
| ៨.១. | ល្បែងថាមពល | ១៥នាទី | ស៊ុត ក្រដាស ជបជ័រ ស្កុត |
| ៨.២. | ការវាយតម្លៃចំណេះដឹងក្រោយការបណ្តុះបណ្តាល | ១៥នាទី | ទម្រង់វាយតម្លៃក្រោយវគ្គ |
| ៨.៣. | ការវាយតម្លៃបញ្ចប់ការបណ្តុះបណ្តាល | ១០នាទី | ក្រដាសផ្ទាំងធំ |
| ៨.៤. | ពិធីបិទវគ្គបណ្តុះបណ្តាលជាផ្លូវការ | ១០នាទី | |
| ៨.៥. | សកម្មភាពក្រោយវគ្គបណ្តុះបណ្តាល | ១០នាទី | |
| **សរុប** | | **៦០នាទី** | |

## គ). ដំណើរការសម្របសម្រួល

| **មេរៀន៨.១**<br>**ល្បែងថាមពល "ការទម្លាក់ស៊ុតដ៏អស្ចារ្យ"** | |
|---|---|
| **គោលដៅ** ៖ | លើកទឹកចិត្តឱ្យអ្នកចូលរួមមានភាពច្នៃប្រឌិត ចេះស្វែងរកដំណោះស្រាយ ចេះធ្វើការងារជាមួយគ្នា និងមិនធ្វើការបោះបង់រាថយ និងធ្វើការបញ្ជាក់ថាអ្នកចូលរួម អាចយកអ្វីដែលពួកគេបានរៀនទៅអនុវត្តបាន។ |
| **រយៈពេល** | ១៥នាទី |

១. គ្រូបណ្តុះបណ្តាលបែងចែកអ្នកចូលរួមជាក្រុម ក្នុងមួយក្រុមមានគ្នាពី៤ ទៅ៥នាក់។ ក្រុមនីមួយៗទទួលបានសម្ភារៈមួយចំនួន ដូចជា ជបជ័រ ស្កុត ក្រដាស និងស៊ុតមួយគ្រាប់... ។

២. គ្រូបណ្តុះបណ្តាលសួរអ្នកចូលរួម ៖ តើស៊ុតនេះនឹងបែកដែរឬទេ នៅពេលដែលអ្នកទម្លាក់វាពីកម្ពស់១ម៉ែត្រ? ចម្លើយ គឺវានឹងបែក។

៣. បន្ទាប់មក គ្រូបណ្តុះបណ្តាលឱ្យក្រុមរៀបចំវេចខ្ចប់ស៊ុតនេះ ក្នុងទម្រង់អ្វីក៏បានដែលពួកចង់ ដើម្បីធានាថា នៅពេលដែលគេទម្លាក់ពីកម្ពស់៣ម៉ែត្រ ស៊ុតនេះមិនអាចបែកបាន។ រយៈពេលរៀបចំ៥នាទី។

៤. បន្ទាប់មក គ្រូបណ្តុះបណ្តាលឱ្យក្រុមនីមួយៗចាត់តំណាងក្រុមរបស់ខ្លួនម្នាក់មកខាងមុខជាមួយនឹងកញ្ចប់ស៊ុត។ តំណាងក្រុមឡើងលើតុ ឬអ្វីមួយដែលខ្ពស់ម្នាក់ម្តងៗ លើកដៃរបស់ខ្លួនឱ្យបានខ្ពស់ (ប្រហែល៣ម៉ែត្រ) ហើយទម្លាក់ស៊ុតចុះមក។

នៅពេលដែលស៊ុតនេះបានធ្លាក់ ពួកគេអាចស្រាយកញ្ចប់ស៊ុតរបស់ពួកគេចេញ ដើម្បីពិនិត្យមើលថា តើស៊ុតនេះបែក ឬអត់។ អ្នកអាចឱ្យកាដូតូចមួយ (ដូចជា ស្ករគ្រាប់ ជាដើម) ទៅកាន់ក្រុមដែលទទួលជោគជ័យ មិនឱ្យស៊ុតនេះបែក។

៥. ក្រោយពីល្បែងថាមពលនេះចប់ ធ្វើការឆ្លុះបញ្ចាំង ដោយសួរអ្នកចូលរួមថា តើពួកគេបានរៀនអ្វីខ្លះពីល្បែងថាមពលនេះ។ បន្ថែមពីលើគំនិត ដែលផ្តល់ដោយអ្នកចូលរួម គ្រូបណ្តុះបណ្តាលលើកឡើងពីអ្វីដែលបង្ហាញក្នុងល្បែងថាមពលនេះថា ៖

- ត្រូវមានភាពច្នៃប្រឌិត ក្នុងការស្វែងរកដំណោះស្រាយ
- ធ្វើការងាររួមគ្នា ដើម្បីស្វែងរកដំណោះស្រាយឱ្យបានល្អ
- ត្រូវបង្ហាញពីគំនិតរបស់ខ្លួន និងស្តាប់គំនិតរបស់អ្នកដទៃ
- មិនធ្វើការបោះបង់នៅពេលដែលគេគិតថា មិនអាចធ្វើបាន ពីព្រោះជានិច្ចកាលត្រូវតែមានមធ្យោបាយ



នៅចុងក្រោយ ប្រសិនបើ គេអាចការពារស៊ុតនេះមិនឱ្យបែក តើគេមិនអាចយកអ្វីដែលបានរៀនសូត្រនៅក្នុងវគ្គបណ្តុះបណ្តាលនេះទៅអនុវត្តបានទេឬ? ជាការពិត ពួកគេអាចធ្វើបាន។

<table>
<tr><td colspan="2">មេរៀន៨.២<br>ការវាយតម្លៃចំណេះដឹងក្រោយការបណ្តុះបណ្តាល</td></tr>
<tr><td colspan="2">គោលដៅ ៖ ការវាយតម្លៃកម្រិតយល់ដឹងដែលទទួលបាននៅក្នុងអំឡុងពេលនៃការបណ្តុះបណ្តាល។</td></tr>
<tr><td>រយៈពេល</td><td>១៥នាទី</td></tr>
</table>

គ្រូបណ្តុះបណ្តាលផ្តល់ទម្រង់វាយតម្លៃក្រោយការបណ្តុះបណ្តាលឱ្យអ្នកចូលរួម រួចឱ្យអ្នកចូលរួមបំពេញទម្រង់នេះរៀងៗខ្លួន។ ដើម្បីជៀសវាងការមើលគ្នា គ្រូបណ្តុះបណ្តាលរំលឹកប្រាប់ពួកគេថា ពួកគេប្រហែលជាដឹងប្រហាក់ប្រហែលគ្នា ឬខ្លួនឯងអាចដឹងច្រើនជាងអ្នកអង្គុយជិតខ្លួន ហេតុនេះត្រូវជឿជាក់លើខ្លួនឯង និងបញ្ជាក់ថា អ្នកនឹងប្រើប្រាស់វាយតម្លៃនេះ ដើម្បីកែលម្អការបណ្តុះបណ្តាលរបស់អ្នក។ នៅពេលដែលអ្នកចូលរួមបំពេញចប់ហើយ ឱ្យពួកគេប្រគល់មកឱ្យគ្រូបណ្តុះបណ្តាលវិញ។

| មេរៀន៨.៣<br>ការវាយតម្លៃបញ្ចប់ការបណ្ដុះបណ្ដាល | |
|---|---|
| **គោលដៅ** ៖ ទទួលព័ត៌មានត្រលប់ពីអ្នកចូលរួម សម្រាប់កែលម្អការបណ្ដុះបណ្ដាលនេះ | |
| **រយៈពេល** | ១០នាទី |

ដោយសារតែគ្រប់គ្នាបានធ្វើការវាយតម្លៃរាល់ថ្ងៃ ពាក់ព័ន្ធជាមួយនឹងអ្វីដែលពួកគេចូលចិត្ត និង អ្វីដែលអាចកែលម្អរួចហើយ ការវាយតម្លៃបញ្ចប់វគ្គបណ្ដុះបណ្ដាលនេះអាចធ្វើឡើងក្នុងក្រុមធំតែម្ដង។ គ្រូបណ្ដុះបណ្ដាលសួរអ្នកចូលរួមនូវសំណួរដូចខាងក្រោម ៖

១. តើអ្នកចូលចិត្តអ្វីជាងគេអំពីការបណ្ដុះបណ្ដាលនេះ?

២. តើគួរកែលម្អចំណុចអ្វីខ្លះ?

៣. តើអ្វីដែលសំខាន់ជាងគេ?

គ្រូបណ្ដុះបណ្ដាលអាចផ្ដល់ឱកាសឱ្យអ្នកចូលរួមដែលនៅតែចង់ចែករំលែកគំនិតយោបល់អ្វីមួយ ប្រសិនបើពួកគេមិនចង់ចែករំលែកនៅក្នុងក្រុមធំ ករណីនេះ គ្រូបណ្ដុះបណ្ដាលឱ្យអ្នកចូលរួមសរសេរ ព័ត៌មានត្រលប់នៅលើក្រដាសកាតពណ៌ ហើយផ្ដល់ទៅឱ្យគ្រូបណ្ដុះបណ្ដាល។

គ្រូបណ្ដុះបណ្ដាលបញ្ជាក់ម្ដងទៀតថា ពួកគេអាចយកឧបករណ៍ទាំងអស់ ដែលមានក្នុងវគ្គបណ្ដុះបណ្ដាលនេះទៅប្រើប្រាស់ក្នុងការងារ ឬតម្រូវការជាបុគ្គលរបស់ខ្លួន។ សៀវភៅណែនាំសម្រាប់អ្នកចូលរួម គឺជាមគ្គុទេសក៍មួយយ៉ាងសំខាន់ ដែលអាចយកប្រើប្រាស់ ឬធ្វើការឆ្លុះបញ្ចាំង នៅពេលដែលពួកគេជួបនឹងជនពិការដើរចូលក្នុងអគារ នៅពេលរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ឬរៀបចំគម្រោង។

| មេរៀន៨.៤<br>ពិធីបិទវគ្គបណ្ដុះបណ្ដាលជាផ្លូវការ | |
|---|---|
| **គោលដៅ** ៖ លើកទឹកចិត្តឱ្យអ្នកចូលរួមយកអ្វីដែលពួកគេបានរៀនទៅអនុវត្ត | |
| **រយៈពេល** | ១០នាទី |

អញ្ជើញគណៈធិបតី ដូចជា អភិបាលរាជធានី ខេត្ត ឬ អភិបាលក្រុង ស្រុក ខណ្ឌ ឬភ្ញៀវកិត្តិយស ដើម្បីចូលរួមបិទវគ្គបណ្ដុះបណ្ដាលនេះ និងចែកវិញ្ញាបនបត្រ។

ពិធីបិទវគ្គបណ្ដុះបណ្ដាលជាផ្លូវការ ក្រោមអធិបតីភាពរបស់អភិបាលរាជធានី ខេត្ត ឬអភិបាលក្រុង ស្រុក ខណ្ឌ ឬភ្ញៀវកិត្តិយសដទៃទៀត។ ចែកវិញ្ញាបនបត្របញ្ចប់ការសិក្សា(បើមាន)។

ក្រោយសកម្មភាពនេះចប់ ការបណ្ដុះបណ្ដាលត្រូវបានបញ្ចប់ និងបិទជាផ្លូវការ ហើយអ្នកចូលរួមអាចចាកចេញបាន។

| មេរៀន៨.៥<br>សកម្មភាពក្រោយវគ្គបណ្តុះបណ្តាល | |
|---|---|
| **គោលដៅ ៖** | ផ្តល់ព័ត៌មានត្រលប់របស់គ្រូបណ្តុះបណ្តាលទៅឱ្យអ្នកចូលរួម ដើម្បីកែលម្អរបៀបធ្វើការបណ្តុះបណ្តាលជាដៃគូ។ |
| **រយៈពេល** | ១០នាទី |

សកម្មភាពក្រោយវគ្គបណ្តុះបណ្តាលនេះ មានគោលដៅធ្វើការឆ្លុះបញ្ចាំងលើការបណ្តុះបណ្តាល ដើម្បីទាញយកបទពិសោធន៍ និងចំណុចរៀនសូត្រដែលទទួលបានពីការបណ្តុះបណ្តាលនេះ សម្រាប់ធ្វើការកែលម្អវគ្គបណ្តុះបណ្តាលនាពេលបន្ទាប់ និងធានាឱ្យមានការតាមដានបន្តឱ្យបានល្អ។

សកម្មភាពក្រោយវគ្គសិក្សា រួមមាន ៖

- សម្អាតបន្ទប់សិក្សា បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល(ដោះក្រដាសផ្ទាំងធំចេញពីជញ្ជាំង)
- ពិភាក្សាពីចំណុចដែលទទួលបានពីការវាយតម្លៃរបស់អ្នកចូលរួម
- ផ្តល់ព័ត៌មានត្រលប់ក្នុងចំណោមគ្រូបណ្តុះបណ្តាល ៖ អ្វីដែលដំណើរការបានល្អ អ្វីដែលអាចកែលម្អបន្ថែម
- ធ្វើការសម្រេចចិត្តថាតើអ្នកណានឹងត្រូវកែកិច្ចការវាយតម្លៃមុន និងក្រោយការបណ្តុះបណ្តាល និងសរសេររបាយការណ៍បណ្តុះបណ្តាល(២-៣ទំព័រ) ដើម្បីផ្តល់ជាព័ត៌មានដល់ថ្នាក់ដឹកនាំ ឬអ្នកពាក់ព័ន្ធ។ របាយការណ៍បណ្តុះបណ្តាល គួរមានមាតិកា ដូចខាងក្រោម ៖
  - កាលបរិច្ឆេទនៃការបណ្តុះបណ្តាល
  - បញ្ជីឈ្មោះអ្នកចូលរួម
  - ការសង្កេតចំណុចសំខាន់ៗរបស់គ្រូបណ្តុះបណ្តាល ផ្អែកទៅតាមការធ្វើការវាយតម្លៃ
  - សកម្មភាពអនុវត្តបន្ត ៖ ពេលវេលាបណ្តុះបណ្តាលបន្តនៅថ្នាក់ខេត្ត និងឃុំសង្កាត់
  - ភ្ជាប់សៀវភៅណែនាំសម្រាប់អ្នកចូលរួម
- ផ្ញើលិខិតសរសើរដល់អ្នកចូលរួមជាជនពិការទាំងអស់ ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល
- ផ្ញើលិខិតសរសើរដល់អភិបាលក្រុង ស្រុក ខណ្ឌ ភ្ជាប់របាយការណ៍សង្ខេបអំពីវគ្គបណ្តុះបណ្តាល។

# ៤. សេចក្តីសន្និដ្ឋាន

## ៤.១. សូចនាករនៃភាពជោគជ័យ

នៅចុងបញ្ចប់នៃការបណ្តុះបណ្តាលនេះ សំណួរដែលសំខាន់គឺថា ៖ តើការបណ្តុះបណ្តាលនេះទទួលបានជោគជ័យដែរឬទេ?

សូចនាករសំខាន់ទី១ ៖ បង្ហាញពីភាពជោគជ័យ គឺថាតើអ្នកចូលរួម សម្រេចតាមគោលបំណងនៃការបណ្តុះបណ្តាលបានកម្រិតណា។

**គោលដៅនៃការបណ្តុះបណ្តាលសម្រាប់ក្រុមគោលដៅនៅថ្នាក់ឃុំ សង្កាត់។ អ្នកចូលរួម ៖**

- អាចកំណត់ដឹងថាតើ នរណាមានពិការភាពក្នុងសហគមន៍
- យល់ពីភាពខុសប្លែកគ្នារវាងភាពខ្សោយ និងពិការភាព
- យល់ និងអាចជំនះ នឹងការយល់ឃើញរបស់សង្គមអំពីពិការភាព
- អាចពិនិត្យផ្ទៀងផ្ទាត់ថារាល់អគារសាធារណៈ កន្លែងផ្តល់សេវា កន្លែងប្រជុំដែលមានស្រាប់ និងសង់ថ្មីទាំងអស់មានភាពងាយស្រួលចេញចូលស្របតាមស្តង់ដារដែលកំណត់ដោយថ្នាក់ជាតិ
- អាចធានាថាជនពិការទាំងអស់នៅក្នុងឃុំ អាចទទួលបានព័ត៌មានសាធារណៈ
- អាចជំរុញឱ្យជនពិការចូលរួមឱ្យបានសកម្មក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដែលតម្រូវឱ្យមានការចូលរួមពីប្រជាជន(ដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់)
- ដឹងពីទីកន្លែង អង្គការជនពិការ និងបណ្តាញជនពិការ ដែលមានវត្តមានក្នុងតំបន់របស់ខ្លួន
- ដឹងពីទីកន្លែងអ្នកផ្តល់សេវាដល់ជនពិការក្នុងតំបន់របស់ខ្លួន ឬតំបន់ដែលនៅជិត និងអាចបញ្ជូនជនពិការទៅរកអ្នកផ្តល់សេវាទាំងនោះ។

**គោលដៅនៃការបណ្តុះបណ្តាលសម្រាប់ក្រុមគោលដៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ អ្នកចូលរួម ៖**

- អាចប្រើប្រាស់ទិន្នន័យសរុបអំពីពិការភាពក្នុងក្រុង ស្រុក ខណ្ឌរបស់ខ្លួន និងប្រើប្រាស់ទិន្នន័យនេះសម្រាប់គោលដៅនៃការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ
- យល់ពីភាពខុសប្លែកគ្នារវាងភាពខ្សោយ និងពិការភាព
- យល់ និងអាចជំនះនឹងការយល់ឃើញរបស់សង្គមអំពីពិការភាព
- អាចពិនិត្យផ្ទៀងផ្ទាត់ថារាល់អគារសាធារណៈ កន្លែងផ្តល់សេវា និងកន្លែងប្រជុំដែលមានស្រាប់ និងសង់ថ្មីទាំងអស់មានភាពងាយស្រួលចេញចូលស្របតាមស្តង់ដារដែលកំណត់ដោយថ្នាក់ជាតិ
- យល់ពីការទទួលខុសត្រូវនៅថ្នាក់ឃុំ និងសារសំខាន់ៗ ពាក់ព័ន្ធនឹងការដាក់បញ្ចូលពិការភាព
- អាចវាយតម្លៃលើដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ពីកម្រិតនៃការដាក់បញ្ចូលពិការភាពក្នុងសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ
- អាចធានា ថាជនពិការទទួលបាននូវព័ត៌មានសាធារណៈដែលផ្សព្វផ្សាយដោយថ្នាក់ក្រុង ស្រុក ខណ្ឌ ។

**គោលដៅនៃការបណ្ដុះបណ្ដាលសម្រាប់ក្រុមគោលដៅថ្នាក់រាជធានី ខេត្ត។ អ្នកចូលរួម ៖**

- អាចប្រើប្រាស់ទិន្នន័យសរុបអំពីពិការភាពក្នុងស្រុករបស់ខ្លួន និងប្រើប្រាស់ទិន្នន័យនេះសម្រាប់គោលដៅនៃការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- យល់ពីភាពខុសប្លែកគ្នារវាងភាពខ្សោយ និងពិការភាព
- យល់ និងអាចជំនះនឹងការយល់ឃើញរបស់សង្គមអំពីពិការភាព
- ដឹងថាសិទ្ធិរបស់ជនពិការត្រូវបានចែងក្នុងច្បាប់ និងគោលនយោបាយនានារបស់ប្រទេសកម្ពុជា
- អាចពិនិត្យផ្ទៀងផ្ទាត់ថារាល់អគារសាធារណៈ កន្លែងផ្ដល់សេវា និងកន្លែងប្រជុំដែលមានស្រាប់ និងសង់ថ្មីទាំងអស់មានភាពងាយស្រួលចេញចូល ស្របតាមស្តង់ដា ដែលកំណត់ដោយថ្នាក់ជាតិ
- អាចធានា ថាជនពិការទទួលបាននូវព័ត៌មានសាធារណៈដែលផ្សព្វផ្សាយដោយថ្នាក់រាជធានី ខេត្ត
- មានទឹកចិត្តរៀបចំវេទិកាសាធារណៈដែលមានការដាក់បញ្ចូលពិការភាព ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធពីចលនាជនពិការ អង្គការជនពិការ ក៏ដូចជា ស្ថាប័នពាក់ព័ន្ធ ដើម្បីពិភាក្សាពីតម្រូវការ និងការព្រួយបារម្ភរបស់ជនពិការនៅក្នុងរាជធានី ខេត្តរបស់ខ្លួន
- យល់ពីតួនាទីរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងការទទួលខុសត្រូវផ្សេងទៀត។

**សូចនាករសំខាន់ទី២ ៖** ភាពជោគជ័យ គឺអ្នកចូលរួមរីករាយជាមួយនឹងការបណ្ដុះបណ្ដាលនេះដែរឬទេ។ អ្នកចូលរួមក្នុងការបណ្ដុះបណ្ដាលនឹងមានទំនោរប្រើប្រាស់ចំណេះដឹង និងជំនាញ ដែលពួកគេទើបទទួលបានថ្មីៗ នៅពេលដែលពួកគេទទួលបាននូវការលើកទឹកចិត្ត ព្រមទាំងបទពិសោធន៍ជាវិជ្ជមានក្នុងអំឡុងពេលបណ្ដុះបណ្ដាល។

មានវិធីផ្សេងទៀត ដើម្បីវាយតម្លៃសូចនាករសំខាន់ៗ នៃភាពជោគជ័យ ៖

- ការវាយតម្លៃមុន និងក្រោយវគ្គបណ្ដុះបណ្ដាល៖ អ្នកចូលរួមបណ្ដុះបណ្ដាលត្រូវបានធ្វើការវាយតម្លៃមុន និងក្រោយការបណ្ដុះបណ្ដាល។
- ការវាយតម្លៃនៅចុងថ្ងៃនីមួយៗ ៖ អ្នកចូលរួមលើកឡើងពីអ្វីដែលពួកគេយល់ឃើញថាមានលក្ខណៈវិជ្ជមានអំពីការបណ្ដុះបណ្ដាលនេះ និងអ្វីដែលចាំបាច់ត្រូវកែលម្អ។
- ការវាយតម្លៃបញ្ចប់វគ្គបណ្ដុះបណ្ដាល ៖ អ្នកចូលរួមលើកឡើងពីអ្វីដែលពួកគេបានរៀន អ្វីដែលចាំបាច់ត្រូវកែលម្អបន្ថែម និងអ្វីដែលពួកគេចូលចិត្តអំពីការបណ្ដុះបណ្ដាលនេះ។

## ៤.២. ផែនការបន្ទាប់

ក្នុងនាមជាគ្រូបណ្ដុះបណ្ដាល រាល់ឱកាសផ្ដល់ការបណ្ដុះបណ្ដាលក៏ជាឱកាសរៀនសូត្រផងដែរ។ មនុស្សមានលក្ខណៈផ្សេងៗពីគ្នាអាចមានប្រតិកម្មខុសៗគ្នាទៅនឹងការបណ្ដុះបណ្ដាល ឬមានរឿងរ៉ាវដែលមិនបានរំពឹងទុកអាចកើតមានឡើង។ សូមប្រើប្រាស់ឱកាសទាំងនេះ ដើម្បីបង្កើនភាពចម្រុះនៃយុទ្ធសាស្ត្រ និងជំនាញរបស់អ្នក ក្នុងនាមជាគ្រូបណ្ដុះបណ្ដាល។

នៅក្នុងប្រអប់ឧបករណ៍បណ្តុះបណ្តាលអំពីការដាក់បញ្ចូលពិការភាពរបស់ប្រទេសកម្ពុជា មានព័ត៌មានសារតារ និងដំបូន្មានជាច្រើនសម្រាប់គ្រូបណ្តុះបណ្តាលអំពី ៖

- របៀបរៀនសូត្ររបស់មនុស្ស
- កត្តាដែលនាំឱ្យគ្រូបណ្តុះបណ្តាលធ្វើការងារប្រកបដោយប្រសិទ្ធភាព និង
- របៀបរៀបចំកម្មវិធីបណ្តុះបណ្តាលដោយមានការដាក់បញ្ចូលពិការភាព

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## កាលវិភាគវគ្គបណ្ដុះបណ្ដាលការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| ពេលវេលា | ចំណេះដឹងមេរៀន | អ្នកសម្របសម្រួល |
|---|---|---|
| | **ថ្ងៃទី១** | |
| ០៨:០០-០៨:៣០ | ពិធីបើកវគ្គបណ្ដុះបណ្ដាល | |
| ០៨:៣០-០៩:៣០ | ជំពូកទី១ ៖ ការចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាល | |
| ០៩:៣០-០៩:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥-១១:៣០ | ជំពូកទី២ ៖ ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាព | |
| ១១:៣០-១៣:៣០ | **សម្រាកថ្ងៃត្រង់** | |
| ១៣:៣០-១៥:៣០ | ជំពូកទី២ ៖ ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាព(ត) | |
| ១៥:៣០-១៥:៤៥ | **សម្រាកអាហារសម្រន់** | |
| ១៥:៤៥-១៧:០០ | ជំពូកទី២ ៖ ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាព(ត) | |
| | **ថ្ងៃទី២** | |
| ០៨:០០-០៩:៣០ | ជំពូកទី៣ ៖ ការបង្ហាញពីការគោរព និងសេចក្ដីថ្លៃថ្នូរ | |
| ០៩:៣០-០៩:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥-១១:៣០ | ជំពូកទី៤ ៖ ការប្រាស្រ័យទាក់ទងជាមួយជនពិការ | |
| ១១:៣០-១៣:៣០ | **សម្រាកថ្ងៃត្រង់** | |
| ១៣:៣០-១៥:៣០ | ជំពូកទី៤ ៖ ការប្រាស្រ័យទាក់ទងជាមួយជនពិការ(ត) | |
| ១៥:៣០-១៥:៤៥ | **សម្រាកអាហារសម្រន់** | |
| ១៥:៤៥-១៧:០០ | ជំពូកទី៥ ៖ ការបង្កភាពងាយស្រួលសម្រាប់ជនពិការដោយគ្មានឧបសគ្គ | |
| | **ថ្ងៃទី៣** | |
| ០៨:០០-០៩:៣០ | ជំពូកទី៥ ៖ ការបង្កភាពងាយស្រួលសម្រាប់ជនពិការដោយគ្មានឧបសគ្គ(ត) | |
| ០៩:៣០-០៩:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥-១១:៣០ | ជំពូកទី៦ ៖ ការធានាឱ្យមានការចូលរួមយ៉ាងសកម្ម | |
| ១១:៣០-១៣:៣០ | **សម្រាកថ្ងៃត្រង់** | |
| ១៣:៣០-១៥:៣០ | ជំពូកទី៧ ៖ ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ | |
| ១៥:៣០-១៥:៤៥ | **សម្រាកអាហារសម្រន់** | |
| ១៥:៤៥-១៦:០០ | ជំពូកទី៧ ៖ ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ(ត) | |
| ១៦:០០-១៧:០០ | ជំពូកទី៨ ៖ សង្ខេបមេរៀន វាយតម្លៃវគ្គ និងផែនការបន្ទាប់ | |

# ឧបសម្ព័ន្ធទី២

## រូបភាពអំពីបទបញ្ញាផ្ទៃក្នុងសម្រាប់ការបណ្តុះបណ្តាល (ត្រូវបោះពុម្ពទុកជាមុន)







# ឧបសម្ព័ន្ធទី៣

# ករណីសិក្សា

## ករណីសិក្សាទី១ ៖ រឿងរបស់ស្រីមុំ



**ស្រីមុំ** កើតមកដោយមានលលាដ៍ក្បាលធំខុសធម្មតា។ នាងពិការអវៈយវៈនៅពេលដែលនាងធំដឹងក្តី។ នេះមានន័យថា ស្រីមុំ មិនអាចធ្វើដំណើរទៅណាមកណាតែឯងឡើយ។ ដោយសារតែស្រីមុំរស់នៅក្នុងភូមិជនបទ ហើយគ្រួសាររបស់នាង រវល់នឹងការងារស្រែចំការជារឿយៗ នាងត្រូវបានគេទុកចោលនៅផ្ទះ។ នៅពេលដែលស្រីមុំអាយុបាន៦ឆ្នាំ នាងចង់ទៅរៀន ប៉ុន្តែ ម្តាយរបស់នាងមិនឱ្យទៅ ដោយសារតែគាត់គិតថា ស្រីមុំរៀនមិនចេះនោះទេ។

នៅក្នុងភូមិនេះមានជនពិការមួយក្រុម ពួកគាត់បានណែនាំស្រីមុំឱ្យស្គាល់អង្គការមិនមែនរដ្ឋាភិបាលមួយដែលមានឈ្មោះថា ADD។ ADD បានជួលគ្រូឱ្យចាប់ផ្តើមបង្រៀន ស្រីមុំ នៅផ្ទះ។ នៅពេលដែលម្តាយរបស់នាងឃើញការរីកចម្រើនរបស់នាង គាត់ចាប់ផ្តើមមានមោទនភាពចំពោះកូនស្រីរបស់គាត់។ ស្រីមុំ បានទៅប្រលងជាមួយនឹងក្មេងផ្សេងទៀត។ នាងជាប់លេខ៤ ក្នុងចំណោមកូនសិស្ស៤២នាក់ ហើយឥឡូវនេះចាប់ផ្តើមរៀនថ្នាក់ទី៥។ ឪពុកម្តាយរបស់នាងគាំទ្រពេញទំហឹងដល់ការប្តេជ្ញាចិត្តរបស់ស្រីមុំ ដើម្បីឱ្យនាងរៀនចប់ចុងចប់ដើម។

## ករណីសិក្សាទី២ ៖ រឿងរបស់ថាវី



**ថាវី** គឺជាស្ត្រីរៀបការហើយមានអាយុ៣០ ឆ្នាំ។ នាងបាត់បង់លទ្ធភាពគំហើញ របស់នាងបន្តិចម្តងៗ ហើយក្លាយជាជនពិការភ្នែក។ ប្តីរបស់នាងដែលជាអ្នកស៊ីឈ្នួលគេប្រចាំថ្ងៃ ពេលខ្លះគ្មានការងារធ្វើ ហើយគ្រួសារនេះមិនអាចធានាមានអាហារពីរពេល ប្រចាំថ្ងៃឡើយ។ វាគឺជាជីវិតដ៏សែនលំបាក ហើយ ថាវី តែងតែនៅផ្ទះ។ បើទោះបីជា នាងបានរៀនចប់សាលាបឋមសិក្សាយ៉ាងណាក៏ដោយ នាងមិនអាចអានបានទៀតឡើយ ហើយត្រូវពឹងផ្អែកលើអ្វីដែលគេប្រាប់នាង និងអ្វីដែលនាងស្តាប់ឮតាមវិទ្យុ។ ដើម្បីទៅចូលរួមក្នុងកិច្ចប្រជុំក្នុងសហគមន៍ នាងត្រូវពឹងឱ្យមនុស្សផ្សេងទៀតប្រាប់នាង ហើយយកនាងទៅ។ ប៉ុន្តែវាមិនមែនចេះតែបែបនេះ ញឹកញាប់នោះទេ អ្វីៗមានការប្រែប្រួល នៅពេលថាវីត្រូវបានជ្រើសរើសឱ្យចូលរួមនៅក្នុងគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលមួយ និងបានទទួលការបណ្តុះបណ្តាលអំពីការចិញ្ចឹមពពែ និងការចិញ្ចឹមមាន់។ នាង ក៏បានទទួលពពែ និងកូនមាន់ សម្រាប់ចាប់ផ្តើមចិញ្ចឹម ជាសកម្មភាពរកចំណូលរបស់នាងផងដែរ។ ថាវី មើលថែសួនដំណាំ ពពែ និងមាន់ ដោយខ្លួនឯង។ ប៉ុន្តែ នាងបានឱ្យសមាជិកគ្រួសាររបស់នាង ទាក់ទងការិយាល័យ បសុពេទ្យឱ្យមកចាក់វ៉ាក់សាំង និងផ្តល់ការថែទាំសុខភាពផ្សេងទៀតដល់ពពែ និងបក្សីរបស់នាង។ ប្តីរបស់នាងទៅលក់បន្លែ និងស៊ុតក្នុងផ្សារ។ ដោយសារគាត់មានសួនដំណាំ និងការចិញ្ចឹមសត្វ (ពពែ និងមាន់) ធ្វើឱ្យសន្តិសុខស្បៀងរបស់គ្រួសារមានភាពប្រសើរជាងមុន។ ថាវី ក៏អាចសន្សំលុយបានខ្លះៗ ជាមួយនឹងក្រុមនៅក្នុងភូមិរបស់នាងផងដែរ។ "ខ្ញុំមើលមិនឃើញ ប៉ុន្តែខ្ញុំមានអារម្មណ៍ដឹងពីស្នាមញញឹមនៃសមាជិកគ្រួសាររបស់ខ្ញុំ ដោយសារគ្រួសាររបស់ខ្ញុំមានអាហារសម្រាប់ហូបគ្រប់គ្រាន់។ ប្រសិនបើយើងអាចបន្តការងារនេះទៀត យើងនឹងមិនធ្លាក់ចុះទៅក្នុងភាពក្រីក្រតោកយ៉ាកនោះទេ"។

## ករណីសិក្សាទី៣ ៖ រឿងរបស់សុផល



**សុផល** មានអាយុ២០ឆ្នាំ។ គាត់មានការលំបាកក្នុងការស្តាប់ឮពីអ្នកដទៃនិយាយ នៅពេលដែលគាត់ទៅរៀន។ គាត់មិនអាចទំនាក់ទំនងជាមួយនឹងមនុស្សផ្សេងទៀត នៅក្នុងថ្នាក់របស់គាត់បានឡើយ។ នៅក្នុងគ្រួសាររបស់គាត់ នៅពេលដែលឪពុកម្តាយរបស់គាត់ហៅគាត់ គាត់មានការលំបាកក្នុងការប្រាស្រ័យទាក់ទង។ នៅតាមផ្លូវទៅសាលា គាត់មានការលំបាក ដោយសារតែគាត់ជាមនុស្សគ-ថ្លង់។ នៅពេលខ្លះមានម៉ូតូ ឬកង់ជិះមកជិតគាត់ សុផលស្ទើរតែត្រូវបានម៉ូតូ ឬកង់បុក ដោយសារគាត់ស្តាប់មិនលឺ។

នៅពេលដែលគាត់មានជំងឺ ម្តាយរបស់គាត់យកគាត់ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ។ ម្តាយរបស់គាត់យកគាត់ទៅផ្នែកត្រចៀករបស់មន្ទីរពេទ្យ ប៉ុន្តែសុផលមានការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយបុគ្គល(គិលានុបដ្ឋាក និងវេជ្ជបណ្ឌិត)មន្ទីរពេទ្យ។ ឥឡូវនេះ គាត់មានអ្នកបកប្រែ ហើយនៅពេលដែលគាត់ទៅមន្ទីរពេទ្យម្តងៗ គាត់មានអ្នកបកប្រែមកពីអង្គការ DDP សម្រាប់ជួយគាត់។

គាត់រៀនភាសាសញ្ញាពីកម្មវិធីអភិវឌ្ឍន៍មនុស្សគ-ថ្លង់។ គាត់ចាប់ផ្តើមរៀននៅពេលដែលគាត់អាយុ១២ឆ្នាំ។ នៅពេលដែលគាត់ទៅសាលារៀន និងជួបជាមួយជនពិការគ-ថ្លង់ផ្សេងទៀត គាត់អាចទំនាក់ទំនងជាមួយអ្នកទាំងនោះបាន ហើយគាត់សប្បាយចិត្តយ៉ាងខ្លាំង។

ឥឡូវនេះ គាត់កំពុងរៀនជំនាញជួសជុលម៉ូតូ។ សុផលពិតជាចង់ធ្វើការងារ ដោយប្រើប្រាស់ជំនាញរបស់គាត់ណាស់ ដើម្បីអាចជួយដល់គ្រួសាររបស់គាត់។ ពេលខ្លះ សុផលមានបញ្ហា ប៉ុន្តែអ្នកគ្រប់គ្រងរបស់គាត់បានជួយគាត់ដោះស្រាយបញ្ហាទាំងនោះ។ សុផលសង្ឃឹមថា មនុស្សទាំងអស់យល់ដឹងថា ជនពិការគ-ថ្លង់មានសិទ្ធិដូចគ្នានឹងមនុស្សផ្សេងទៀតដែរ។

ឥឡូវនេះ សុផលមានមិត្តស្រី ហើយគាត់អាចទំនាក់ទំនងបានយ៉ាងងាយជាមួយនាង ដោយសារតែនាង ក៏ជាជនពិការគ-ថ្លង់ដែរ។

## ករណីសិក្សាទី៤ ៖ រឿងរបស់មករា



**មករា** គឺជាបុរសអាយុ២៣ឆ្នាំ មកពីខេត្តកំពត ដែលមានបំណងចង់ធ្វើស្រែចំការ និងស្រលាញ់ការងារជាគ្រូបង្រៀន។ ដោយសារតែគាត់មានបញ្ហាប្រព័ន្ធបញ្ហាចលនា មករាពុំមានភាពងាយស្រួលក្នុងការដើរ ចំងាយឆ្ងាយ ឬនិយាយបានច្បាស់ឡើយ ប៉ុន្តែការលំបាកធំជាងគេរបស់គាត់ គឺការរើសអើងដែលគាត់ត្រូវជំនះពេញមួយជីវិតរបស់គាត់។

ឪពុកម្តាយរបស់ខ្ញុំបានបញ្ជូនខ្ញុំឱ្យទៅរៀននៅសាលាបឋមសិក្សាមួយ។ នៅពេលដែលគ្រូប្រាប់ឱ្យយើងលើកដៃក្នុងថ្នាក់ ខ្ញុំពិបាកធ្វើចលនាបញ្ហាដៃទាំងពីរ ដោយសារតែភាពតឹងរបស់សាច់ដុំដែលធ្វើឱ្យគ្រូវាយខ្ញុំ។ ខ្ញុំបោះបង់ចោលការសិក្សានៅថ្នាក់ទី៦ ដោយសារតែអនុវិទ្យាល័យ នៅឆ្ងាយពីផ្ទះរបស់ខ្ញុំ ហើយខ្ញុំមានការពិបាកក្នុងការដើរទៅទីនោះ។ ខ្ញុំនៅផ្ទះអស់រយៈពេល១០ឆ្នាំ ជួយឪពុកម្តាយរបស់ខ្ញុំធ្វើស្រែ និងដាំបន្លែ។ ខ្ញុំមិនចង់ជួបមនុស្សប្លែកមុខឡើយ ដោយសារតែខ្ញុំគិតថា ពួកគាត់នឹងខ្លាចខ្ញុំ ហើយគិតថា ខ្ញុំជាមនុស្សឆ្កួត ដោយសារតែពិការភាពរបស់ខ្ញុំ។

នៅខែ មករា ឆ្នាំ២០១១ អង្គការមិនមែនរដ្ឋាភិបាលមួយបានបើកមណ្ឌលថែទាំកុមារមួយ (Day Center) នៅជិតផ្ទះ មករា។ បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលមួយបានអញ្ជើញមករា ឱ្យមកកាន់មណ្ឌលនេះ ៖ "យើងឃើញថា មករា ដឹងរឿងច្រើន ដូច្នេះយើងសួរគាត់ថាតើគាត់អាចបង្រៀនក្មេងៗជាមួយនឹងយើងដែរឬទេ។ ដំបូង គាត់និយាយថា គាត់មិនអាចបង្រៀនបានឡើយ ដោយសារតែគាត់ជា "ជនពិការ"។ យើងបានលើកទឹកចិត្តឱ្យគាត់ដឹងថា មានជនពិការជាច្រើននាក់ ដែលអាចធ្វើកិច្ចការបានជាច្រើន។ គាត់យល់ព្រមចាប់ ផ្តើមជួយក្មេងតូចៗ ហើយឥឡូវនេះ គាត់ខុសប្លែកពីមុន ហើយមានទំនុកចិត្តជាងមុនច្រើន។"

នៅពេលដែលបុគ្គលិករបស់អង្គការនេះ ចាប់ផ្តើមឃើញពីបំណងប្រាថ្នាចង់បង្កបង្កើនផលរបស់ មករា ពួកគេបានលើកទឹកចិត្តឱ្យ មករា ពិចារណាចូលរួមក្នុងវគ្គសិក្សាជំនាញកសិកម្ម ដើម្បីរៀនសូត្រជំនាញថ្មីៗ យកទៅប្រើប្រាស់នៅក្នុងស្រែចំការរបស់គ្រួសារគាត់។ បច្ចុប្បន្ន គាត់កំពង់បានចូលរៀន ៣ សប្តាហ៍ហើយ នៅក្នុងវគ្គសិក្សារយៈពេល៦ខែ។ មករា ជាមនុស្សដែលមានការប្រុងប្រយ័ត្ន ប៉ុន្តែគាត់មានការរំភើបចំពោះអនាគតរបស់គាត់។ "ពេលបច្ចុប្បន្ននេះ គ្រួសាររបស់ខ្ញុំគ្រាន់តែធ្វើស្រែ និងដាំបន្លែប៉ុណ្ណោះ ប៉ុន្តែក្រោយពេលដែលខ្ញុំរៀនចប់វគ្គនេះ ខ្ញុំសង្ឃឹមថា យើងនឹងអាចសាកល្បងអ្វីដែលថ្មី ដូចជាចិញ្ចឹមសត្វ និងចាប់ផ្តើមចិញ្ចឹមត្រីជាដើម។ ដោយ សារតែខ្ញុំបានចូលរួមជាមួយនឹងអង្គការនេះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានផ្លាស់ប្តូរច្រើន។ ខ្ញុំបានជួបមនុស្សជាច្រើននាក់ និងរៀនបានច្រើន។ ឥឡូវនេះ ខ្ញុំលែងបារម្ភថា **អ្នកដទៃមកលើរូប**ខ្ញុំជាមនុស្សឆ្កួតទៀតហើយ! ខ្ញុំមានអារម្មណ៍ធម្មតា។"

**ករណីសិក្សាទី៥ ៖ រឿងរបស់បុប្ផា**

**បុប្ផា** គឺជាស្ត្រីអាយុ ៣០ឆ្នាំ ដែលមានពិការខ្សោយសតិបញ្ញា ហើយរស់នៅជាមួយម្តាយរបស់នាង ឈ្មោះ យាយ ដា។ បុប្ផា អាចចូលរួមក្នុងក្រុមស្ត្រីប្រចាំភូមិ ក្នុងនាមជាសមាជិករបស់ក្រុមនេះ នាងទទួលបានពពែ២ក្បាល និងមាន់១០ក្បាល។ នៅពេលដែលពពែ២ក្បាលនេះ កើតកូនចំនួន៤ក្បាល បុប្ផាចែកកូន២ក្បាល ទៅឱ្យស្ត្រីម្នាក់ទៀតដែលចូលរួមក្នុងក្រុមស្ត្រីជាមួយនាងដែរ។

ពេលខ្លះបុប្ផា មានការលំបាកក្នុងការយល់ពីអ្វីដែលគេនិយាយ និងមិនអាចនិយាយបានឡើយ ប៉ុន្តែនាងអាចប្រាស្រ័យទាក់ទង ដោយប្រើដៃជាសញ្ញា កាយវិការ និងទំនាក់ទំនងតាមកែវភ្នែក។ នាងប្រមូលពងមាន់ជារៀងរាល់ថ្ងៃ ហើយម្តាយរបស់នាងយកទៅលក់នៅផ្សារ។ បើទោះបីជាម្តាយរបស់នាងជួយនាងបានតិចតួចក៏ដោយ នាងទទួលខុសត្រូវចំពោះសត្វរបស់នាងខ្លាំងណាស់។

នៅពេលដែលយាយ ដា និងបុប្ផា ចង់ដាក់លុយខ្លះក្នុងធនាគារសម្រាប់បុប្ផា គាត់ជួបនឹងការលំបាកជាច្រើន ពួកគាត់ទៅធនាគារ ប៉ុន្តែបុគ្គលិកធនាគារមិនចង់បើកគណនីធនាគារឱ្យមនុស្ស "ខុសធម្មតា" នោះទេ។ នៅថ្ងៃបន្ទាប់ ពួកគាត់ទៅធនាគារម្តងទៀត ហើយសួររកអ្នកគ្រប់គ្រងធនាគារ និងដាក់ពាក្យសុំបើកគណនីធនាគារម្តងទៀត។ ចុងក្រោយ អ្នកគ្រប់គ្រងរូបនេះអនុញ្ញាត និងឱ្យបុប្ផាចុះហត្ថលេខា ប៉ុន្តែបុប្ផាមិនអាចចុះហត្ថលេខាបានឡើយ។ ម្តាយរបស់នាងសុំឱ្យអ្នកគ្រប់គ្រងធនាគារទទួលយកស្នាមមេដៃរបស់បុប្ផាជំនួសវិញ។ អ្នកគ្រប់គ្រងបានអនុញ្ញាត ហើយ បុប្ផា បានក្លាយជាអតិថិជនម្នាក់របស់ធនាគារនេះ។ យាយ ដា និង បុប្ផា សប្បាយចិត្តយ៉ាងខ្លាំងនៅពេលដែលពួកគាត់ទទួលបានជោគជ័យ។

## ឧបសម្ព័ន្ធទី៤

### ពិការភាព (ត្រូវបោះពុម្ពទុកជាមុន)

# ភាពខ្សោយ + ឧបសគ្គ = ពិការភាព

# ឧបសម្ព័ន្ធទី៥

## គំនូរអំពីស្ត្រីពិការ (ត្រូវបោះពុម្ពទុកជាមុន)













# ឧបសម្ព័ន្ធទី៦

## សំណួរវាយតម្លៃសម្រាប់កំណត់ពីជនពិការ

១. តើអ្នកមានការពិបាកក្នុងការមើលដែរឬទេ សូម្បីតែពាក់វ៉ែនតាក៏ដោយ?

ក). ទេ - មិនពិបាកអ្វីទេ

ខ). បាទ/ចាស - ពិបាកខ្លះដែរ

គ). បាទ/ចាស - ពិបាកខ្លាំង

ឃ). មិនអាចមើលឃើញសោះតែម្តង

២. តើអ្នកមានការពិបាកក្នុងស្តាប់ដែរឬទេ សូម្បីតែប្រើប្រាស់ឧបករណ៍ជំនួយការស្តាប់ក៏ដោយ?

ក). ទេ - មិនពិបាកអ្វីទេ

ខ). បាទ/ចាស - ពិបាកខ្លះដែរ

គ). បាទ/ចាស - ពិបាកខ្លាំង

ឃ). មិនអាចស្តាប់ឮសោះតែម្តង

៣. តើអ្នកមានការពិបាកក្នុងការផ្លាស់ទី ឬឡើងជណ្តើរដែរឬទេ?

ក). ទេ - មិនពិបាកអ្វីទេ

ខ). បាទ/ចាស - ពិបាកខ្លះដែរ

គ). បាទ/ចាស - ពិបាកខ្លាំង

ឃ). មិនអាចធ្វើបានសោះតែម្តង

៤. តើអ្នកមានការពិបាកក្នុងការចងចាំ ឬផ្ចង់អារម្មណ៍ដែរឬទេ?

ក). ទេ - មិនពិបាកអ្វីទេ

ខ). បាទ/ចាស - ពិបាកខ្លះដែរ

គ). បាទ/ចាស - ពិបាកខ្លាំង

ឃ). មិនអាចធ្វើបានសោះតែម្តង

៥. តើអ្នកមានការពិបាកក្នុងការថែទាំខ្លួនឯងដែរឬទេ ដូចជាការងូតទឹក ឬស្លៀកពាក់?

ក). ទេ - មិនពិបាកអ្វីទេ

ខ). បាទ/ចាស - ពិបាកខ្លះដែរ

គ). បាទ/ចាស - ពិបាកខ្លាំង

ឃ). មិនអាចធ្វើបានសោះតែម្តង

៦. ដោយប្រើប្រាស់ភាសាធម្មតា (តាមទម្លាប់) របស់អ្នក តើអ្នកមានការលំបាកក្នុងការនិយាយដែរឬទេ ឧ. ដូចជា យល់អ្នកដទៃ ឬឱ្យអ្នកដទៃយល់អ្នក ជាដើម?

ក). ទេ - មិនពិបាកអ្វីទេ

ខ). បាទ/ចាស - ពិបាកខ្លះដែរ

គ). បាទ/ចាស - ពិបាកខ្លាំង

ឃ). មិនអាចធ្វើបានសោះតែម្តង

# ឧបសម្ព័ន្ធទី ៧

## បញ្ជីផ្ទៀងផ្ទាត់ការបង្កភាពងាយស្រួលសម្រាប់ជនពិការ

| សំណួរ | លទ្ធផលរកឃើញ (បាទចាស/ទេ/ មិនពាក់ព័ន្ធ) |
|---|---|
| **១. ខាងក្រៅ** | |
| • តើផ្លូវដើរមានសភាពរាបស្មើ និងជាប់គ្នារហូតដែរឬទេ ? | |
| • តើផ្លូវដើរមានទំហំធំទូលាយគ្រប់គ្រាន់ដែរឬទេ ( ១៥០០មីលីម៉ែត្រ ) ? | |
| • តើផ្លូវដើរមិនរអិល និងមិនមានឧបសគ្គបាំងដែរឬទេ ? | |
| • តើច្រកចូលអគារងាយស្រួលចេញ ចូលសម្រាប់អ្នកប្រើរទេះរុញដែរឬទេ ? | |
| **២. ច្រកផ្លូវ** | |
| • តើច្រកទាំងនេះមិនមានអ្វីមកបាំងមែនទេ ? | |
| • តើច្រកសាធារណៈដែលមិនសូវមានគេធ្វើដំណើរ មានទំហំយ៉ាងហោចណាស់១៥០០មីលីម៉ែត្រឬ ? | |
| • តើផ្ទៃរបស់ច្រកផ្លូវមានលក្ខណៈរាបស្មើ និងមិនរអិលដែរឬទេ ? | |
| • តើច្រកផ្លូវសម្រាប់ធ្វើដំណើរងាយស្រួលសម្គាល់ដែរឬទេ ?  | |
| **៣. ទ្វារ** | |
| • តើទ្វារមានទទឹងយ៉ាងហោចណាស់ ៨០០មីលីម៉ែត្រដែរឬទេ ? | |
| • តើអ្នកប្រើប្រាស់ត្រូវឆ្លងកាត់ចំណោតខ្ពស់ជាង២០មីលីម៉ែត្រឬ ? | |
| • តើទ្វារងាយស្រួលបើក ដោយប្រើដៃម្ខាងឬទេ ? | |

<table>
<tr><th>សំណួរ</th><th>លទ្ធផលរកឃើញ<br>(បាទចាស/ទេ/ មិនពាក់ព័ន្ធ)</th></tr>
<tr><td>• តើទ្វារមានទំហំយ៉ាងហោចណាស់ ១៥០០មីលីម៉ែត្រx១៨០០មីលីម៉ែត្រ ដើម្បីឱ្យអ្នកប្រើប្រាស់រទេះរុញងាយស្រួលបើកទ្វារដែរឬទេ ?<br><br></td><td></td></tr>
<tr><td>• តើទ្វារងាយស្រួលបើកដែរឬទេ ?</td><td></td></tr>
<tr><td colspan="2">៤. ជម្រាល ជណ្តើរ និងបង្កាន់ដៃ</td></tr>
<tr><td>• តើនៅជាន់តែមួយ ផ្លូវដើរពុំមានការផ្លាស់ប្តូរកម្ពស់ ឬជណ្តើរមែនទេ ?</td><td></td></tr>
<tr><td>• តើចំណោតរបស់ជម្រាលដែលកំពុងគ្រោងទុក ដែលមានស្រាប់ ឬជម្រាលសម្រាប់ទប់មានកម្ពស់អតិបរមា ១:១២ ឬ?<br><br><br><br></td><td></td></tr>
<tr><td>• តើជម្រាលមានទទឹងយ៉ាងហោចណាស់ ១០០០មីលីម៉ែត្រ ឬ?</td><td></td></tr>
<tr><td>• តើបង្កាន់ដៃ ត្រូវបានបំពាក់នៅកម្ពស់ចន្លោះពី៨០០មីលីម៉ែត្រ ទៅ៩០០មីលីម៉ែត្រ ដើម្បីបង្កើនសុវត្ថិភាពនៅពេលប្រើប្រាស់ជម្រាល និងជណ្តើរដែរឬទេ ?</td><td></td></tr>
</table>

| **សំណួរ** | **លទ្ធផលរកឃើញ**<br>(បាទចាស/ទេ/ មិនពាក់ព័ន្ធ) |
|---|---|
| • តើជណ្ដើរ និងជម្រាលងាយស្រួលសម្គាល់ដែរឬទេ ?<br> | |
| **៥. កន្លែងរង់ចាំ និងសម្ភាររូបវ័ន្តពាក់ព័ន្ធ** | |
| • តើមានផ្ដល់កន្លែងឈប់សម្រាករៀងរាល់ ២០ម៉ែត្រម្ដងដែរឬទេ ? | |
| • តើកន្លែងសម្រាកមានទំហំធំគ្រប់គ្រាន់ សម្រាប់អ្នកប្រើប្រាស់រទេះ ដែរឬទេ ? | |
| • តើកៅអីសាធារណៈមានកម្ពស់ចន្លោះពី៤៥០មីលីម៉ែត្រ ទៅ៥០០មីលីម៉ែត្រ ហើយតុមានកម្ពស់ចន្លោះពី៧៥០មីលីម៉ែត្រ ទៅ៨០០មីលីម៉ែត្រ ដោយមានចន្លោះសម្រាប់ដាក់ជង្គង់មានកម្ពស់យ៉ាងហោចណាស់៧០០មីលីម៉ែត្រ និងជម្រៅ៦០០មីលីម៉ែត្រ ដែរឬទេ ? | |
| **៦. បង្គន់ បន្ទប់ទឹក** | |
| • តើមានបង្គន់ងាយស្រួលប្រើប្រាស់ ដោយជនពិការដែរឬទេ ?<br><br><br>How a wheelchair user transfer himself from his chair to the toilet seat | |
| • តើបង្គន់ដែលអាចប្រើបានដោយជនពិការ មានសញ្ញាសម្គាល់ដែរឬទេ ? | |

| សំណួរ | លទ្ធផលរកឃើញ<br>(បាទចាស/ទេ/ មិនពាក់ព័ន្ធ) |
|---|---|
| **៧. ស្លាកសញ្ញា** | |
| • តើកន្លែង និងសម្ភាររូបវ័ន្តដែលអាចប្រើប្រាស់បានដោយជនពិការ មានសញ្ញាបង្ហាញដែរឬទេ ? | |
| • តើមានការបង្ហាញពីទីតាំងរបស់កន្លែង និងសម្ភាររូបវ័ន្ត ដែលអាចប្រើប្រាស់បានដោយជនពិការដែរឬទេ ? | |
| • តើផែនទី ផ្ទាំងព័ត៌មាន និងស្លាកសញ្ញាដែលភ្ជាប់ទៅនឹងជញ្ជាំងទាំងអស់មានកម្ពស់សមស្របចន្លោះពី៩០០មីលីម៉ែត្រ ទៅ១៨០០មីលីម៉ែត្រដែរឬទេ ? | |
| • តើព័ត៌មានសំខាន់ៗអំពីសញ្ញាត្រូវបានបំពេញបន្ថែមដោយអក្សរផុស ឬអក្សរស្ទាបដែរឬទេ ? | |
| • តើសញ្ញាមានភាពច្បាស់លាស់ និងងាយស្រួលអានដែរឬទេ ?<br><br> | |
| **៨. ប្រព័ន្ធពេលមានអាសន្ន** | |
| • តើច្រកផ្លូវអាសន្នអាចកំណត់ដឹងបាន ដោយអ្នកដែលខ្សោយខាងគំហើញដែរឬទេ ? | |
| • តើក្នុងស្ថានភាពអាសន្ន អ្នកដែលខ្សោយខាងការស្តាប់អាចដឹងបានដែរឬទេ ? | |

# ឧបសម្ព័ន្ធទី៨

## បញ្ជីផ្ទៀងផ្ទាត់សម្រាប់កិច្ចប្រជុំ និងព្រឹត្តិការណ៍ដែលជនពិការអាចចូលរួមបាន

- **គោលដៅ** ៖ រៀបចំកិច្ចប្រជុំ និងព្រឹត្តិការណ៍នានាដែលអាចឱ្យជនពិការអាចចូលរួមបាន។
- **លទ្ធផលរំពឹងទុក** ៖ ជនពិការអាចចូលរួមក្នុងកិច្ចប្រជុំ និងព្រឹត្តិការណ៍នានា ដែលបានរៀបចំឡើង។
- **គោលការណ៍ណែនាំ** ៖ ការបង្កភាពងាយស្រួលសម្រាប់ជនពិការ និងការរៀបចំ ៖
  - អំពីការរៀបចំទីកន្លែង
  - តើគេនឹងទៅដល់កន្លែងរៀបចំព្រឹត្តិការណ៍ ដោយរបៀបណា?
  - តើគេគេនឹងអាចចូលរួម នៅក្នុងព្រឹត្តិការណ៍នេះបាន ដោយរបៀបណា?

ជនពិការ គឺជាអ្នកជំនាញផ្នែកបង្កភាពងាយស្រួលសម្រាប់ជនពិការ អង្គការជនពិការនៅមូលដ្ឋាន អាចជួយអ្នកក្នុងការរៀបចំកិច្ចប្រជុំ ដែលជនពិការអាចចូលរួមបាន។

**ក). ការអញ្ជើញជនពិការក្នុងសហគមន៍** ៖ តើការកំណត់ និងការអញ្ជើញជនពិការត្រូវបានធ្វើឡើងយ៉ាងដូចម្ដេច?

| លរ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាន/ចាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | តើជនពិការ ឬអង្គការជនពិការត្រូវបានអញ្ជើញ ដូច អង្គការផ្សេងៗទៀតដែរឬទេ? | | | |
| ២. | តើការអញ្ជើញធ្វើឡើងក្នុងទម្រង់ផ្សេងៗគ្នា(លិខិត ផ្ទាល់មាត់)ដែរឬទេ? | | | |
| ៣. | តើព័ត៌មានត្រូវបានផ្ដល់ ដោយប្រើប្រាស់ភាសាសាមញ្ញសមស្របដែរឬទេ? | | | |
| ៤. | តើការអញ្ជើញបានផ្ដល់ព័ត៌មានអំពីភាពងាយស្រួលចេញចូលកន្លែងប្រជុំដែរឬទេ? | | | |
| ៥. | តើអ្នកចូលរួមដែលជាជនពិការ បានសួរនាំអំពី តម្រូវការពាក់ព័ន្ធនឹងការបង្កភាពងាយស្រួលដែរឬទេ? | | | |

**ខ). ការបង្កភាពងាយស្រួលសម្រាប់ជនពិការ** ៖ តើឧបសគ្គចំពោះការចូលរួមត្រូវបានលុបបំបាត់ដោយរបៀបណា?

| លរ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាន/ចាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | សូមចាំថា ការបង្កភាពងាយស្រួលសម្រាប់ជនពិការ សំដៅលើរចនាសម្ព័ន្ធរូបវន្តផង និងលើវិធីសាស្ត្រប្រាស្រ័យទាក់ទងផង | | | |
| ២. | តើការបង្កភាពងាយស្រួលសម្រាប់ជនពិការគឺសម្រាប់គ្រប់ៗគ្នាឬ? សម្រាប់ក្រុមផ្សេងៗឬ? (ចាស់ជរា ស្ត្រីមានផ្ទៃពោះ និងកុមារ។ល។) | | | |
| ៣. | អត្ថបទរបស់ឯកសារបានប្រើប្រាស់អក្សរដិតច្បាស់ ស្របតាមផ្ទៃពណ៌ក្រដាស | | | |

**គ). រៀបចំកន្លែងសម្រាប់កិច្ចប្រជុំ ៖** តើកន្លែងប្រជុំបានបង្កភាពងាយស្រួលសម្រាប់ជនពិការដែរឬទេ ?

| លរ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាន/បាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | តើកន្លែងរៀបចំកិច្ចប្រជុំ បានពិនិត្យជាមុន ដើម្បីកំណត់ការបង្កភាពងាយស្រួលសម្រាប់ជនពិការដែរឬទេ ? | | | |
| ២. | តើអគារប្រជុំមានភាពងាយស្រួលចេញចូលសម្រាប់ជនពិការដែរឬទេ ? | | | |
| ៣. | តើបង្គន់ ច្រកផ្លូវដើរ និងកន្លែងញ៉ាំអាហារ ងាយស្រួលប្រើប្រាស់សម្រាប់ជនពិការដែរឬទេ ? | | | |

**ឃ). ការធ្វើដំណើរចូលរួមរបស់ជនពិការ ៖** តើជនពិការទៅដល់កន្លែងរៀបចំព្រឹត្តិការណ៍នេះយ៉ាងដូចម្តេច ?

| លរ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាន/បាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | តើមានមធ្យោបាយធ្វើដំណើរសាធារណៈ ដែលជនពិការអាចទៅដល់កន្លែងរៀបចំព្រឹត្តិការណ៍ដែរឬទេ ? ប្រសិនបើ មិនមាន តើមានជម្រើសផ្សេងទៀតដែរឬទេ ?( ឧទាហរណ៍ ៖ ការរៀបចំធ្វើដំណើរដោយមានការគាំទ្រពីអង្គការជនពិការនៅមូលដ្ឋាន )។ | | | |
| ២. | តើមានព័ត៌មានអំពីកន្លែងប្រជុំ និងរបៀបទៅដល់ទីនោះដែរឬទេ ? តើមានការគាំទ្រអ្វីខ្លះ នៅពេលកិច្ចប្រជុំ តើមានអ្វីខ្លះដែលត្រូវទូទាត់សងទៅលើការចំណាយ ? | | | |
| ៣. | តើមានអ្នកចាំនៅច្រកចូលទៅកន្លែងរៀបចំព្រឹត្តិការណ៍ ដើម្បីនាំផ្លូវទៅកន្លែងដែលពួកគេចាំបាច់ត្រូវ ទៅនិងផ្តល់ជំនួយក្នុងករណីដែលចាំបាច់ដែរឬទេ ? | | | |

**ង). ការចូលរួមរបស់ជនពិការ ៖** តើជនពិការអាចចូលរួមនៅក្នុងព្រឹត្តិការណ៍តាមរបៀបណាខ្លះ ?

| លរ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាន/បាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | តើអ្នកមានព័ត៌មានអំពីអ្នកដែលត្រូវបានអញ្ជើញ ថា តើពួកគេមានតម្រូវការពិសេសអ្វីខ្លះ ចំពោះការបង្កភាពងាយស្រួលសម្រាប់ជនពិការ ឬ តើពួកគេនឹងនាំជំនួយការផ្ទាល់ខ្លួនទៅដែរឬទេ ? | | | |
| ២. | ករណី ដែលមានអ្នកខ្សោយខាងស្តាប់មកចូលរួម តើមានការរៀបចំ និងគ្រោងថវិកាសម្រាប់ការបកប្រែសញ្ញាដែរឬទេ ? | | | |

| លរ | ចំណុចដែលត្រូវត្រួតពិនិត្យ | បានចាស/ | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ៣. | ករណីដែលមានអ្នកខ្សោយគំហើញមកចូលរួម តើមានការរៀបចំ និងគ្រោងថវិកាសម្រាប់រៀបចំព័ត៌មានជាអក្សរស្ទាប អក្សរបោះពុម្ពធំៗ ឬសំឡេងដែរឬទេ ? | | | |
| ៤. | តើវាគ្មិននៅក្នុងកិច្ចប្រជុំនេះ បានទទួលព័ត៌មានអំពីការប្រាស្រ័យទាក់ទងដែរឬទេ ? តើវាគ្មិននិយាយយឺតៗ និងច្បាស់លាស់ដែរឬទេ និងតើមានអ្នកបកប្រែសម្រាប់ជួយបកប្រែដែរឬទេ ? | | | |
| ៥. | តើបន្ទប់ប្រជុំត្រូវបានរៀបចំឡើង ដើម្បីឱ្យរទេះរុញអាចឆ្លងកាត់បានដែរឬទេ ? តើពុំមានវត្ថុអ្វីដែលពួកគេអាចជំពប់ដែរឬទេ ? | | | |
| ៦. | តើកាលវិភាគសមស្របសម្រាប់អ្នកចូលរួមទាំងអស់ដែរឬទេ ? | | | |

## ឧបសម្ព័ន្ធទី៩

## ក្រដាសកាតពណ៌សម្រាប់ការបំផុសគំនិត

គ្រូបណ្តុះបណ្តាលត្រូវសរសេរក្រដាសកាតពណ៌នូវខ្លឹមសារ ដូចខាងក្រោម ៖

| | |
|---|---|
| ស្ត្រីពិការជួបការលំបាកជាងបុរស<br>**ស្រីមុំ** | អ្នកផ្សេងទៀតរាប់អានខ្ញុំប្រកបដោយការគោរព ពួកគេដឹងថា ខ្ញុំអាចរកចំណូលទទួលទាននាបច្ចុប្បន្ននេះ<br>**មករា** |
| ខ្ញុំអាចទៅដល់ទីនោះ ដោយប្រើរទេះរុញរបស់ខ្ញុំ<br>**ស្រីមុំ** | គ្រូមិនអនុញ្ញាតឱ្យកុមារដទៃទៀត មកសម្លុត ឬធ្វើបាបខ្ញុំឡើយ<br>**មករា** |
| តើអ្នកដឹងថា បង្គន់នេះ ជនពិការអាចប្រើប្រាស់បានដែរឬទេ ?<br>**ស្រីមុំ** | មេភូមិបានបញ្ជាក់យ៉ាងប្រាកដថា ខ្ញុំនឹងទទួលការអញ្ជើញឱ្យចូលរួមកិច្ចប្រជុំទាន់ពេលវេលា<br>**សុផល** |
| ខ្ញុំអាចតាមទាន់ការពិភាក្សាទាំងអស់ ដោយសារតែគ្រូបណ្តុះបណ្តាលធ្វើការពន្យល់បានក្បោះក្បាយ តាមរយៈ រូបភាព<br>**ថារី** | ខ្ញុំចង់យល់ដឹង ថាតើដំណាំណា ដែលខ្ញុំចាំបាច់ត្រូវដាំ ដើម្បីរកប្រាក់ចំណេញ<br>**មករា** |
| ជនពិការចង់ចូលរួមនៅក្នុងការអភិវឌ្ឍឃុំ ប៉ុន្តែយើងក៏មានតម្រូវការជាក់លាក់ ដើម្បីជួយយើងក្នុងការចូលរួមក្នុងសកម្មភាពក្នុងឃុំដែរ។ ឧទាហរណ៍ ខ្ញុំត្រូវការរទេះរុញ ជាដើម<br>**ស្រីមុំ** | អ្វីដែលល្អគឺថា មនុស្សដទៃ គេបានផ្តល់ពេលវេលាឱ្យខ្ញុំ ដើម្បីឱ្យខ្ញុំអាចផ្តល់នូវគំនិតរបស់ខ្ញុំបាន<br>**សុផល** |

# ឧបសម្ព័ន្ធទី១០

# បញ្ជីសំណួរវាយតម្លៃចំណេះដឹងមុនការបណ្តុះបណ្តាល

**ឈ្មោះ ៖ ភេទ ៖ កាលបរិច្ឆេទ ៖**

សូមជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរដូចក្រោម ៖

**១. អ្វីទៅដែលហៅថាពិការភាព?**

ក). ពិការភាពជាបញ្ហាកាយសម្បទា

ខ). ពិការភាពជាបញ្ហាកាយសម្បទា(ភាពខ្សោយ) គួបផ្សំជាមួយនឹងឧបសគ្គនៅក្នុងសង្គម

គ). ពិការភាពកើតឡើងនៅពេលដែលមនុស្សម្នាក់បាត់បង់ដៃ ឬជើង ដោយសារតែគ្រាប់មីន

ឃ). ពិការភាពកើតឡើងនៅពេលដែលអ្នកត្រូវទៅជួបនឹងវេជ្ជបណ្ឌិត

**២. តើនៅលើពិភពលោកមានមនុស្សប៉ុន្មាននាក់ ដែលមានពិការភាពនៅក្នុងចំណោមខាងក្រោម?**

ក). ១០០នាក់ មាន ១នាក់

ខ). ៥០នាក់ មាន ១នាក់

គ). ២០នាក់ មាន ១នាក់

ឃ). ៧នាក់ មាន ១នាក់

**៣. តើពាក្យពេចន៍ណាមួយដែលមិនគួរប្រើប្រាស់នៅពេលនិយាយអំពីជនពិការ?**

ក). អ្នកដែលខ្សោយខាងគំហើញ

ខ). ជនរងគ្រោះ

គ). ជនពិការភ្នែក

ឃ). ជនពិការផ្នែកសុខភាពផ្លូវចិត្ត

**៤. តើការបង្កភាពងាយស្រួលសម្រាប់ជនពិការន័យយ៉ាងដូចម្តេច?**

ក). មនុស្សម្នាក់អាចផ្លាស់ទីដោយសេរី ដោយម្ចាស់ការ និងប្រកបដោយទំនុកចិត្ត

ខ). មានជម្រាល

គ). ការអនុវត្តតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាលអំពីរបៀបកសាងអគារ

ឃ). មានជំនួយការ ដើម្បីជួយជនពិការក្នុងការផ្លាស់ទី

**៥. តើគម្រោងណាមួយ ដែលមានភាពពាក់ព័ន្ធជាមួយនឹងជនពិការ?**

ក). ពុំមានគម្រោងណាឡើយ

ខ). ពួកគេគួរអាចប្រើប្រាស់កម្មវិធីថែទាំសុខភាព ក៏ដូចជាកម្មវិធីសម្រាប់ជនពិការ

គ). គម្រោងពិសេសៗសម្រាប់ជនពិការ ដូចជា ទារកដ្ឋាន សម្រាប់កុមារ ពិការជាដើម

ឃ). គម្រោង និងកម្មវិធីទាំងអស់ ដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋ នឹងពាក់ព័ន្ធជនពិការដែរ

**៦. តើវិធីមួយណាដែលមិនមែនជាវិធីត្រឹមត្រូវ សម្រាប់ប្រាស្រ័យទាក់ទងនឹងអ្នកខ្សោយខាងស្តាប់?**

ក). និយាយផ្ទាល់ទៅកាន់ជំនួយការ ឬអ្នកបកប្រែរបស់ពួកគេ

ខ). សួរទៅកាន់ជននោះថាតើគាត់ចង់ធ្វើការប្រាស្រ័យទាក់ទងយ៉ាងដូចម្តេច

គ). បែរមុខចំគាត់ នៅពេលដែលអ្នកនិយាយទៅកាន់គាត់

ឃ). និយាយសំឡេងធម្មតា កុំស្រែក

**៧. តើឃ្លា"ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើពុំមានការចូលរួមពីយើង" មានន័យយ៉ាងដូចម្តេច?**

ក). ជនពិការចង់បានគម្រោង និងកម្មវិធីខ្លួនឯង

ខ). ជនពិការគួរចូលរួមក្នុងរាល់សេចក្តីសម្រេច និងដំណើរការទាំងអស់ ដែលពាក់ព័ន្ធនឹងពួកគេ

គ). គ្រប់គ្នាចាំបាច់ត្រូវតែបោះឆ្នោត រាល់ពេលធ្វើការធ្វើសេចក្តីសម្រេចចិត្តទាំងអស់

ឃ). ជនពិការចាំបាច់ត្រូវតែស្ថិតនៅក្នុងបន្ទប់ នៅពេលដែលមានការសម្រេចចិត្តអំពីពួកគេ

**៨. តើខាងក្រោមនេះ មួយណាជាឧបសគ្គ?**

ក). ស្រីមុំ គឺជាមនុស្សថ្លង់ ដោយសារតែនាងមានជំងឺត្រចៀក

ខ). ដារា មិនអាចទៅរៀននៅសាលារៀនបាន ដោយសារតែគាត់ជិះរទេះ ហើយសាលារៀនមាន ជណ្តើរច្រើនកាំ និងគ្មានជម្រាល

គ). ម៉ៅ មានការលំបាកក្នុងការដើរ ដោយសារគាត់មានជំងឺគ្រុនស្វិតដៃជើង កាលគាត់នៅតូច

ឃ). លាភ មានបញ្ហា ក្នុងការចងចាំ ដោយសារគាត់ខូចខួរក្បាល នៅពេលដែលគាត់កើត

**៩. តើអ្នកអាចប្រាស្រ័យទាក់ទងនឹងមនុស្សដែលខ្សោយខាងគំហើញ ដោយរបៀបណា?**

ក). ផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរនៅលើក្រដាស

ខ). ចាប់ផ្តើមនិយាយ នៅពេលដែលអ្នកនៅកៀកពួកគេ

គ). ពុំមានវិធីណាមួយប្រាស្រ័យទាក់ទងនឹងគាត់ទេ

ឃ). ស្រែកឱ្យបានឮបំផុត ដើម្បីឱ្យពួកគេអាច ឮអ្នកនិយាយ

**១០. តើអ្នកណាដែលមានឱកាសច្រើនជាងនៅក្នុងជីវិត?**

ក). បុរសមិនពិការ

ខ). ស្ត្រីពិការ

គ). បុរសពិការ

ឃ). ស្ត្រីមិនពិការ

# ឧបសម្ព័ន្ធទី១១

## បញ្ជីសំណួរវាយតម្លៃចំណេះដឹងក្រោយការបណ្តុះបណ្តាល

**ឈ្មោះ ៖ ភេទ ៖ កាលបរិច្ឆេទ ៖**

សូមជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរដូចក្រោម ៖

**១. អ្វីទៅដែលហៅថាពិការភាព?**

ក). ពិការភាពជាបញ្ហាកាយសម្បទា

ខ). ពិការភាពជាបញ្ហាកាយសម្បទា(ភាពខ្សោយ) គួបផ្សំជាមួយនឹងឧបសគ្គនៅក្នុងសង្គម

គ). ពិការភាពកើតឡើងនៅពេលដែលមនុស្សម្នាក់បាត់បង់ដៃ ឬជើង ដោយសារតែគ្រាប់មីន

ឃ). ពិការភាពកើតឡើងនៅពេលដែលអ្នកត្រូវទៅជួបនឹងវេជ្ជបណ្ឌិត

**២. តើនៅលើពិភពលោកមានមនុស្សប៉ុន្មាននាក់ ដែលមានពិការភាពនៅក្នុងចំណោមខាងក្រោម?**

ក). ១០០នាក់ មាន ១នាក់

ខ). ៥០នាក់ មាន ១នាក់

គ). ២០នាក់ មាន ១នាក់

ឃ). ៧នាក់ មាន ១នាក់

**៣. តើពាក្យពេចន៍ណាមួយដែលមិនគួរប្រើប្រាស់នៅពេលនិយាយអំពីជនពិការ?**

ក). អ្នកដែលខ្សោយខាងគំហើញ

ខ). ជនរងគ្រោះ

គ). ជនពិការភ្នែក

ឃ). ជនពិការផ្នែកសុខភាពផ្លូវចិត្ត

**៤. តើការបង្កភាពងាយស្រួលសម្រាប់ជនពិការន័យយ៉ាងដូចម្តេច?**

ក). មនុស្សម្នាក់អាចផ្លាស់ទីដោយសេរី ដោយម្ចាស់ការ និងប្រកបដោយទំនុកចិត្ត

ខ). មានជម្រាល

គ). ការអនុវត្តតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាលអំពីរបៀបកសាងអគារ

ឃ). មានជំនួយការ ដើម្បីជួយជនពិការក្នុងការផ្លាស់ទី

**៥. តើគម្រោងណាមួយ ដែលមានភាពពាក់ព័ន្ធជាមួយនឹងជនពិការ?**

ក). ពុំមានគម្រោងណាឡើយ

ខ). ពួកគេគួរអាចប្រើប្រាស់កម្មវិធីថែទាំសុខភាព ក៏ដូចជាកម្មវិធីសម្រាប់ជនពិការ

គ). គម្រោងពិសេសៗសម្រាប់ជនពិការ ដូចជា ទារកដ្ឋាន សម្រាប់កុមារ ពិការជាដើម

ឃ). គម្រោង និងកម្មវិធីទាំងអស់ ដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋ នឹងពាក់ព័ន្ធជនពិការដែរ

**៦. តើវិធីមួយណាដែលមិនមែនជាវិធីត្រឹមត្រូវ សម្រាប់ប្រាស្រ័យទាក់ទងនឹងអ្នកខ្សោយខាងស្តាប់?**

ក). និយាយផ្ទាល់ទៅកាន់ជំនួយការ ឬអ្នកបកប្រែរបស់ពួកគេ

ខ). សួរទៅកាន់ជននោះថាតើគាត់ចង់ធ្វើការប្រាស្រ័យទាក់ទងយ៉ាងដូចម្តេច

គ). បែរមុខចំគាត់ នៅពេលដែលអ្នកនិយាយទៅកាន់គាត់

ឃ). និយាយសំឡេងធម្មតា កុំស្រែក

**៧. តើឃ្លា"ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើពុំមានការចូលរួមពីយើង" មានន័យយ៉ាងដូចម្តេច?**

ក). ជនពិការចង់បានគម្រោង និងកម្មវិធីខ្លួនឯង

ខ). ជនពិការគួរចូលរួមក្នុងរាល់សេចក្តីសម្រេច និងដំណើរការទាំងអស់ ដែលពាក់ព័ន្ធនឹងពួកគេ

គ). គ្រប់គ្នាចាំបាច់ត្រូវតែបោះឆ្នោត រាល់ពេលធ្វើការធ្វើសេចក្តីសម្រេចចិត្តទាំងអស់

ឃ). ជនពិការចាំបាច់ត្រូវតែស្ថិតនៅក្នុងបន្ទប់ នៅពេលដែលមានការសម្រេចចិត្តអំពីពួកគេ

**៨. តើខាងក្រោមនេះ មួយណាជាឧបសគ្គ?**

ក). ស្រីមុំ គឺជាមនុស្សថ្លង់ ដោយសារតែនាងមានជំងឺត្រចៀក

ខ). ដារា មិនអាចទៅរៀននៅសាលារៀនបាន ដោយសារតែគាត់ជិះរទេះ ហើយសាលារៀនមាន ជណ្តើរច្រើនកាំ និងគ្មានជម្រាល

គ). ម៉ៅ មានការលំបាកក្នុងការដើរ ដោយសារគាត់មានជំងឺគ្រុនស្វិតដៃជើង កាលគាត់នៅតូច

ឃ). លាភ មានបញ្ហា ក្នុងការចងចាំ ដោយសារគាត់ខូចខួរក្បាល នៅពេលដែលគាត់កើត

**៩. តើអ្នកអាចប្រាស្រ័យទាក់ទងនឹងមនុស្សដែលខ្សោយខាងគំហើញ ដោយរបៀបណា?**

ក). ផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរនៅលើក្រដាស

ខ). ចាប់ផ្តើមនិយាយ នៅពេលដែលអ្នកនៅកៀកពួកគេ

គ). ពុំមានវិធីណាមួយប្រាស្រ័យទាក់ទងនឹងគាត់ទេ

ឃ). ស្រែកឱ្យបានឮបំផុត ដើម្បីឱ្យពួកគេអាច ឮអ្នកនិយាយ

**១០. តើអ្នកណាដែលមានឱកាសច្រើនជាងនៅក្នុងជីវិត?**

ក). បុរសមិនពិការ

ខ). ស្ត្រីពិការ

គ). បុរសពិការ

ឃ). ស្ត្រីមិនពិការ

# ឧបសម្ព័ន្ធទី១២

## ចម្លើយនៃបញ្ជីសំណួរវាយតម្លៃចំណេះដឹងមុន និងក្រោយការបណ្តុះបណ្តាល

សូមជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរដូចក្រោម ៖

**១. អ្វីទៅដែលហៅថាពិការភាព?**

ក). ពិការភាពជាបញ្ហាកាយសម្បទា

ខ). ពិការភាពជាបញ្ហាកាយសម្បទា(ភាពខ្សោយ) គួបផ្សំជាមួយនឹងឧបសគ្គនៅក្នុងសង្គម

គ). ពិការភាពកើតឡើងនៅពេលដែលមនុស្សម្នាក់បាត់បង់ដៃ ឬជើង ដោយសារតែគ្រាប់មីន

ឃ). ពិការភាពកើតឡើងនៅពេលដែលអ្នកត្រូវទៅជួបនឹងវេជ្ជបណ្ឌិត

**២. តើនៅលើពិភពលោកមានមនុស្សប៉ុន្មាននាក់ ដែលមានពិការភាពនៅក្នុងចំណោមខាងក្រោម?**

ក). ១០០នាក់ មាន ១នាក់

ខ). ៥០នាក់ មាន ១នាក់

គ). ២០នាក់ មាន ១នាក់

ឃ). ៧នាក់ មាន ១នាក់

**៣. តើពាក្យពេចន៍ណាមួយដែលមិនគួរប្រើប្រាស់នៅពេលនិយាយអំពីជនពិការ?**

ក). អ្នកដែលខ្សោយខាងគំហើញ

ខ). ជនរងគ្រោះ

គ). ជនពិការភ្នែក

ឃ). ជនពិការផ្នែកសុខភាពផ្លូវចិត្ត

**៤. តើការបង្កភាពងាយស្រួលសម្រាប់ជនពិការន័យយ៉ាងដូចម្តេច?**

ក). មនុស្សម្នាក់អាចផ្លាស់ទីដោយសេរី ដោយម្ចាស់ការ និងប្រកបដោយទំនុកចិត្ត

ខ). មានជម្រាល

គ). ការអនុវត្តតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាលអំពីរបៀបកសាងអគារ

ឃ). មានជំនួយការ ដើម្បីជួយជនពិការក្នុងការផ្លាស់ទី

**៥. តើគម្រោងណាមួយ ដែលមានភាពពាក់ព័ន្ធជាមួយនឹងជនពិការ?**

ក). ពុំមានគម្រោងណាឡើយ

ខ). ពួកគេគួរអាចប្រើប្រាស់កម្មវិធីថែទាំសុខភាព ក៏ដូចជាកម្មវិធីសម្រាប់ជនពិការ

គ). គម្រោងពិសេសៗសម្រាប់ជនពិការ ដូចជា ទារកដ្ឋាន សម្រាប់កុមារ ពិការជាដើម

ឃ). គម្រោង និងកម្មវិធីទាំងអស់ ដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋ នឹងពាក់ព័ន្ធជនពិការដែរ

**៦. តើវិធីមួយណាដែលមិនមែនជាវិធីត្រឹមត្រូវ សម្រាប់ប្រាស្រ័យទាក់ទងនឹងអ្នកខ្សោយខាងស្ដាប់?**

ក). និយាយផ្ទាល់ទៅកាន់ជំនួយការ ឬអ្នកបកប្រែរបស់ពួកគេ

ខ). សួរទៅកាន់ជននោះថាតើគាត់ចង់ធ្វើការប្រាស្រ័យទាក់ទងយ៉ាងដូចម្ដេច

គ). បែរមុខចំគាត់ នៅពេលដែលអ្នកនិយាយទៅកាន់គាត់

ឃ). និយាយសំឡេងធម្មតា កុំស្រែក

**៧. តើឃ្លា "ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើពុំមានការចូលរួមពីយើង" មានន័យយ៉ាងដូចម្ដេច?**

ក). ជនពិការចង់បានគម្រោង និងកម្មវិធីខ្លួនឯង

ខ). ជនពិការគួរចូលរួមក្នុងរាល់សេចក្ដីសម្រេច និងដំណើរការទាំងអស់ដែលពាក់ព័ន្ធនឹងពួកគេ

គ). គ្រប់គ្នាចាំបាច់ត្រូវតែបោះឆ្នោត រាល់ពេលធ្វើការធ្វើសេចក្ដីសម្រេចចិត្តទាំងអស់

ឃ). ជនពិការចាំបាច់ត្រូវតែស្ថិតនៅក្នុងបន្ទប់ នៅពេលដែលមានការសម្រេចចិត្តអំពីពួកគេ

**៨. តើខាងក្រោមនេះ មួយណាជាឧបសគ្គ?**

ក). ស្រីមុំ គឺជាមនុស្សថ្លង់ ដោយសារតែនាងមានជំងឺត្រចៀក

ខ). ដារា មិនអាចទៅរៀននៅសាលារៀនបាន ដោយសារតែគាត់ជិះរទេះ ហើយសាលារៀនមាន ជណ្ដើរច្រើនកាំ និងគ្មានជម្រាល

គ). ម៉ៅ មានការលំបាកក្នុងការដើរ ដោយសារគាត់មានជំងឺគ្រុនស្វិតដៃជើង កាលគាត់នៅតូច

ឃ). លាភ មានបញ្ហា ក្នុងការចងចាំ ដោយសារគាត់ខូចខួរក្បាល នៅពេលដែលគាត់កើត

**៩. តើអ្នកអាចប្រាស្រ័យទាក់ទងនឹងមនុស្សដែលខ្សោយខាងគំហើញ ដោយរបៀបណា?**

ក). ផ្ដល់ព័ត៌មានជាលាយលក្ខណ៍អក្សរនៅលើក្រដាស

ខ). ចាប់ផ្ដើមនិយាយ នៅពេលដែលអ្នកនៅកៀកពួកគេ

គ). ពុំមានវិធីណាមួយប្រាស្រ័យទាក់ទងនឹងគាត់ទេ

ឃ). ស្រែកឱ្យបានឮបំផុត ដើម្បីឱ្យពួកគេអាច ឮអ្នកនិយាយ

**១០. តើអ្នកណាដែលមានឱកាសច្រើនជាងនៅក្នុងជីវិត?**

ក). បុរសមិនពិការ

ខ). ស្ត្រីពិការ

គ). បុរសពិការ

ឃ). ស្ត្រីមិនពិការ